បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

# អំណាចនៃយុទ្ធសាស្ត្រ

ហ្គារី ឃីស៊ី
GARY KEESEE

REV
OLU
TION

## បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក

# អំណាចនៃយុទ្ធសាស្ត្រ

ហ្គារី ឃីស៊ី
GARY KEESEE

*បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃយុទ្ធសាស្ត្រ*

រក្សាសិទ្ធិ © ២០១៩ ដោយ ហ្គារី ឃីស៊ី (Gary Keesee)

សម្រាប់សម្រង់ខគម្ពីរគឺបានដកស្រង់ចេញពីព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន ឆ្នាំ២០០៥ ដោយសមាគមព្រះគម្ពីរកម្ពុជា ©រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល ២០០៥ - ដកស្រង់ដោយមានការអនុញ្ញាត។

សៀវភៅនេះត្រូវបានរក្សាសិទ្ធិគ្រប់យ៉ាងក្រោមច្បាប់ស្តីអំពីសិទ្ធិអ្នកនិពន្ធអន្តរជាតិ។ សម្រាប់មាតិកា និង/ឬក្របសៀវភៅនេះនឹងមិនត្រូវផលិតឡើងវិញទាំងស្រុង ឬតាមផ្នែកនៅក្នុងទម្រង់ណាមួយដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីគ្រឹះស្ថានបោះពុម្ពផ្សាយឡើយ។

លេខ ISBN: 978-1-945930-14-0

បោះពុម្ពផ្សាយដោយ Free Indeed Publishers ។
ធ្វើការចែកចាយដោយ Faith Life Now

Faith Life Now
P.O. Box 779
New Albany, OH 43054
1-(888)-391-LIFE

អ្នកអាចទំនាក់ទំនងទៅកាន់ព័ន្ធកិច្ច Faith Life Now តាមប្រព័ន្ធអ៊ីនធឺណិតតាមគេហទំព័រ www.faithlifenow.com

# ការឧទ្ទិស

ខ្ញុំចង់ឧទ្ទិសសៀវភៅនេះជូនចំពោះឌ្រិនដា (Drenda) ភរិយារបស់ខ្ញុំដោយសារតែសៀវភៅនេះបានកើតឡើងដោយសារតែមានការលើកទឹកចិត្តពីគាត់ ចិត្តឆេះឆួលរបស់គាត់ចំពោះរឿងរ៉ាវរបស់ព្រះជាម្ចាស់ និងសេចក្តីស្រលាញ់របស់គាត់ចំពោះក្រុមគ្រួសាររបស់គាត់ និងខ្ញុំ ជាអ្វីដែលបានជំរុញទឹកចិត្តដល់ខ្ញុំក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ។ ជាមួយគ្នានេះ យើងបានបញ្ជាក់ឱ្យឃើញថាសុបិនពិតជាអាចក្លាយជាការពិតបានមែន!

ហ្គារី ឃីស៊ី

# បញ្ជីមាតិកា

សេចក្តីផ្តើម ........ 1
ជំពូក ១ ទ្រង់ចង់ឱ្យពួកយើងធ្វើអ្វី? ........ 13
ជំពូក ២ ព្រះរាជ្យនៃព្រះ ........ 29
ជំពូក ៣ ស្ងប់ស្ងៃង ........ 39
ជំពូក ៤ មូលដ្ឋានគ្រឹះ៖ កុំទាន់ចេញពីផ្ទះឱ្យសោះប្រសិនបើអ្នកគ្មានវាទេ ........ 57
ជំពូក ៥ ភស្តុតាងពីបទគម្ពីរ ........ 77
ជំពូក ៦ តើគ្រប់គ្នាសុទ្ធតែអធិស្ឋានជាភាសាដទៃឬ? ........ 87
ជំពូក ៧ កំណប់ទ្រព្យ ........ 101
ជំពូក ៨ កន្លែងដ៏ពិបាកនៃការដំឡើងតំណែង ........ 121
ជំពូក ៩ សំឡេងតូចឆ្មារ ........ 133
ជំពូក ១០ និមិត្ត និងសុបិននិមិត្ត ........ 147
ជំពូកទី១១ ព្រះវិញ្ញាណដ៏វិសុទ្ធស្តាប់ទៅដូចជាថៅហ្វាយខ្ញុំ ........ 163
ជំពូកទី១២ របៀបអធិស្ឋាន និងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ........ 181

# សេចក្ដីផ្ដើម

សៀវភៅ *បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃយុទ្ធសាស្ត្រ* គឺជាសៀវភៅទីបី នៅក្នុងសេរីសៀវភៅបដិវត្តន៍ហិរញ្ញវត្ថុ។ ពេលដែលសេរីនេះបញ្ចប់ នឹងមានសៀវភៅចំនួនប្រាំក្បាល ហើយសៀវភៅមួយក្បាលៗ គឺជាកំណែដែលមានការពង្រីកបន្ថែម ចេញពីសន្និបាតមួយដែលខ្ញុំបានធ្វើឡើងនៅប្រទេសអាល់បានី (Albania) ក្នុងឆ្នាំ២០០៥។ គឺនៅក្នុងសន្និបាតនេះហើយ ជាទីកន្លែងដែលទិសដៅជីវិតរបស់ខ្ញុំបានផ្លាស់ប្ដូរយ៉ាងគួរឱ្យកត់សម្គាល់។ ប្រសិនបើអ្នកបានស្ដាប់រឿងនេះរួចហើយ អ្នកអាចនឹងចង់រំលងសេចក្ដីផ្ដើម ហើយចូលទៅចាប់ផ្ដើមជំពូកទី១ តែម្ដង។ ក៏ប៉ុន្តែប្រសិនបើអ្នកមិនទាន់បានស្ដាប់វាទេ ខ្ញុំសូមនិយាយប្រាប់អ្នកអំពីអ័ព្ទពណ៌ខៀវ។ និយាយពី «អ័ព្ទពណ៌ខៀវ» អ្នកមុខជាឆ្ងល់ហើយ ថាសួរថា «វាជាអ្វីទៅ»? ខ្ញុំយល់ពីសំណួរនោះ។ ពេលដែលខ្ញុំបានឃើញវា ខ្ញុំក៏មិនដឹងដែរថា វាជាអ្វី ក៏ប៉ុន្តែអំណាចរបស់ព្រះជាម្ចាស់ ពិតជាខ្លាំងក្លាណាស់ រហូតធ្វើឱ្យខ្ញុំដឹងថាវា មុខជាអ្វីដែលមកពីទ្រង់មិនខានទេ។ ខ្ញុំសូមប្រាប់អ្នកពីរឿងនោះ។

ភរិយាខ្ញុំ និងខ្ញុំបានចាប់ផ្ដើមជីវិតអាពាហ៍ពិពាហ៍ក្នុងបំណុល និងបានរស់នៅជាប់បំណុលអស់រយៈពេល ៩ឆ្នាំ។ មិនត្រឹមតែជាប់បំណុលប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ទទួលរងភាពតានតឹងដ៏ធ្ងន់ធ្ងរ និងភាពភ័យខ្លាចអំពីរឿងលុយ និងបញ្ហាផ្សេងៗជាច្រើនពាក់ព័ន្ធនឹងលុយ។ ទោះបីជាយើងមិនដែលមានបំណងធ្វើឱ្យជីវិតយើងជួបបញ្ហាផ្នែកហិរញ្ញវត្ថុទេ ក៏ប៉ុន្តែយើងក៏ធ្វើឱ្យមានបញ្ហានោះកើតឡើង។ យើងបានចាប់ផ្ដើមដោយការប្រើកាតក្រេឌីតសម្រាប់ចាក់សាំង បន្ទាប់មកយើងមានកាតវីសា (Visa card) មួយ ហើយក្រោយមកក៏កើនដល់មានកាតវីសា១០។ ពេលយើងគ្មានលុយបងថ្លៃកាតវីសា យើងក៏យកប្រាក់កម្ចីពីក្រុមហ៊ុន ដែលមានការប្រាក់ពី២៨ ទៅ ៣៣ភាគរយ ដើម្បីយកមករួមបញ្ចូលគ្នាប្រើសម្រាប់ការចំណាយរបស់យើង។ ក៏ប៉ុន្តែពេលយើងចេញទៅក្រៅ និងប្រើកាតរបស់យើងម្ដងទៀត បំណុលក៏ចេះតែបន្តកើនឡើង! ទីបំផុតយើងក៏មានកាតក្រេឌីតដែលបានប្រើដល់ចំនួនកំណត់ និងកាតដែលត្រូវគេលុបចោលដល់ទៅ ១០កាតឯណោះ ថែមទាំងបំណុលលុយកម្ចីពីក្រុមហ៊ុនហិរញ្ញវត្ថុដល់ទៅបី និងបំណុលជំពាក់បំណុលពន្ធអាករ (IRS) ចំនួន ១០,០០០ ដុល្លារ ហើយមានបំណុលតូចៗជាច្រើនផ្សេងទៀត។ យើងជំពាក់ពេទ្យធ្មេញយើង និងថ្លៃ

បោកគក់សម្លៀកបំពាក់ និងឪពុកម្ដាយយើងដល់ទៅ ១០,០០០ដុល្លារ ព្រមទាំងការបង់លុយសម្រាប់ឡានពីរ ផ្ទះជួលមួយ និងមានបំណុលច្រើនទៀតនៅក្នុងបញ្ជី។ ពេលនោះយើងរស់នៅពឹងតែលើប្រាក់កម្រៃជើងសារតែប៉ុណ្ណោះ ហើយភាពតានតឹងពេលនេះកំពុងតែធ្វើឱ្យខ្ញុំស្លាប់យ៉ាងពិតប្រាកដ។ ខ្ញុំមានអាការៈស្លន់ស្លោ ហើយពេលនោះខ្ញុំបានប្រើប្រាស់ថ្នាំបន្ធូរអារម្មណ៍ ដែលហាក់ដូចជាមិនជួយអ្វីដល់ខ្ញុំសោះ។

អ្វីៗដែលយើងមានសុទ្ធតែរបស់បាក់បែក។ ឡានរបស់យើងបើកបរបានចម្ងាយលើសពី ៣២២,០០០ គ.មទៅហើយ។ ផ្ទះតូចទ្រុឌទ្រោមតាំងពីជំនាន់ឆ្នាំ ១៨៥៦របស់យើងដែលជួលក្នុងតម្លៃ ៣០០ដុល្លារក្នុងមួយខែនោះក៏ខូចច្រើនដែរ។ បង្អួចចាស់ៗជាច្រើនសុទ្ធតែបាក់បែក ហើយដោយសារយើងគ្មានលុយជួសជុលវា យើងក៏បិទស្កុតខ្មៅពីលើស្នាមប្រេះ។ ក៏ប៉ុន្តែទោះបីជាធ្វើអ៊ីចឹងហើយក៏ដោយ ក៏វាមិនទាន់ល្អដែរ។ វល្លិដែលនៅខាងក្រៅដុះចូលតាមស្នាមប្រេះលើកញ្ចក់បង្អួច។ ភរិយាខ្ញុំ ឌ្រិនដា គ្រាន់តែកាត់តម្រឹមវាទុកជាផ្នែកនៃការតុបតែងផ្ទះ។ កម្រាលព្រំនៅក្នុងបន្ទប់គេងកូនប្រុសយើង គឺយើងរកបានមកពីគំនរសំរាមនៅតាមផ្លូវ។ ឯតួយរបស់ពួកគេ គឺយកមកពីគំនររបស់របរដែលគេបោះចោលនៅផ្ទះថែទាំអ្នកជំងឺ។ គ្រឿងសង្ហារឹមនីមួយៗសុទ្ធតែរកទិញនៅក្នុងតាមការ៉ាស់លក់អីវ៉ាន់មួយទឹកនៅកន្លែងណាមួយ ឬឃើញគេយកទៅចោលនៅគំនរសំរាមតាមផ្ទះគេឯង។

គ្មានឡើយ ភាពសប្បាយរីករាយក្នុងជីវិត នៅពេលដែលអ្នកក្រោកឡើងមករាល់ថ្ងៃ ហើយមិនថានឹងមានអ្វីមកចម្អែតក្រពះគ្រួសារអ្នក។ ភាពភ័យខ្លាចបានរួបរឹតជីវិតខ្ញុំ ហើយអំណរ និងក្ដីសង្ឃឹមត្រូវបានរួបរឹតនៅក្នុងភាពរឹកររនៃការតស៊ូឱ្យបានរស់។ ឌ្រិនដា និងខ្ញុំបានរស់នៅក្នុងជីវិតបែបនោះដល់ទៅ៩ឆ្នាំ! ៩ឆ្នាំពិតជាយូរណាស់! ប្រសិនបើមួយខែ ឬនិយាយឱ្យអាក្រក់ទៅថាមួយឆ្នាំ នោះខ្ញុំអាចយល់បានថាមូលហេតុអ្វី តែនេះដល់ទៅ៩ឆ្នាំ តើព្រោះអ្វីទៅ? អស់ពេល ៩ ឆ្នាំនៃភាពតានតឹងបែបនោះ អារម្មណ៍របស់អ្នកប្រែក្លាយទៅជាឆេវឆាវ និងគ្មានភាពអត់ធ្មត់។

ទោះបីជាយ៉ាងណាក៏ដោយក្នុងរយៈពេល៩ឆ្នាំនោះ យើងគឺជាគ្រិស្តបរិស័ទដែលចូលរួមនៅក្នុងក្រុមជំនុំធំមួយ ដែលបង្រៀនយើងថាភាពក្រីក្រមិនមែនជាព្រះហឫទ័យព្រះជាម្ចាស់សម្រាប់ប្រជាជនទ្រង់ទេ។ យើងថ្វាយតង្វាយ និងឱ្យអ្នកដទៃជាញឹកញាប់ ក៏ប៉ុន្តែហិរញ្ញវត្ថុរបស់យើងមិនឆ្លុះបញ្ចាំងពីភាពស្មោះត្រង់របស់ព្រះជាម្ចាស់ និងអ្វីដែលព្រះបន្ទូលរបស់ទ្រង់បង្ហាញយើងទេ។ ខ្ញុំមានសញ្ញាបត្រផ្នែកសម្ពន្ធមេត្រីចាស់ ហើយក៏បានចូលរៀន

នៅសាលាព្រះគម្ពីរអស់រយៈពេលជាងមួយឆ្នាំដែរ។ ខ្ញុំបានដឹងថាមានអ្វីមួយដូចជាមិនត្រឹមត្រូវសោះ ក៏ប៉ុន្តែខ្ញុំនៅតែសង្ឃឹមថា នៅទីបំផុតអ្វីៗនឹងប្រែត្រលប់ជាត្រឹមត្រូវវិញ។ តែអ្វីៗមិនផ្លាស់ប្តូរដល់ទៅ ៩ឆ្នាំ។ អ្នកប្រមូលលុយចំណាយលើវិក្កយបត្រ ទូរស័ព្ទមកយើងជារៀងរាល់ថ្ងៃ ហើយឌ្រិនដា និងខ្ញុំស្ទើរតែលែងមានក្តីសង្ឃឹមទៅហើយ។

មិនតែប៉ុណ្ណោះ គ្រូពេទ្យបានប្រាប់ថា ខ្ញុំមានរោគសញ្ញាទាំងអស់ដែលបង្ហាញពីការចាប់ផ្តើមមានជំងឺទឹកនោមផ្អែម ពេលដែលខ្ញុំបានប្រឈមមុខនឹងបញ្ហាសុខភាពកាន់តែធ្ងន់ធ្ងរ។ យើងគ្មានលុយ ហើយកាតក្រេឌីតទាំងអស់ត្រូវគេលុបចោល ហើយយើងគ្មានអាហារនៅក្នុងផ្ទះទេ។ ភាពភ័យខ្លាចបានធ្វើទុក្ខបុកម្នេញជីវិតខ្ញុំ រហូតដល់ដំណាក់កាលមួយដែលខ្ញុំខ្លាចមិនហ៊ានចេញក្រៅផ្ទះ។ ភរិយាខ្ញុំបានចាប់ផ្តើមរៀបចំផែនការនៅក្នុងចិត្តគាត់ ថាតើគាត់ និងកូនៗត្រូវរើទៅនៅផ្ទះរបស់ឪពុកម្តាយគាត់វិញដោយរបៀបណា ពេលដែលគាត់គិតថាគាត់នឹងបាត់បង់ប្តីរបស់គាត់ហើយ។ ទោះជាយ៉ាងណាក៏ដោយ គឺនៅចំណុចបាតក្រោមបំផុតនៃជីវិតខ្ញុំនេះហើយ ដែលជីវិតខ្ញុំជួបការផ្លាស់ប្តូរមួយ។

មានមេធាវីម្នាក់ចេះតែទូរស័ព្ទមកខ្ញុំ ហើយខ្ញុំចេះសន្យានឹងគាត់ថានឹង ទូទាត់លុយឱ្យគាត់ ជាអ្វីដែលខ្ញុំសង្ឃឹមចង់ធ្វើ ក៏ប៉ុន្តែខ្ញុំមិនដែលរកលុយបានមកបង់ថ្លៃវិក្កយបត្រទេ។ ដូច្នេះហើយព្រឹកមួយនោះពេលគាត់ទូរស័ព្ទមក គាត់គ្មានភាពអត់ធ្មត់ទៀតទេ គាត់និយាយថា «លោកត្រូវតែរកលុយមកក្នុងរយៈពេលបីថ្ងៃ បើមិនអីចឹងទេខ្ញុំនឹងដាក់ពាក្យបណ្តឹងប្តឹងលោក ព្រោះលោកជំពាក់លុយកូនក្តីខ្ញុំ»។ វាគឺជាពេលដែលខ្ញុំដឹងថាការកុហកតទៅទៀត ត្រូវតែបញ្ចប់។ ខ្ញុំគ្មានលុយទេ ហើយសូម្បីតែមនុស្សក្នុងគ្រួសារយើងក៏មិនឱ្យលុយយើងខ្ចីទៀតដែរ។ ដោយក្តីអស់សង្ឃឹម ខ្ញុំបានឡើងជណ្តើរចូលទៅបន្ទប់យើង នៅក្នុងផ្ទះតូចបែបស្រុកស្រែរបស់យើង គេងលើគ្រែ ហើយស្រែករកព្រះជាម្ចាស់។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះគឺថា ទ្រង់បានឆ្លើយតបភ្លាមៗចេញពីវិញ្ញាណខ្ញុំ។ ជាដំបូងទ្រង់រំលឹកខ្ញុំយ៉ាងសាមញ្ញពីខគម្ពីរដែលខ្ញុំធ្លាប់បានឮ និងអានជាច្រើនដងហើយគឺនៅក្នុង ភីលីព ៤:១៩៖

*«ព្រះរបស់ខ្ញុំនឹងបំពេញសេចក្តីត្រូវការគ្រប់យ៉ាងរបស់បងប្អូន ស្របតាមសិរីរុងរឿងដ៏ប្រសើរបំផុតរបស់ព្រះអង្គ ដោយរួមក្នុងអង្គព្រះគ្រិស្តយេស៊ូ»*។

ខ្ញុំបានប្រាប់ព្រះអម្ចាស់ថា «ជាការពិតណាស់ ខ្ញុំស្គាល់ខនោះ» ហើយខ្ញុំនិយាយបន្តទៀតថា «ក៏ប៉ុន្តែវាមិនកើតឡើងនៅក្នុងជីវិតខ្ញុំទេ។ គ្មានតម្រូវការមួយណារបស់ខ្ញុំបានបំពេញរួចហើយទេ»។ ព្រះអម្ចាស់បានឆ្លើយតបមកវិញថា «យើងមិនពាក់ព័ន្ធនឹងភាពរញ៉េរ

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

ញ៉ែក្នុងជីវិតអ្នកទេ។ អ្នកស្ថិតក្នុងសភាពរញ៉េរញ៉ៃនោះដោយសារតែអ្នក មិនបានដឹងពីររបៀបដែលព្រះរាជ្យរបស់យើងដំណើរការ»។ ទ្រង់បានបន្តប្រាប់ខ្ញុំនូវរឿងមួយចំនួនទៀត តែសារដែលខ្ញុំទទួលបានទៀតគឺ ៖ បំណុលមិនមែនជាបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់ជីវិតខ្ញុំទេ។ ទោះបីជាខ្ញុំរំភើបយ៉ាងខ្លាំងដោយបានឮអ្វីដែលព្រះជាម្ចាស់មានបន្ទូល តែខ្ញុំត្រូវតែទទួលស្គាល់ថា ខ្ញុំមិនដឹងថាព្រះរាជ្យមានន័យដូចម្តេចទេ។ ខ្ញុំមានសញ្ញាបត្រព្រះគម្ពីរ និងមានអារម្មណ៍ថាខ្ញុំស្គាល់ព្រះគម្ពីរច្បាស់ ក៏ប៉ុន្តែតាមការពិតទៅខ្ញុំគិតខុសហើយ។ រឿងដំបូងដែលខ្ញុំបានធ្វើបន្ទាប់ពីបានឮព្រះបន្ទូលទាំងនេះ គឺទៅរក ឌ្រិនដា និងសារភាពកំហុសចំពោះគាត់អំពីភាពរីករវដែលខ្ញុំនាំចូលក្នុងជីវិតយើង។ បន្ទាប់មកយើងទាំងពីរបានអធិស្ឋានទៅព្រះជាម្ចាស់សុំឱ្យ ទ្រង់បង្រៀនយើងពីរបៀបដែលព្រះរាជ្យមានដំណើរការ។ យើងក៏សារភាពកំហុសដែលបានពឹងលើបំណុល និងបានប្តេជ្ញាថាយើងនឹងមិនពឹងលើបំណុលទុកជារបៀបរស់នៅរបស់យើងទៀតទេ។ ក៏ប៉ុន្តែការពិតទៅ ទោះបីជាយើងមានសញ្ញាបត្រព្រះគម្ពីរក៏ដោយ ព្រះរាជ្យនៅតែជារឿងអាថ៌កំបាំងនៅពេលនោះដែរ។ ពេលតែមួយដែលខ្ញុំអាចចាំបានពាក្យថា ព្រះរាជ្យ ត្រូវគេយកមកប្រើប្រាស់នៅក្នុងសម្ពន្ធមេត្រីថ្មី គឺនៅក្នុងសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់។

*«សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់ សូមឱ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ»។ (ម៉ាថាយ ៦:១០)*

យើងពិតជាមិនយល់ពីអ្វីដែលព្រះជាម្ចាស់ព្យាយាមមានបន្ទូលមកយើងទេ ក៏ប៉ុន្តែពេលយើងចាប់ផ្តើមស្វែងរកព្រះអម្ចាស់ ទ្រង់បានចាប់ផ្តើមបង្រៀនយើង។ រឿងដំបូងដែលយើងត្រូវគិតនោះគឺ តើព្រះរាជ្យគឺជាអ្វី ហើយហេតុអ្វីបានជាទ្រង់ប្រើប្រាស់ពាក្យនោះ។ តើទ្រង់ចង់ប្រាប់យើងពីអ្វី? បន្ទាប់ពីធ្វើការស្រាវជ្រាវមួយចំនួន ខ្ញុំបានដឹងថាព្រះរាជ្យមិនមែនគ្រាន់តែសំដៅទៅលើហ្វូងមនុស្សទេ។ តែសំដៅទៅលើហ្វូងមនុស្សដែលរស់នៅក្រោមយុត្តាធិការ របស់រាជរដ្ឋាភិបាលមួយ និងព្រះមហាក្សត្រ។ ជាក់ស្តែង ពាក្យថាព្រះរាជ្យសំដៅទៅលើអំណាចរបស់ព្រះមហាក្សត្រមួយអង្គ។ អំណាចរបស់ព្រះមហាក្សត្រ ឬសិទ្ធិអំណាចរបស់ទ្រង់ និងច្បាប់របស់ទ្រង់ ត្រូវប្រតិបត្តិតាមពីសំណាក់ប្រជារាស្ត្រគ្រប់រូប ដោយអំណាចរបស់ទ្រង់ តាមរយៈរដ្ឋាភិបាលរបស់ទ្រង់។ ហេតុដូច្នេះហើយ នៅទីនេះគឺជាកូនសោសំខាន់មួយសម្រាប់ខ្ញុំ ៖ ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជារដ្ឋាភិបាលមួយ។

ហើយរដ្ឋាភិបាលមានច្បាប់!

## សេចក្ដីផ្ដើម

អ្នកឃើញហើយថាខ្ញុំ មើលទៅព្រះជាម្ចាស់ដូចជាគ្រិស្តបរិស័ទភាគច្រើនដែរ មើលទៅដោយការយល់ខុស អំពីអ្វីដែលទ្រង់អាចធ្វើបាន។ ខ្ញុំបានស្មានថា ដោយសារតែទ្រង់គឺជាព្រះ ហើយថាទ្រង់អាចធ្វើអ្វីក៏បានដែលទ្រង់ចង់ធ្វើ។ ខ្ញុំដឹងថានៅត្រង់ចំណុចនេះនៅក្នុងសៀវភៅនេះ អ្នកនឹងនិយាយថា ខ្ញុំខុសហើយ ក៏ប៉ុន្តែសូមទុកឱ្យខ្ញុំនិយាយបន្តសិន។ ដោយសារតែខ្ញុំជឿថា ព្រះជាម្ចាស់អាចធ្វើអ្វីៗគ្រប់យ៉ាងដែលទ្រង់ចង់ធ្វើ ខ្ញុំយល់ថាពាក្យអធិស្ឋានដែលទ្រង់មិនបានឆ្លើយតប គឺជាសំណូមពរដែលទ្រង់បានបដិសេធចោល។ ភាពមិនច្បាស់លាស់នេះទាក់ទងនឹងការអធិស្ឋានបាននាំខ្ញុំឱ្យត្រឹមតែមានសង្ឃឹមថាទ្រង់នឹងឆ្លើយតបពាក្យអធិស្ឋាន។ ជាការពិតណាស់ ទម្រង់នៃពាក្យអធិស្ឋានភាគច្រើនរបស់ខ្ញុំក្នុងជីវិតរបស់ខ្ញុំគឺជាការសុំអង្វរ និងស្រែកសុំក្ដីមេត្តាករុណា គ្រាន់តែធ្វើយ៉ាងណាឱ្យរឿងរបស់ខ្ញុំស្ដាប់ទៅធ្ងន់ធ្ងរ ដើម្បីឱ្យព្រះជាម្ចាស់ចាប់អារម្មណ៍ប៉ុណ្ណោះ។ ក៏ប៉ុន្តែ ពេលព្រះជាម្ចាស់ចាប់ផ្ដើមបង្រៀនខ្ញុំថា ព្រះរាជ្យទាំងមូលរបស់ទ្រង់ គឺជារដ្ឋាភិបាលដែលមានច្បាប់ ដែលយើងអាចរៀន និងប្រើប្រាស់ ខ្ញុំក៏មានចិត្តរំភើបឡើង។ ខ្ញុំបានដឹងថា ពេលដែលខ្ញុំចូលមករកព្រះគ្រិស្ត ខ្ញុំបានក្លាយជាអ្នកស្នងមរតក និងជាប្រជារាស្ត្ររបស់ព្រះរាជ្យដ៏អស្ចារ្យរបស់ទ្រង់។

*«ហេតុនេះ បងប្អូនលែងជាជនបរទេស ឬជាអាណិកជនទៀតហើយ គឺបងប្អូនជាជនរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធ និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់»។*(អេភេសូ ២:១៩)

ខ្ញុំចាំបានពេលខ្ញុំអានខគម្ពីរ និងគិតថា *ខ្ញុំមានសិទ្ធិស្របច្បាប់នៅក្នុងព្រះរាជ្យរបស់ទ្រង់! តើវាអាចជារឿងសាមញ្ញយ៉ាងនេះដែរមែនទេ? ក្នុងនាមជាពលរដ្ឋរបស់សហរដ្ឋអាមេរិក ខ្ញុំមិនចាំបាច់ត្រូវសុំអង្វរ និងសុំអ្វីដែលជារបស់ខ្ញុំស្រាប់ទៅហើយទេ ក្នុងនាមជាពលរដ្ឋម្នាក់។ ខ្ញុំមិនចាំបាច់ត្រូវមានអារម្មណ៍ថាព្រឺសម្បុរទេ ដើម្បីបង្ហាញថាខ្ញុំជាពលរដ្ឋម្នាក់។ ខ្ញុំបានកើតនៅទីនេះ។ ពេលខ្ញុំបានកើតជាថ្មីនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ខ្ញុំក្លាយទៅជាពលរដ្ឋម្នាក់នៅក្នុងព្រះរាជ្យទ្រង់។ នោះមានន័យថាខ្ញុំមានសិទ្ធិតាមច្បាប់នៅក្នុងច្បាប់នីមួយៗ និងអត្ថប្រយោជន៍ដែលបានកត់ត្រាទុកនៅក្នុងច្បាប់របស់ព្រះរាជ្យទ្រង់ហើយ។* ពិតពលោករបស់ខ្ញុំបានផ្លាស់ប្ដូរយ៉ាងខ្លាំង ពេលដែលព្រះជាម្ចាស់ចាប់ផ្ដើមបង្ហាញខ្ញុំពីរឿងនោះ។ តើអ្នកឃើញទេថា ឌ្រិនដា និងខ្ញុំក៏ដូចជាគ្រិស្តបរិស័ទភាគច្រើនដែរ យើងមិនយល់ពីព្រះរាជ្យ និងច្បាប់របស់ព្រះរាជ្យទេ។

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

ជាក់ស្តែង អ្នកនឹងឮគ្រិស្តបរិស័ទភាគច្រើននិយាយថា «ព្រះជាម្ចាស់អនុញ្ញាត ព្រះជាម្ចាស់ជ្រាបទាំងអស់ ព្រះជាម្ចាស់គ្រប់គ្រងវាហើយ ឬថាព្រះជាម្ចាស់មានអានុភាព» ពេលដែលនរណាម្នាក់ជួបប្រទះទុក្ខលំបាក។ ពាក្យសម្តីទាំងនេះបង្ហាញពីជំនឿថា ព្រះជាម្ចាស់មានអំណាចក្នុងការផ្តល់ចម្លើយ តែមិនមានបំណង ឬមិនបានសម្រេចព្រះទ័យថាចង់ពាក់ព័ន្ធទេ។ គំនិតខុសឆ្គងទាក់ទងនឹងព្រះជាម្ចាស់នេះ គឺជាលទ្ធផលពីការមិនស្គាល់ពីលក្ខណៈរបស់ព្រះជាម្ចាស់ ឬយល់ពីរបៀបដែលព្រះរាជ្យមានដំណើរការ។

ខ្ញុំសូមពន្យល់អ្នកពីអ្វីដែលខ្ញុំនិយាយ។ ប្រសិនបើអ្នកមានលុយមួយពាន់លានដុល្លារ នៅក្នុងធនាគារ អ្នកនឹងនិយាយថា «ខ្ញុំមានលុយមួយពាន់លានដុល្លារ»។ ក៏ប៉ុន្តែការពិតទៅអ្នកគ្មានលុយមួយពាន់លានក្នុងហោប៉ៅអ្នក ពេលអ្នកនិយាយប្រាប់គេបែបនោះទេ។ ផ្ទុយទៅវិញ អ្នកមានលុយមួយពាន់លានដុល្លារនៅឯស្ថាប័នមួយ ដែលអ្នកត្រូវតែធ្វើតាមដំណើរស្របច្បាប់មួយដើម្បីយកលុយចេញពីស្ថាប័ននោះមកនៅក្នុងដៃអ្នក។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ក៏ដូច្នេះដែរ។ ក្នុងនាមជាពលរដ្ឋ និងជាសមាជិកក្នុងគ្រួសារព្រះជាម្ចាស់ យើងពិតជាអ្នកស្នងមរតកទាំងអស់ដែលព្រះជាម្ចាស់មាន។ ក៏ប៉ុន្តែមានច្បាប់ និងដំណើរការជាច្រើនតាមរយៈការដែលយើងកាន់អ្វីដែលជារបស់យើងដោយស្របច្បាប់រួចទៅហើយ។

ដោយសារតែមនុស្សភាគច្រើនមិនយល់ពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងមិនយល់ពីដំណើរការ និងច្បាប់ដែលព្រះរាជ្យដំណើរការ ពេលដែលគ្មានអ្វីមួយកើតឡើង ដូចព្រះបន្ទូលទ្រង់ មនុស្សសន្មតថាកំហុសនៅត្រង់ការសម្រេចចិត្តរបស់ព្រះ មិនមែនជាកំហុសរបស់ពួកគេទេ។

នេះគឺជាអ្វីដែលខ្ញុំរកឃើញ។ ឧបមាថាអ្នកសម្រេចចិត្តថាលោតពីលើអគារ Empire State គ្មានឆ័ត្រយោង គ្មានអ្វីទាំងអស់ ក៏ប៉ុន្តែអ្នកជឿថាប្រសិនបើអ្នកទះដៃទាំងពីរគ្រប់ល្មម នោះអ្នកអាចហោះបានដោយសុវត្ថិភាពចុះទៅក្រោម។ ខ្ញុំគិតថាអ្នកនឹងដឹងពីលទ្ធផល នៃការបោកបញ្ឆោតដ៏ល្ងង់ខ្លៅនោះហើយ។ ហេតុផលដែលធ្វើឱ្យអ្នកដឹងពីលទ្ធផលគឺដោយសារតែអ្នកយល់ពីច្បាប់នៃទំនាញផែនដី។ ការដឹងពីច្បាប់នៃទំនាញផែនដីនោះ មិនប្រកាន់បក្សពួក មិនធ្វើការតាមតែការពេញចិត្ត ហើយមានដំណើរការដូចគ្នារាល់ពេល អ្នកនឹងយល់ច្បាស់ពីលទ្ធផល។ នៅក្នុងរបៀបដូចគ្នានេះ នៅពេលដែលអ្នកចុចកុងតាក់បើកភ្លើង អ្នករំពឹងថាភ្លើងនឹងភ្លឺ ព្រោះអ្នកយល់ពីច្បាប់របស់អគ្គិសនី។ នៅពេលដែលខ្ញុំនៅលើ

យន្តហោះ ខ្ញុំរំពឹងថាវានឹងហោះដោយសារតែខ្ញុំយល់ពីច្បាប់នៃការហោះឡើង។ យន្តហោះ និងភ្លើងដំណើរការគ្រប់ពេល ដោយសារតែមុខងាររបស់វា ផ្អែកលើច្បាប់ដែលអាចរៀនបាន ហើយបន្ទាប់មកបានថតចម្លង ដើម្បីយកបង្កើតឱ្យបានលទ្ធផល និងមុខគ្នាដូចគ្នាគ្រប់ពេល។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ ដំណើរការនៅក្នុងកម្រិតដូចគ្នាទៅនឹងភាពច្បាស់លាស់ដែរ។

> *«ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភ័ក្ត្រព្រះអង្គ គឺថា ប្រសិនបើយើងទូលសូមអ្វីស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះព្រះអង្គនឹងព្រះសណ្ដាប់យើងជាមិនខាន។ បើយើងដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថា យើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ»។*

១ យ៉ូហាន ៥:១៤-១៥

នេះគឺជាទំនុកចិត្តរបស់យើង។ ប្រសិនបើយើងសុំអ្វីមួយស្របតាម បំណងព្រះហឫទ័យព្រះជាម្ចាស់ យើងដឹងថាទ្រង់ព្រះសណ្ដាប់យើង ហើយប្រសិនបើយើងដឹងថាទ្រង់ព្រះសណ្ដាប់យើង យើងដឹងថាយើងបានអ្វីដែលយើងសុំទ្រង់ហើយ។ អ្នកឃើញហើយថាខ្ញុំអាចមានទំនុកចិត្តអំពីលទ្ធផល ដោយសារតែព្រះមហាក្សត្រគឺជាអ្នកដែលបានបង្កើតច្បាប់។ ទ្រង់ក៏នឹងការពារច្បាប់របស់ទ្រង់ដែរ។ នៅពេលដែលព្រះគម្ពីរចែងថាទ្រង់ព្រះសណ្ដាប់យើង វាមិនសំដៅលើការ គ្រាន់តែឮពាក្យសម្ដីយើងយើងប៉ុណ្ណោះទេ តែផ្ទុយទៅវិញវាសំដៅលើការដែលចៅក្រមម្នាក់ ស្ដាប់ករណីណាមួយ ដើម្បីស្វែងរកយុត្តិធម៌។ ចៅក្រមមិនជំនុំជម្រះតាមអារម្មណ៍របស់គាត់ទេ តែផ្ទុយទៅវិញគាត់ធានាថាច្បាប់ ត្រូវគេយកមកអនុវត្តដើម្បីជាប្រយោជន៍ របស់ពលរដ្ឋក្នុងព្រះរាជ្យ។ ខ្ញុំបានដឹងរួចទៅហើយពីរបៀបដែលករណីនៅក្នុងតុលាការ និងបញ្ចប់ទៅមុនពេលដែលវាចាប់ផ្ដើម។

ឌ្រិនដា និងខ្ញុំបានឃើញរឿងដ៏គួរឱ្យកត់សម្គាល់ជាច្រើនកើតឡើង នៅក្នុងជីវិតយើងពេលយើងចាប់ផ្ដើមអនុវត្តច្បាប់របស់ព្រះរាជ្យ នៅក្នុងជីវិតយើង។ យើងបានរួចពីបំណុលទាំងស្រុង ក្នុងអំឡុងពេល ២ឆ្នាំកន្លះ។ យើងចេញពីពេលវេលាដែលត្រូវបែងចែកអាហារឆ្នាញ់មួយមុខ ឱ្យទៅកូនៗបីនាក់ ប្រែទៅជាមានលុយសុទ្ធដើម្បីទិញឡានថ្មីៗ និងអគារដែលជាផ្ទះក្នុងក្ដីស្រមៃយើងនៅលើដីទំហំជាង ២២ហិកតា និងមានលុយសម្រាប់ទិញវា។ យើងបានចាប់ផ្ដើមក្រុមហ៊ុន នៅក្នុងឆ្នាំនោះ ក្រោយមកក៏នៅតែរកលុយបានរាប់

រយពាន់ដុល្លារក្នុងមួយឆ្នាំ គិតជាប្រាក់ចំណេញសរុប។ បន្ទាប់មកយើងបានបន្តចាប់ផ្តើមក្រុមជំនុំមួយនៅក្នុងស្រុកកំណើត ដើម្បីចែករំលែកប្រាប់មនុស្ស ពីអ្វីដែលយើងរកឃើញអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ហើយយើងរកឃើញថា មានមនុស្សជាច្រើនចង់ដឹងពីអ្វីដែលយើងបានរកឃើញ និងរស់នៅក្នុងជីវិតដ៏ប្រសើរ ដែលព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រទានមក។ ដោយសារតែដំណឹងល្អនៃព្រះរាជ្យ ចាប់តាំងពីពេលនោះមក ក្រុមជំនុំក៏បានរីកចម្រើនរហូតមានសមាជិករឹងមាំដល់ទៅរាប់ពាន់នាក់។

ទោះបីជាខ្ញុំបានបង្រៀនពីព្រះរាជ្យស្ទើរតែរាល់ថ្ងៃ ទៅមនុស្សជាច្រើនដែលចង់ស្តាប់ ខ្ញុំមានបំណងក្នុងការឈោងចាប់ក្រុមមនុស្សមួយក្រុម ដែលមិនទាន់បានឮពីរឿងនេះពីមុនមកទុកជាការពិសោធមួយ។ ខ្ញុំដឹងថា ដើម្បីមើលឃើញពីការផ្លាស់ប្តូរក្នុងជីវិតរបស់នរណាម្នាក់ ផ្អែកលើការយល់ដឹងរបស់ពួកគេអំពីព្រះរាជ្យ ខ្ញុំនឹងត្រូវការលើសពីមួយវគ្គសិក្សា ដើម្បីពន្យល់ពីការយល់ដឹងមូលដ្ឋាន ពីព្រះរាជ្យទាំងមូល។ គំនិតដែលខ្ញុំគិតថា នឹងដំណើរការបាន បានកើតចេញពីបទពិសោធរបស់ខ្ញុំដែលធំធាត់ឡើង នៅក្នុងព្រះវិហារមេតូឌីស្ត។ ពេលខ្ញុំនៅក្មេង យើងមានពេលវេលាសម្រាប់ការផុសផុលដល់ទៅមួយសប្តាហ៍ នាពេលល្ងាចៗ។ ហេតុដូច្នេះហើយខ្ញុំស្រមៃពីការមានពេលមួយសប្តាហ៍ដើម្បីមានការផុសផុលផ្នែកហិរញ្ញវត្ថុ ប្រសិនបើអ្នកនឹងធ្វើវា។ ខ្ញុំបានស្រមៃថាវាជាវគ្គសិក្សាដែលមានរយៈពេលប្រាំសប្តាហ៍ក្នុងពេលល្ងាចៗ។ ខ្ញុំមិនដែលបង្រៀនអំពីព្រះរាជ្យម្តងមួយបន្ទាត់ម្តងមួយបន្ទាត់ពីមុនមកទេ ខ្ញុំឆ្ងល់ណាស់ថាតើខ្ញុំដាក់រឿងរ៉ាវបញ្ចូលគ្នាបានដោយរបៀបណា។ ក៏ប៉ុន្តែខ្ញុំចង់ដឹងថាតើ ការបង្រៀនប្រាំសប្តាហ៍ជាប់គ្នានឹងមានឥទ្ធិពលអ្វីខ្លះទៅលើមនុស្សដែលបានស្តាប់មេរៀន។ ខ្ញុំបានចាប់ផ្តើមអធិស្ឋានអំពីការរៀបចំការប្រជុំបែបនោះឡើង និងបានសុំព្រះជាម្ចាស់នូវឱកាសដើម្បីធ្វើវា។ លក្ខខណ្ឌរបស់ខ្ញុំ នឹងជាការបង្រៀនមេរៀនទៅក្រុមមនុស្សដែលមិនដែលធ្លាប់ឮ ពីមេរៀននេះពីមុនមក។

នៅពេលថ្ងៃមួយ ខ្ញុំបានជួបមិត្តម្នាក់ ដែលជាបេសកកជននៅ ប្រទេសអាល់បានី។ ការសន្ទនារបស់យើងវិលទៅវិលមកជុំវិញគំនិតជាច្រើន អំពីក្រុមជំនុំ និងព័ន្ធកិច្ច ហើយចុងក្រោយការសន្ទនារបស់យើងបានធ្លាក់ទៅដល់អ្វីដែលព្រះជាម្ចាស់បានបង្ហាញដល់ខ្ញុំ។ ពេលនោះឡារី (Larry) កំពុងតែរៀបចំសន្និបាតព័ន្ធកិច្ចទូទាំងប្រទេសមួយ នៅប្រទេសអាល់បានី សម្រាប់ពេលក្រោយក្នុងឆ្នាំដដែលនោះ នៅរដូវស្លឹកឈើជ្រុះ ហើយបានអញ្ជើញខ្ញុំឱ្យធ្វើជាវាគ្មិន។ ខ្ញុំមិនបានប្រាប់គាត់ពីបំណងចង់ធ្វើការបង្រៀនប្រាំវគ្គនោះទេ ក៏ប៉ុន្តែខ្ញុំមានចិត្តរំភើបពេលដែលគាត់បាននិយាយថា ខ្ញុំនឹងដឹកនាំវគ្គដល់ទៅបីនៅទីនេះ។ គាត់បាន

ប្រាប់ខ្ញុំថា ខ្ញុំ និងគ្រូគង្វាលជាច្រើនទៀត ដែលចង់ចូលរួមត្រូវតែធ្វើការចំណាយផ្ទាល់ខ្លួន ដើម្បីមក ព្រោះតែពេលនោះប្រទេសអាល់បានីពិតជាក្រីក្រណាស់។ ខ្ញុំបានយល់ព្រម និង បានរៀបចំផែនការទៅដល់ប្រទេសអាល់បានី នៅរដូវស្លឹកឈើជ្រុះ នៅឆ្នាំ ២០០៥។

ទីបំផុតការធ្វើដំណើរនោះក៏ចូលមកដល់ ហើយខ្ញុំរំភើបចិត្តជាខ្លាំង ដែលអាច បង្រៀនពីព្រះរាជ្យទៅក្រុមមនុស្សដែល ទើបតែបានចាប់ផ្តើមរៀនពីអត្ថន័យក្នុងការក្លាយ ជាគ្រិស្តបរិស័ទ។ ពេលខ្ញុំទៅដល់អាល់បានី ឡារីបានជួបខ្ញុំនៅព្រលានយន្តហោះ និងបាន ប្រាប់ថាវាគ្មិនម្នាក់បានលុបចោលការណាត់ជួប និងប្រាប់ថាខ្ញុំនឹងត្រូវបង្រៀនដល់ទៅប្រាំ វគ្គ។ ខ្ញុំដឹងយ៉ាងច្បាស់ថានេះគឺជាការរៀបចំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ! ខ្ញុំមានកំណត់ត្រា សម្រាប់វគ្គតែបីប៉ុណ្ណោះ ប៉ុន្តែខ្ញុំបានអធិស្ឋានយ៉ាងរហ័ស និងសរសេរមេរៀនសម្រាប់វគ្គពីរ ទៀត។ កាលនោះខ្ញុំរាងព្រួយបារម្ភបន្តិច អំពីរបៀបដែលមនុស្សនឹងឆ្លើយតប ក្នុងពេល ដែលភាពក្រីក្ររបស់ពួកគេជាបញ្ហាដ៏ធ្ងន់ធ្ងរ ហើយអំពើពុករលួយកើតឡើងគ្រប់ទីកន្លែង នៅក្នុងប្រទេសដូច្នេះ។

ខ្ញុំអាចប្រាប់បានថា អំឡុងពេលបង្រៀនវគ្គទី១ ពួកគេហាក់ដូចជាស្ទាក់ស្ទើរបន្តិច តែពេលខ្ញុំបន្តបង្រៀនពីអ្វីដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំ ជាមួយនឹងរឿងជាច្រើនដែលធ្វើ ឱ្យអ្វីដែលខ្ញុំបង្រៀនមានសុពលភាព មនុស្សក៏រីករាយ និងមានចិត្តរំភើបជាងមុន។ នៅក្នុង វគ្គទីបួនដែលខ្ញុំបង្រៀន ពួកគេសើច ហើយរីករាយអំពីអ្វីដែលពួកគេបានឮ រហូតដល់មាន អ្នកខ្លះស្រែកឡើងផង។ អ្វីដែលប្លែកនោះគឺ ខ្ញុំមានអារម្មណ៍ថាព្រះជាម្ចាស់បានប្រាប់ខ្ញុំថា ខ្ញុំ នឹងត្រូវសុំតង្វាយនៅក្នុងការបង្រៀនវគ្គទីប្រាំ។ ខ្ញុំនិយាយថាចម្លែក ដោយសារតែខ្ញុំបាន ចេញលុយឱ្យមនុស្សជាច្រើនដែលមកចូលរួម ការប្រជុំ ហើយដឹងថាពួកគេមានលុយមិន ច្រើនទេ ឬក៏គ្មានលុយទៀតផងមាន។ ក៏ប៉ុន្តែបន្ទាប់ពីខ្ញុំគិតអំពីរឿងនេះ ខ្ញុំដឹងថាពួកគេត្រូវ តែបញ្ចេញសកម្មភាព អនុវត្តអ្វីដែលពួកគេបានឮ។ ខ្ញុំព្រួយបារម្ភបន្តិចអំពីការប្រាប់ទៅឡារី អំពីរឿងនេះ តែទោះជាយ៉ាងណាក៏ដោយ គាត់បានប្រាប់ខ្ញុំថាឱ្យធ្វើអ្វីដែលខ្ញុំចង់ធ្វើ ហើយ សុំតង្វាយទៅចុះ។ ជាការពិតណាស់ ខ្ញុំមិនមែនយកតង្វាយសម្រាប់ខ្លួនខ្ញុំទេ តង្វាយនឹង ទុកនៅប្រទេសអាល់បានី សម្រាប់ជាប្រយោជន៍ដល់ក្រុមជំនុំនៅអាល់បានី។

ការបង្រៀនវគ្គចុងក្រោយបានចូលមកដល់ ហើយខ្ញុំកំពុងតែបង្រៀនតាមអ្វីដែល ខ្ញុំសរសេរ ពីរបៀបស្រាយជំនឿ ពីការបញ្ជាក់ពីច្បាប់មួយចំនួនដែលខ្ញុំបានរៀន។ នៅចុង បញ្ចប់នៃវេនថ្វាយបង្គំ ពេលដែលខ្ញុំសុំតង្វាយ អ្វីៗស្រាប់តែបាត់បង់ភាពម្ចាស់ការ។ មនុស្ស

ចាប់ផ្ដើមស្រែក និងច្រៀងពេលដែល ការចាក់ប្រេងតាំងរបស់ព្រះជាម្ចាស់បានបំពេញសាលប្រជុំ។ យើងឱ្យមនុស្សបួននាក់ ឈរកាន់កន្ត្រកនៅខាងមុខ ហើយពួកគេហាក់ដូចជាពិបាកក្នុងការឈរផង។ ពួកគេយំ និងញ័រខ្លួននៅក្រោមព្រះវត្តមានរបស់ព្រះជាម្ចាស់ ពេលមនុស្សយកតង្វាយមកដាក់។ ខ្ញុំមិនដែលឃើញការប្រជុំបែបនេះសោះ ជាពិសេសទាក់ទងនឹងការថ្វាយលុយតង្វាយដូច្នេះ!

ពេលឡារី និងខ្ញុំចាកចេញពីការប្រជុំ យើងបាននិយាយថាយើងភ្ញាក់ផ្អើលយ៉ាងណា ដោយសារតែអំណាចនៃការចាក់ប្រេងតាំង និងការឆ្លើយតបរបស់មនុស្សនៅក្នុងយប់នោះ។ ក្រោយពេលមកដល់ផ្ទះរបស់ឡារីវិញ ឡារីរាប់លុយទាំងងឿងឆ្ងល់ ដោយសារតែគាត់មិនដែលទទួលបានលុយដល់ទៅពីរកាបូបពេញៗ ពីការថ្វាយដង្វាយទេ។ គាត់និយាយថាលុយមួយភាគបួននៃថង់មួយស្មើនឹងចំនួនធម្មតា ដែលគាត់ប្រមូលបាន ពេលគាត់សុំតង្វាយកាលពីមុន។ ពេលដែលឡារីចាក់លុយនោះចេញនៅលើតុ ក្នុងបន្ទប់ទទួលភ្ញៀវរបស់គាត់ ស្រាប់តែមានអ័ព្ទពណ៌ខៀវស្រាល ពេញនៅក្នុងបន្ទប់នោះ និងមានការចាក់ប្រេងតាំង ដែលខ្ញុំមិនដែលធ្លាប់ទទួលអារម្មណ៍ថាមានពីមុនមក បានចាក់លើយើង។ យើងមិនអាចធ្វើអ្វីបានទេ ក្រៅពីដួលចុះទៅនឹងកៅអីដែលយើងអង្គុយវិញ។ ពេលដែលខ្ញុំសម្លឹងមើលទៅគំនរលុយនៅលើតុនៅចំពោះមុខយើង ខ្ញុំកត់សម្គាល់ឃើញ ចិញ្ចៀនរៀបការរបស់បុរសម្នាក់នៅកណ្ដាលគំនរនោះ។ ខ្ញុំបានដឹងថាអ្នកដែលឱ្យចិញ្ចៀននោះគឺជាមនុស្សដែលគ្មានលុយ តែគាត់បានឱ្យអ្វីទាំងអស់ដែលគាត់មាន។ ពេលខ្ញុំមើលឃើញចិញ្ចៀននោះ ព្រះអម្ចាស់មានបន្ទូលមកខ្ញុំ។

«យើងត្រាស់ហៅអ្នកឱ្យចូលទៅកាន់ប្រជាជាតិជាច្រើន ដើម្បីបង្រៀនពីសម្ពន្ធមេត្រីរបស់យើង អំពីការប្រទានពរផ្នែកហិរញ្ញវត្ថុ ហើយគ្រប់កន្លែងដែលយើងបញ្ជូនអ្នកទៅ យើងគឺជាអ្នកចេញថ្លៃចំណាយ»។

ខ្ញុំធ្វើអ្វីលែងកើត ហើយខ្ញុំមិនអាចគេងលក់បានដល់ទៅបីថ្ងៃ។ ការចាក់ប្រេងតាំងនោះបាននៅជាប់ជាមួយខ្ញុំអស់ពេលជាច្រើនសប្ដាហ៍បន្ទាប់ពីនោះ។ ប្រសិនបើខ្ញុំបានជួបនរណាម្នាក់ ពីក្នុងចំណោមប្រជាជាតិផ្សេងទៀត ខ្ញុំនឹងទទួលអារម្មណ៍ដឹងពីការចាក់ប្រេងតាំងបែបនោះម្ដងទៀត។ ទោះបីជាខ្ញុំទុកតង្វាយទាំងនោះសម្រាប់ក្រុមជំនុំនៅអាល់បានី តែពេលខ្ញុំមកដល់ផ្ទះ ឡារីទូរស័ព្ទមកខ្ញុំ ហើយនិយាយថាព្រះអម្ចាស់មានបន្ទូលប្រាប់គាត់ឱ្យផ្ញើចិញ្ចៀនមកឱ្យខ្ញុំ។ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង។ ទោះបីជាខ្ញុំមិនបានប្រាប់ឡារីពីបំណង

របស់ខ្ញុំ ដែលចង់បានចិញ្ចៀននោះ តែគាត់បានឮពីព្រះជាម្ចាស់ឱ្យផ្ញើវាមកឱ្យខ្ញុំ។ ខ្ញុំទុកចិញ្ចៀននោះជាការចងចាំពីអ្វីដែលព្រះអម្ចាស់មានបន្ទូលមកខ្ញុំ ហើយសព្វថ្ងៃនេះខ្ញុំទុកវាព្យួរនៅលើជញ្ជាំងរបស់ខ្ញុំ។

ពេលខ្ញុំមកដល់ផ្ទះនៅរដ្ឋអូហៃយ៉ូ គ្រូគង្វាលម្នាក់ដែលជាមិត្តរបស់ឡារី ជាគ្រូគង្វាលក្នុងក្រុមជំនុំតូចមួយ នៅក្នុងរដ្ឋអ៊ូតា (Utah) បានឮពីអ្វីដែលបានកើតឡើងនៅអាល់បានី ហើយបានទាក់ទងសុំជួបខ្ញុំ ប្រសិនបើខ្ញុំអាចជួបគាត់បាន។ គាត់បានធ្វើជាគ្រូគង្វាលនៅក្នុងតំបន់កុលសម្ព័ន្ធជាតិដើមអាមេរិក ហើយគាត់ប្រាប់ថាមនុស្សនៅទីនោះក្រីក្រណាស់។ គាត់ប្រាប់ថាក្រុមជំនុំគាត់មានមនុស្សប្រមាណ ៦០នាក់ប៉ុណ្ណោះ ក៏ប៉ុន្តែខ្ញុំបានប្រាប់គាត់ថាមិនអីទេ ខ្ញុំនឹងទៅទីនោះ។

ខ្ញុំបានបង្រៀនវគ្គទាំងប្រាំដដែល ដែលខ្ញុំបង្រៀននៅអាល់បានី។ ខ្ញុំមិនបានឃើញអ័ព្ទពណ៌ខៀវនៅទីនោះទេ ក៏ប៉ុន្តែការចាក់ប្រេងតាំងពិតជាមានសភាពខ្លាំងក្លាម្តងទៀត។

តង្វាយលើកនេះគឺយកសម្រាប់ព័ន្ធកិច្ចផ្ទាល់ខ្លួនរបស់ខ្ញុំ ដូច្នេះហើយខ្ញុំបានបិទកាបូបដាក់លុយរបស់ខ្ញុំ និងយកវាទៅអូហៃយ៉ូវិញ។ ពេលខ្ញុំមកដល់ការិយាល័យរបស់ខ្ញុំ ខ្ញុំបានហុចកាបូបរបស់ខ្ញុំទៅឱ្យលេខាខ្ញុំ ដើម្បីរាប់ និងដាក់វាចូលធនាគារឱ្យខ្ញុំ បន្ទាប់មកខ្ញុំបានចេញទៅញ៉ាំអាហារថ្ងៃត្រង់។ ពេលញ៉ាំអាហារថ្ងៃត្រង់ ទូរស័ព្ទដៃខ្ញុំរោទិ៍ឡើង គឺជាលេខរបស់លេខាខ្ញុំ។ ពេលខ្ញុំលើកទូរស័ព្ទ ខ្ញុំមិនឮនរណានិយាយអ្វីទេ។ តែពេលខ្ញុំរៀបនឹងដាក់ទូរស័ព្ទចុះ ខ្ញុំដូចជាឮនរណាម្នាក់យំ ហើយខ្ញុំសួរថា «ត្រេស៊ី (Tracy) មែនទេ?» ត្រេស៊ី បានឆ្លើយ ដោយព្យាយាមទប់អារម្មណ៍របស់គាត់ថា «លោកគ្រូ តើមានរឿងអ្វីកើតឡើងនៅរដ្ឋអ៊ូតាចំពោះលុយទាំងនេះ»? «តើនាងចង់និយាយពីអ្វីទៅ តើមានអ្វីកើតឡើងចំពោះលុយនោះ»? នាងតបថា «ពេលខ្ញុំបើកកាបូប ហើយចាក់វាដាក់លើតុដើម្បីរាប់ ស្រាប់តែមានការចាក់ប្រេងតាំងពីព្រះជាម្ចាស់យ៉ាងខ្លាំងរហូតធ្វើឱ្យខ្ញុំដួល។ លេខាម្នាក់ទៀតដែលបានឮព្រឹត្តិការណ៍នោះ បានចូលមកមើលថាមានរឿងអីកើតឡើង ហើយអំណាចរបស់ព្រះជាម្ចាស់បានប៉ះទង្គិចគាត់ដូចគ្នានឹងខ្ញុំដែរ! តើមានរឿងអ្វីកើតឡើងចំពោះលុយនោះទៅ លោកគ្រូ»? ខ្ញុំបានប្រាប់គាត់ពីអ្វីដែលកើតឡើងនៅអ៊ូតា និងការចាក់ប្រេងតាំងដ៏ខ្លាំងក្លា នៅទីនោះពេលខ្ញុំប្រមូលតង្វាយ ក៏ប៉ុន្តែក្រៅពីនោះដូចជាគ្មានអ្វីទៀតទេ។ ខ្ញុំត្រូវតែទទួលស្គាល់ថា ខ្ញុំចង់ដឹងចង់ឮខ្លាំងណាស់ពីអ្វីដែលបានកើតឡើង ដោយសារតែខ្ញុំមិនដែលឮពីរឿងបែបនេះ

ពីមុនមកទេ។ ទោះបីជាខ្ញុំមិនយល់ពីវា តែវាប្រាកដណាស់ថា វាជាការចាក់ប្រេងតាំងមកពីការប្រជុំនោះ នៅលើលុយនោះ! គឺជាការពិត!

យើងបានចាប់ផ្តើមធ្វើសន្និបាតដែលមានឈ្មោះថា បដិវត្តន៍ហិរញ្ញវត្ថុ នៅទូទាំងប្រទេស នៅក្នុងក្រុមជំនុំតូចធំជាច្រើន នៅទីណាក៏ដោយឱ្យតែមានមនុស្សស្តាប់។ ទោះបីជាយើងមើលឃើញអ័ព្ទពណ៌ខៀវ តែពេលខ្លះ ក៏ការចាក់ប្រេងតាំងតែងតែមានសភាពខ្លាំងក្លាដែរ។ ដូចជានៅអាល់បានី និងការថ្វាយតង្វាយពីក្រុមជំនុំជនជាតិដើមអាមេរិកនៅរដ្ឋអ៊ូតាដែរ ការចាក់ប្រេងតាំងដែលនៅសេសសល់ គឺស្ថិតនៅលើតង្វាយនោះផ្ទាល់តែម្តង។ ខ្ញុំកត់សម្គាល់មើលឃើញថា បន្ទាប់ពីការប្រជុំ ហើយតង្វាយត្រូវយកមករាប់ ពេលមនុស្សចាប់កាន់កាក់មួយពីតង្វាយនោះ គេនឹងចាប់ផ្តើមញ័រក្រោមអំណាចនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ រឿងម៉្យាងទៀតដែលគួរឱ្យចាប់អារម្មណ៍ដែលយើងកត់សម្គាល់ឃើញថា គ្រប់ចំណែកនៃលុយ ឬមូលប្បទានបត្រមានភាពខុសប្លែកគ្នា។ លុយទាំងនោះមិនមានកម្រិតនៃការចាក់ប្រេងតាំងដូចគ្នាទេ។ ក្រោយមកទើបខ្ញុំដឹងថា នេះគឺជាលទ្ធផលនៃជំនឿដែលបានបង្ហាញចេញមក នៅក្នុងតង្វាយដែលបុគ្គលម្នាក់ៗថ្វាយ។ ពិតជាអស្ចារ្យណាស់!

នៅក្នុងស៊េរីសៀវភៅ *បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក* មានមេរៀនប្រាំវគ្គ ដែលខ្ញុំបានបង្រៀននៅក្នុងការប្រជុំដំបូងនៅអាល់បានី។ ជាការពិតណាស់សៀវភៅទាំងនេះ វែងជាងសន្និបាតដំបូងបន្តិចហើយ។ ខ្ញុំជឿជាក់ថាពេលអ្នកចាប់ផ្តើមសិក្សាពីព្រះរាជ្យ ដូចជាឌ្រិនដា និងខ្ញុំ វានឹងផ្លាស់ប្តូររបៀបដែលអ្នកមើលទៅអ្វីគ្រប់យ៉ាង ឃើញដូចយើងពីមុនដែរ។ សៀវភៅនេះគឺជាស៊េរីទី៣ ដែលពីមុនមានឈ្មោះថា *ទ្រព្យសម្បត្តិតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ* ពេលដែលខ្ញុំបង្រៀននៅអាល់បានី។ ខ្ញុំជឿថាឈ្មោះនោះនៅតែជាការពិតក្នុងពេលបច្ចុប្បន្ននេះ។ វានឹងក្លាយជាយុទ្ធសាស្ត្រដែលបានទទួលការលើកទឹកចិត្តពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនឹងនាំឱ្យអ្នកបានចម្រុងចម្រើន។ ក្តីសង្ឃឹមរបស់ខ្ញុំគឺថា តាមរយៈសៀវភៅនេះ អ្នកនឹងរៀនពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការនៅលើផែនដីនេះ ដើម្បីនាំយុទ្ធសាស្ត្រទាំងនេះបានសម្រេចឡើង។

# ជំពូក ១

# ទ្រង់ចង់ឱ្យពួកយើងធ្វើអ្វី?

នៅពេលដែលខ្ញុំទើបត្រលប់មកពីប្រទេសអាល់បានីដំបូង ខ្ញុំមានអារម្មណ៍ស្អុកស្អាញមែនទែន។ ឥទ្ធិពលនៃអ្វីដែលព្រះអម្ចាស់បានធ្វើក្នុងជីវិតរបស់ពួកយើង និងបន្ទាប់មកទៀត របៀបដែលទ្រង់បានប្រាប់ខ្ញុំថា ខ្ញុំត្រូវចែករំលែករឿងនេះជាមួយប្រជាជាតិនានា ធ្វើឱ្យខ្ញុំមានអារម្មណ៍លើសលប់ក្រៃលែង។ ប្រជាជាតិនានា? នៅពេលយើងទើបរៀបការដំបូង ខ្ញុំធ្លាប់ប្រាប់ឌ្រិនដាថា ខ្ញុំនឹងមិនធ្វើដំណើរទេ ខ្ញុំមិនដែលមានចិត្តចង់ធ្វើដំណើរបេសកម្មទៅប្រទេសផ្សេងទេ។ ក៏ប៉ុន្តែ ពិតណាស់ ព្រះជាម្ចាស់មានគម្រោងការផ្សេងសម្រាប់ខ្ញុំ។ ខ្ញុំត្រូវធ្វើដំណើរទៅប្រទេសនានា តើដោយរបៀបណាទៅ? ខ្ញុំមានជំនួញមួយដែលគ្របដណ្តប់នៅតំបន់ភាគច្រើននៅសហរដ្ឋអាមេរិក មានក្រុមជំនុំដែលត្រូវដឹកនាំ មានគ្រួសារដែលត្រូវថែរក្សា និងមានទំនួលខុសត្រូវជាច្រើនទៀត។ ខ្ញុំមើលមិនឃើញពីរបៀបដែលខ្ញុំអាចធ្វើដំណើរទៅប្រទេសនានាបានទេ។ ក៏ប៉ុន្តែ ព្រះជាម្ចាស់មានគម្រោងការផ្សេង ជាគម្រោងការដែលមិនតម្រូវឱ្យខ្ញុំធ្វើដំណើរនោះទេ ជាគម្រោងការដែលខ្ញុំមិនធ្លាប់គិតដល់ ហើយក៏មិនចង់គិតអំពីវាផងដែរគឺ ការផ្សាយតាមទូរទស្សន៍។

ឌ្រិនដា និងខ្ញុំមិនមានចំណេះដឹងអ្វីសោះអំពីការផ្សាយតាមទូរទស្សន៍។ នៅពេលនោះ យើងនៅមិនទាន់បានថតវេនថ្វាយបង្គំរបស់យើងនៅឡើយផង។ ក៏ប៉ុន្តែ ទ្រង់បានចាប់ផ្តើមបង្ហាញយើងអំពីអ្វីដែលនឹងត្រូវមកដល់ និងរបៀបធ្វើវាឱ្យកើតឡើង ហើយចំណាប់អារម្មណ៍របស់យើងមានទំនោរទៅរកការផ្សាយតាមទូរទស្សន៍។ រឿងដំបូងដែលខ្ញុំបានរៀនគឺ ត្រូវចំណាយលុយជាច្រើនដើម្បីធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍។ បន្ទាប់ពីធ្វើការបូកសរុបថ្លៃចំណាយទាំងអស់មក យើងឃើញថា វាត្រូវចំណាយប្រាក់អស់ប្រហែល ៣០ម៉ឺនដុល្លារ ដើម្បីបើកដំណើរការការផ្សព្វផ្សាយតាមទូរទស្សន៍ឆ្នាំដំបូង។ និយាយឱ្យស្មោះត្រង់ ខ្ញុំទទួលស្គាល់ថា ខ្ញុំពិតជាមានការភ្ញាក់ផ្អើលចំពោះតម្លៃនៃការផ្សាយតាមទូរទស្សន៍។ បញ្ហាធំគឺថា ក្រុមជំនុំរបស់យើងមានគម្រោងថវិកាច្រើនដល់កម្រិតអតិប្បរមារួចទៅ

ហើយ ដោយសារយើងកំពុងសាងសង់មជ្ឈមណ្ឌលឥឡូវនេះ ដែលជាអគារព័ន្ធកិច្ចរបស់យើង ហើយយើងមិនមានថវិកាបន្ថែមទៀតសម្រាប់ការផ្សព្វផ្សាយតាមទូរទស្សន៍ទេ។ ដូច្នេះ ខ្ញុំបានប្រាប់ទ្រង់ថា យើងមិនមានថវិកា ដើម្បីបើកដំណើរការការផ្សព្វផ្សាយតាមទូរទស្សន៍ពេលឥឡូវនេះទេ។ ខ្ញុំចាំថា ទ្រង់បានយល់ស្របជាមួយខ្ញុំ ហើយបានមានបន្ទូលថា «ត្រូវហើយ ហើយនេះជាមូលហេតុដែលកូន និងឌ្រិនដា ត្រូវចេញថ្លៃចំណាយទាំងនេះ!»

បើនិយាយថា យើងគ្រាន់តែមានអារម្មណ៍លើសលប់បន្តិចបន្តួច វាមិនត្រឹមត្រូវនោះទេ ជាពិសេសពេលដែលយើងកំពុងតែសាងសង់អគារដែលមានគម្រោងថវិកាពីប្រាំមួយទៅប្រាំពីរលានដុល្លារ។ សូមជឿខ្ញុំទៅ គម្រោងសាងសង់អគារមជ្ឈមណ្ឌលឥឡូវនេះ គឺជាកិច្ចការដែលត្រូវប្រើជំនឿដ៏ច្រើនលើសលប់ ហើយត្រូវប្រើធនធានទាំងប៉ុន្មានដែលយើងទទួលបាន។ លើសពីនេះទៅទៀត ឌ្រិនដា និងខ្ញុំបានប្តេជ្ញាចិត្តថ្វាយថវិកាចំនួន២៥ម៉ឺនដុល្លារសម្រាប់គម្រោងអគារនេះ ហើយនៅពេលនោះ យើងមិនទាន់មានលុយថ្វាយតាមការសន្យារបស់យើងនៅឡើយទេ។ បើថែម៣០ម៉ឺនដុល្លារពីលើចំនួននេះទៀត នៅក្នុងឆ្នាំតែមួយ វាហាក់ដូចជាទៅមិនរួចទេ។

ខ្ញុំដឹងថាដំណើរដែលខ្ញុំកំពុងឆ្លងកាត់ គឺមកពីព្រះជាម្ចាស់ ហើយការសន្យារបស់ទ្រង់ក្នុងការផ្គត់ផ្គង់សម្រាប់អ្វីៗគ្រប់យ៉ាងដែលទ្រង់សព្វព្រះហឫទ័យឱ្យខ្ញុំធ្វើ នៅតែដក់ជាប់ក្នុងវិញ្ញាណរបស់ខ្ញុំ។ ទោះជាយ៉ាងនេះក្តី តាមលក្ខណៈធម្មជាតិ ឬក្នុងនាមជាមនុស្សម្នាក់ ខ្ញុំមើលមិនឃើញពីរបៀបដែលឌ្រិនដា និងខ្ញុំអាចចេញថ្លៃចំណាយ៣០ម៉ឺនដុល្លារបន្ថែមលើអ្វីផ្សេងទៀតដែលយើងកំពុងតែធ្វើនោះទេ។

ខ្ញុំដឹងថាព្រះជាម្ចាស់ទ្រង់ស្មោះត្រង់នឹងព្រះបន្ទូលសន្យារបស់ទ្រង់ ហើយខ្ញុំក៏ដឹងថា ខ្ញុំត្រូវបោះជំហានដោយជំនឿ ដោយជឿជាក់ថាទ្រង់នឹងបង្ហាញផ្លូវ។ បើអាច ខ្ញុំពិតជាចង់ប្រាប់អ្នកថា ខ្ញុំមានទំនុកចិត្ត ហើយគ្មានការព្រួយបារម្ភចំពោះការសម្រេចចិត្តមួយនេះទេ ក៏ប៉ុន្តែខ្ញុំមិនអាចនោះទេ។ ក្រុមជំនុំបានប្រើប្រាស់គ្រប់កាក់សេនទាំងអស់ដែលយើងទទួលបានដើម្បីការសាងសង់អគារ។ រាល់ថវិកាផ្ទាល់ខ្លួនរបស់ខ្ញុំត្រូវបានប្រើសម្រាប់តង្វាយសន្យា២៥ម៉ឺនដុល្លារ ហើយផ្នែកជាច្រើនផ្សេងទៀតនៃជំនួញរបស់ខ្ញុំក៏ត្រូវការថវិកាផងដែរក្នុងឆ្នាំនោះ។ ពិតជាមិនមានថវិកា៣០ម៉ឺនដុល្លារ ដែលជាថ្លៃចាប់ផ្តើមដំណើរការការផ្សព្វផ្សាយតាមទូរទស្សន៍ទេ!

**ខ្ញុំដឹងថាព្រះជាម្ចាស់ទ្រង់ស្មោះត្រង់នឹងព្រះបន្ទូលសន្យារបស់ទ្រង់ ហើយខ្ញុំក៏ដឹងថា ខ្ញុំត្រូវបោះជំហានដោយជំនឿ ដោយជឿជាក់ថាទ្រង់នឹងបង្ហាញផ្លូវ។**

គ្រិនដា និងខ្ញុំបានមានគម្រោងធ្វើវិស្សមកាលរយៈពេលពីរសប្តាហ៍នៅកោះហាវ៉ៃ ហើយបន្ទាប់ពីពេលខ្ញុំត្រលប់មកផ្ទះវិញ ខ្ញុំនឹងត្រូវចុះកិច្ចសន្យាលើគម្រោងផ្សព្វផ្សាយតាមទូរទស្សន៍។ ខ្ញុំពិតជាពេញចិត្តនឹងកោះហាវ៉ៃ ក៏ប៉ុន្តែ ខ្ញុំក៏ត្រូវសារភាពតាមត្រង់ថា វាពិបាកបន្តិចក្នុងការមានអារម្មណ៍សម្រាកទាំងស្រុង នៅពេលទម្ងន់នៃការសម្រេចចិត្តដែលខ្ញុំត្រូវធ្វើ បន្ទាប់ពីត្រលប់មកផ្ទះវិញ មិនអាចដកចេញពីចិត្តគំនិតរបស់ខ្ញុំបាន។ ក្រៅពីផ្នែកថវិកា ខ្ញុំក៏មិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការផ្សព្វផ្សាយតាមទូរទស្សន៍ដែរ ដោយសារខ្ញុំមានអារម្មណ៍មិនសុខស្រួលពេលនិយាយនៅពីមុខកាមេរ៉ា។ ខ្ញុំអាចនិយាយជាមួយមនុស្សរាប់ពាន់អ្នកក្នុងការប្រជុំ ក៏ប៉ុន្តែពេលនៅពីមុខកាមេរ៉ា ខ្ញុំស្រាប់តែមានអារម្មណ៍ភ័យតក់ស្លុត។ នៅក្នុងខួរក្បាល និងវិញ្ញាណរបស់ខ្ញុំ ខ្ញុំបានតយុទ្ធប្រឆាំងនឹងវិញ្ញាណនៃសេចក្តីភ័យខ្លាច ពេលធ្វើការសម្រេចចិត្តមួយនេះ។

ទោះបីខ្ញុំដឹងថា ខ្ញុំពិតជាបានឮពីព្រះជាម្ចាស់ក៏ពិតមែន ក៏ប៉ុន្តែ ខ្ញុំនៅតែប្រឈមមុខនឹងការពិតមួយនេះ គឺខ្ញុំគ្មានលុយទេ។ មុខជំនួញរបស់ខ្ញុំក៏តានតឹងផ្នែកថវិកាក្នុងឆ្នាំនេះ ហើយខ្ញុំពិតជាមិនអាចមើលឃើញថា វាអាចទៅរួចដោយរបៀបណាទេ។ បាទ! វាជាសេចក្តីភ័យខ្លាច ហើយវាការដែលមិនជឿ។ ខ្ញុំដឹងហើយ។ ខ្ញុំគ្រាន់តែចង់បង្ហាញភាពស្មោះត្រង់នៅទីនេះ។ ខ្ញុំដឹងថា ខ្ញុំត្រូវទុកចិត្តលើព្រះបន្ទូលសន្យា ឈប់សម្លឹងមើលអ្វីដែលខ្ញុំមាន និងសម្លឹងមើលព្រះបន្ទូលសន្យារបស់ទ្រង់វិញ។ ទ្រង់បានមានបន្ទូលថា ទ្រង់នឹងចេញថ្លៃចំណាយ! កំឡុងពេលនោះ ពួកយើងទទួលបានកាក់មាសមួយនៅពេលទទួលប្រាក់តង្វាយ។ និយាយតាមត្រង់ទៅ ខ្ញុំមិនធ្លាប់ឃើញកាក់មាសពីមុនទេ។ នៅពេលខ្ញុំកាន់កាក់មាសនោះ ទ្រង់បានមានបន្ទូលមកខ្ញុំ។ «ដូចដែលយើងបានបង្ហាញពេត្រុស ពីកន្លែងដែលត្រូវយកកាក់ដើម្បីបង់ពន្ធ យើងនឹងបង្ហាញកូន ពីកន្លែងដែលត្រូវរកប្រាក់ ដើម្បីបង់ថ្លៃចំណាយសម្រាប់ការផ្សាយតាមទូរទស្សន៍ផងដែរ។»

ខ្ញុំបានយកកាក់មាសនេះទៅជាមួយខ្ញុំ ពេលដែលយើងធ្វើដំណើរកំសាន្តនៅកោះហាវ៉ៃ។ ខ្ញុំបានដើរលើឆ្នេរខ្សាច់ និងអធិស្ឋាន ដោយកាន់កាក់នោះជាប់នឹងដៃ ដើម្បីរំលឹកខ្ញុំថា ព្រះជាម្ចាស់បានបង់ថ្លៃចំណាយរួចរាល់ហើយ។ ដំណើរអធិស្ឋានរបស់ខ្ញុំនៅតាមឆ្នេរខ្សាច់មានលក្ខណៈបែបនេះ៖ បន្ទាប់ពីបានអធិស្ឋានដោយវិញ្ញាណមួយរយៈពេលមក ខ្ញុំ

មានសន្តិភាពក្នុងចិត្តដើម្បីចុះហត្ថលេខាលើកិច្ចសន្យា ហើយពេលដែលចាប់ផ្តើមដើរត្រលប់ទៅផ្ទះកំសាន្តវិញ ពេលដើរបានពី៦ទៅ១៥ម៉ែត្រ គំនិតរបស់ខ្ញុំចាប់ផ្តើមស្រែកដាក់ខ្ញុំជាថ្មីម្តងទៀតថា គ្មានវិធីណាតាមបែបធម្មជាតិ ដែលអាចរកលុយចំនួនប៉ុណ្ណឹងបានទេ។ តាមភាពពិតជាក់ស្តែង យើងគ្មានលុយទេ ហើយក៏មិនដឹងពីរបៀបធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍ ក៏មិនមានឧបករណ៍ ហើយមិនមានអ្វីៗជាច្រើនទៀត។ ប៉ុន្តែនៅក្នុងវិញ្ញាណរបស់ខ្ញុំ ខ្ញុំនៅតែចាំអ្វីដែលទ្រង់បានមានព្រះបន្ទូលមកកាន់ខ្ញុំនៅប្រទេសអាល់បានី ដែលថាគ្រប់ទីកន្លែងដែលទ្រង់បញ្ជូនខ្ញុំទៅ ទ្រង់នឹងផ្គត់ផ្គង់។ ពេលដែលរឿងនេះកើតឡើង វាគឺដល់ខែឧសភាទៅហើយ ហើយបើតាមការជាក់ស្តែង ខ្ញុំត្រូវរកលុយឱ្យបាន៣០ម៉ឺនដុល្លារ នៅចុងឆ្នាំនោះ ទើបការផ្សព្វផ្សាយតាមទូរទស្សន៍អាចកើតមានឡើងបាន។ ជាមួយរយៈពេលដ៏ខ្លីបែបនេះ វាកាន់តែពិបាកធ្វើឱ្យការនេះកើតឡើងជាងមុនទៅទៀត។

វិញ្ញាណនៃសេចក្តីភ័យខ្លាចក៏និយាយមកកាន់ខ្ញុំ ល្បងលទំនុកចិត្តរបស់ខ្ញុំលើព្រះបន្ទូលសន្យា។ «ឯងបង្រៀនគេពីភាពស្មោះត្រង់ផ្នែកហិរញ្ញវត្ថុ ហើយឥឡូវនេះវាយ៉ាងម៉េចដែរ ដែលឯងមិនអាចបង់ថ្លៃចំណាយនេះបាន?» ដូច្នេះខ្ញុំក៏ងាកក្រោយ ត្រលប់ទៅឆ្នេរខ្សាច់វិញ ដើម្បីអធិស្ឋាន និងកែប្រែចិត្តគំនិតទៅតាមព្រះបន្ទូលរបស់ព្រះ រហូតទាល់តែខ្ញុំមានសន្តិភាពក្នុងចិត្តវិញ។ ខ្ញុំត្រលប់ទៅវិញទៅមក ដោយតយុទ្ធទាំងក្នុងគំនិត និងវិញ្ញាណទាក់ទងនឹងកិច្ចសន្យាមួយនេះ អស់រយៈពេលមួយសប្តាហ៍ រហូតទាល់តែខ្ញុំដឹងថា អ្វីៗនឹងមិនអីទេ ហើយសេចក្តីភ័យខ្លាចក៏មិនអាចធ្វើទុក្ខបុកម្នេញដល់ខ្ញុំជាមួយនឹងគំនិតអវិជ្ជមានទៀត។ ឌ្រិនដា និងខ្ញុំមិនដឹងថានឹងរកលុយមកពីណាទេ ក៏ប៉ុន្តែយើងប្រាកដក្នុងចិត្តថា យើងបានឮពីព្រះជាម្ចាស់។ ដូច្នេះ ពេលដែលខ្ញុំត្រលប់មកផ្ទះវិញ ខ្ញុំបានចុះហត្ថលេខាលើកិច្ចសន្យា ហើយបន្ទាប់មកយើងបានរិះរកវិធីដើម្បីធ្វើឱ្យការនេះកើតឡើង។

ទាក់ទងនឹងផ្នែកថវិកា ប៉ុន្មានខែមុនពេលវិស្សមកាលទៅកោះហាវ៉ៃ ដោយការអស្ចារ្យ ខ្ញុំបានទទួលទូរស័ព្ទពីបុរសម្នាក់នៅទីក្រុងអាត្លង់តា ដែលខ្ញុំមិនធ្លាប់ស្គាល់គាត់ពីមុនមកទេ។ គាត់បានប្រាប់ខ្ញុំថា គាត់បានអានសៀវភៅរបស់ខ្ញុំ ស្តីអំពីហិរញ្ញវត្ថុ ហើយគាត់ចូលចិត្តវា។ នៅពេលនោះ សៀវភៅរបស់ខ្ញុំត្រូវបានបោះពុម្ពផ្សាយដោយខ្លួនឯង ហើយមិនបានលក់នៅកន្លែងណាផ្សេង ក្រៅពីទីក្រុងដែលខ្ញុំកំពុងរស់នៅទេ។ ក៏ប៉ុន្តែមានបុគ្គលិករបស់ខ្ញុំម្នាក់បានធ្វើវិស្សមកាលទៅទីក្រុងអាត្លង់តា ហើយបានជជែកគ្នាលេងជាមួយបុរសម្នាក់នេះ ដែលគាត់បានជួបដោយចៃដន្យនៅឯព្រលានយន្តហោះ។ បុគ្គលិករបស់ខ្ញុំគាប់ជួនបានយកសៀវភៅនេះទៅជាមួយ ហើយក៏បានឱ្យវាទៅគាត់។

ដូច្នេះបន្ទាប់ពីគាត់បានអានវារួចហើយ គាត់បានចាប់អារម្មណ៍លើវាខ្លាំងមែនទែន ដែលគាត់បាននិយាយថា ត្រូវតែជួបនិយាយជាមួយខ្ញុំ។ យើងបានជជែកគ្នាអស់រយៈពេលជាយូរ ហើយគាត់បានប្រាប់ខ្ញុំថា គាត់ជាអ្នកធ្វើដំណើរផ្សាយដំណឹងល្អ ដោយផ្តោតលើប្រទេសបរទេស ជាការឈោងចាប់ចម្បងរបស់គាត់។ គាត់បានសួរខ្ញុំថា តើយើងអាចជួបគ្នាពេលណាមួយបានដែរឬទេ? ខ្ញុំក៏ប្រាប់គាត់វិញថា ខ្ញុំនឹងទៅអាកាសយានដ្ឋានអាត្លង់តាក្នុងរយៈពេលប្រហែលមួយខែខាងមុខនេះ ដើម្បីការប្រជុំមួយ បន្ទាប់ពីវិស្សមកាលរបស់ខ្ញុំ។ យើងក៏បានយល់ព្រមក្នុងការជួបគ្នា។ នៅពេលយើងបានជួបគ្នា ការសន្ទនារបស់យើងពិតជាល្អមែនទែន។ ខ្ញុំពិតជារីករាយដែលបានស្តាប់នូវរឿងរ៉ាវនៃការអស្ចារ្យ និងគ្រោះថ្នាក់ដែលគាត់ត្រូវប្រឈមជាញឹកញាប់នៅពេលដែលគាត់ធ្វើដំណើរ។ ក៏ប៉ុន្តែប្រធានបទដែលភ្ជាប់ទំនាក់ទំនងយើងទាំងពីរគឺទាក់ទងនឹងរឿងហិរញ្ញវត្ថុ។ គាត់ហាក់ដូចជាចាប់អារម្មណ៍នឹងសៀវភៅរបស់ខ្ញុំ ព្រមទាំងរឿងដែលខ្ញុំមានសេរីភាពពីបំណុល។

អំឡុងពេលនៃការសន្ទនារបស់យើង គាត់បានប្រាប់ខ្ញុំថា គាត់ទើបត្រលប់មកពីក្រុងឆាឡុត ដែលគាត់ជាភ្ញៀវនៅក្នុងកម្មវិធីទូរទស្សន៍មួយ ហើយគាត់មានអារម្មណ៍ថារឿងរ៉ាវហិរញ្ញវត្ថុរបស់ខ្ញុំ អាចជារឿងដ៏ល្អមួយសម្រាប់កម្មវិធីទូរទស្សន៍នោះ។ គាត់បានប្រាប់ខ្ញុំថា គាត់នឹងឱ្យសៀវភៅរបស់ខ្ញុំទៅពួកគេ ហើយនិងប្រាប់ពួកគេអំពីខ្ញុំ។ ពេលខ្ញុំឮដូច្នេះ ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលចំពោះដំណើររឿងទាំងមូល។

ខ្ញុំមិនដែលធ្លាប់ឮកម្មវិធីទូរទស្សន៍ដែលគាត់បានប្រាប់ខ្ញុំទេ ក៏ប៉ុន្តែប៉ុន្មានសប្តាហ៍ក្រោយមក ខ្ញុំបានទទួលទូរស័ព្ទពីនាយកកម្មវិធីទូរទស្សន៍នោះ អញ្ជើញខ្ញុំឱ្យចូលរួមកម្មវិធីទូរទស្សន៍របស់គាត់។ តម្រូវការមួយ ដើម្បីអាចជាភ្ញៀវនៅក្នុងកម្មវិធីទូរទស្សន៍នោះ គឺត្រូវមានផលិតផលមួយដែលពួកគេអាចផ្តល់ជូនទស្សនិកជនតាមទូរទស្សន៍។ ដូច្នេះខ្ញុំបានប្រាប់គាត់វិញថា ខ្ញុំមានស៊ីឌីចំនួន៥ អំពីការបង្រៀន «បដិវត្តហិរញ្ញវត្ថុរបស់ខ្ញុំ»។ គាត់បាននិយាយថា វាជាការល្អប្រសើរណាស់ ហើយពួកយើងក៏បានព្រមព្រៀងគ្នាលើតម្លៃ ដែលខ្ញុំផ្គត់ផ្គង់ពួកគេជាមួយនឹងស៊ីឌីទាំងនោះ។ ពិតប្រាកដណាស់ ខ្ញុំបានផ្តល់តម្លៃបោះដុំដល់ពួកគេ ក៏ប៉ុន្តែទោះបីវាជាតម្លៃបោះដុំក៏ដោយ ក៏យើងនៅតែអាចមានប្រាក់ចំណេញខ្លះសម្រាប់ព័ន្ធកិច្ចរបស់យើងដែរ។ ពិតជាអស្ចារ្យខ្លាំងណាស់ កម្មវិធីទូរទស្សន៍នោះទទួលបានជោគជ័យយ៉ាងខ្លាំង ហើយយើងបានលក់ស៊ីឌីអស់រាប់សិបពាន់ស៊ីឌី។ ប្រាក់ចំណូលពីការលក់ស៊ីឌីនេះមានចំនួនរាប់សិបពាន់ដុល្លារ បានចូលក្នុងគម្រោងថវិកាសម្រាប់កម្មវិធី

ទូរទស្សន៍របស់យើង ដែលខ្ញុំមិនបានដឹងអំពីប្រភពរបស់វា ពេលដែលខ្ញុំបានចុះកិច្ចសន្យានោះទេ។

បន្ទាប់មកទៀត មានការភ្ញាក់ផ្អើលមួយទៀតបានកើតឡើង បុរសម្នាក់នៅក្នុងក្រុមជំនុំរបស់ខ្ញុំ ដែលពេលដំបូងដែលគាត់បានមកដល់ក្រុមជំនុំយើង គាត់ដាច់ម៉ៃ ហើយរៀបនឹងត្រូវបានគេបណ្តេញចេញពីផ្ទះកាលពីប៉ុន្មានឆ្នាំមុននេះ គាត់បានមកជួបខ្ញុំ ហើយបានប្រាប់ថា ចង់ជួយផ្តត់ផ្គង់ថវិកាសម្រាប់គម្រោងទូរទស្សន៍របស់យើង។ គាត់បានអនុវត្តតាមអ្វី ដែលគាត់បានឮពីការអធិប្បាយអំពីព្រះរាជ្យរបស់ព្រះ ហើយគាត់មិនក្រដូចពេលមុននោះទេ។ គាត់បានឱ្យប្រាក់ចំនួន១២ម៉ឺនដុល្លារ សម្រាប់ព័ន្ធកិច្ចទូរទស្សន៍របស់យើង!

សរុបចំនួនលុយដែលបានមកពីការលក់ស៊ីឌី អំណោយពីមិត្តរបស់ខ្ញុំក្នុងក្រុមជំនុំ និងអំណោយផ្សេងទៀត ឌ្រិនដា និងខ្ញុំមិនចាំបាច់ចេញលុយផ្ទាល់ខ្លួន សម្រាប់កម្មវិធីទូរទស្សន៍ឆ្នាំទីមួយនោះទេ! ព្រះជាម្ចាស់ទ្រង់ពិតជាស្មោះត្រង់ចំពោះព្រះបន្ទូលសន្យារបស់ទ្រង់។ ទ្រង់បានសន្យាថា ទ្រង់នឹងផ្គត់ផ្គង់ ហើយទ្រង់ពិតជាបានផ្គត់ផ្គង់ពិតមែន។ មិនអីទេ បញ្ហាពាក់កណ្តាលត្រូវបានដោះស្រាយរួចរាល់ហើយ ប៉ុន្តែខ្ញុំនៅមានបញ្ហាធំមួយទៀតដែលត្រូវដោះស្រាយផងដែរ។ ដូចដែលខ្ញុំបាននិយាយពីដើមមក ខ្ញុំមិនមានចំណេះដឹងអំពីការផ្សព្វផ្សាយតាមទូរទស្សន៍ទេ!

នៅរដូវស្លឹកឈើជ្រុះឆ្នាំនោះ ឌ្រិនដា ត្រូវបានគេអញ្ជើញឱ្យចូលរួមសន្និបាតស្ត្រីគ្រិស្តបរិស័ទដ៏ធំមួយ ហើយត្រូវបានអញ្ជើញឱ្យសម្រាកនៅបន្ទប់សម្រាប់សម្រាកជាមួយភ្ញៀវដទៃទៀត ក្នុងចន្លោះពេលប្រជុំ។ ឌ្រិនដាពិតជាមានកិត្តិយសខ្លាំងណាស់ ដែលត្រូវបានគេអញ្ជើញ ហើយគាត់ពិតជារំភើបណាស់ដែលបានទៅចូលរួម។ បន្ទាប់ពីវគ្គមួយបានបញ្ចប់ គាត់បានអង្គុយចុះដើម្បីញ៉ាំអាហារថ្ងៃត្រង់ មានស្ត្រីម្នាក់ដែលគាត់មិនធ្លាប់ស្គាល់ពីមុនបានអង្គុយក្បែរគាត់។ បន្ទាប់ពីការណែនាំខ្លួនទៅវិញទៅមករួចមក ភ្លាមៗនោះស្ត្រីម្នាក់នោះបានសួរគាត់ថា «ដូច្នេះ តើអ្នកកំពុងតែធ្វើកម្មវិធីទូរទស្សន៍ហើយឬ?» ឌ្រិនដា រៀងភ្ញាក់ផ្អើលបន្តិច ហើយក៏បានឆ្លើយថា «នៅទេ។ ប៉ុន្តែពួកយើងកំពុងតែគិតអំពីវា»។ បន្ទាប់មកស្ត្រីម្នាក់នោះបាននិយាយថា «ចាស ប្រសិនបើអ្នកធ្វើវា អ្នកអាចទាក់ទងទៅបុរសម្នាក់នេះ គាត់អាចជួយអ្នកបាន។» ឌ្រិនដាបានសរសេរលេខទូរស័ព្ទ និងអ៊ីម៉ែល ដែលស្ត្រីម្នាក់នោះឱ្យ ហើយបានដាក់វាក្នុងកាបូបរបស់គាត់។

ពីរបីសប្ដាហ៍បានកន្លងផុតទៅ ហើយគាត់បានភ្លេចអំពីក្រដាសលេខទូរស័ព្ទ និង អ៊ីម៉ែល ដែលគាត់បានដាក់ក្នុងកាបូបគាត់។ នៅយប់មួយនោះ គាត់រកឃើញក្រដាសនោះ ហើយគាត់ក៏បានសរសេរអ៊ីម៉ែលទៅបុរសម្នាក់នោះ។ បុរសនោះហាក់ដូចជាចាប់អារម្មណ៍ ហើយបានស្នើសុំឱ្យគ្រិនដាផ្ញើស៊ីឌី «បដិវត្តហិរញ្ញវត្ថុរបស់ខ្ញុំ» ទៅឱ្យគាត់។ មួយសប្ដាហ៍ក្រោយមក ជំនួយការរបស់គាត់បានទូរស័ព្ទមកយើងវិញ ហើយបានប្រាប់យើងថា ប្រធានរបស់គាត់ពិតជាចាប់អារម្មណ៍ ហើយចង់ជួបពួកយើងនៅសន្និបាតប្រចាំឆ្នាំរបស់អ្នកផ្សព្វផ្សាយសាសនាជាតិ ដែលនៅសល់ពេលតែពីរបីសប្ដាហ៍ទៀតប៉ុណ្ណោះ។ យើងបានប្រាប់គាត់ថា យើងនឹងទៅសន្និបាតនោះ។

គ្រិនដា និងខ្ញុំបានបើកឡានទៅចូលរួមសន្និបាតនោះ ហើយមានអារម្មណ៍ភិតភ័យបន្តិចបន្តួចមុនពេលការប្រជុំ។ ខ្ញុំទើបតែទិញខោអាវឈុតពណ៌ខ្មៅសម្រាប់ការប្រជុំនេះ ដោយមិនដឹងថាមានការរំពឹងទុកអ្វីខ្លះនោះទេ។ គាត់បានស្នើសុំឱ្យពួកយើងជួបគាត់នៅបន្ទប់សណ្ឋាគាររបស់គាត់ ដើម្បីពិភាក្សាអំពីកម្មវិធីទូរទស្សន៍។ នៅពេលដែលយើងឡើងទៅជួបគាត់ ខ្ញុំបានចាំថា ពួកយើងបានដើរចុះដើរឡើងនៅសាលសណ្ឋាគាពីរបីដង មុនពេលដែលយើងគោះទ្វារបន្ទប់គាត់ ដើម្បីឱ្យអារម្មណ៍យើងបានស្ងប់បន្តិច។ ពេលដែលយើងដើរចូលក្នុងបន្ទប់គាត់ យើងមានការភ្ញាក់ផ្អើល ដោយបានឃើញមនុស្សមួយក្រុមកំពុងរង់ចាំជួបពួកយើង។ គេបានរៀបចំកៅអីជាពាក់កណ្ដាលរង្វង់ ហើយគេដាក់ពួកយើងឱ្យអង្គុយនៅពីមុខពួកគេ។ យើងមិនដែលធ្លាប់ជួបពួកគេពីមុនមកទេ ប៉ុន្តែពួកគេសុទ្ធតែស្លៀកសម្លៀកបំពាក់យ៉ាងថ្លៃថ្នូរ។

ពួកយើងចាប់ផ្ដើមដោយនិយាយរឿងតូចៗសាមញ្ញធម្មតា ប៉ុន្តែបន្ទាប់មកពួកគេបានចាប់ផ្ដើមសួរសំណួរដែលទាក់ទងនឹងបំណងប្រាថ្នារបស់ពួកយើងក្នុងការធ្វើកម្មវិធីទូរទស្សន៍។ ខ្ញុំនៅតែចាំបានសំណួរទីមួយរបស់ពួកគេ «តើហេតុអ្វីបានជាអ្នកចង់ធ្វើកម្មវិធីទូរទស្សន៍?»។ ទោះបីខ្ញុំមិនបានដឹងនៅពេលនោះក៏ដោយថា មនុស្សដែលបានជួបជុំគ្នាក្នុងបន្ទប់នោះសុទ្ធតែជាអ្នកប្រតិបត្តិជាន់ខ្ពស់ ដែលមកពីផ្នែកផ្សេងៗនៃការផលិតកម្មវិធីទូរទស្សន៍។ ជាការពិត បុរសដែលបាននិយាយជាមួយពួកយើងបាននៅទីនោះដែរ ប៉ុន្តែក៏មានមនុស្សដទៃទៀត ដែលជាអ្នកផលិតកម្ម អ្នកធ្វើទីផ្សារ និងអ្នកដទៃទៀត ទាំងអស់គ្នាសួរសំណួរពិបាកៗ។ និយាយរួមទៅ ខ្ញុំមានអារម្មណ៍ថា ការប្រជុំនោះមានដំណើរការល្អ។ យើងនិយាយអ្វីដែលចេញពីចិត្តរបស់យើង មិនបានព្យាយាមធ្វើឱ្យអ្នកណាម្នាក់ចាប់អារម្មណ៍លើយើងទេ យើងគ្រាន់តែចែករំលែករឿងរ៉ាវដែលព្រះជាម្ចាស់បានធ្វើក្នុងជីវិតរបស់ពួក

យើង។ ពួកគេហាក់ដូចជាពេញចិត្តនឹងនិមិត្ត និងចិត្តឆេះឆួលរបស់ពួកយើង ហើយបានប្រាប់ពួកយើងថា ពួកគេនឹងទូរស័ព្ទមកយើងវិញពីរបីសប្ដាហ៍ទៀត ដើម្បីពិភាក្សាលម្អិតបន្ថែម។

ដូច្នេះពីរបីសប្ដាហ៍ក្រោយមក យើងក៏បាននិយាយគ្នាម្ដងទៀត។ លើកនេះពួកយើងទាំងអស់គ្នាបានសម្រេចចិត្តធ្វើផែនការជាក់ស្ដែង សម្រាប់ការចាក់ផ្សាយកម្មវិធីទូរទស្សន៍របស់យើងតែម្ដង។ នៅពេលនោះយើងបានបញ្ចប់ការប្រជុំដោយសន្មតថា យើងគ្រាន់តែថតកម្មវិធីនោះនៅផ្ទះរបស់យើង ដូច្នេះបុរសដែលឌ្រិនដាបានទាក់ទងទៅ បានស្នើសុំជួបគ្នាលើកក្រោយនៅផ្ទះរបស់យើង គាត់ចង់ឃើញផ្ទះរបស់យើង ដើម្បីប្រាកដថាពិតជាអាចថតនៅទីនោះបាន។

ថ្ងៃកំណត់នៃការជួបគ្នាបានមកដល់ ហើយយើងទាំងអស់គ្នាបានអង្គុយចុះពិភាក្សាគ្នា។ រហូតមកដល់ការជួបលើកនេះ យើងពិតជាមិនបានដឹងអំពីប្រវត្តិរបស់គាត់ទាក់ទងនឹងការផ្សាយតាមទូរទស្សន៍ទេ យើងគ្រាន់តែបានទទួលលេខទំនាក់ទំនងរបស់គាត់ពីស្ត្រីម្នាក់នៅឯសន្និបាតស្ត្រីគ្រិស្តបរិស័ទដែលឌ្រិនដាបានចូលរួម។ ប៉ុន្តែនៅពេលដែលយើងជជែកគ្នាលើកនេះ គាត់បានរៀបរាប់ប្រាប់យើងអំពីកម្មវិធីទូរទស្សន៍ទាំងអស់ដែលគាត់ធ្លាប់ផលិត ព្រមទាំងកម្មវិធីទូរទស្សន៍ដែលគាត់កំពុងតែធ្វើពេលបច្ចុប្បន្នផងដែរ។ ឈ្មោះកម្មវិធីទាំងអស់នោះសុទ្ធតែកម្មវិធីល្បីៗ! ខ្ញុំអង្គុយស្ដាប់ដោយចិត្តស្ងប់ស្ងែង «ឱព្រះជាម្ចាស់! តើទ្រង់បាននាំបុរសម្នាក់នេះ ពីទីក្រុងឡូសអាន់ជើឡែស មកដល់ផ្ទះខ្ញុំដែលនៅលើផ្លូវដីលំដ៏តូច នៅទីជនបទនេះដោយរបៀបណា?» គាត់បានយល់ព្រមធ្វើកម្មវិធីទាំងមូលឱ្យយើង ទាំងការថត ការកែសម្រួល និងផលិតវាក្នុងតម្លៃសមរម្យ។ យើងទាំងអស់គ្នាក៏បានយល់ស្របថា យើងនឹងថតកម្មវិធីនៅផ្ទះរបស់យើង ដោយចាប់ផ្ដើមថតនៅបន្ទប់ទទួលភ្ញៀវ។

ថ្ងៃដំបូងនៃការថតបានមកដល់ ហើយខ្ញុំសារភាពថា ខ្ញុំពិតជាមានអារម្មណ៍ភ័យ។ ដូចខ្ញុំធ្លាប់បាននិយាយហើយ ថាខ្ញុំគ្មានបទពិសោធជាមួយកម្មវិធីទូរទស្សន៍ទេ។ ខ្ញុំមិនដឹងថាកម្មវិធីទូរទស្សន៍គួរចាប់ផ្ដើមពីណាទៅណា ក៏មិនដែលធ្លាប់និយាយចំពោះមុខកាមេរ៉ា វាជាបទពិសោធថ្មីសន្លាងសម្រាប់ខ្ញុំ។ ខ្ញុំពិតជារំភើបណាស់ ដែលអាចចែករំលែករឿងរ៉ាវរបស់ខ្ញុំអំពីព្រះរាជ្យព្រះជាម្ចាស់ទៅកាន់មនុស្សដទៃទៀត ក៏ប៉ុន្តែការធ្វើកម្មវិធីទូរទស្សន៍នេះ គឺជាចំណុចចាប់ផ្ដើមដ៏គួរឱ្យភ័យខ្លាចមួយក្នុងជីវិតរបស់ខ្ញុំ ដែលខ្ញុំត្រូវតែយកឈ្នះ។

មានព្រឹត្តការណ៍ដ៏សោកសៅមួយបានកើតឡើងនៅថ្ងៃដែលយើងចាប់ផ្ដើមថតដំបូង ដែលបានធ្វើឱ្យថ្ងៃនោះកាន់តែពិបាកជាងមុនទៅទៀត។ ផលិតករដែលត្រូវថតកម្មវិធីទូរទស្សន៍ពេញមួយសប្ដាហ៍នោះបានចាកចេញទាំងពាក់កណ្ដាលយប់។ គួរឱ្យសោកស្ដាយ កូនប្រុសរបស់គាត់ត្រូវបានឡានអ្នកជិតខាងកិនស្លាប់ នៅពេលគេកំពុងថយឡាន។ អ្នកជំនួយការដែលមានវត្តមាននៅទីនោះបានពន្យល់ពីអ្វីដែលបានកើតឡើង ហើយយើងក៏បានសម្រេចចិត្តថាមិនប្រាប់អ្នកដទៃទៀតរហូតដល់ចប់ការថត។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងបានឆ្លងកាត់វា។ យើងបានថតកម្មវិធីចំនួនបីនៅថ្ងៃនោះ ហើយយើងបានចាក់ផ្សាយកម្មវិធីនោះជាផ្លូវការលើកញ្ចក់ទូរទស្សន៍។ ពិតជាអស្ចារ្យណាស់!

**ក្នុងចំណោមបងប្អូន បើមាននរណាម្នាក់កើតទុក្ខលំបាក ត្រូវឱ្យគាត់អធិស្ឋាន**
**(យ៉ាកុប ៥:១៣)**

នៅពេលដែលយើងចាប់ផ្ដើមចាក់ផ្សាយតាមទូរទស្សន៍ យើងមិនដឹងថាត្រូវបន្តបង់ថ្លៃចំណាយដោយរបៀបណាទេ។ ក៏ប៉ុន្តែព្រះជាម្ចាស់ចាប់ផ្ដើមបង្រៀនយើងថា ទ្រង់មិនត្រឹមតែផ្គត់ផ្គង់ប្រាក់ចំនួន៣០ម៉ឺនដុល្លារ ដែលយើងត្រូវការសម្រាប់ការចាប់ផ្ដើមប៉ុណ្ណោះទេ ទ្រង់ក៏នឹងបន្តផ្គត់ផ្គង់សម្រាប់ថ្លៃចាក់ផ្សាយផងដែរ។ យើងមានអ្វីជាច្រើនទៀតដែលត្រូវរៀន។ តើអ្នកដឹងទេ យើងមិនដែលធ្លាប់គិតថា មនុស្សចង់សាបព្រោះក្នុងព័ន្ធកិច្ចទូរទស្សន៍របស់យើងទេ។ យើងពិតជាល្ងីល្ងើដល់ថ្នាក់ហ្នឹង។

ខ្ញុំចាំបានថា លេខារបស់ខ្ញុំដែលមានឈ្មោះថាទ្រេស៊ី បានទូរស័ព្ទមកខ្ញុំពីការិយាល័យភ្លាមៗ បន្ទាប់ពីកម្មវិធីរបស់យើងបានចាក់ផ្សាយលើកញ្ចក់ទូរទស្សន៍។ នៅពេលដែលខ្ញុំលើកទូរស័ព្ទគាត់ ខ្ញុំអាចដឹងថា គាត់កំពុងតែញ័រ។ នាងបាននិយាយថា « លោកគ្រូ! មានមនុស្សម្នាក់ដែលបានមើលកម្មវិធីទូរទស្សន៍យើង បានផ្ញើមូលប្បទានបត្រ៥០០ដុល្លារដល់យើង។ ហើយលោកគ្រូ! ពេលដែលខ្ញុំកាន់មូលប្បទានបត្រនេះ ខ្ញុំមានអារម្មណ៍ពីការចាក់ប្រេងតាំង ដូចការចាក់ប្រេងតាំងដែលនៅលើលុយ ដែលលោកគ្រូបានយកពីប្រទេសតណ្ឌា។» ខ្ញុំនិយាយទាំងរំភើប «ពិតជាអីចឹងមែនឬ?» «ពិតជាមានមនុស្សផ្ញើប្រាក់ឱ្យពួកយើងមែន?» ខ្ញុំពិតជាមិនដែលធ្លាប់គិតថា នឹងមានមនុស្សផ្ញើប្រាក់ដើម្បីគាំទ្រការផ្សព្វផ្សាយរបស់យើងទេ រហូតទាល់តែយើងបានទទួលមូលប្បទានបត្រមួយនោះ។ សូមសរសើរតម្កើងព្រះជាម្ចាស់! មានមនុស្សផ្ញើប្រាក់ជាបន្តបន្ទាប់ចាប់តាំងពីពេលនោះមក ដោយផ្ញើមកកម្មវិធីនៅជុំវិញពិតពលោក ឥឡូវនេះជារៀងរាល់ថ្ងៃ និងនៅគ្រប់តំបន់ពេល

វេលា! វិក្កយបត្របានកើនឡើងដល់រាប់លានក្នុងមួយឆ្នាំ ក៏ប៉ុន្តែព្រះជាម្ចាស់តែងតែបំពេញតាមព្រះបន្ទូលសន្យារបស់ទ្រង់ចំពោះខ្ញុំ។ ទ្រង់តែងតែបង់ថ្លៃចំណាយ។

សៀវភៅនេះនិយាយអំពីការរស់ដោយការស្តាប់តាម និងការណែនាំពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ទីបន្ទាល់អំពីកម្មវិធីទូរទស្សន៍របស់យើង គឺជាឧទាហរណ៍ដ៏ល្អមួយ អំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធអាចដឹកនាំមនុស្សឱ្យធ្វើអ្វីដែលអស្ចារ្យជាងនេះ ដែលពួកគេមិនដែលធ្លាប់គិតដល់។ អ្វីៗដែលព្រះបានធ្វើក្នុងជីវិតរបស់យើង គឺកើតចេញពីសមត្ថភាពរបស់យើង ដែលមិនត្រឹមតែដឹងពីរបៀបដែលព្រះរាជ្យព្រះមានដំណើរការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចឮការណែនាំពីព្រះជាម្ចាស់ ប្រាជ្ញា និងចម្លើយដែលយើងត្រូវការផងដែរ។ រឿងដែលខ្ញុំទើបតែបានប្រាប់អ្នកនឹងមិនអាចកើតឡើងបានទេ ប្រសិនបើខ្ញុំមិនដឹងពីរបៀបឮពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ពេលខ្លះ យើងទាំងអស់គ្នាអាចប្រឈមនឹងស្ថានភាពដែលហាក់ដូចជាអស់សង្ឃឹម។ ប៉ុន្តែ ព្រះជាម្ចាស់មានចម្លើយ។

*ក្នុងចំណោមបងប្អូន បើមាននរណាម្នាក់កើតទុក្ខលំបាក ត្រូវឱ្យគាត់អធិស្ឋាន។ (យ៉ាកុប ៥:១៣)*

ហេតុអ្វីត្រូវអធិស្ឋាន? ពីព្រោះអ្នកចង់ដឹងចម្លើយ ទិសដៅ និងដំណោះស្រាយសម្រាប់បញ្ហាដែលអ្នកមាន។ ជាច្រើនលើកច្រើនសា ឌ្រិនដា និងខ្ញុំបានស្វែងយល់ថា ព្រះជាម្ចាស់អាចធ្វើលើសពីការនឹកស្មានរបស់យើងពេលដែលយើងជួបបញ្ហា។ ទ្រង់នឹងជួយអ្នកជាមួយនឹងដំណោះស្រាយ និងយុទ្ធសាស្ត្រពិសេសៗ ហើយពេលខ្លះប្លែកៗ ដើម្បីឱ្យអ្នកយកឈ្នះលើស្ថានភាពដែលអ្នកគិតថា មិនអាចទៅរួច។ ជាច្រើនលើក សមត្ថភាពរបស់អ្នកក្នុងការស្តាប់ចម្លើយពីព្រះ អាចជាភាពខុសគ្នារវាងភាពជោគជ័យ និងបរាជ័យ ជីវិត និងសេចក្តីស្លាប់។ ខ្ញុំនឹងនិយាយច្រើនអំពីការឮព្រះសូរសៀងរបស់ព្រះក្នុងសៀវភៅនេះ ប៉ុន្តែដំបូងខ្ញុំចង់ប្រាប់អ្នកពីឧទាហរណ៍មួយទៀត អំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធអាចជួយអ្នកក្នុងគ្រាលំបាក។

ពេលដែលយើងបានចាប់ផ្តើមគម្រោងសាងសង់អគារ មជ្ឈមណ្ឌលរបស់យើងនាពេលបច្ចុប្បន្ននេះ វាជាគម្រោងអគារដែលមានទឹកប្រាក់សរុប ៦.៥លានដុល្លារ ដំបូងឡើយយើងបានរៃអង្គាសបានជាទឹកប្រាក់ចំនួន ២.៥លានដុល្លារ ហើយក៏បានប្រើប្រាស់លុយធនាគារមួយចំនួនដែរ។ យើងក៏មានថវិកាដទៃទៀតដែលបានចូលមកអំឡុងពេល១៨ខែនៃគម្រោងអគាររបស់យើង។ វាគឺជាគម្រោងដ៏ធំមួយ សម្រាប់ក្រុមជំនុំដែលមានសមាជិក

តែ៥៥០នាក់។ យើងបានបើកការដ្ឋាននៅរដូវស្លឹកឈើជ្រុះឆ្នាំ២០០៧ ហើយអ្វីៗមានដំណើរការល្អប្រសើរ រហូតដល់និទាឃរដូវឆ្នាំ២០០៨។ អ្នកប្រហែលអាចនៅចាំអំពីវិបត្តិសេដ្ឋកិច្ចឆ្នាំ២០០៨។ បាទ! យើងបានបន្តការសាងសង់រហូតដល់ពាក់កណ្ដាលឆ្នាំនោះ។ ហើយតម្លៃអ្វីៗគ្រប់យ៉ាងបានឡើងខ្ពស់កប់ពពក! តម្លៃដែកថែបបានឡើងលើសពី៣០ម៉ឺនដុល្លារ ខ្ពស់ជាងតម្លៃដេញថ្លៃដែលបានព្រមព្រៀងគ្នា។ នេះគ្រាន់តែជាឧទាហរណ៍មួយប៉ុណ្ណោះ។ គម្រោងអគារទាំងមូលបានកើនឡើងលើសពីគម្រោងថវិការបស់យើង ដោយសារតម្លៃទំនិញបានកើនឡើងនៅឆ្នាំនោះ។

នៅចុងឆ្នាំ ២០០៨ ធនាគារនៅក្នុងតំបន់របស់យើង ហើយបើតាមភាពពិតជាក់ស្ដែង គឺទូទាំងប្រទេស បានប្រមូលឥណទានរបស់ពួកគេវិញ ហើយអំពាវនាវរកប្រាក់កម្ចីនៅពេលដែលវិបត្តិសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរជាងមុន។ អំឡុងពេលនោះ ថ្ងៃមួយអ្នកម៉ៅការសាងសង់របស់យើងបានមករកយើង ដើម្បីទូរទាត់ថ្លៃចំណាយដែលបានអនុម័តដោយធនាគាររបស់យើងរួចរាល់ហើយ។ គាត់ត្រូវបង់ប្រាក់ឱ្យអ្នកម៉ៅការរបស់គាត់ និងថ្លៃវិក្កយបត្រដទៃទៀត ដែលគាត់បានចំណាយរួចហើយ។ យើងបានគ្រោងប្រគល់មូលប្បទានបត្រចំនួន១លានដុល្លារ ដែលត្រូវទូរទាត់ដោយហិរញ្ញវត្ថុធនាគាររបស់យើង ខណៈថវិកាជាសាច់ប្រាក់របស់យើងខ្សោះណាស់ទៅហើយនៅពេលនោះ។ ក៏ប៉ុន្តែ បែរជាមិនមានមូលប្បទានបត្រចំនួន១លានដុល្លានោះទៅវិញ។ យើងរន្ធត់មែនទែន នៅពេលយើងដឹងថាធនាគាររបស់យើងបានដកការផ្ដល់ជូនរបស់ពួកគេវិញ។ ជាថ្មីម្ដងទៀត វាមិនមែនតែធនាគាររបស់យើងទេ តែគ្រប់ធនាគារក្នុងស្រុកទាំងអស់។ ឈ្មោះធនាគាររបស់យើងបានមាននៅលើទំព័រដំបូងនៃកាសែតក្នុងតំបន់របស់យើង។ ពួកគេទើបតែបានបញ្ឈប់បុគ្គលិកចំនួន៥៥០នាក់ក្នុងសប្ដាហ៍នោះ ហើយពួកគេកំពុងតែតស៊ូ ដើម្បីរស់រានពីវិបត្តិហិរញ្ញវត្ថុ។

ជាថ្មីម្ដងទៀត បញ្ហាដែលនៅចំពោះមុខយើងគឺអ្នកម៉ៅការសាងសង់របស់យើងត្រូវការប្រាក់ដើម្បីបង់ថ្លៃឈ្នួលអ្នកម៉ៅការបន្តរបស់គាត់ និងបង់ថ្លៃសម្ភារៈដែលគាត់បានប្រើប្រាស់រួចហើយ។ មូលប្បទានបត្រចំនួន១លានដុល្លានេះមិនមែនសម្រាប់អ្វីដែលគាត់នឹងត្រូវការនៅពេលខាងមុខទេ។ គាត់បានចាយប្រាក់១លានដុល្លារនេះរួចរាល់ហើយ! ឥឡូវនេះយើងត្រូវតែបង់ថ្លៃឱ្យអ្នកម៉ៅការសាងសង់របស់យើង ដើម្បីឱ្យគាត់អាចបង់ថ្លៃឱ្យក្រុមហ៊ុន និងមនុស្សដទៃទៀត។ ដូចពួកយើងដែរ គាត់ក៏រំពឹងថាធនាគារនឹងបន្តគាំទ្រការប្ដេជ្ញាចិត្តរបស់គាត់។ ចុះពេលឥឡូវនេះវាយ៉ាងម៉េចវិញ? តើអ្នកនឹងធ្វើអ្វីក្នុងគ្រាបែបនេះ? ខ្ញុំមិនមានលុយ១លានដុល្លារនៅក្នុងដៃទេ ហើយខ្ញុំក៏មិនសុំឱ្យពួកជំនុំជួយក្នុងគ្រានេះដែរ។ ក្រៅ

**បនិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

ពីនេះ ថ្លៃចំណាយលើកម្មវិធីទូរទស្សន៍ក៏កាន់តែច្រើនជាងមុន ដោយសារយើងបានពង្រីកបណ្តាញជាច្រើនទៀត។ ឥឡូវនេះថ្លៃចំណាយលើម៉ោងផ្សាយរបស់យើងមួយខែ៥ម៉ឺនដុល្លារ។ តើមានអ្វីដែលយើងអាចធ្វើបាននៅពេលនេះ គឺមានតែដូចបានចែងនៅក្នុងយ៉ាកុប ៥:១៣ ប៉ុណ្ណោះ គឺអធិស្ឋាន!

វាបានកើតឡើងដូច្នេះ យើងទើបតែឈ្នះការធ្វើដំណើរមួយទៀតទៅកោះហាវ៉ៃ តាមរយៈជំនួញរបស់ខ្ញុំក្នុងកំឡុងពេលនោះ។ ខ្ញុំបានទទួលដំណឹងថាធនាគារបានដកឥណទានវិញពីរបីថ្ងៃមុនពេលយើងធ្វើដំណើរ។ នៅពេលខ្ញុំធ្វើដំណើរតាមអាកាសយានដ្ឋាន ដើម្បីភ្ជាប់ជើងយន្តហោះទៅកោះម៉ៅអ៊ី ខ្ញុំទទួលស្គាល់ថា ខ្ញុំនៅមានអារម្មណ៍រន្ធត់តិចតួចនៅឡើយ។ ខ្ញុំគិតច្រើនហើយស្មុគស្មាញខ្លាំងមែនទែន។ នៅពេលដែលខ្ញុំកំពុងដើរឆ្លងកាត់អាកាសយានដ្ឋាន កំពុងមានអារម្មណ៍ចង់អាណិតខ្លួនឯង ខ្ញុំបានឮព្រះសូរសៀងពីព្រះ។ ទ្រង់បានមានបន្ទូលថា «ចូរលើកដំបងរបស់អ្នកឡើង!» ពេលដែលខ្ញុំឈប់ ហើយគិតអំពីអ្វីដែលព្រះជាម្ចាស់កំពុងព្យាយាមប្រាប់ខ្ញុំ ខ្ញុំក៏បានយល់ភ្លាម។

នេះជាអ្វីដែលព្រះជាម្ចាស់បានប្រាប់ដល់លោកម៉ូសេ នៅពេលដែលអ៊ីស្រាអែលលែងមានកន្លែងរត់ទៅមុខទៀត ពេលដែលកងទ័ពរបស់ព្រះចៅផារ៉ោនតាមទាន់ពួកគេដល់សមុទ្រក្រហម។ ព្រះជាម្ចាស់បានប្រាប់លោកម៉ូសេឱ្យលើកដំបងរបស់គាត់ឡើង ហើយពេលដែលគាត់បានលើកវាឡើង សមុទ្រក្រហមបានញែកជាពីរ បើកផ្លូវឱ្យប្រជាជនអ៊ីស្រាអែលឆ្លងផុត និងរត់គេចខ្លួនរួច។ ដំបងដែលលោកម៉ូសេកាន់ តំណាងឱ្យការសន្យារបស់ព្រះ ព្រមទាំងសិទ្ធិអំណាចដែលគាត់មាន ដើម្បីបំពេញតាមការត្រាស់ហៅ។

ខ្ញុំបានដឹងពីអ្វីដែលទ្រង់ចង់ប្រាប់ខ្ញុំនៅពេលនោះ។ ខ្ញុំគឺជាអ្នកដឹកនាំ ជាគ្រូគង្វាលនៃក្រុមជំនុំរបស់ទ្រង់ ខ្ញុំត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីដោះស្រាយបញ្ហាក្នុងស្ថានភាពមួយនេះ។ ខ្ញុំត្រូវទទួលយកសិទ្ធិអំណាចនេះ ក្រោកឈរឡើង ហើយស្វែងរកដំណោះស្រាយ។ ពេលដែលយើងទៅដល់កោះហាវ៉ៃ អ្វីដែលខ្ញុំអាចធ្វើបាន គឺអធិស្ឋាន។ ខ្ញុំគេងមិនលក់សោះនៅយប់នោះ។ ខ្ញុំមានអារម្មណ៍រសាប់រសល់ ហើយខ្ញុំដឹងថា ខ្ញុំកំពុងតយុទ្ធខាងវិញ្ញាណសម្រាប់ចម្លើយដែលខ្ញុំត្រូវការ។ ទីបំផុត ឌ្រិនដាមានគំនិតមួយ ដែលគាត់ជឿថា វាមកពីព្រះជាម្ចាស់។ អរគុណព្រះជាម្ចាស់ សម្រាប់ភរិយារបស់ខ្ញុំ! ព្រះជាម្ចាស់ធ្លាប់ប្រើគាត់ច្រើនលើកច្រើនសាក្នុងការស្វែងរកផែនការ និងទិសដៅដែលខ្ញុំត្រូវទៅ គ្រប់ស្ថានភាពទាំងអស់។

គាត់មានតម្លៃខ្លាំងណាស់ចំពោះខ្ញុំ ហើយខ្ញុំក៏ស្រលាញ់គាត់ខ្លាំងផងដែរ។ គាត់មិនដែលចុះចាញ់ទេ!

ផែនការរបស់គាត់សាមញ្ញ ប៉ុន្តែមានអត្ថន័យជ្រាលជ្រៅ។ គ្មានអ្វីដែលបង្ហាញថា ផែនការនេះនឹងមានដំណើរទេ ប៉ុន្តែយើងចាប់ផ្តើមធ្វើវាភ្លាមៗ។ ផែនការរបស់យើងគឺ យើងនឹងរៀបចំបទបង្ហាញមួយ ដើម្បីផ្ញើទៅឱ្យធនាគារអ្នកសាងសង់របស់យើង មិនមែនធនាគាររបស់យើងទេ ដោយស្នើសុំការកម្ចីប្រាក់ពីពួកគេ។ បទបង្ហាញរបស់យើងនឹងបង្ហាញថា យើងជានរណា ហើយហេតុអ្វីយើងជឿជាក់ថាការកម្ចីប្រាក់គឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់ពួកយើង។ វាជាការប្រថុយប្រថាន ព្រោះថាដូចដែលខ្ញុំបាននិយាយរួចហើយ ធនាគារទាំងអស់ក្នុងក្រុងបិទការផ្តល់ប្រាក់កម្ចីទាំងអស់។ ការគិតរបស់យើងគឺថា ប្រសិនបើយើងមិនបង់ថ្លៃឱ្យអ្នកសាងសង់របស់យើងទេ បន្ទាប់មកគាត់អាចត្រូវប្រកាសក្ស័យធនដោយខ្លួនឯង ដែលធ្វើឱ្យប្រាក់កម្ចីទាំងអស់ដែលគាត់មានជាមួយធនាគារគាត់ធ្លាក់ក្នុងហានិភ័យដោយស្វ័យប្រវត្តិ។ យើងដឹងប្រាកដថា វាជាការបណ្តាក់ទុនចំណាយខ្ពស់សម្រាប់ធនាគាររបស់គាត់ ហើយយើងក៏ប្រាកដថា ពួកគេមិនចង់ធ្វើវាទេ។ ហើយជាថ្មីម្តងទៀត នេះមិនមែនជាធនាគាររបស់យើងទេ ពួកគេមិនធ្លាប់មានទំនាក់ទំនង ឬស្គាល់ពួកយើងពីមុនមកទេ។

ដូច្នេះយើងបានធ្វើតារាងលម្អិតបង្ហាញអំពីភូមិសាស្ត្រតំបន់របស់យើង និងការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងតំបន់នោះ។ យើងបានបង្ហាញធនាគារអំពីប្រវត្តិ និងការរីកចម្រើនដែលយើងរំពឹងទុក។ យើងក៏បានបង្ហាញរបៀបជាច្រើនទៀត ដែលអគាររបស់យើងអាចរកប្រាក់ចំណូលបានក្រៅពីតង្វាយមកពីក្រុមជំនុំ ដូចជាចំណូលពីកម្មវិធីទូរទស្សន៍របស់យើងបានកើនឡើងយ៉ាងឆាប់រហ័ស និងមានអ្វីជាច្រើនទៀតដែលយើងគិតថាពួកគេអាចចាប់អារម្មណ៍។ យើងចង់បញ្ជាក់ដល់ពួកគេថា យើងគឺជាហានិភ័យដ៏ធំមួយ ដែលនឹងផ្តល់ផលចំណេញដល់ធនាគារ សូម្បីតែនៅក្នុងគ្រាលំបាកនេះក៏ដោយ។ យើងក៏ចង់បញ្ជាក់ដែរថា ប្រសិនបើអ្នកសាងសង់របស់យើងមិនបានទទួលប្រាក់បង់ថ្លៃ ពួកគេក៏ប្រឈមនឹងហានិភ័យ នៃការបាត់បង់ដែលយើង«ចង់ជួយ»ពួកគេជៀសវាង។ យើងបានស្នើសុំជួបអនុប្រធានធនាគារ ដែលទទួលបន្ទុកផ្នែកប្រាក់កម្ចីពាណិជ្ជកម្ម។ យើងបានអធិស្ឋាន ហើយបានដើរក្នុងការិយាល័យរបស់គាត់ ទាំងមានទំនុកចិត្តថា នេះជាផែនការដែលព្រះវិញ្ញាណដ៏វិសុទ្ធបានប្រទានឱ្យយើង ដែលឆ្លើយតបការអធិស្ឋានរបស់យើង។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

ពិតជាអស្ចារ្យណាស់ បន្ទាប់ពីការធ្វើបទបង្ហាញរបស់យើង មន្ត្រីបនោះបានស្នើសុំអ្នកជំនួយការរបស់គាត់ ធ្វើមូលប្បទានបត្រសម្រាប់ក្រុមជំនុំរបស់យើងចំនួនទឹកប្រាក់៥០ម៉ឺនដុល្លារ នៅនឹងកន្លែង ឱ្យយើងយកទៅជាមួយ។ គាត់បាននិយាយថា អ្វីដែលគាត់បានធ្វើគឺខុសពីធម្មតា ហើយវាមិនមែនជារបៀបធម្មតាដែលពួកគេធ្វើការតាមបែបនេះទេ។ មិនមានការធានា មិនមានទម្រង់បែបបទ គ្រាន់តែមានមូលប្បទានបត្រចំនួន៥០ម៉ឺនដុល្លារ។ គាត់បាននិយាយថាទឹកប្រាក់ចំនួន៥០ម៉ឺនដុល្លារទៀតនឹងត្រូវឆ្លងកាត់ការធានារ៉ាប់រង ហើយគាត់បានធានាដល់យើងថាវានឹងកើតមានឡើង ព្រោះថាគាត់ជាអ្នកធ្វើការសម្រេចចិត្តហើយវាពិតជាបានសម្រេចពិតមែន។ យើងបានបង់លុយឱ្យអ្នកសាងសង់របស់យើង១លានដុល្លារ ហើយបានបញ្ចប់សំណង់អគាររបស់យើង។

**ប្រសិនបើអ្នកចង់ទទួលបានប្រយោជន៍ពីសក្ដានុពលដ៏អស្ចារ្យនៃព្រះរាជ្យព្រះជាម្ចាស់ អ្នកត្រូវរៀនពីរបៀបស្ដាប់ព្រះសូរសៀងព្រះវិញ្ញាណដ៏វិសុទ្ធ។**

វាពិបាកក្នុងការពិពណ៌នាប្រាប់អ្នកអំពីអារម្មណ៍ដែលឌ្រិនដា និងខ្ញុំមាន នៅពេលយើងបើកឡានត្រលប់ទៅផ្ទះវិញ ជាមួយមូលប្បទានបត្រដែលមានទឹកប្រាក់ចំនួន៥០ម៉ឺនដុល្លារ នៅក្នុងហោប៉ៅរបស់ពួកយើង។ យើងពិតជាត្រេកអរ និងមានអារម្មណ៍អស្ចារ្យខ្លាំងណាស់! មិនមានពាក្យណាដែលអាចពិពណ៌នាត្រឹមត្រូវពីអារម្មណ៍ពិតរបស់ពួកយើងក្នុងពេលនោះទេ ប៉ុន្តែយើងពិតជាស្ញប់ស្ញែងចំពោះអ្វីដែលព្រះវិញ្ញាណដ៏វិសុទ្ធទើបតែបានធ្វើ។ មនុស្សដំបូងដែលយើងបានទូរស័ព្ទប្រាប់ពីដំណឹងនេះគឺ អ្នកសាងសង់របស់យើង។ ខ្ញុំនៅតែចាំសំឡេងនៃអំណររបស់គាត់ នៅពេលដែលយើងបានប្រាប់គាត់ពីដំណឹងល្អនោះ។ គាត់បាននិយាយថា «អ្នកបានធ្វើអ្វី?» «គេឱ្យមូលប្បទានបត្រអ្នកនៅនឹងកន្លែងតែម្ដង?» យើងទាំងពីរនាក់ដឹងច្បាស់ថា វាមកពីព្រះជាម្ចាស់។

តើរឿងនេះកើតឡើងដោយរបៀបណា? ព្រះវិញ្ញាណដ៏វិសុទ្ធ! មិត្តសម្លាញ់អើយ! ព្រះជាម្ចាស់មានចម្លើយដែលអ្នកត្រូវការ។ ប្រសិនបើអ្នកចង់ទទួលបានប្រយោជន៍ពីសក្ដានុពលដ៏អស្ចារ្យនៃព្រះរាជ្យព្រះជាម្ចាស់ អ្នកត្រូវរៀនពីរបៀបស្ដាប់ព្រះសូរសៀងព្រះវិញ្ញាណដ៏វិសុទ្ធ។ ហើយសៀវភៅនេះ គឺនិយាយអំពីការនេះឯង។

ការដើរជាមួយព្រះវិញ្ញាណដ៏វិសុទ្ធឆ្លងកាត់ស្ថានភាពអស់ទាំងនេះ គឺគួរឱ្យរំភើបជាងខ្សែភាពយន្ត ជេមស៍ បូន ដែលអ្នកធ្លាប់បានមើលទៅទៀត! ហើយដូចជាខ្សែភាពយន្តដែរ អ្នកតែងតែដឹងថា អ្នកណាជាអ្នកឈ្នះនៅទីបញ្ចប់ មិនថាមានឈុតឆាកតានតឹងច្រើនប៉ុណ្ណាទេ។

# ជំពូក ២

# ព្រះរាជ្យនៃព្រះ

ខ្ញុំប្រាកដថាអ្នកបានឮអំពីបណ្ដឹងដែលគ្មានខ្លឹមសារជាច្រើន ដែលក្រោយមកត្រូវបានលុបចេញពីតុលាការ។ នេះជាឧទាហរណ៍មួយ។

អ្នកទោសនៅក្នុងពន្ធនាគាររដ្ឋខូឡូរ៉ាដូបានដាក់ពាក្យបណ្ដឹងទាមទារប្រាក់ជាង ៨៨ពាន់លានដុល្លារ (បាទ *ពាន់លាន*) ពីសហព័ន្ធបាល់ទាត់ជាតិ។ បណ្ដឹងនេះផ្ដើមចេញពីសេចក្ដីសម្រេចដែលធ្វើឡើងដោយក្រុមមន្ត្រីក្នុងកំឡុងពេលប្រកួតរវាងក្រុមឌូឡាសខូយប៊យ និងក្រុមហ្គ្រីនប៊េផេកឃឺរ។ ក្រុមមន្ត្រីបានកំណត់ថា ការចាប់បាល់របស់ ដិស ប្រាយអិន (ក្រុមខូយប៊យ) គឺមិនពេញលេញទេ។ អ្នកទោសមិនយល់ស្របទេ។ បណ្ដឹងរបស់គាត់បានចោទប្រកាន់ថា មន្ត្រីNFLបានធ្វើសកម្មភាពធ្វេសប្រហែស និងរំលោភកាតព្វកិច្ចរបស់ពួកគេ។ ហេតុអ្វីបានជាអ្នកទោសប្ដឹងទារប្រាក់៨៨ពាន់លានដុល្លារ? លេខនៅលើអាវរបស់ប្រាយអិន គឺ៨៨។[1]

ឆ្កួត មែនទេ? ខ្ញុំគិតថាមនុស្សគ្រប់គ្នាអាចដឹងថាបណ្ដឹងនេះមិនមានសុពលភាពទេ។ ប៉ុន្តែ តើអ្វីដែលកំណត់ថាបណ្ដឹងមួយមានសុពលភាព ឬអត់? បាទ បើតាមគេហទំព័រ law.com មូលហេតុសំខាន់ពីរដែលរឿងក្ដីត្រូវបានគេលុបចេញពីតុលាការគឺ វាមានបញ្ហាយុត្តាធិការ ឬគ្មានមូលដ្ឋានផ្លូវច្បាប់ក្នុងការឈរលើផ្នែកច្បាប់។ ហេតុអ្វីបានជាខ្ញុំលើកយកបញ្ហាច្បាប់នៅក្នុងសៀវភៅអំពីព្រះវិញ្ញាណដ៏វិសុទ្ធ? ពីព្រោះថា ប្រសិនបើអ្នកចង់ឃើញព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការក្នុងស្ថានភាពរបស់អ្នក អ្នកត្រូវតែស្គាល់ច្បាស់អំពីអ្វីដែលច្បាប់បានចែង។ ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺដូច្នេះឯង ជានរគរមួយដែលប្រតិបត្តិទៅតាមព្រំដែននៃច្បាប់របស់ព្រះរាជ្យព្រះ។ នៅក្នុងសៀវភៅពីរក្បាលមុនរបស់ខ្ញុំក្នុងស៊េរីនេះ *បដិវត្តហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃភាពស្មោះត្រង់ និងបដិវត្តហិរញ្ញវត្ថុរបស់អ្នក៖ អំណាចនៃការសម្រាក* ខ្ញុំបានបង្ហាញមូលដ្ឋានគ្រឹះនៃរបៀបដែលព្រះរាជ្យរបស់ព្រះមានដំណើរការ ទាក់ទងនឹង

យុត្តាធិការ និងច្បាប់។ ប៉ុន្តែដើម្បីយល់អំពីអ្វីដែលខ្ញុំកំពុងនិយាយទាក់ទងនឹងព្រះវិញ្ញាណដ៏វិសុទ្ធ វាជាការល្អក្នុងការត្រលប់ទៅវិញ ហើយយ៉ាងហោចណាស់រំលឹកខ្លួនឯងឡើងវិញអំពីគោលការណ៍ទាំងនេះ។ យើងនឹងចាប់ផ្តើមជាមួយនឹងសំណួរមួយ។

> *ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ធម្មតាគេមើលងាយព្យាការីតែក្នុងស្រុកកំណើត ក្នុងក្រុមគ្រួសារ និងក្នុងផ្ទះរបស់លោកប៉ុណ្ណោះ»។ នៅទីនោះ* ***<u>ព្រះអង្គពុំអាច</u>****ធ្វើការអស្ចារ្យអ្វីបានឡើយ បានត្រឹមតែដាក់ព្រះហស្តលើអ្នកជំងឺខ្លះ ដើម្បីប្រោសគេឱ្យបានជាប៉ុណ្ណោះ។ ព្រះអង្គនឹកឆ្ងល់ ដោយឃើញគេគ្មានជំនឿបែបនេះ។*
>
> *លូកា ៥:៥-៦*

តើអ្នកអាចប្រាប់ខ្ញុំបានទេថាមូលហេតុអ្វីបានជាព្រះយេស៊ូមិនអាចប្រោសមនុស្សនៅក្នុងអត្ថបទខគម្ពីរនេះឱ្យជា? ចម្លើយតាមបទដ្ឋានខាងសាសនាគឺថា មកពីព្រះជាម្ចាស់មិនសព្វព្រះហឫទ័យប្រោសពួកគេឱ្យជា។ លើសពីនេះទៀត ទ្រង់ដឹងច្បាស់ថាអ្វីដែលល្អបំផុត ហើយប្រសិនបើទ្រង់ចង់ប្រោសពួកគេឱ្យគេ ទ្រង់ពិតជាអាចប្រោសពួកគេឱ្យជាបានតើត្រូវដែរឬទេ? ខ្ញុំចង់មានន័យថា ទ្រង់គឺជាព្រះ។ ហើយអ្នកក៏អាចស្មានថា មានមនុស្សនៅទីនោះដែលត្រូវការការប្រោសឱ្យជា ប៉ុន្តែមិនបានទទួលការប្រោសឱ្យជា? ខ្ញុំគិតថា វាជាក់ច្បាស់ណាស់ ដោយសារអត្ថបទគម្ពីរនេះ។ ការដឹងចម្លើយអំពីមូលហេតុដែលព្រះយេស៊ូមិនអាចប្រោសពួកគេឱ្យជាបាន គឺជាការសំខាន់។ ប្រសិនបើយើងអានសេចក្តីសន្និដ្ឋាននៃរឿងនោះ យើងឃើញថាព្រះយេស៊ូមានបន្ទូលថា ដោយសារពួកគេខ្វះជំនឿ ទើបពួកគេមិនបានទទួលការប្រោសឱ្យជា។ ដើម្បីយល់ពីការសង្កេត និងការសន្និដ្ឋានរបស់ព្រះយេស៊ូអំពីមូលហេតុដែលពួកគេមិនបានទទួលការប្រោសឱ្យជា យើងត្រូវយល់ច្បាស់ថាអ្វីជាជំនឿ និងហេតុផលដែលចាំបាច់ត្រូវតែមានវានៅលើផែនដីនេះ ដើម្បីឱ្យស្ថានសួគ៌ទទួលបានយុត្តាធិការស្របច្បាប់នៅទីនេះ។

ខ្ញុំសូមសង្ខេបបញ្ហាក្នុងករណីនេះ។ បញ្ហាគឺមិនមែនមកពីកង្វះអំណាច ឬឆន្ទៈទេ នេះបើតាមទស្សនៈរបស់ព្រះយេស៊ូ។ បញ្ហាគឺបណ្តាលមកពីបញ្ហាយុត្តាធិការ។ អ្វីដែលសំខាន់គឺថា ស្ថានសួគ៌មិនមានមូលដ្ឋានស្របច្បាប់ ដើម្បីធ្វើសកម្មភាពក្នុងស្ថានភាពដែលគ្មានជំនឿទេ។ ឥឡូវនេះ មុនពេលដែលអ្នកបោះសៀវភៅនេះចោល ដោយនិយាយថាខ្ញុំមិនដឹងពីអ្វីដែលខ្ញុំកំពុងនិយាយ សូមទុកពេលមួយនាទីឱ្យខ្ញុំពន្យល់បន្តិចសិន។

នៅពេលដែលព្រះជាម្ចាស់ដាក់អដាំ និងអេវ៉ានៅលើផែនដី ពួកគេមានសិទ្ធិអំណាចពេញលេញនៅលើផែនដី។ ខ្ញុំគិតថាអត្ថបទគម្ពីរខាងក្រោមបញ្ជាក់ការថ្លែងរបស់ខ្ញុំជាការពិត។

> *«ព្រះអង្គបានធ្វើឱ្យគេមានឋានៈទាបជាងទេវតាតែមួយរយៈប៉ុណ្ណោះ ព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់គេ ទុកជាមកុដរាជ្យ ព្រះអង្គបានបង្ក្រាបអ្វីៗទាំងអស់ឱ្យនៅក្រោមជើងរបស់គេ»*។
>
> *ហេព្រើ ២:៧-៨*

សូមកត់សម្គាល់ ព្រះគម្ពីរចែងថា អដាំទទួលបានសិរីរុងរឿង និងកិត្តិយស ទុកជាមកុដរាជ្យ។ ពាក្យមកុដរាជ្យនៅទីនេះគឺសំដៅលើកន្លែងនៃសិទ្ធិអំណាច ដែលអដាំបានគ្រប់គ្រង មិនមែនមានន័យថា គាត់ពិតជាពាក់មកុដនៅក្នុងសួនច្បារទេ។ ប៉ុន្តែយើងអាចគិតស្រមៃថា មានពន្លឺចែងចាំងនៅជុំវិញគាត់ គ្រាន់តែជាការគិតតែប៉ុណ្ណោះ។ អដាំមានសិរីរុងរឿង (ការចាក់ប្រេងតាំង និងភាពរុងរឿងនៃព្រះរាជ្យព្រះ) និងកិត្តិយស (ឋានៈអំណាច) នៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ គាត់បានគ្រប់គ្រងលើផែនដីប្រកបដោយសិរីរុងរឿង និងកិត្តិយស ដោយមានអំណាចដែលបានផ្ទេរសិទ្ធិ ជំនួសឱ្យព្រះរាជ្យរបស់ព្រះជាម្ចាស់។ សាតាំង ដែលមានវត្តមាននៅលើផែនដីរួចហើយនៅពេលមនុស្សបានបង្កើតមក បានមើលងាយមនុស្ស ហើយលោភលន់ចង់បានអំណាចដែលមនុស្សមាន។ ដោយដឹងថា វាមិនអាចយកមកុដនៃសិទ្ធិអំណាចពីអដាំបាន ព្រោះអដាំមានសិទ្ធិអំណាចពេញលេញលើវា វាក៏បង្កើតឧបាយកល ដើម្បីបោកបញ្ឆោតឱ្យគាត់ដាក់មកុដ (សិទ្ធិអំណាច) ដោយស្ម័គ្រចិត្ត។

ដូច្នេះ សាតាំងបានបោកបញ្ឆោតអេវ៉ា ហើយអដាំបានធ្វើតាមអេវ៉ា ពួកគេបានបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ជាលទ្ធផលពួកគេបានបាត់បង់តំណែងរបស់ពួកគេក្នុងព្រះរាជ្យរបស់ព្រះ។ ដោយយកតម្រាប់តាមសាតាំង ឥឡូវនេះពួកគេស្ថិតនៅក្រោមយុត្តាធិការនៃរាជ្យរបស់សាតាំង។ ដូច្នេះអ្នកអាចសួរថា «ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតឱ្យសាតាំងនៅក្នុងសួនច្បារតាំងពីដំបូងដូច្នេះ?» បាទ ទ្រង់ត្រូវតែធ្វើដូច្នោះ។ ខ្ញុំដឹងថា អ្នកប្រហែលជាមានការភ្ញាក់ផ្អើលបន្តិច ដោយបានឮចម្លើយបែបនេះ ប៉ុន្តែវាជាការពិត។ សូមមើល លោកុប្បត្តិ ២:៨-៩។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

*ព្រះជាអម្ចាស់បានធ្វើសួនឧទ្យានមួយ ក្នុងស្រុកអេដែន ដែលនៅខាងកើត រួចយកមនុស្ស ដែលព្រះអង្គបានសូន ទៅដាក់ក្នុងសួនឧទ្យាននោះ។ ព្រះជាអម្ចាស់បានធ្វើឱ្យដើមឈើគ្រប់មុខដុះចេញពីដីមក មានសំរស់គួរឱ្យទាក់ទាញចិត្ត និងមានផ្លែឆ្ងាញ់ពិសាផង។ នៅកណ្ដាលសួនឧទ្យានក៏មានដើមឈើដែលផ្ដល់ជីវិត និងដើមឈើដែលនាំឱ្យស្គាល់ល្អស្គាល់អាក្រក់ដែរ។*

ពេលអានអត្ថបទគម្ពីរនេះ យើងអាចឆ្ងល់ថា ហេតុអ្វីបានជាព្រះជាម្ចាស់ដាក់ដើមឈើដែលនាំឱ្យស្គាល់ល្អស្គាល់អាក្រក់នៅកណ្ដាលសួនឧទ្យាន ក្បែរនឹងដើមឈើដែលផ្ដល់ជីវិតទៅវិញ? ជាទូទៅ ដើម្បីធ្វើឱ្យព្រះជាម្ចាស់មានសិទ្ធិស្របច្បាប់ ក្នុងការចូលទឹកដីរបស់មារសាតាំង ទ្រង់ត្រូវតែផ្ដល់ជម្រើសដល់មនុស្ស ថាគេចង់បម្រើទ្រង់ ឬមារសាតាំង។ ទ្រង់មិនអាចគ្រាន់តែចូលក្នុងដែនសមត្ថកិច្ចរបស់សាតាំងដោយស្របច្បាប់ ហើយដាក់មនុស្សនៅទីនោះទេ។ ដើម្បីធ្វើវាឱ្យស្របច្បាប់ មនុស្សត្រូវតែធ្វើការជ្រើសរើស ថាគេចង់ចុះចូលជាមួយអ្នកណា។ ដរាបណាមនុស្សជ្រើសរើសព្រះជាម្ចាស់ ដើមឈើដែលផ្ដល់ជីវិត មនុស្សនឹងគ្រប់គ្រងលើមារសាតាំង។ ដូច្នេះ ដើមឈើដែលនាំឱ្យស្គាល់ល្អស្គាល់អាក្រក់ ត្រូវតែដាក់ឱ្យនៅក្បែរដើមឈើដែលផ្ដល់ជីវិត។

នេះជាការសង្កេតដ៏សំខាន់មួយដែលយើងត្រូវធ្វើ។ មនុស្សមិនអាចត្រូវដាក់នៅលើផែនដី ដោយគ្មានឆន្ទៈសេរីបានទេ។ ខ្ញុំដឹងហើយថាគ្រិស្តសាសនាភាគច្រើននិយាយថា យើងត្រូវបង្កើតមកជាមួយឆន្ទៈសេរី ដើម្បីឱ្យព្រះជាម្ចាស់អាចដឹងថាអ្នកណាខ្លះស្រលាញ់ទ្រង់។ ខ្ញុំគិតថាការថ្លែងនេះមានការពិតបន្តិចបន្តួច។ ប៉ុន្តែជាទូទៅ វាមិនស្របច្បាប់ទេ បើមនុស្សគ្មានសមត្ថភាពក្នុងការជ្រើសរើស។ ប្រសិនបើមនុស្សមិនមានឆន្ទៈសេរីទេ នោះគាត់មិនអាចត្រូវបានដាក់ក្នុងសួនឧទ្យាននោះទេ។ មានអ្វីជាច្រើនទៀតដែលខ្ញុំអាចនិយាយក្នុងការពិភាក្សាមួយនេះ ប៉ុន្តែខ្ញុំបានបរិយាយអំពីវានៅក្នុងសៀវភៅពីរក្បាលមុនរបស់ខ្ញុំរួចហើយ។

ដូច្នេះ អដាំបានជ្រើសរើសការបោកបញ្ឆោតរបស់មារសាតាំង បានបាត់បង់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយទ្រង់បានជួបជាមួយគាត់នៅក្នុងលោកុប្បត្តិ ៣:១៧-១៩។

*ដីនឹងត្រូវបណ្ដាសា ព្រោះតែអ្នក។ ដូច្នេះ អ្នកនឹងកាប់គាស់ដីចិញ្ចឹមជីវិត<u>យ៉ាងវេទនា</u>ជារៀងរាល់ថ្ងៃអស់មួយជីវិត។ ដីនឹងដុះចេញជាបន្លា និងអញ្ចាញ ហើយអ្នកនឹងបរិភោគតិណជាតិទាំងឡាយ ដែលដុះនៅតាមទីវាល។ អ្នកត្រូវរកស៊ី*

*ចិញ្ចឹមជីវិត<u>ទាំងបង្ហូរញើស</u> រហូតដល់ថ្ងៃដែលអ្នកត្រឡប់ទៅជាដីវិញ ដ្បិតអ្នកមានកំណើតមកពីដី។ អ្នកកើតពីធូលីដី អ្នកត្រូវតែត្រឡប់ទៅជាធូលីដីវិញ»។*

ជាបឋម ព្រះជាម្ចាស់ប្រាប់អដាំថា អដាំ ឯងបានដាក់បណ្តាសាលើដី។ ដោយសារតែអដាំមានអំណាចត្រួតត្រាពេញលេញលើផែនដី គាត់គឺជាអ្នកដែលបានបើកទ្វារឱ្យមារសាតាំងគ្រប់គ្រងលើផែនដី ហើយបានបណ្តេញព្រះជាម្ចាស់ចេញ។ ព្រះហស្តព្រះជាម្ចាស់ត្រូវបានចង ហើយអដាំត្រូវរកស៊ីចិញ្ចឹមជីវិតទាំងបង្ហូរញើស។ មានសេចក្តីលម្អិតតូចមួយដែលមារសាតាំងភ្លេចប្រាប់អេវ៉ានៅពេលវាល្បួងនាង។ សេចក្តីលម្អិតនោះគឺ ព្រះជាម្ចាស់បានវិនិច្ឆ័យមារសាតាំងរួចរាល់ហើយ ហើយបានបណ្តេញវាចេញពីស្ថានសួគ៌ និងបានប្រកាសទីអស់កល្បដែលជាកន្លែងដែលវាត្រូវនៅគឺ ស្ថាននរក។ វាជាការសំខាន់ដែលអ្នកត្រូវយល់ពីការមួយនេះ។ មនុស្សជាច្រើននឹងនិយាយថា «តើព្រះជាម្ចាស់ ដែលប្រកបទៅដោយសេចក្តីស្រលាញ់ អាចបោះមនុស្សទៅកន្លែងមួយដែលហៅថាស្ថាននរកយ៉ាងដូចម្តេចបាន?» ទ្រង់មិនបានធ្វើដូច្នោះទេ គឺអដាំទេតើដែលជាអ្នកបានធ្វើដូច្នេះ។ ដូចដែលយើងបានឃើញនៅក្នុងអត្ថបទគម្ពីរខាងក្រោម ស្ថាននរកមិនបានបង្កើតឡើងសម្រាប់មនុស្សទេ។

*បន្ទាប់មក ព្រះអង្គនឹងមានព្រះបន្ទូលទៅពួកអ្នកនៅខាងឆ្វេងថាៈ "ពួកត្រូវបណ្តាសាអើយ! ចូរថយចេញឱ្យឆ្ងាយពីយើង ហើយធ្លាក់ទៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច ជាភ្លើង**<u>បម្រុងទុកសំរាប់ផ្តន្ទាទោសមារសាតាំង និងបរិវាររបស់វា</u>**នោះទៅ! (ម៉ាថាយ ២៥:៤១)*

នៅពេលដែលអដាំ និងអេវ៉ាចូលក្រោមដែនសមត្ថកិច្ចរបស់មារសាតាំង ពួកគេក៏ស្ថិតនៅក្រោមការកាត់ទោសរបស់មារសាតាំងផងដែរ។ ពូជមនុស្សទាំងអស់ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មារសាតាំងតាមរយៈអដាំ។ សូមគិតអំពីការចិញ្ចឹមសត្វគោ។ ប្រសិនបើគោណាមួយរបស់អ្នកមានកូន កូនគោនោះនឹងក្លាយជារបស់អ្នក ព្រោះហ្វូងគោទាំងមូលជារបស់អ្នក។ ដូច្នេះ កូនចៅទាំងអស់របស់អដាំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មារសាតាំងដោយស្វ័យប្រវត្តិ។ ការយល់ដឹងតាមបទដ្ឋានខាងសាសនា ឬខ្ញុំគួរតែនិយាយថាកង្វះការយល់ដឹងវិញ គឺថាជោគវាសនារបស់មនុស្ស ត្រូវទៅស្ថានសួគ៌ ឬស្ថាននរក វាអាស្រ័យលើគាត់ជាមនុស្សល្អ ឬអាក្រក់ នេះគឺជាការយល់ខុសទាំងស្រុង។ ការពិតគឺថា ការវិនិច្ឆ័យរបស់ពួកគេត្រូវបានកំណត់រួចរាល់ហើយ។ ពួកគេទាំងអស់គ្នាត្រូវទៅស្ថាន

នរក។ មិនមែនដោយសារអ្វីដែលពួកគេបានធ្វើខុស ប៉ុន្តែដោយសារអ្វីដែលអដាំបានធ្វើ។ ឥឡូវនេះ ដោយសារសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ចំពោះបុរស និងស្ត្រីដែលទ្រង់បានបង្កើតមក ទ្រង់បានរៀបចំផែនការសង្គ្រោះមួយ តាមរយៈព្រះអង្គម្ចាស់ព្រះយេស៊ូគ្រិស្ត ដែលអាចឱ្យមនុស្សប្រុស និងស្ត្រីរួចផុតពីការជំនុំជម្រះ ហើយអាចត្រលប់ចូលក្នុងការគ្រប់គ្រងរបស់ព្រះរាជ្យរបស់ព្រះជាម្ចាស់វិញ។

*«ព្រះអង្គ**បានរំដោះ**យើងឱ្យរួចផុតពីអំណាចនៃសេចក្ដីងងឹត ហើយចម្លងយើងចូលទៅក្នុងព្រះរាជ្យនៃព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។» (កូឡុស ១:១៣)*

គួរឱ្យកត់សម្គាល់ថា ព្រះជាម្ចាស់បានរៀបចំឱ្យមានការចៀសផុតស្របច្បាប់ពីការគ្រប់គ្រង និងការវិនិច្ឆ័យរបស់មារសាតាំង។ ប៉ុន្តែដើម្បីទទួលបានប្រយោជន៍ពីការរៀបចំនេះ មនុស្សប្រុស ស្ត្រី និងកុមារ ម្នាក់ៗរៀងៗខ្លួនត្រូវជ្រើសរើសដោយខ្លួនឯង ដោយអំពាវនាវរកព្រះនាមព្រះយេស៊ូ។ បងប្អូនគ្រិស្តបរិស័ទអើយ សូមស្ដាប់ខ្ញុំមួយភ្លែតសិន។ ស្ត្រីដ៏ល្អម្នាក់ដែលកំពុងតែដើរនៅតាមផ្លូវ ទីបំផុតនឹងធ្លាក់ក្នុងស្ថាននរក លុះត្រាតែមាននរណាម្នាក់ប្រាប់គាត់ឱ្យអង្វររកព្រះនាមព្រះយេស៊ូមុនពេលគាត់ស្លាប់។ នឹងមានមនុស្សល្អៗជាច្រើននៅក្នុងស្ថាននរក។ វាជាការកុហករបស់មារសាតាំង ដែលធ្វើឱ្យមនុស្សគិតថា ពួកគេអាចរួចផុតពីស្ថាននរក ដោយសារការធ្វើអំពើល្អ។ មានតែព្រះនាមព្រះយេស៊ូមួយគត់ ដែលអាចផ្ដល់ការសង្គ្រោះដល់មនុស្សទាំងអស់ទាំងប្រុស និងស្ត្រី ឱ្យរួចផុតពីការកាត់ទោសរបស់មារសាតាំង។ ខ្ញុំក៏ចង់បញ្ជាក់ផងដែរថា នៅពេលអដាំបានធ្វើបាប គាត់បានស្លាប់ខាងវិញ្ញាណ ហើយត្រូវបានកាត់ចេញពីព្រះជាម្ចាស់។ ទោះជាយ៉ាងនេះក៏ដោយ គាត់នៅតែរក្សាការកាន់កាប់ស្របច្បាប់របស់គាត់លើផែនដីនេះ។ ដោយសារករណីនេះ មារសាតាំងត្រូវប្រើមនុស្សដែលមានចិត្តជាមារ ហើយព្រះជាម្ចាស់ត្រូវប្រើមនុស្សដែលពោរពេញដោយព្រះវិញ្ញាណដើម្បីសម្រេចកិច្ចការនៅក្នុងលោកិយនេះ។ ដូច្នេះ ដើម្បីរំលឹកឡើងវិញ យើងដឹងថាការទៅស្ថានសួគ៌ ឬស្ថាននរក គឺទាក់ទងនឹងបញ្ហាស្របច្បាប់ មិនទាក់ទងនឹងអំពើល្អ ឬអាក្រក់របស់មនុស្សយើងទេ ប៉ុន្តែវាពឹងផ្អែកលើជ័យជម្នះស្របច្បាប់ ដែលព្រះយេស៊ូបានយកឈ្នះលើមារសាតាំងនៅលើឈើឆ្កាង។ ទោះបីជាព្រះយេស៊ូបានរៀបចំផ្លូវស្របច្បាប់ឱ្យមនុស្សអាចចៀសផុតពីការគ្រប់គ្រងរបស់មារសាតាំងរួចរាល់ហើយក៏ដោយ ក៏ប៉ុន្តែ មនុស្សម្នាក់ៗត្រូវតែអង្វររកព្រះនាមព្រះយេស៊ូដោយជំនឿ ដើម្បីទទួលប្រយោជន៍ពីការរៀបចំនេះ។

ខ្ញុំដឹងថា យើងបានផ្អាកនិយាយអំពីការពិភាក្សាមួយនេះពីរបីកថាខណ្ឌមុន ប៉ុន្តែឥឡូវនេះ សូមត្រលប់ទៅសំណួរដែលយើងបានសួរពីពេលមុន «ហេតុអ្វីព្រះយេស៊ូមិនអាចប្រោសមនុស្សឱ្យជានៅ ម៉ាថាយជំពូក ៦?» ខ្ញុំបាននិយាយថា វាជាបញ្ហាយុត្តាធិការ ហើយវាពិតជាអ៊ីចឹងមែន។ ចាប់តាំងពីអដាំបានប្រគល់ការគ្រប់គ្រងខាងវិញ្ញាណនៃលោកិយនេះឱ្យទៅមារសាតាំង ព្រះជាម្ចាស់មិនអាចលូកដៃក្នុងរឿងលោកិយនេះពេលណាក៏បានទេ ព្រោះថាវាមិនស្របច្បាប់។ សូមកុំយកអ្វីដែលខ្ញុំទើបបាននិយាយច្រឡំជាមួយអ្នកណាជាម្ចាស់លើផែនដីនេះ។ ព្រះគម្ពីរចែងយ៉ាងច្បាស់ ព្រះជាម្ចាស់ជាម្ចាស់លើគេពផែនដី និងអ្វីៗទាំងអស់ដែលទ្រង់បានបង្កើតមក។ ទោះជាយ៉ាងនេះក៏ដោយ ទាក់ទងនឹងលោកិយនេះ ទ្រង់មិនមានសិទ្ធិស្របច្បាប់ក្នុងការគ្រប់គ្រងលើលោកិយនេះទេ។ យើងអាចឃើញដូច្នេះនៅក្នុង លូកា ៤:៥-៧។

> *មារនាំព្រះអង្គទៅកន្លែងមួយដ៏ខ្ពស់ ហើយចង្អុលបង្ហាញ នគរទាំងប៉ុន្មាននៅលើផែនដីឱ្យព្រះអង្គឃើញ ក្នុងមួយរយៈពេលដ៏ខ្លី។ មារសាតាំងទូលព្រះអង្គថា៖ «ខ្ញុំនឹងប្រគល់អំណាច ព្រមទាំងភោគទ្រព្យរបស់នគរទាំងនោះឱ្យលោក ដ្បិតអ្វីៗទាំងអស់ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់ឱ្យអ្នកណាក៏បានស្រេចតែនឹងចិត្តខ្ញុំ។ ដូច្នេះ ប្រសិនបើលោកក្រាបថ្វាយបង្គំខ្ញុំ សម្បត្តិទាំងនោះនឹងបានជារបស់លោកហើយ»។*

យើងអាចឃើញនៅទីនេះថា អដាំបានប្រគល់ការគ្រប់គ្រងស្របច្បាប់នៃលោកិយនេះដល់មារសាតាំង។ ដោយសារបញ្ហានេះ ព្រះជាម្ចាស់មិនអាចធ្វើអ្វីតាមតែព្រះហឫទ័យទ្រង់ចំពោះមនុស្សលោកនៅលើផែនដីនេះទេ។ ក៏ប៉ុន្តែ ប្រសិនបើទ្រង់អាចរកឃើញមនុស្សប្រុស ឬស្ត្រីណាដែលជឿលើទ្រង់ និងចុះចូលទាំងស្រុងលើសិទ្ធិអំណាចពីស្ថានសួគ៌ នោះទ្រង់អាចប្រើសិទ្ធិអំណាចរបស់ទ្រង់តាមរយៈបុគ្គលម្នាក់នេះ។ នេះជារបៀបដូចគ្នាដែលមារសាតាំងបានចូលមកផែនដីនេះពីដំបូង តាមរយៈមនុស្សម្នាក់ដែលមានសិទ្ធិកាន់កាប់ស្របច្បាប់លើផែនដីនេះ គឺអដាំ។ ពេលដែលព្រះជាម្ចាស់បានបាត់បង់អដាំ ទ្រង់ត្រូវរកច្រកចូលមួយទៀតមកកាន់ផែនដីដើម្បីឱ្យគម្រោងការនៃការសង្គ្រោះរបស់ទ្រង់អាចកើតឡើងបាន ហើយទ្រង់បានរកឃើញលោកអាប់រ៉ាម។

> *ព្រះអម្ចាស់មានព្រះបន្ទូលមកកាន់លោកអាប់រ៉ាមថា៖ «ចូរចាកចេញពីស្រុករបស់អ្នក ចាកចេញពីញាតិសន្តាន និងចាកចេញពីក្រុមគ្រួសារឪពុករបស់អ្នក តម្រង់*

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

*ឆ្ពោះទៅស្រុកដែលយើងនឹងបង្ហាញអ្នក។ យើងនឹងឱ្យប្រជាជាតិមួយដ៏ធំកើតចេញពីអ្នក ហើយយើងនឹងឱ្យពរអ្នក។ យើងនឹងធ្វើឱ្យអ្នកមានឈ្មោះល្បី។ ដូច្នេះចូរធ្វើជាអ្នកផ្តល់ពរដល់អ្នកដទៃចុះ!។ យើងនឹងឱ្យពរដល់ជនទាំងឡាយណាដែលឱ្យពរអ្នក យើងក៏នឹងដាក់បណ្តាសាដល់ជនទាំងឡាយណាដែលដាក់បណ្តាសាអ្នកដែរ ក្រុមគ្រួសារទាំងអស់នៅលើផែនដីនឹងបានទទួលពរដោយសារអ្នក»។*

*លោកុប្បត្តិ ១២:១-៣*

លោកអាប់រ៉ាម ឬអប្រាហាំ គឺជាទ្វារដែលព្រះជាម្ចាស់បានប្រើ ដើម្បីអាចត្រលប់ចូលផែនដីវិញ ហើយនាំផែនការនៃការសង្គ្រោះរបស់ទ្រង់មកកាន់មនុស្សជាតិ។ ព្រះជាម្ចាស់បានចងសម្ពន្ធមេត្រីជាមួយលោកអប្រាហាំ និងកូនចៅរបស់គាត់ ហើយតាមរយៈសម្ពន្ធមេត្រីស្របច្បាប់មួយនេះ ទ្រង់អាចនាំព្រះយេស៊ូគ្រិស្តចូលក្នុងផែនដី ប៉ុន្តែអាចចូលបានតែតាមរយៈពូជពង្សរបស់លោកអប្រាហាំតែប៉ុណ្ណោះ។ នេះជាមូលហេតុដែលព្រះយេស៊ូត្រូវតែជាកូនចៅរបស់លោកអប្រាហាំ និងមូលហេតុដែលជនជាតិអ៊ីស្រាអែលមិនត្រូវអនុញ្ញាតឱ្យរៀបការជាមួយប្រទេសជិតខាង។ ហើយវាក៏ហេតុផលដែលសៀវភៅដំបូងនៃគម្ពីរសម្ពន្ធមេត្រីថ្មីមិនចែងអ្វីផ្សេងក្រៅពីពង្សាវតារ។ តាមពិតនេះជាភស្តុតាងបញ្ជាក់ថា ព្រះយេស៊ូពិតជាកូនចៅរបស់អប្រាហាំត្រឹមត្រូវតាមច្បាប់ ហើយដូច្នេះវាក៏បង្ហាញដល់មារសាតាំងថា វាជាការស្របច្បាប់ដែលព្រះយេស៊ូយាងមក និងបង់ថ្លៃសម្រាប់អំពើបាប។

ដោយសារមនុស្សប្រុស និងស្ត្រីនៅតែមានសិទ្ធិគ្រប់គ្រងលើផែនដីស្របច្បាប់ សូមកុំច្រឡំជាមួយការគ្រប់គ្រងខាងវិញ្ញាណ ព្រះជាម្ចាស់ និងមារសាតាំងត្រូវតែប្រើមនុស្សដើម្បីសម្រេចកិច្ចការផ្សេងៗ។ បើនិយាយយ៉ាងសាមញ្ញ មានតែមនុស្សប្រុស និងស្ត្រីទេដែលជាបុគ្គលស្របច្បាប់នៅលើផែនដីនេះ។ ប៉ុន្តែ ដូចដែលមារសាតាំងបានមានសិទ្ធិចូលមកក្នុងផែនដីតាមរយៈអដាំ និងអេវ៉ា ដោយបានជឿលើអ្វីដែលវានិយាយ ដូច្នេះព្រះជាម្ចាស់ត្រូវរកមនុស្សដែលជឿលើអ្វីដែលទ្រង់មានព្រះបន្ទូល ដើម្បីឱ្យទ្រង់អាចមានសិទ្ធិលូកដៃក្នុងរឿងនៅលើផែនដីនេះបាន។ នៅពេលដែលមនុស្សប្រុស ឬស្ត្រីចុះចូលចេញពីចិត្ត ដោយជឿជាក់លើអ្វីដែលស្ថានសួគ៌និយាយ ជាជាងអ្វីដែលលោកិយរបស់មារសាតាំងនិយាយដែលគេហៅថាជាជំនឿ នោះវាផ្តល់យុត្តាធិការស្របច្បាប់ដល់ស្ថានសួគ៌ក្នុងការធ្វើសកម្មភាពក្នុងបុគ្គលរូបនោះដែលនៅលើផែនដី ហើយនាំព្រះហឫទ័យរបស់ព្រះប្រឆាំងនឹង

លោកិយរបស់មារសាតាំង។ មានរឿងជាច្រើនទៀតដែលត្រូវនិយាយ ប៉ុន្តែខ្ញុំបាននិយាយរឿងនេះយ៉ាងល្អិតល្អន់នៅក្នុងសៀវភៅពីរក្បាលដំបូងរបស់ខ្ញុំរួចហើយ។

គន្លឹះសំខាន់នោះគឺ ដោយសារមារសាតាំងមានវត្តមានលើផែនដីនេះ វាតែងតែការពារនគររបស់វា ហើយវាព្យាយាមយកឈ្នះលើគម្រោងការរបស់ព្រះជាម្ចាស់។ ដោយសារហេតុផលនេះ ព្រះជាម្ចាស់ត្រូវធ្វើការសម្ងាត់ ដើម្បីសម្រេចផែនការ និងយុទ្ធសាស្ត្ររបស់ទ្រង់នៅលើផែនដីនេះ។ ពេលដែលអ្នកដឹងអំពីរបៀបដែលព្រះជាម្ចាស់ធ្វើការសម្ងាត់ អ្នកនឹងរកឃើញគន្លឹះដ៏អស្ចារ្យបំផុត សម្រាប់ភាពជោគជ័យ និងជ័យជម្នះនៅក្នុងជីវិត។ ខ្ញុំហៅវាថា អំណាចនៃយុទ្ធសាស្ត្រ!

-

# ជំពូក ៣
# សួប់ស្វែង

ខ្ញុំទទួលបានទូរស័ព្ទពីបុរសម្នាក់ដែលខ្ញុំមិនធ្លាប់ស្គាល់ពីមុនមក។ គាត់បានណែនាំខ្លួនគាត់ ហើយប្រាប់ខ្ញុំថា គាត់ និងបុរសពីរបីនាក់ទៀតពិតជាពេញចិត្តសៀវភៅ *ប្រមាញ់ជំនឿ*របស់ខ្ញុំ និងការបង្រៀនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ តាមពិត គាត់ក៏បានសួរថា តើខ្ញុំចាប់អារម្មណ៍ចង់ទៅរដ្ឋម៉ុនតាណា និងបង្រៀនក្រុមបុរសមួយក្រុម មានគ្នាប្រហែល៧០នាក់ នៅល្ងាចថ្ងៃសុក្រ និងព្រឹកថ្ងៃសៅរ៍ដែរឬទេ។ មុនពេលខ្ញុំឆ្លើយតបទៅកាន់គាត់វិញ គាត់បាននិយាយថា «បន្ទាប់ពីលោកគ្រូបង្រៀននៅព្រឹកថ្ងៃសៅរ៍ហើយ ពួកយើងចង់នាំលោកគ្រូទៅបរបាញ់សត្វរមាំង ព្រោះពេលនេះជារដូវកាលបរបាញ់វា។» មែនហើយ ខ្ញុំមិនត្រូវការពេលយូរ ដើម្បីឆ្លើយសំណួរនេះទេ។ គាត់បាននិយាយថា កូនប្រុសរបស់ខ្ញុំក៏ត្រូវបានអញ្ជើញឱ្យចូលរួមផងដែរ ប្រសិនបើពួកគេចាប់អារម្មណ៍។ បន្ទាប់មក ក្នុងអំឡុងពេលខែនៃរដូវក្ដៅ ពួកគេបានជួយខ្ញុំឱ្យទទួលបានសិទ្ធិត្រឹមត្រូវសម្រាប់ការបរបាញ់ដែលនឹងមកដល់នៅរដូវស្លឹកឈើជ្រុះខាងមុខនេះ។ កូនប្រុសរបស់ខ្ញុំ ធីម ក៏បានសម្រេចចិត្តចូលរួមការបរបាញ់នេះដែរ ហើយគាត់ក៏ទទួលបានអាជ្ញាបណ្ណរបស់គាត់ដែរ។

ខ្ញុំក៏បានដឹងថា ក្រុមនេះជាក្រុមមួយនៃចលនា រក្សាការសន្យា (Promise Keepers) ហើយពួកគេចាប់អារម្មណ៍យ៉ាងខ្លាំងជាមួយនឹងរឿងបរបាញ់ដែលខ្ញុំបានប្រាប់ក្នុងការបង្រៀនរបស់ខ្ញុំ និងរបៀបដែលខ្ញុំទទួលបានសត្វក្ដាន់ដោយជំនឿ។ ពួកគេចង់ដឹងថែមទៀតអំពីរបៀបដែលខ្ញុំបាញ់បានសត្វក្ដាន់ ក្នុងរយៈពេលតែ៣០ ឬ៤០នាទី និងរបៀបដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំឱ្យច្បាស់លាស់អំពីប្រភេទសត្វដែលខ្ញុំចង់បាន ដូចជាភេទ និងទំហំនៃស្នែងរបស់វាជាដើម។ ខ្ញុំយល់ស្របថា រឿងដែលបានកើតឡើងស្ទើរតែមិនគួរឱ្យជឿទេ ហើយប្រសិនបើខ្ញុំមិនបានឃើញវាកើតឡើងដោយផ្ទាល់ភ្នែកខ្ញុំទេ នោះខ្ញុំក៏ប្រហែលជាឆ្ងល់ដូចពួកគេដែរ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

ទីបំផុតក៏ដល់សប្ដាហ៍ដែលយើងត្រូវទៅរដ្ឋម៉ុនតាណា។ ធីម និងខ្ញុំបានធ្វើដំណើរតាមយន្តហោះ ហើយបានជួបជាមួយអ្នកដឹកនាំនៃក្រុមបុរសនោះមួយចំនួន ពួកគេជាបុរសអស្ចារ្យដែលពិតជាស្រលាញ់ព្រះជាម្ចាស់។ ពួកគេបាននាំយើងទៅស្ទូចត្រី ទៅកន្លែងបរបាញ់ដើម្បីមើលកាំភ្លើងដែលពួកគេបានរៀបចំសម្រាប់ពួកយើង។ ដោយបានធំពេញវ័យឡើងនៅរដ្ឋអូហៃយ៉ូ ខ្ញុំមិនមានទម្លាប់បាញ់កាំភ្លើងពីចម្ងាយឆ្ងាយទេ។ ច្បាប់នៅរដ្ឋរបស់យើងអនុញ្ញាតតែកាំភ្លើងខ្លីសម្រាប់បាញ់សត្វក្ដាន់តែប៉ុណ្ណោះ ហើយបាញ់បានត្រឹមចម្ងាយតិចជាង៩០ម៉ែត្រ ភាគច្រើនអាចតិចជាង៤៥ម៉ែត្រទៅទៀតក៏មាន។ ដូច្នេះ នៅពេលដែលពួកគេកំណត់គោលដៅ នៅចម្ងាយ១៨០ម៉ែត្រ ខ្ញុំត្រូវកែសម្រួលរបៀបដែលខ្ញុំបាញ់។ ប៉ុន្តែបន្ទាប់ពីបានអនុវត្តបានបន្តិចមក ខ្ញុំក៏បាញ់ត្រូវចំដែក ហើយគេក៏បានប្រកាសថា ខ្ញុំត្រៀមខ្លួនរួចរាល់សម្រាប់ការបរបាញ់ហើយ។

នៅល្ងាចនោះ ខ្ញុំបានបង្រៀនបុរសទាំងនោះនៅសាលប្រជុំរបស់សាលារៀនមួយក្នុងតំបន់ ហើយព្រឹកបន្ទាប់ក៏បានបង្រៀនពួកគេនៅទីនោះផងដែរ។ បុរសទាំងនោះចង់ស្ដាប់ និងចង់ដឹងពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ជាពិសេសរបៀបដែលព្រះជាម្ចាស់បានបង្រៀនខ្ញុំអំពីច្បាប់នៃព្រះរាជ្យនៃព្រះតាមរយៈការប្រមាញ់។ បន្ទាប់ពីទទួលទានអាហារថ្ងៃត្រង់រួចរាល់ហើយ ពួកគេបាននិយាយថា «តោះយើង ទៅបាញ់សត្វរមាំង»។ ខ្ញុំមិនដែលធ្លាប់បាញ់សត្វរមាំងពីមុនមកទេ ហើយក៏មិនយល់ថាវាមានបែបបទបែបណាដែរ។ តាមបទពិសោធនៃការប្រមាញ់របស់ខ្ញុំ យើងទៅគ្នាច្រើនបំផុតតែពីរ ឬបីនាក់ប៉ុណ្ណោះ។ ប៉ុន្តែ ពួកគេបាននាំគ្នាទៅពីរបីឡាន។ ខ្ញុំនៅចាំបានយប់មុនថ្ងៃទៅបរបាញ់ ធីមបានសួរខ្ញុំថា «ប៉ា តើប៉ាមានអារម្មណ៍ភ័យទេ? ប៉ានឹងបង្រៀនពួកគេអំពីព្រះរាជ្យនៃព្រះ ហើយប្រកាសដោយភាពជឿជាក់ថា ព្រះរាជ្យនៃព្រះមានដំណើរការគ្រប់ពេលវេលា ប៉ុន្តែ ចុះវានឹងទៅជាយ៉ាងណា ប្រសិនបើប៉ាបាញ់សត្វរមាំងមិនបាន ហើយពួកគេមើលឃើញទាំងអស់គ្នា?»។ ខ្ញុំបានប្រាប់គាត់វិញថា ខ្ញុំមិនខ្លាចបាញ់សត្វរមាំងមិនបានទេ។ ឌ្រិនដា និងខ្ញុំបានដាំគ្រាប់ពូជរបស់យើងរួចរាល់ហើយ ហើយបានព្រមព្រៀងគ្នាថា នឹងទទួលបានសត្វរមាំងមួយ។ វានឹងនៅទីនោះ។

នៅពេលដែលយើងបើកឡានទៅកាន់កន្លែងបរបាញ់សត្វ ដែលពួកគេទទួលបានការអនុញ្ញាតឱ្យបរបាញ់ ពួកគេបានពន្យល់ប្រាប់ខ្ញុំថា សត្វរមាំងជាសត្វដែលរត់លឿនបំផុតនៅអាមេរិកខាងជើង ហើយជាសត្វរត់លឿនបំផុតលេខពីរនៅលើផែនដីនេះ មានតែសត្វខ្លារខិនទេទើបអាចចាប់វាបាន។ ពួកគេបានពន្យល់ប្រាប់ថា សត្វរមាំងមានភ្នែកវៃខ្លាំងណាស់

ហើយរបៀបការពារខ្លួនរបស់វាគឺការរត់ ដូច្នេះ ប្រសិនបើវាឃើញអ្នក វានឹងបាត់ខ្លួនភ្លាមក្នុងពេលមួយវិនាទី។ ខ្ញុំមានស្លាកអនុញ្ញាតឱ្យបាញ់រមាំងឈ្មោល ហើយធីម រមាំងញី។

ផែនការរបស់យើងគឺ បើកឡានទៅកន្លែងបរបាញ់សត្វ បើកទៅទីខ្ពស់ ហើយបន្ទាប់មកដើរឡើងទៅលើកំពូលភ្នំ និងក្រឡេកមើលមកជ្រលងទាបៗ ដើម្បីរកមើលសត្វ។ នៅពេលដែលយើងកំពុងឡើងលើកំពូលភ្នំ យើងបានឃើញសត្វរមាំងមួយហ្វូងពីចម្ងាយ។ ដោយសារស្ថានភាពភូមិសាស្ត្រ យើងមានអារម្មណ៍ថា យើងអាចចូលទៅជិតល្មមដើម្បីបាញ់វា ដោយគ្រាន់តែនៅតាមជ្រលងទាបៗ ពេលដែលយើងចូលទៅជិតពួកវា។ យើងនឹងត្រូវឡើងលើភ្នំចុងក្រោយដោយប្រុងប្រយ័ត្ន ហើយបន្ទាប់មកយើងត្រូវឡើងយឺតៗលើកំពូលភ្នំនោះដើម្បីបាញ់សត្វរមាំង ប្រសិនបើពួកវានៅតែនៅទីនោះ នៅពេលយើងឡើងទៅដល់។ នៅពេលទៅដល់ទីនោះ យើងអាចបាញ់វាបាន ប្រសិនបើវាមានចម្ងាយពី១៨០ ទៅ ២៣០ម៉ែត្រ ពីពួកយើង។

ធីម និងខ្ញុំត្រូវលូនយឺតៗមួយសន្ទុះដើម្បីទៅដល់គែមចំហៀងភ្នំ ដែលអាចមើលឃើញសត្វរមាំងទាំងនោះ។ យើងមានគម្រោងថា បន្ទាប់ពីខ្ញុំបាញ់បានសត្វរមាំងរបស់ខ្ញុំហើយ ធីមនឹងបាញ់រមាំងញីរបស់គាត់។ ខ្ញុំបានលូនយឺតៗទៅដល់គែម ហើយក្រឡេកមើលទៅហ្វូងរមាំងនោះ។ ប្រាកដណាស់ ផែនការរបស់យើងបានមានដំណើរការហើយ រមាំងមួយហ្វូងតូចនោះមិនឃើញពួកយើងទេ។ ខ្ញុំលើកកាំភ្លើងឡើង ហើយក៏បានស្វែងយល់ថាវាពិបាកកាន់កាំភ្លើងឱ្យនឹង ដោយសារចម្ងាយ និងការហត់ពីការដង្ហើមដោយការលូន។ ប៉ុន្តែទីបំផុត នៅពេលខ្ញុំគិតថា ខ្ញុំតម្រង់ចំរមាំងមួយហើយ ខ្ញុំក៏បានកេះកៃកាំភ្លើង។ ខ្ញុំបាញ់ខុស។ ហ្វូងរមាំងហាក់ដូចជាច្របូកច្របល់នៅពេលខ្ញុំកេះកៃកាំភ្លើងលើកទីពីរ។ ខ្ញុំបាញ់ខុសម្តងទៀត។ ឥឡូវនេះហ្វូងរមាំងចាប់ផ្តើមរត់ នៅពេលខ្ញុំបាញ់លើកទីបី និងទីបួនដែលខុសទាំងអស់។ នៅពេលខ្ញុំកេះកៃកាំភ្លើងលើកទីប្រាំ អ្វីដែលខ្ញុំបានឮគឺ ក្រិប។ កាំភ្លើងខ្ញុំអស់គ្រាប់ហើយ។

នៅក្នុងភាពច្របូកច្របល់ ខ្ញុំមិនបានកត់សម្គាល់ទេ ប៉ុន្តែហ្វូងសត្វទាំងមូលបានរត់បែកខ្ញែកឆ្ងាយពីគ្នា។ សត្វទាំងអស់ លើកលែងតែសត្វរមាំងដែលខ្ញុំតម្រង់បាញ់ វាបានឈរនៅទីតាំងដ៏ល្អឥតខ្ចោះ ចម្ងាយពីរបីម៉ែត្រពីកន្លែងដែលខ្ញុំបានបាញ់វាលើកដំបូង។ ខ្ញុំសុំកាំភ្លើងពីធីមយ៉ាងត្រហេបត្រហប។ ខ្ញុំបានក្រោកឈរឡើង តម្រង់ទៅសត្វរមាំងនោះ បានកេះកៃកាំភ្លើង ហើយវាក៏ដួលចុះ។ ខ្ញុំមានអារម្មណ៍រំភើប និងធូរចិត្តក្នុងពេលតែមួយ។ រមាំង

**ពិភពលោកនេះស្រេកឃ្លានចង់ឃើញរឿងពិត ហើយព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យធ្វើឱ្យពួកគេភ្ញាក់ផ្អើលផងដែរ។**

ឈ្មោលនេះជារបស់ខ្ញុំហើយពេលនេះ។ ពេលដែលខ្ញុំងាកទៅក្រោយស្មារបស់ខ្ញុំ ខ្ញុំមានអារម្មណ៍រំភើប ដោយបានឃើញក្រុមបុរសទាំងអស់ស្រែកហ៊ោអបអរសាទរដល់ខ្ញុំ។ មានអ្នកខ្លះកាន់ទូរស័ព្ទនៅនឹងដៃ ហើយម្នាក់បាននិយាយថា «ត្រូវហើយ វាដូចជានៅក្នុងសៀវភៅ*ប្រមាញ់ជំនឿ*អីចឹង រយៈពេលតែ៤០នាទីទេ រមាំងឈ្មោលមួយឈរត្រើងស្មៀម ដូចនៅក្នុងសៀវភៅដែរ»។ ពួកគេទាំងអស់គ្នាបានមើលឃើញព្រះរាជ្យនៃព្រះមានដំណើរការ។ យ៉ាងណាមិញ ខ្ញុំបានបង្រៀនដល់ពួកគេជាច្រើនម៉ោង ហើយពួកគេចង់ឃើញដំណើរការរបស់វា។ មែនហើយ ទោះបីជាការប្រមាញ់របស់ខ្ញុំមិនល្អក៏ដោយ វានៅតែមានដំណើរការ ហើយបានបន្ថែមតាពជឿជាក់លើអ្វីដែលខ្ញុំបានបង្រៀន។ នៅរសៀលនោះ ធីមក៏បាញ់បានរមាំងញីមួយក្បាលផងដែរ គាត់បានបាញ់ចំរមាំងមួយដែលកំពុងតែរត់។ យើងទាំងពីរនាក់រំភើបខ្លាំងណាស់! រដ្ឋម៉ុនតាណាពិតជាស្រស់ស្អាតខ្លាំងណាស់ ហើយធីម និងខ្ញុំក៏មានបទពិសោធនូវព្រះរាជ្យនៃព្រះយ៉ាងអស្ចារ្យផងដែរ។ ខ្ញុំបានតាំងក្បាលសត្វរមាំងក្នុងបន្ទប់ការិយាល័យរបស់ខ្ញុំ ដើម្បីរំលឹកអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងតាពស្មោះត្រង់របស់ទ្រង់។

ហេតុអ្វីបានជាខ្ញុំប្រាប់អ្នកអំពីរឿងបរបាញ់នៅក្នុងសៀវភៅនេះ? ពីព្រោះព្រះជាម្ចាស់សព្វព្រះឫទ័យប្រើអ្នក ដើម្បីបង្ហាញព្រះរាជ្យរបស់ទ្រង់ដល់មិត្តភក្តិ អ្នកជិតខាង និងក្រុមគ្រួសាររបស់អ្នក។ ពួកគេទាំងអស់គ្នាចង់ឃើញពីរបៀបវាមានដំណើរការ។ ពិតពលោកនេះស្រេកឃ្លានចង់ឃើញរឿងពិត ហើយព្រះជាម្ចាស់ក៏សព្វព្រះហឫទ័យធ្វើឱ្យពួកគេភ្ញាក់ផ្អើលផងដែរ។ ដើម្បីធ្វើឱ្យពួកគេភ្ញាក់ផ្អើល អ្នកត្រូវរៀនពីរបៀបដែលព្រះរាជ្យនៃព្រះមានដំណើរការ និងរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធនាំយកនូវចម្លើយ និងឱកាសដែលអ្នកត្រូវការ ដើម្បីធ្វើឱ្យមនុស្សគ្រប់គ្នាភ្ញាក់ផ្អើល សូម្បីតែអ្នក។ ក្រោយមកខ្ញុំបានដឹងថា បុរសពីរបីនាក់ដែលដឹកនាំក្រុមបុរសមួយក្រុមនោះ បាននាំខ្ញុំមកជួបពួកគេគឺក្នុងគោលបំណងបង្ហាញព្រះរាជ្យនៃព្រះទៅកាន់បុរសទាំងនោះ ដោយសារពួកគេជាប់គាំងក្នុងលក្ខណៈសាសនា។ ក្រោយមកខ្ញុំក៏បានដឹងថា មានមនុស្សជាច្រើនទៀតបានថ្វាយដួងចិត្តឱ្យព្រះដឹកនាំតាមរយៈការបង្រៀនរបស់ខ្ញុំ។ ព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នករៀបចំផែនការនេះ ហើយទ្រង់នឹងជួយអ្នកជាមួយផែនការជោគជ័យរបស់អ្នកផងដែរ។

ខ្ញុំសូមប្រាប់អ្នករឿងមួយបន្ថែមទៀត ប៉ុន្តែរឿងនេះដកស្រង់ចេញពីព្រះគម្ពីរ ហើយជាថ្មីម្តងទៀត រឿងនេះនឹងបង្ហាញអំពីរបៀបដែលព្រះជាម្ចាស់សព្វព្រះហឫទ័យធ្វើឱ្យអ្នកភ្ញាក់ផ្អើល ដោយសារផែនការ និងយុទ្ធសាស្ត្រដ៏អស្ចារ្យ ដែលនឹងនាំមកនូវភស្តុតាងនៃភាពពិតរបស់ទ្រង់ និងសេចក្តីស្រលាញ់ដល់អស់អ្នកដែលនៅជុំវិញអ្នក។

*ថ្ងៃមួយ ព្រះយេស៊ូគង់នៅមាត់បឹងគេនេសារ៉ែត មានបណ្តាជនជាច្រើនប្រជ្រៀតគ្នានៅជុំវិញព្រះអង្គ ដើម្បីស្តាប់ ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអង្គទតឃើញទូកពីរចតនៅមាត់ច្រាំង រីឯអ្នកនេសាទនាំគ្នាចុះទៅលាងអួន របស់គេ។ ព្រះយេស៊ូយាងចុះទៅក្នុងទូករបស់លោកស៊ីម៉ូន រួចទ្រង់សុំឱ្យគាត់ចេញទូក ទៅឆ្ងាយពីច្រាំងបន្តិច។ ព្រះអង្គគង់បង្រៀនបណ្តាជនពីក្នុងទូកនោះ។*

*លុះព្រះអង្គបង្រៀនគេចប់ហើយ ទ្រង់មានព្រះបន្ទូលទៅកាន់លោកស៊ីម៉ូនថា៖ «ចូរបង្ហួសទូកទៅទីកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ»។*

*លោកស៊ីម៉ូនតបទៅព្រះយេស៊ូវិញថា៖ «លោកគ្រូ! យើងខ្ញុំបានអូសអួនពេញមួយយប់ហើយ អត់បានត្រីសោះ ប៉ុន្តែ បើលោកគ្រូមានប្រសាសន៍ដូច្នេះ ខ្ញុំនឹងទម្លាក់អួនតាមពាក្យរបស់លោកគ្រូ»*

*គេក៏ទម្លាក់អួនទៅក្នុងទឹក ជាប់ត្រីយ៉ាងច្រើនស្ទើរតែធ្លាយអួន។ គេបក់ដៃហៅមិត្តភក្តិដែលនៅក្នុងទូកមួយទៀតឱ្យមកជួយ។ ពួកនោះមកដល់ ជួយចាប់ត្រីដាក់ពេញទូកទាំងពីរ ស្ទើរតែនឹងលិច។*

*ពេលលោកស៊ីម៉ូន-ពេត្រុសឃើញដូច្នោះ គាត់ក្រាបទៀបព្រះបាទាព្រះយេស៊ូ ទូលព្រះអង្គថា៖ «ព្រះអម្ចាស់អើយ សូមយាងឱ្យឆ្ងាយពីទូលបង្គំទៅ ព្រោះទូលបង្គំជាមនុស្សបាប»។ លោកស៊ីម៉ូននិយាយដូច្នេះ ព្រោះគាត់ និងអស់អ្នកដែលនៅជាមួយភ័យស្ញប់ស្ញែងជាខ្លាំង នៅពេលបានឃើញត្រីច្រើនយ៉ាងនេះ។ រីឯលោកយ៉ាកុប និងលោកយ៉ូហានជាកូនលោកសេបេដេ ដែលនេសាទរួមជាមួយលោកស៊ីម៉ូន ក៏មានចិត្តដូច្នោះដែរ។*

លូកា ៥:១-១០

ពេត្រុស យ៉ាកុប និងយ៉ូហាន បាននេសាទត្រីពេញមួយយប់ តែមិនបានអ្វីទាល់តែសោះ។ ពួកគេជាអ្នកនេសាទដែលមានបទពិសោធ ដែលបានធំធាត់ឡើងនៅលើ

បឹង ហើយដឹងច្បាស់ពីរបៀបនេសាទត្រី ប៉ុន្តែពួកគេចាប់ត្រីមិនបានសោះ។ ជាការពិតណាស់ រឿងនេះមិនបានបញ្ចប់នៅទីនេះទេ។ ព្រះយេស៊ូបានខ្ចីទូកលោកពេត្រុស ដើម្បីបង្រៀនមហាជនពីលើទូក បន្ទាប់មកទ្រង់បានប្រាប់គាត់ឱ្យទម្លាក់អួនក្នុងទឹកជ្រៅ ដើម្បីចាប់ត្រី។ លោកពេត្រុស ដោយមានអារម្មណ៍ភ្ញាក់ផ្អើលបន្តិច បាននិយាយថា ពួកគេបាននេសាទត្រីពេញមួយយប់ហើយ ប៉ុន្តែចាប់ត្រីមិនបានសូម្បីមួយក្បាល ប៉ុន្តែ ដោយសារព្រះយេស៊ូបានមានព្រះបន្ទូលដូច្នេះ គាត់នឹងធ្វើតាម។ នៅពេលលោកពេត្រុសបានទម្លាក់អួន ព្រះគម្ពីរបានចែងថា គាត់ចាប់ត្រីបានច្រើនសន្ធឹកសន្ធាប់រហូតស្ទើរតែធ្លាយអួនរបស់គាត់ ដូច្នេះគាត់បានហៅមិត្តភក្តិរបស់គាត់ឱ្យមកជួយ។ អត្ថបទគម្ពីរបន្តចែងថា អួនរបស់មិត្តភក្តិគាត់ក៏ស្ទើរតែធ្លាយផងដែរ ហើយទូកទាំងពីរមានត្រីពេញហូរហៀរស្ទើរតែលិចទូក។ ព្រះគម្ពីរចែងថា អ្នកនេសាទដែលមានបទពិសោធទាំងនេះ បានស្ញប់ស្ញែងជាខ្លាំង នៅពេលដែលបានចាប់ត្រីនៅថ្ងៃនោះ ដែលធ្វើឱ្យពួកគេឈប់នេសាទត្រី ហើយដើរតាមព្រះយេស៊ូវិញ។

នេះជារឿងមួយក្នុងចំណោមរឿងជាច្រើនក្នុងព្រះគម្ពីរដែលខ្ញុំចូលចិត្តបំផុត ព្រោះវាបង្ហាញយ៉ាងច្បាស់អំពីរូបភាពនៃភាពខុសគ្នារវាងនគរទាំងពីរ គឺនគរនៃភាពងងឹត និងព្រះរាជ្យរបស់ព្រះជាម្ចាស់។ នគរនៃភាពងងឹតដែលជាការគ្រប់គ្រងរបស់មារសាតាំង ជាប្រព័ន្ធដែលខ្ទេចខ្ទាំ ខ្វះខាត នេសាទពេញមួយយប់តែចាប់ត្រីមួយក្បាលមិនបាន ពោរពេញទៅដោយការឈឺចាប់ និងរកស៊ីចិញ្ចឹមជីវិតទាំងបង្ហូរញើស។ ខ្ញុំហៅវាថា ប្រព័ន្ធផែនដីត្រូវបណ្តាសា កើតឡើងដោយសារការបះបោររបស់អដាំ បើប្រៀបធៀបនឹងរូបភាពដ៏រុងរឿងនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ និងអ្វីដែលព្រះរាជ្យរបស់ទ្រង់ផលិត។ សូមក្រឡេកមើលចុងម្ខាងៗនៃជ្រុងទាំងពីរ ហើយសូមជ្រាបថាព្រះជាម្ចាស់ប្រទានទ្វារទីពីរឱ្យអ្នក គឺព្រះរាជ្យនៃព្រះ។

ឥឡូវនេះ គ្រិស្តបរិស័ទគ្រប់រូបនឹងស្រែកហ៊ោ ទះដៃ ហើយនិយាយថា «មែនហើយ ព្រះរាជ្យរបស់ព្រះជាម្ចាស់ពិតជាអស្ចារ្យណាស់ ដូចជាការនេសាទត្រីនេះអីចឹង!»។ ប៉ុន្តែមានមនុស្សតិចណាស់ដែលនឹងសួរអំពីរបៀបដែលព្រះយេស៊ូបានធ្វើដូច្នេះ ហើយមនុស្សភាគច្រើនមិនបានដឹងថាពួកគេត្រូវបានផ្តល់សិទ្ធិអំណាច និងសមត្ថភាពដើម្បីរីករាយជាមួយនឹងការផ្គត់ផ្គង់ ដូចដែលលោកពេត្រុស យ៉ាកុប និងយ៉ូហានបានទទួលនៅថ្ងៃនោះផងដែរនោះទេ។ ចម្លើយជាស្តង់ដាទាក់ទងនឹងការពន្យល់អំពីរបៀបដែលព្រះយេស៊ូបានធ្វើអ្វីដែលទ្រង់បានធ្វើនៅពេលនោះគឺ ព្រះយេស៊ូអាចធ្វើដូច្នេះបានដោយ

សារទ្រង់ជាព្រះយេស៊ូ។ ប៉ុន្តែសូមចាំបន្តិចសិន យើងបានឃើញរួចហើយថា ព្រះយេស៊ូមិនអាចព្យាបាលមនុស្សគ្រប់គ្នានៅ ម៉ាកុសជំពូក៦ទេ ព្រោះស្ថានសួគ៌គ្មានយុត្តាធិការនៅទីនោះ។ អត់ទេ មានច្បាប់ខាងវិញ្ញាណនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលកំពុងមានដំណើរការនៅថ្ងៃនោះ ដែលជួយសម្រួល និងផលិតត្រីដែលចាប់បាន។

ប៉ុន្តែ នេះគឺជាបញ្ហា។ គ្រិស្តបរិស័ទភាគច្រើនដែលខ្ញុំបានជួប មិនដែលធ្លាប់គិតថា ការដែលធ្វើអ្វីដូចព្រះយេស៊ូបានធ្វើអាចទៅរួច ហើយប្រសិនបើគេគិតថាអាចទៅរួច គេមិនបានដឹងថា ព្រះយេស៊ូបានធ្វើវាដោយរបៀបណាទេ។ ខ្ញុំមានឃ្លាមួយដែលខ្ញុំប្រើក្នុងសន្និបាតរបស់ខ្ញុំ ដែលនិយាយថា ប្រសិនបើអ្នកមិនអាចបង្រៀនវាបានទេ អ្នកក៏មិនអាចរស់នៅតាមវាបានដែរ។ ខ្ញុំចង់មានន័យថា ប្រសិនបើអ្នកមិនអាចកំណត់អំពីរបៀបដែលការចាប់ត្រីនោះកើតឡើងដោយរបៀបណាទេ នោះអ្នកក៏មិនអាចធ្វើឱ្យវាកើតឡើងម្តងទៀតបានដែរ។ ដូច្នេះ តើការចាប់ត្រីបានយ៉ាងសន្ធឹកសន្ធាប់កើតឡើងដោយរបៀបណា? តើអ្នកអាចកំណត់វាបានដែរឬទេ? ប្រសិនបើអ្នកចង់បានជោគជ័យបែបនោះដែរ អ្នកត្រូវតែស្វែងយល់អំពីរបៀបដែលត្រីទាំងនោះបង្ហាញខ្លួន។ យ៉ាងណាមិញ មនុស្សភាគច្រើនភ្ញាក់ផ្អើលពេលដែលខ្ញុំចាប់ផ្តើមនិយាយបែបនេះ។ ប៉ុន្តែ តើព្រះយេស៊ូបានមានបន្ទូលយ៉ាងដូចម្តេច?

> *ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាជឿលើខ្ញុំ អ្នកនោះនឹងធ្វើកិច្ចការដែលខ្ញុំធ្វើដែរ ហើយនឹងធ្វើកិច្ចការធំជាងនេះទៅទៀត ពីព្រោះខ្ញុំទៅឯព្រះបិតា។*
>
> លូកា ១៤:១២

នៅពេលដែលព្រះយេស៊ូមានបន្ទូលថា យើងអាចធ្វើកិច្ចការដូចដែលទ្រង់កំពុងធ្វើ ព្រោះទ្រង់នឹងយាងទៅឯព្រះវរបិតា ទ្រង់បានសំដៅលើព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនឹងយាងមកបន្ទាប់ពីការសុគត និងការរស់ឡើងវិញរបស់ទ្រង់។ នេះគឺជាព្រះវិញ្ញាណដ៏វិសុទ្ធតែមួយ ដែលបានយាងមកលើទ្រង់នៅឯទន្លេយ័រដាន់ ដែលអនុញ្ញាតឱ្យទ្រង់អាចធ្វើកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ដែលយើងឃើញនៅពេលយើងធ្វើតាមការត្រាស់ហៅរបស់ទ្រង់។ យើងដឹងថាអំណាចនេះត្រូវបានរាំងនៅក្នុងម៉ាកុស៦ ដោយសារតែការមិនជឿរបស់មនុស្ស ក៏ប៉ុន្តែ អំណាចនេះមិនត្រូវបានរាំងនៅក្នុងលូកាជំពូក៥ ដែលទាក់ទងនឹងការចាប់ត្រីទេ។ យើងត្រូវសិក្សាច្បាប់នៃព្រះរាជ្យនៃព្រះ ដើម្បីយើងអាចកំណត់បានថា អ្វីដែលរាំង ឬអ្វីដែលជួយសម្រួលដល់លំហូរសេរីនៃព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងស្ថានភាពណាក៏

ដោយ។ ដូច្នេះសូមក្រឡេកមើលរឿងនេះ ហើយមើលថា តើយើងអាចឃើញច្បាប់ និង គោលការណ៍នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលយើងអាចកំណត់ និងរៀនបានដែរឬទេ។

ឥឡូវនេះ ប្រសិនបើអ្នកបានអានសៀវភៅដំបូងរបស់ខ្ញុំ អ្នកដឹងថាមានអ្វីកើតឡើងខាងវិញ្ញាណ នៅពេលលោកពេត្រុសបានឱ្យព្រះយេស៊ូប្រើទូករបស់គាត់។ ទូករបស់លោកពេត្រុស និងជំនួញនេសាទទាំងមូលរបស់គាត់ បានផ្លាស់ប្តូរនគរ ឬយុត្តាធិការ! ត្រូវហើយ នៅពេលដែលព្រះយេស៊ូយកទូកលោកពេត្រុសប្រើក្នុងព័ន្ធកិច្ចរបស់ទ្រង់ ទូករបស់លោកពេត្រុសស្ថិតនៅក្រោមយុត្តាធិការនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ នៅពេលដែលទូកនោះស្ថិតនៅក្រោមយុត្តាធិការនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ព្រះវិញ្ញាណដ៏វិសុទ្ធមានយុត្តាធិការស្របច្បាប់ ដើម្បីបញ្ជូនពាក្យនៃចំណេះដឹងដល់ព្រះយេស៊ូ ដូចជាទីតាំងនៃហ្វូងត្រីក្នុងទឹកជ្រៅជាដើម។ ការចាប់ត្រីបានដ៏ច្រើនសន្ធឹកសន្ធាប់គឺជាលទ្ធផលនៃផែនការ និងយុទ្ធសាស្ត្រដ៏អស្ចារ្យរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលផ្តល់ឱ្យលោកពេត្រុសតាមរយៈព្រះយេស៊ូ។ ខ្ញុំហៅវាថា ចំណេះដឹងលាក់កំបាំង ហើយដោយសារតែវា លោកពេត្រុស យ៉ាកុប និងយ៉ូហានបានឃើញការចាប់ត្រីដ៏ច្រើនសន្ធឹកសន្ធាប់បំផុតដែលពួកគេមិនធ្លាប់ឃើញពីមុនមក។ តាមពិត ព្រះគម្ពីរចែងថា អ្នកនេសាទដែលមានបទពិសោធទាំងនេះមានចិត្តស្ញប់ស្ញែងយ៉ាងខ្លាំង។

ខ្ញុំជឿថាព្រះយេស៊ូសព្វព្រះហឫទ័យឱ្យអ្នករស់នៅក្នុងជីវិតដែលពោរពេញទៅដោយការអស្ចារ្យផងដែរ ជាជីវិតដែលបង្ហាញពីព្រះរាជ្យនៃព្រះ ដើម្បីឱ្យមនុស្សនៅជុំវិញអ្នកមានចិត្តស្ញប់ស្ញែង ដោយបានឃើញការអស្ចារ្យក្នុងជីវិតអ្នក ហើយពួកគេនឹងស្គាល់ព្រះយេស៊ូផងដែរ។ ខ្ញុំជឿថា ទូកនេសាទ-ទទេនៃសាសនានឹងមិនទាក់ទាញមនុស្សមករកព្រះជាម្ចាស់ឡើយ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឱ្យមនុស្សឃើញភាពល្អនៃព្រះរាជ្យរបស់ទ្រង់ ដើម្បីឱ្យមនុស្សគ្រប់គ្នាបានឃើញ និងជឿថាទ្រង់ជាព្រះល្អ និងទទួលយកអស់អ្នកដែលមករកទ្រង់។ ព្យាការីអេសាយបាននិយាយអំពីរឿងនេះ នៅពេលគាត់ប្រកាសពាក្យទំនាយខាងក្រោម ដែលសំដៅលើក្រុមជំនុំ។

*«គេនឹងប្រដូចអ្នកក្រុងយេរូសាឡឹម ទៅនឹងដើមឈើសក្ការៈនៃព្រះដ៏សុចរិត ជាសួនឧទ្យានរបស់**ព្រះអម្ចាស់** ដើម្បីបង្ហាញភាពថ្កុំថ្កើងរបស់ព្រះអង្គ។»* (អេសាយ ៦១:៣)

ដូច្នេះ តើសារអ្វីដែលខ្ញុំចង់ប្រាប់អ្នក ចេញពីរឿងនេសាទត្រីនៅលូកា ជំពូក៥? បាទ មានច្បាប់ខាងវិញ្ញាណជាច្រើន ដែលអ្នកអាចទាញចេញពីរឿងនេះ ប៉ុន្តែ ប្រសិនបើអ្នកអាចគ្រាន់តែដើរចេញជាមួយគំនិតមួយនេះ វានឹងផ្លាស់ប្តូរជីវិតអ្នក។

**អ្នកណាក៏អាចចាប់ត្រីបានដែរ ប្រសិនបើព្រះយេស៊ូប្រាប់គេយ៉ាងច្បាស់ពីកន្លែងដែលត្រូវទម្លាក់អួន!! ឬអនុញ្ញាតឱ្យខ្ញុំនិយាយតាមរបៀបនេះ៖ អ្នកណាក៏អាចចាប់ត្រីបានដែរ ប្រសិនបើព្រះយេស៊ូប្រាប់គេពីកន្លែងដែលមានត្រី និងរបៀបដើម្បីចាប់វា!**

មានមនុស្សប្រាប់ខ្ញុំថា «មែនហើយ លោកគ្រូហ្គារី វាពិតជាល្អមែន ប៉ុន្តែ ព្រះយេស៊ូមិននៅទីនេះទៀតទេ»។ អត់ទេ! ព្រះវិញ្ញាណដ៏វិសុទ្ធដែលបានប្រាប់ទ្រង់ពីទីកន្លែងដែលមានត្រី ទ្រង់មានវត្តមាននៅទីនេះ ហើយគង់ក្នុងអ្នក ប្រសិនបើអ្នកជាអ្នកជឿ។ សូមស្តាប់អ្វីដែលព្រះយេស៊ូបានប្រាប់ដល់ពួកសិស្សរបស់ទ្រង់ នៅពេលដែលទ្រង់រៀបចំចាកចេញពីពួកគេ។

> *ខ្ញុំបានប្រាប់សេចក្តីទាំងនេះឱ្យអ្នករាល់គ្នាដឹងក្នុងពេលដែលខ្ញុំស្ថិតនៅជាមួយអ្នករាល់គ្នានៅឡើយ ប៉ុន្តែ ព្រះដ៏ជួយការពារ គឺព្រះវិញ្ញាណដ៏វិសុទ្ធ ដែលព្រះបិតាចាត់ឱ្យមកក្នុងនាមខ្ញុំនឹងបង្រៀនសេចក្តីទាំងអស់ដល់អ្នករាល់គ្នា ព្រមទាំងរំលឹកអ្វីៗដែលខ្ញុំបានប្រាប់អ្នករាល់គ្នាផង។ ខ្ញុំទុកសេចក្តីសុខសាន្តឱ្យអ្នករាល់គ្នា ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំឱ្យអ្នករាល់គ្នា។ សេចក្តីសុខសាន្តដែលខ្ញុំផ្តល់ឱ្យនេះមិនដូចសេចក្តីសុខសាន្តដែលមនុស្សលោកឱ្យទេ។ ចូរកុំរន្ធត់ចិត្ត កុំភ័យខ្លាចឱ្យសោះ។*

យ៉ូហាន ១៤:២៥-២៧

តើសេចក្តីសុខសាន្តដែលព្រះយេស៊ូផ្តល់ឱ្យជាអ្វី? គឺជាព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានប្រាប់ទ្រង់ពីរបៀបដោះស្រាយគ្រប់ស្ថានការណ៍ ដែលទ្រង់បានជួបប្រទះ។ ព្រះយេស៊ូបានហៅព្រះវិញ្ញាណដ៏វិសុទ្ធថា ជាព្រះដ៏ជួយការពារ។ មិត្តអើយ ព្រះដ៏ជួយការពាររស់នៅក្នុងអ្នក ហើយនឹងមិនដែលចាកចេញពីអ្នកទេ។ តើអ្នកស្តាប់ទ្រង់ដែរឬទេ? អ្នកអាចយល់ស្របថា ព្រះជាម្ចាស់ប្រហែលជាមានចម្លើយសម្រាប់ស្ថានភាពណាមួយដែលអ្នកជួបប្រទះ។ ព្រះយេស៊ូមានបន្ទូលថា ព្រះដ៏ជួយការពារនេះ អាចបង្រៀនអ្នក ឬផ្តល់ឱវាទអំពីគ្រប់រឿងទាំងអស់ដល់អ្នក។ យោងតាមសៀវភៅ *Strong's Exhaustive Concordance of the Bible (3875)* ពាក្យជាភាសាក្រិចដែលបានបកប្រែថា ព្រះដ៏ជួយការពារ មានន័យថា ៖ ម្នាក់ដែល

ត្រូវបានកោះហៅ ឬត្រាស់ហៅដើម្បីគាំទ្រ ជាពិសេសត្រូវបានត្រាស់ហៅដើម្បីជួយនរណាម្នាក់។ វាក៏មានន័យថា អ្នកអង្វរជំនួសឱ្យម្នាក់ទៀតនៅពីមុខចៅក្រម មេធាវីការពារក្តី អ្នកជំនួយការផ្នែកច្បាប់ ឬអ្នកតស៊ូមតិ។ ក្នុងន័យទូលំទូលាយបំផុត ពាក្យនេះមានន័យថា អ្នកជំនួយ អ្នកនាំជំនួយ ឬអ្នកជំនួយការ។

**ព្រះយេស៊ូបានហៅព្រះវិញ្ញាណដ៏វិសុទ្ធថា ជាព្រះដ៏ជួយការពារ។ មិត្តអើយ ព្រះដ៏ជួយការពាររស់នៅក្នុងអ្នក ហើយនឹងមិនដែលចាកចេញពីអ្នកទេ។**

ខ្ញុំមិនដឹងអំពីអ្នកទេ ប៉ុន្តែសម្រាប់ខ្ញុំវិញ ខ្ញុំអាចប្រើជំនួយការម្នាក់បែបនេះបាន។ ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាចម្លើយរបស់លោកពេត្រុស នៅពេលដែលពួកគេបាននេសាទពេញមួយយប់ តែមិនបានអ្វីសោះ។ ហើយព្រះវិញ្ញាណដ៏វិសុទ្ធគឺជាចម្លើយរបស់ខ្ញុំ នៅពេលដែលខ្ញុំមិនដឹងថារកលុយមកពីណាដើម្បីសងបំណុលគេ។ បន្ទាប់ពីបានធ្វើឱ្យគ្រួសារខ្ញុំមានបញ្ហាហិរញ្ញវត្ថុអស់រយៈពេលជាច្រើនឆ្នាំ ហើយពេលដែលខ្ញុំស្វែងរកជំនួយពីព្រះជាម្ចាស់ ព្រះវិញ្ញាណដ៏វិសុទ្ធបានបង្ហាញខ្ញុំតាមរយៈសុបិនមួយ ឱ្យខ្ញុំចាកចេញពីក្រុមហ៊ុនដែលខ្ញុំកំពុងធ្វើការ ហើយចាប់ផ្តើមក្រុមហ៊ុនមួយដោយខ្លួនឯងពីបាតដៃទទេស្អាត។

ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រាប់ខ្ញុំអំពីបេសកកម្មរបស់ក្រុមហ៊ុនថ្មីរបស់ខ្ញុំ គឺដើម្បីប្រកាសពីភាពល្អរបស់ព្រះជាម្ចាស់ និងជួយមនុស្សឱ្យមានសេរីភាពពីបំណុល ដែលនៅពេលនោះខ្ញុំធ្លាប់គិតថា វាជាគំនិតដ៏ឆ្កួតលីលាបំផុត។ ខ្ញុំហ្នឹងជាអ្នកជួយគេឱ្យមានសេរីភាពពីបំណុល? ខ្ញុំគួរជាគំរូនៃការដែលមនុស្សមិនគួរធ្វើជាមួយលុយ។ ជីវិតរបស់ខ្ញុំប្រៀបដូចជាសុបិនអាក្រក់ផ្នែកហិរញ្ញវត្ថុ។ ក៏ប៉ុន្តែ នេះជាអ្វីដែលទ្រង់ប្រាប់ឱ្យខ្ញុំធ្វើ ដូច្នេះដោយសេចក្តីជំនឿ ឌ្រិនដា និងខ្ញុំបានបោះជំហានទៅមុខ ហើយបាននិយាយដូចអ្វីដែលលោកពេត្រុសបាននិយាយ។ «ព្រះអម្ចាស់អើយ! វាមិនសមហេតុផលទេ ក៏ប៉ុន្តែ ដោយសារទ្រង់មានបន្ទូលដូច្នេះ យើងនឹងធ្វើតាម»។ ដោយធ្វើតាមឱវាទរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ក្រុមហ៊ុនថ្មីនោះបានបន្តរីកចម្រើន ហើយបានផ្តល់ប្រាក់ដែលអាចឱ្យ ឌ្រិនដា និងខ្ញុំបានរួចពីបំណុលទាំងស្រុង។ ក្រុមហ៊ុននោះនៅតែមានដំណើរការពេលបច្ចុប្បន្ននេះ ឥឡូវនេះមានរយៈពេល ៣០ឆ្នាំហើយ ហើយវានៅតែផ្តល់ប្រាក់ចំណេញរាប់រយពាន់ដុល្លារក្នុងមួយឆ្នាំ។

នែ! ខ្ញុំមិនមែនជាមនុស្សឆ្លាតទេ ហើយអ្នកក៏មិនឆ្លាតដែរ ក៏ប៉ុន្តែព្រះជាម្ចាស់បានប្រទានព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីជួយអ្នកជាមួយនឹងចម្លើយដែលអ្នកត្រូវការក្នុងជីវិត។

ប៉ុន្តែដូចដែលយើងនឹងរៀនក្នុងសៀវភៅនេះ យើងមានផ្នែករបស់យើងដែលត្រូវធ្វើ ដោយធ្វើការរួមគ្នាជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឱ្យព្រះហឫទ័យរបស់ព្រះបានសម្រេច។

ជាអកុសល តាមរយៈបទពិសោធរបស់ខ្ញុំជាមួយមនុស្សជាច្រើន វាហាក់ដូចជាមានគ្រិស្តបរិស័ទជាច្រើនមិនមានចម្លើយសម្រាប់បញ្ហា ដែលពួកគេជួបប្រទះក្នុងជីវិតទេ។ ពួកគេហាក់ដូចជាគ្រាន់តែនេសាទត្រីទៅតាមសមត្ថភាពរបស់ពួកគេ ហើយបន្ទាប់ពីបាននេសាទពេញមួយយប់ ពួកគេមិនទទួលបានអ្វីសោះ ឬសឹងមិនបានទទួលអ្វីសោះ។ ពួកគេមិនធ្លាប់ដែលឮថា ព្រះវិញ្ញាណដ៏វិសុទ្ធមានវត្តមាននៅទីនេះ ដើម្បីជួយពួកគេក្នុងស្ថានភាពនីមួយៗរបស់ពួកគេនោះទេ។ បើទោះបីជាមានគ្រិស្តបរិស័ទភាគច្រើននិយាយថា «ព្រះជាម្ចាស់នឹងជួយខ្ញុំ ធ្វើកិច្ចការនេះ ឬធ្វើកិច្ចការនោះ» ពួកគេមិនបានយល់ថាទ្រង់ជួយពួកគេដោយរបៀបណា ឬមិនបានដឹងពីរបៀបឮចម្លើយដែលពួកគេត្រូវការទេ។ ដូច្នេះ មនុស្សជាច្រើនមិនបានដឹងថាពួកគេត្រូវតែធ្វើការជាមួយព្រះជាម្ចាស់ ដើម្បីសម្រេចបាននូវចម្លើយដែលពួកគេត្រូវការ ហើយពួកគេនៅតែរងចាំព្រះធ្វើអ្វីមួយទាក់ទងនឹងបញ្ហារបស់ពួកគេ នៅពេលចម្លើយមានស្រាប់រួចទៅហើយ គឺនៅក្នុងពួកគេ។

ឧទាហរណ៍ទាក់ទងនឹងរឿងលុយ មនុស្សនិយាយថាព្រះជាម្ចាស់នឹងចម្រុងចម្រើនខ្ញុំ។ ខ្ញុំនិយាយថា «អស្ចារ្យណាស់! តើព្រះជាម្ចាស់នឹងឱ្យលុយអ្នកដោយរបៀបណា?» ដំបូងពួកគេរៀងអាក់អន់ចិត្តនឹងខ្ញុំ ដែលសួរសំណួរបែបនេះដល់ពួកគេ វាហាក់ដូចជាខ្ញុំកំពុងតែសួរដេញដោលជំនឿរបស់ពួកគេ។ ប៉ុន្តែ ខ្ញុំនៅតែទទូចសួរ។ «តើនឹងបានលុយមកពីណា? តើព្រះជាម្ចាស់នឹងនាំវាមកឱ្យអ្នកដោយរបៀបណា?» នៅពេលខ្ញុំចុចរកចម្លើយពីពួកគេ ពួកគេមិនដឹងចម្លើយទេ។ វាមិនអីទេ បើអ្នកមិនដឹងចម្លើយក្នុងរយៈពេលខ្លី ប៉ុន្តែនៅទីបំផុត អ្នកត្រូវដឹងចម្លើយ។ អ្នកមិនអាចប្រមូលផលពីអ្វីដែលអ្នកមើលមិនឃើញនោះទេ។ សូមចាំថា ព្រះយេស៊ូមានភាពជាក់លាក់ណាស់ នៅពេលដែលទ្រង់មានបន្ទូលទៅកាន់លោកពេត្រុសថាត្រីនៅទីណា ហើយទ្រង់ថែមទាំងប្រាប់គាត់ពីរបៀបដែលចាប់វាផងដែរ៖ « ចូរទម្លាក់អួនរបស់អ្នក»។ នៅទីបំផុត អ្នកនឹងត្រូវដឹងពីកន្លែងដែលត្រូវទម្លាក់អួន ប្រសិនបើអ្នកចាប់ត្រី។

ដោយសារធម្មតាមនុស្សមានផ្នត់គំនិត ដែលខ្ញុំហៅវាថាជាផ្នត់គំនិតប្រអប់សំបុត្រ ពួកគេគ្រាន់តែគិតថា ព្រះជាម្ចាស់នឹងធ្វើកិច្ចការនេះឱ្យខ្ញុំ នោះជីវិតផ្នែកហិរញ្ញវត្ថុរបស់ពួកគេនៅតែមានភាពអាក់រអួល ទោះបី១០ ឬ២០ឆ្នាំក៏ដោយ អ្វីៗនៅតែដដែល គ្មាន

ការផ្លាស់ប្តូរទេ។ វាគួរឱ្យក្រៀមក្រំណាស់។ តើអ្នកចង់ដឹងថា ហេតុអ្វីបានជាពួកគេនៅតែដដែលទេ? គឺដោយសារតែពួកគេមិនដែលរៀនអំពីរបៀបនេសាទត្រីតាមបែបព្រះវិញ្ញាណដ៏វិសុទ្ធ ជារបៀបនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ពួកគេមិនបានដឹងពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធមានប្រតិបត្តិការនៅលើផែនដី ដើម្បីជួយពួកគេឱ្យទទួលបានជោគជ័យទេ។ ពួកគេមិនបានដឹងផ្នែកដែលពួកគេត្រូវធ្វើ និងផ្នែកដែលព្រះវិញ្ញាណដ៏វិសុទ្ធត្រូវធ្វើ ដើម្បីសម្រេចបាននូវជោគជ័យដែលពួកគេពិតជាត្រូវការយ៉ាងខ្លាំងនោះឡើយ។

វាដូចជាបុរសម្នាក់ដែលខ្ញុំបានឃើញពេលអាហារថ្ងៃត្រង់ថ្ងៃនេះ។ គាត់មានមាឌធំណាស់ ប្រហែល១៧០គីឡូ។ ជើងម្ខាងរបស់គាត់រុំប៉ង់ស៊ីម៉ង់ និងមានឈើច្រត់ពីរជាមួយគាត់។ គាត់កម្រើកស្ទើរមិនបាន។ បន្ទាប់ពីគាត់បានញ៉ាំឈីសបឺហ្គឺររបស់គាត់ហើយ គាត់បានកម្មង់នំផាយសណ្តែកដី។ ខ្ញុំអង្គុយទាំងស្លុតចិត្ត ពេលឮគាត់កម្មង់នំនោះ។ ខ្ញុំមិនដឹងថាគាត់កំពុងតែគិតអ្វីទេ ប៉ុន្តែគាត់គួរតែបានញ៉ាំនំនោះគ្រប់គ្រាន់ហើយ។ វាច្បាស់ណាស់ថា អ្វីដែលគាត់ញ៉ាំកំពុងតែសម្លាប់គាត់។ គាត់ខំប្រឹងក្រោកពីតុយ៉ាងលំបាក ហើយបានចេញពីភោជនីយដ្ឋានទៅយ៉ាងយឺតៗ។ នេះជារបៀបដែលខ្ញុំឃើញគ្រិស្តបរិស័ទរស់នៅសព្វថ្ងៃនេះ បានឮពីការសន្យា ប៉ុន្តែនៅបន្តបរិភោគថ្នាំពុល

ហើយឆ្ងល់ថា ហេតុអ្វីបានជាអ្វីៗមិនមានដំណើរការយ៉ាងដូច្នេះ។

**ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះជាម្ចាស់ គង់នៅក្នុងអ្នក ដើម្បីផ្តល់ចម្លើយដែលអ្នកត្រូវការ។**

មិត្តអើយ អ្នកមានចម្លើយ! ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះជាម្ចាស់ គង់នៅក្នុងអ្នក ដើម្បីផ្តល់ចម្លើយដែលអ្នកត្រូវការ។ មនុស្សសួរខ្ញុំថា

តើពួកគេគួររៀបការជាមួយអ្នកណា ស៊ូសាន ឬសាលី? តើគេគួរធ្វើការងារនេះ ឬការងារនោះ? តើគេគួរផ្លាស់ទីលំនៅ ឬនៅកន្លែងដដែល? គួរលក់ ឬទិញភាគហ៊ុនរបស់ពួកគេ? ព្រះវិញ្ញានដ៏វិសុទ្ធដែលគង់ក្នុងអ្នកមានចម្លើយ។ ជាថ្មីម្តងទៀត នេះគឺជាគោលបំណងនៃសៀវភៅនេះ គឺដើម្បីរៀនអំពីរបៀបព្រះវិញ្ញាណដ៏វិសុទ្ធជួយយើង និងរបៀបព្រះរាជ្យនៃព្រះមានប្រតិបត្តិការ ទាក់ទងនឹងការឮព្រះសូរសៀងព្រះជាម្ចាស់។

ដូច្នេះខ្ញុំសូមរំលឹកឡើងវិញ។

**អ្នកណាក៏អាចចាប់ត្រីបានដែរ ប្រសិនបើព្រះយេស៊ូប្រាប់ពួកគេពីទីកន្លែងរបស់ត្រី និងរបៀបចាប់ត្រី សូម្បីតែអ្នក!**

ឃែរ៉ូលពន្យល់នៅក្នុងអ៊ីមែលនេះ អំពីរបៀបដែលជីវិតរបស់គាត់បានផ្លាស់ប្តូរ។

*នៅថ្ងៃនេះកាលពីឆ្នាំមុន ខ្ញុំបានទិញអំណោយបុណ្យណូអែលដោយប្រើកាតឥណទាន រហូតដល់កម្រិតកំណត់ ព្រោះខ្ញុំមិនមានលុយជាសាច់ប្រាក់ ដើម្បីទិញអំណោយសម្រាប់កូនស្រីរបស់ខ្ញុំ ដែលនៅតែជឿលើតាសាន់តាក្លូសទេ។ ខ្ញុំរស់នៅក្នុងក្តីថប់បារម្ភ និងទុក្ខព្រួយឥតឈប់ឈរ ហើយខ្ញុំបានសរសេរទៅកាន់លោកគ្រូគង្វាលហ្គារីថា រឿងដែលសាបព្រោះនោះមិនមានដំណើរការទេ គ្មានអ្វីបានកើតឡើងឡើយ។ គាត់បានឆ្លើយតបយ៉ាងអត់ធ្មត់ ឱ្យខ្ញុំរង់ចាំ គាត់ប្រាប់ថាការច្រូតកាត់ត្រូវការពេលវេលា ហើយជាធម្មតាមិនកើតឡើងនៅថ្ងៃបន្ទាប់ទេ។*

*ឥឡូវថ្ងៃនេះ មួយឆ្នាំក្រោយមក ខ្ញុំអាចទិញអំណោយសម្រាប់គ្រួសារខ្ញុំដោយប្រើសាច់ប្រាក់។ ខ្ញុំទិញអំណោយដែលមានតម្លៃ ៣០០ ឬ៤០០ដុល្លារ ដើម្បីផ្តល់កិត្តិយសដល់មនុស្សមួយចំនួនដែលបានជួយខ្ញុំក្នុងគ្រាលំបាក។ កាលពីឆ្នាំមុន ខ្ញុំរស់នៅបន្ទប់ជាន់ក្រោមដី ដែលមិត្តភក្តិមួយចំនួនបានអនុញ្ញាតឱ្យខ្ញុំស្នាក់នៅរយៈពេលពីរបីខែ។ ខ្ញុំមិនមានលុយសម្រាប់ទិញអាហារ ឬចាក់សាំងទេ។ ប៉ុន្តែពេលនេះ ខ្ញុំរស់នៅក្នុងអផាតមិនដ៏ស្រស់ស្អាត យ៉ាងប្រណិតមួយ ហើយទូទឹកកករបស់ខ្ញុំពេញទៅដោយអាហារ។*

*ថ្ងៃទី៣ ខែធ្នូ ជាថ្ងៃខួបកំណើតកូនស្រីរបស់ខ្ញុំ ហើយយើងបាននាំគាត់ទៅឧទ្យានហ៊ើសស៊ី ក្នុងរដ្ឋផិនស៊ីលវេញ៉ា។ យើងបានអញ្ជើញមិត្តភក្តិល្អបំផុតរបស់គាត់ទៅជាមួយយើងដែរ ពួកយើងបានស្នាក់នៅសណ្ឋាគារហ៊ើសស៊ី ហើយយើងបានចេញថ្លៃចំណាយទាំងអស់ជាសាច់ប្រាក់។ ឆ្នាំនេះខ្ញុំអាចទិញអំណោយដ៏ល្អអស្ចារ្យសម្រាប់គាត់ ដែលមានតម្លៃជាង៤០០ដុល្លារ ឆ្នាំមុនមានមនុស្សម្នាក់ធ្វើឱ្យខ្ញុំអាម៉ាស់មុខ ដោយឱ្យលុយខ្ញុំ៣០ដុល្លារ ដើម្បីអបអរថ្ងៃកំណើតរបស់កូនស្រីខ្ញុំ។*

*ខ្ញុំមិនអាចសរសេររៀបរាប់ដោយមិនយំបានទេ។ ខ្ញុំពិតជាមានចិត្តដឹងគុណចំពោះលោកគ្រូគង្វាលហ្គារី និងភរិយារបស់គាត់ ឌ្រិនដា។ ឆ្នាំនេះគឺជាឆ្នាំដ៏ល្អបំផុតនៃជីវិតរបស់ខ្ញុំ។ អ្វីៗដែលព្រះជាម្ចាស់បានធ្វើក្នុងជីវិតរបស់ខ្ញុំ ពិតជាអស្ចារ្យ*

*ខ្លាំងណាស់។ ខ្ញុំអាចសរសេរសៀវភៅមួយក្បាល រៀបរាប់រឿងរ៉ាវទាំងអស់របស់ខ្ញុំ។ អរគុណដែលបានបង្រៀនខ្ញុំ ឱ្យខ្ញុំរស់នៅស្ថានសួគ៌នៅលើផែនដីនេះ។*

អ៊ីមែលខាងក្រោមគឺជារឿងមួយក្នុងចំណោមរឿងដ៏អស្ចារ្យបំផុតជាច្រើន នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលខ្ញុំធ្លាប់ឮ។ វាមកពីសារ៉ុន នៅរដ្ឋមីឈីហ្គែន។

*លោកគ្រូគង្វាលហ្គារី ខ្ញុំសរសេររឿងនេះក្នុងនាមស្វាមីរបស់ខ្ញុំ និងខ្ញុំផ្ទាល់។ ខ្ញុំគ្រាន់តែចង់ថ្លែងអំណរគុណចំពោះលោកគ្រូ ពីព្រោះលោកគ្រូ និងភរិយារបស់លោកគ្រូពិតជាបានជម្រុញទឹកចិត្តពួកយើងខ្លាំងមែនទែន។ ពួកយើងបានឮពីលោកគ្រូតាមរយៈកម្មវិធីស៊ីដវ័ត្ន ប្រហែលបីឬបួនឆ្នាំមុន។ យើងកំពុងតែឆ្លងកាត់គ្រាដ៏លំបាកមួយ។ ស្វាមីរបស់ខ្ញុំត្រូវបានគេបញ្ឈប់ពីការងាររបស់គាត់បន្ទាប់ពីបានធ្វើការរយៈពេល១៨ឆ្នាំ ហើយយើងទើបតែសាងសង់ផ្ទះតម្លៃ២៨ម៉ឺនដុល្លារ ពេលរឿងនេះកើតឡើង។ យើងជំពាក់បំណុលគេវ៉ែនករ និងមានការតានតឹងចិត្តជាខ្លាំង។*

*យើងបានកម្មង់ទិញស៊ីឌីរបស់លោកគ្រូ ហើយវាបានជួយយើងឆ្លងកាត់ការលំបាកមួយនេះ។ យើងបានរៀនពីរបៀបដែលបំណុលអាចធ្វើឱ្យខូច និងប៉ះពាល់ដល់សុខភាព និងជីវិតរបស់មនុស្សយ៉ាងខ្លាំង។ យើងមើលមិនឃើញផ្លូវចេញទេ។ ទោះបីជាយើងមិនអាចបង់លុយសម្រាប់ផ្ទះថ្មីរបស់យើង យើងនៅតែអាចរស់នៅក្នុងផ្ទះនោះរយៈពេលពីរឆ្នាំមុនពេលយើងត្រូវរើចេញ។ វាជាព្រះពរមួយរបស់យើង។*

*ប៉ុន្តែ ដើម្បីសង្ខេបរឿងរបស់យើងឱ្យខ្លី ស្វាមីរបស់ខ្ញុំបានទទួលការងាររបស់គាត់ត្រលប់មកវិញ បន្ទាប់ពីរយៈពេល៨ឆ្នាំ ព្រោះគាត់នៅរក្សាជំនឿ ហើយជឿលើការសន្យារបស់ព្រះជាម្ចាស់ ព្រមទាំងជំនួយពីលោកគ្រូ និងភរិយារបស់លោកគ្រូតាមរយៈការស្តាប់ស៊ីឌីរបស់លោកគ្រូ។ ស្វាមីរបស់ខ្ញុំទទួលបានការងារចាស់របស់គាត់ត្រលប់មកវិញ ព្រមទាំងទទួលបានប្រាក់ឈ្នួលសម្រាប់រយៈពេល៨ឆ្នាំនោះផងដែរ! មិនមានពាក់ព័ន្ធជាមួយមេធាវី ឬផ្លូវច្បាប់អីនោះទេ។ គាត់ក៏ទទួលបានពេលវិស្សមកាលរយៈពេល៨ឆ្នាំរបស់គាត់ទាំងអស់មកវិញផងដែរ។ តាមពិតទៅពេលពួកគេជួលគាត់ត្រលប់ទៅធ្វើការវិញ រឿងដំបូងដែលពួកគេឱ្យគាត់ធ្វើ គឺត្រូវទៅវិស្សមកាល! វាប្រសើរខ្លាំងណាស់ យើងអាចបង់លុយជាសាច់ប្រាក់ សម្រាប់*

*ផ្ទះថ្មីដែលល្អប្រសើរជាងផ្ទះមុន ដែលយើងបានបាត់បង់ទៅទៀត តាមរយៈលុយសំណងរបស់ក្រុមហ៊ុនគាត់។ សូមអរគុណសម្រាប់អ្វីដែលលោកគ្រូបានធ្វើ។*

អេនឌ្រូ មកពីរដ្ឋមីស៊ូរី

*កាលពីពីរឆ្នាំមុននៅខែឧសភា ខ្ញុំស្ថិតក្នុងស្ថានភាពដ៏លំបាកមួយ។ ខ្ញុំមិនពេញចិត្តនឹងការងារពីមុនរបស់ខ្ញុំទេ ហើយបានទទួលយកមុខតំណែងថ្មីក្នុងផ្នែកលក់នៅខាងក្រៅ។ អ្នកទូទាត់វិក័យប័ត្របានទូរស័ព្ទមកខ្ញុំ ខ្ញុំស្ទើរតែមិនមានប្រាក់គ្រប់គ្រាន់សម្រាប់ចាក់សាំង និងទិញអាហារ ចុងបញ្ចប់នៃខែក៏ជិតមកដល់ហើយក៏ត្រូវបង់ថ្លៃជួលផ្ទះផងដែរ។ អ្វីដែលខ្ញុំមាននៅពេលនោះគឺស៊ីឌីមួយឈុតរបស់លោកគ្រូហ្គារី ស៊េរីបដិវត្ត ២.០។ ថ្ងៃមួយខ្ញុំកំពុងអង្គុយក្នុងវេនថ្វាយបង្គំមួយ ហើយមានចិត្តចង់សាបព្រោះ ប៉ុន្តែខ្ញុំមានលុយតែ២៣ដុល្លារតែប៉ុណ្ណោះ ហើយមានសាំងស្ទើរតែមិនគ្រប់គ្រាន់សម្រាប់ឆ្លងកាត់សប្តាហ៍នោះ។ ការងារក៏មានដំណើរការមិនសូវល្អ ខ្ញុំបានប្រាប់ទ្រង់ថា ខ្ញុំចង់សាបព្រោះ ប៉ុន្តែខ្ញុំមិនមានលុយទេ។ ខ្ញុំបានឮសម្លេងមួយចេញពីក្នុងខ្លួនខ្ញុំថា យើង (ព្រះជាម្ចាស់) អាចធ្វើអ្វីច្រើនជាងឯង ជាមួយប្រាក់២៣ដុល្លារដែលឯងមាន។ ព្រះអង្គបានដោះស្រាយជាមួយខ្ញុំ ហើយខ្ញុំបានសាបព្រោះ២០ដុល្លារ ដោយជឿជាក់ថានឹងទទួលបានផលល្អត្រលប់មកវិញ។*

*ថ្ងៃព្រហស្បតិ៍សប្តាហ៍នោះ ខ្ញុំបានជួយការងាររបស់បុគ្គលិកម្នាក់ ដែលកំពុងតែបម្រើសេវាកម្មរបស់យើង។ ខ្ញុំសុខចិត្តជួយ ទោះបីខ្ញុំមិនទទួលបានអ្វីច្រើនត្រលប់មកវិញ ពេលដែលយើងលក់បានផលិតផលអ្វីក៏ដោយ។ នៅចុងបញ្ចប់នៃថ្ងៃនោះ អ្នកគ្រប់គ្រងរបស់ខ្ញុំបាននិយាយថា គាត់កោតសរសើរចំពោះការជួយរបស់ខ្ញុំ ហើយថាខ្ញុំអាចទទួលបានកម្រៃពីការលក់ទាំងអស់នៅថ្ងៃនោះ (ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា វាមិនគ្រាន់ត្រឹមតែកម្រៃជើងសារពីការលក់នោះទេ)។ តើអ្នកដឹងទេ? ប្រាក់ចំណេញសរុបដែលខ្ញុំទទួលបានគឺ... ២០០០ដុល្លារ!!! ខ្ញុំទទួលបាន១០០ដងត្រលប់មកវិញ ក្នុងរយៈពេលតិចជាងមួយសប្តាហ៍!*

*ព្រះជាម្ចាស់ពិតជាស្មោះត្រង់ ហើយអ្វីដែលតិចក្លាយទៅជាច្រើននៅពេលទ្រង់គង់ក្នុងការនោះ។ ចាប់តាំងពីពេលនោះមក ខ្ញុំឧស្សាហ៍ព្យាយាម ក្នុងការថ្វាយដង្វាយ*

*មួយភាគដប់ និងដង្វាយដទៃទៀត ដោយចិត្តរីករាយ និងរំពឹងថានឹងមានភាពចម្រុងចម្រើន។*

*ពីរបីខែបន្ទាប់ពីរឿងនេះបានកើតឡើង ខ្ញុំទទួលបានព្រះពរដោយទទួលបានមុខតំណែងថ្មី ដូចអ្វីដែលខ្ញុំសាបព្រោះចង់បាន។ ប្រាក់ចំណូលរបស់ខ្ញុំបានកើនឡើង ៤ដង ក្នុងរយៈពេលតែពីរឆ្នាំប៉ុណ្ណោះ។ សូមសរសើរតម្កើងព្រះជាម្ចាស់ ហើយទ្រង់សាកសមនឹងទទួលបានសេរីល្អទាំងអស់។ ទីបន្ទាល់តូចមួយទៀត៖ ធនាគារលែងជាម្ចាស់ឡានរបស់ខ្ញុំហើយ ហើយខ្ញុំកំពុងតែបើករថយន្តថ្មីស្រឡាងមួយគ្រឿង ដែលបានបង់ថ្លៃរួចរាល់ហើយ!!!*

នេះគឺជាទីបន្ទាល់ពីប្រទេសកូរ៉េ៖

*ជូនចំពោះលោកគ្រូគង្វាលហ្គារី*

*ខ្ញុំធ្លាប់រស់ក្នុងជីវិតដែលគ្មានគោលបំណង និងមិនអាចទិញអ្វីបានដោយខ្លួនឯងទេ។ ខ្ញុំធ្លាប់រស់នៅដោយការទទួលអំណោយ ហើយនៅពេលដែលមនុស្សគុញទ្រាន់ក្នុងការជួយដល់ខ្ញុំ អ្វីដែលខ្ញុំសង្ឃឹមទទួលបាន គឺនំមួយកញ្ចប់ និងទឹកក្រូចកូកាមួយដបតែប៉ុណ្ណោះ។ នេះជាអ្វីដែលខ្ញុំអាចមានលទ្ធភាពផ្តល់ឱ្យខ្លួនឯង និងកូនតូចៗពីរនាក់ទៀត។ ខ្ញុំមិនមានលទ្ធភាពបង់ថ្លៃជួលផ្ទះ ឬវិក័យប័ត្ររបស់យើងទេ។ ខ្ញុំនៅតែអាចចាំបាន ពេលដំបូងដែលខ្ញុំបានមើលការផ្សាយបន្តផ្ទាល់វេនថ្វាយបង្គំរបស់ក្រុមជំនុំជីវិតនៃសេចក្តីជំនឿ។ ខ្ញុំបានពន្យល់លោកគ្រូគង្វាលតាមអនឡាញរបស់លោកគ្រូ អំពីស្ថានភាពដ៏លំបាករបស់ខ្ញុំ ហើយអ្វីដែលគាត់បាននិយាយគឺ ខ្ញុំត្រូវសុំព្រះជាម្ចាស់ឱ្យបង្ហាញខ្ញុំអំពីរបៀប និងកន្លែងដែលត្រូវចាប់ត្រី ដូចដែលទ្រង់បានបង្ហាញលោកពេត្រុស នៅពេលដែលគាត់ត្រូវបង់ពន្ធ។ ដើម្បីសង្ខេបរឿងនេះឱ្យខ្លី ពេលនេះខ្ញុំជាម្ចាស់ភោជនីយដ្ឋានអាហ្វ្រិកមួយ និងហាងកាត់សក់មួយ ដោយសារបានស្តាប់ការបង្រៀនរបស់លោកគ្រូគង្វាលហ្គារី។ សូមសរសើរតម្កើងដល់ព្រះជាម្ចាស់!*

ទាំងនេះគឺជាទីបន្ទាល់ដ៏អស្ចារ្យ! ប៉ុន្តែអ្នកអាចនិយាយថា «វាពិតជាអស្ចារ្យណាស់លោកគ្រូហ្គារី។ ពិតណាស់ អ្វីៗមានដំណើរការល្អសម្រាប់មនុស្សដទៃ តែវាមិនមានដំណើរការល្អសម្រាប់ខ្ញុំទេ»។ បាទ រឿងរបស់អ្នកមិនចប់ត្រឹមតែប៉ុណ្ណឹងទេ! ខ្ញុំសូមសួរអ្នកមួយសំណួរ។ ពេលដែលអ្នកកំពុងតែអង្គុយអានសៀវភៅនេះជំពូកនេះ តើអ្នកកំពុងតែតោងកៅអី

អ្នកយ៉ាងខ្លាំង ដោយភ័យខ្លាចថាអ្នកនឹងអណ្តែតត្រសែតទៅឆ្ងាយទេ? អត់ទេ មិនអីចឹងទេ។ ហេតុអ្វី? ដោយសារអ្នកយល់អំពីច្បាប់ទំនាញផែនដី ហើយអ្នកដឹងថា វាមានប្រសិទ្ធភាពដូចគ្នា សម្រាប់មនុស្សគ្រប់គ្នា។ មែនហើយ ព្រះរាជ្យរបស់ព្រះជាម្ចាស់មានដំណើរការដូចគ្នា។ អ្នកអាចរៀនច្បាប់ទាំងនេះបាន។ អ្នកអាចរៀនស្តាប់យុទ្ធសាស្ត្រល្អឯក ដែលនឹងធ្វើឱ្យជីវិតរបស់អ្នកក្លាយជាទីបន្ទាល់នៃអំណាចរបស់ព្រះជាម្ចាស់។ យើងបានបញ្ជាក់រួចហើយថា ជាការយល់ដឹង និងជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនាំឱ្យការអស្ចារ្យទាំងនេះកើតមានឡើង។ ដូច្នេះ សូមចាប់ផ្តើមដំណើររបស់យើងជាមួយនឹងការរំលឹកឡើងវិញអំពីមូលដ្ឋានគ្រឹះនៃព្រះវិញ្ញាណដ៏វិសុទ្ធ បន្ទាប់មកយើងនឹងស្វែងយល់លម្អិតអំពីការឮយុទ្ធសាស្ត្រដែលយើងត្រូវការ។

# ជំពូក ៤

# មូលដ្ឋានគ្រឹះ៖ កុំទាន់ចេញពីផ្ទះឱ្យសោះ ប្រសិនបើអ្នកគ្មានវាទេ

ប្រសិនបើអ្នកចង់ដឹកនាំជីវិតប្រកបដោយយុទ្ធសាស្ត្រនៃព្រះវិញ្ញាណដ៏វិសុទ្ធ និងការណែនាំពីព្រះវិញ្ញាណទៅរកភាពជោគជ័យ ជាដំបូងអ្នកត្រូវតែកើតជាថ្មី បន្ទាប់មកអ្នកត្រូវជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ពិតណាស់ កិច្ចការទាំងពីរនេះជាកិច្ចការពីរផ្សេងគ្នា តែក្នុងព្រះវិញ្ញាណតែមួយ។ ប្រសិនបើអ្នកយល់ថា រឿងនេះជារឿងចម្លែកចំពោះអ្នក វាមិនអីទេ។ ខ្ញុំនឹងពន្យល់ប្រាប់អ្នក។ ប៉ុន្តែខ្ញុំចង់និយាយឱ្យត្រង់ថា ព្រះយេស៊ូបានមានបន្ទូលថា វាជាការសំខាន់ខ្លាំងណាស់ ក្នុងការទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលទ្រង់បានបញ្ជាក់ថា កុំទាន់ទៅណាឆ្ងាយ ប្រសិនបើមិនទាន់បានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធទេនោះ! ទ្រង់មានបន្ទូលយ៉ាងដូច្នេះក្នុងសៀវភៅ កិច្ចការ ១:៤-៥។

> *ទ្រង់ហាមគេមិនឱ្យចេញទៅណាឆ្ងាយពីក្រុងយេរូសាឡឹមឡើយ «គឺត្រូវរង់ចាំទទួលព្រះវិញ្ញាណ តាមព្រះបន្ទូលសន្យារបស់ព្រះបិតា ដូចខ្ញុំបានប្រាប់អ្នករាល់គ្នារួចមកហើយថា លោកយ៉ូហានបានធ្វើពិធីជ្រមុជឱ្យគេក្នុងទឹក ប៉ុន្តែ នៅប៉ុន្មានថ្ងៃទៀត អ្នករាល់គ្នានឹងទទួលពិធី<u>ជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ</u>វិញ»។*

កិច្ចការ ១:៤-៥

> *ប៉ុន្តែ អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី»។*

កិច្ចការ ១:៨

**បនិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

ចូរកត់សម្គាល់ ព្រះយេស៊ូមានព្រះបន្ទូលថា «កុំទាន់ចេញទៅណាឆ្ងាយ ប្រសិនបើមិនទាន់បានទទួលការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធទេនោះ។ ការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធពិតជាចាំបាច់ខ្លាំងណាស់!» ជាទូទៅ ទ្រង់ចង់មានបន្ទូលថា «អ្នកត្រូវការអំណាចរបស់ទ្រង់ ដើម្បីធ្វើកិច្ចការរបស់ព្រះជាម្ចាស់ ធ្វើជាបន្ទាល់របស់ព្រះរាជ្យនៃព្រះ។» រហូតមកដល់សព្វថ្ងៃនេះ មានគ្រិស្តបរិស័ទជាច្រើនដែលមិនទាន់បានឮ ឬធ្លាប់ទទួលបទពិសោធនៃពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនេះទេ។ ហើយក៏មានគ្រិស្តបរិស័ទជាច្រើនទៀតដែលបានធំឡើងនៅក្នុងក្រុមជំនុំ ប៉ុន្តែនៅតែមិនទាន់បានឮអំពីតម្រូវការនៃការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ឬពួកគេធំឡើងនៅក្នុងក្រុមជំនុំ ហើយត្រូវបានគេប្រាប់ថា ពិធីជ្រមុជនេះមិនមែនសម្រាប់អ្នកជឿពេលបច្ចុប្បន្នទេ ហើយការអស្ចារ្យបានកន្លងផុតហើយ។

ខ្ញុំបានធំឡើងនៅក្នុងក្រុមជំនុំបែបនេះ ហើយមិនដែលធ្លាប់ឮអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធទេ។ ខ្ញុំក៏ទទួលបានអ៊ីមែលជាច្រើនពីមនុស្សនៅទូទាំងពិភពលោកដែលមិនទាន់បានឮអំពីសេចក្តីពិតដ៏មានឥទ្ធិពលនេះទេ។ ពួកគេបានសួរអំពីសុពលភាពនៃឫទ្ធិអំណាចនេះក្នុងពេលបច្ចុប្បន្ន ហើយនេះជាមូលហេតុដែលខ្ញុំបានឆ្លៀតពេល ដើម្បីសរសេរអំពីសេចក្តីពិតទាក់ទងនឹងពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។

ខ្ញុំជឿថាព្រះគម្ពីរបានចែងយ៉ាងច្បាស់ទាក់ទងនឹងរឿងនេះ ហើយខ្ញុំទុកឱ្យព្រះគម្ពីរបញ្ជាក់ដោយខ្លួនឯង។ ព្រះគម្ពីរនឹងឆ្លើយសំណួរទាំងអស់របស់អ្នក។ ប៉ុន្តែ ជាដំបូងខ្ញុំចង់ប្រាប់អ្នកអំពីប្រវត្តិដែលខ្ញុំបានរកឃើញសេចក្តីពិតអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនេះសិន។

កាលពីវ័យក្មេង ខ្ញុំស្រេកឃ្លានព្រះជាម្ចាស់ (ខ្ញុំនៅតែស្រេកឃ្លានទ្រង់ដដែលទេ គ្រាន់តែពេលនេះខ្ញុំកើនវ័យច្រើនជាងមុន) ហើយខ្ញុំបានចូលរួមក្រុមជំនុំមួយ។ យើងបានធ្វើតាមទម្លាប់សាសនាជាធម្មតារៀងរាល់ព្រឹកថ្ងៃអាទិត្យ។ ប្រហែលអ្នកក៏ធ្លាប់ធ្វើដូច្នេះដែរ។ ខ្ញុំនៅចាំបទចម្រៀងពីរបីបទ ដែលអមដោយការស្ងប់ស្ងាត់មួយភ្លែត បន្ទាប់មកយើងអធិស្ឋានតាមការអធិស្ឋានរបស់ព្រះយេស៊ូ ហើយបន្ទាប់មកគ្រូគង្វាលអធិប្បាយ ហើយយើងច្រៀងបទចម្រៀងចុងក្រោយ និងបញ្ចប់ដោយការអធិស្ឋានប្រសិទ្ធិពរ។ គ្រប់វេនថ្វាយបង្គំទាំងអស់មានលំនាំបែបនេះដូចគ្នា។

មនុស្សនៅក្រុមជំនុំជាមនុស្សល្អ ហើយពួកគេពិតជាស្រលាញ់ព្រះជាម្ចាស់ខ្លាំងណាស់។ ប៉ុន្តែ ខ្ញុំពិតជាមិនដែលបានឃើញសេចក្តីពិតនៃដំណឹងល្អទេ។ ខ្ញុំមិនធ្លាប់បាន

ឃើញមនុស្សទទួលការផ្លាស់ប្រែយ៉ាងខ្លាំង ឬទទួលបានការព្យាបាលដោយអំណាចរបស់ទ្រង់ទេ។ ខ្ញុំគិតថា ខ្ញុំអាចនិយាយបានថា ខ្ញុំមិនធ្លាប់បានឃើញការបង្ហាញជាច្រើនអំពីលក្ខណៈរបស់ព្រះរាជ្យព្រះជាម្ចាស់ទេ។

កាលនោះ ខ្ញុំមានអាយុប្រមាណ១៨ឆ្នាំ ខ្ញុំស្រេកឃ្លានព្រះជាម្ចាស់ជាខ្លាំង ហើយខ្ញុំមើលការខុសត្រូវលើហាងតីហ្សារបស់ឪពុកខ្ញុំ។ នៅយប់មួយមានបុរសម្នាក់បានចូលក្នុងហាងតីហ្សារបស់យើង ហើយបានអញ្ជើញខ្ញុំឱ្យចូលរួមកម្មវិធីគ្រិស្តបរិស័ទមួយ។ គេធ្វើកម្មវិធីនោះនៅក្រុមជំនុំមេតូឌីស្ទដ៏តូចមួយនៅក្នុងភូមិរបស់ខ្ញុំ ហើយវាគ្មិននៃកម្មវិធីនោះ គឺជាអ្នកផ្សាយដំណឹងល្អដែលបាននិយាយអំពីកិច្ចការដែលព្រះយេស៊ូកំពុងធ្វើនាពេលបច្ចុប្បន្ននេះ ដូចកិច្ចការដែលទ្រង់ធ្លាប់ធ្វើនៅក្នុងព្រះគម្ពីរដែរ។

ពេលខ្ញុំបានឮដូច្នោះ ខ្ញុំបានចាប់អារម្មណ៍ជាខ្លាំង ដោយសារខ្ញុំចង់ឃើញការទាំងអស់នោះកើតឡើង។ មានមិត្តភក្តិពីរបីនាក់របស់ខ្ញុំចូលរួមក្រុមជំនុំនេះ ដូច្នេះទើបខ្ញុំសម្រេចចិត្តមកចូលរួមកម្មវិធីនេះ។ ទោះបីខ្ញុំមិនបានឮអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនៅយប់នោះក៏ដោយ តែខ្ញុំបានទទួលអារម្មណ៍យ៉ាងខ្លាំងអំពីព្រះវត្តមានរបស់ព្រះជាម្ចាស់ក្នុងពេលថ្វាយបង្គំយប់នោះ។ មិត្តភក្តិរបស់ខ្ញុំដែលចូលរួមក្រុមជំនុំនោះ បានលើកទឹកចិត្តខ្ញុំឱ្យត្រលប់មកចូលរួមវេនថ្វាយបង្គំថ្ងៃអាទិត្យទៀត ហើយខ្ញុំក៏បានមកចូលរួម។ ខ្ញុំបាក់ចិត្តស្រលាញ់ក្រុមជំនុំនោះ ហើយក៏សម្រេចចិត្តយកក្រុមជំនុំនោះជាក្រុមជំនុំថ្មីរបស់ខ្ញុំ។

ពីរបីសប្តាហ៍បន្ទាប់ពីកម្មវិធីនោះមក ខ្ញុំបានជួបក្រុមស្ត្រីមួយក្រុមដែលចូលរួមក្រុមជំនុំនោះដែរ ហើយពួកគេមានក្រុមការសិក្សាព្រះគម្ពីរមួយជារៀងរាល់សប្តាហ៍។ ពួកគេកំពុងតែនិយាយអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះអំណោយទានខាងវិញ្ញាណ និងរឿងរ៉ាវផ្សេងៗទៀតដែលខ្ញុំមិនធ្លាប់បានឮពីមុនមក។ ខ្ញុំពិតជាចង់ដឹងអំពីឫទ្ធានុភាពនៃព្រះវិញ្ញាណដែលពួកគេបាននិយាយ ហើយខ្ញុំបានសុំពួកគេចូលរួមការសិក្សាព្រះគម្ពីរជាមួយពួកគេដែរ។ ពួកគេជួបជុំសិក្សាព្រះគម្ពីរនៅពេលព្រឹក ហើយដោយសារខ្ញុំធ្វើការនៅហាងតីហ្សាពេលយប់ ដូច្នេះខ្ញុំក៏អាចចូលរួមការសិក្សាព្រះគម្ពីរជាមួយពួកគេបាន។

នៅពេលខ្ញុំទៅដល់ទីនោះ ខ្ញុំបានឃើញថា ខ្ញុំពិតជាបុរសតែម្នាក់នៅទីនោះ ហើយក៏មានតែខ្ញុំម្នាក់គត់ដែលមានអាយុ១៨ឆ្នាំ តែវាមិនសំខាន់ចំពោះខ្ញុំទេ។ ខ្ញុំបានចូលរួមក្រុមសិក្សាព្រះគម្ពីរនោះ ដោយសារខ្ញុំស្រេកឃ្លានព្រះជាម្ចាស់ ហើយខ្ញុំបានសួរសំណួរជាច្រើន។

**បនិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

ស្ត្រីទាំងនោះបានអត់ធ្មត់ជាមួយខ្ញុំ ហើយបានចំណាយពេលពន្យល់ខ្ញុំតាមបទគម្ពីរ និងបានបង្ហាញខ្ញុំនៅក្នុងព្រះគម្ពីរ*របស់ខ្ញុំ*ថា ពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធគឺនៅមានក្នុងពេលបច្ចុប្បន្ននេះ ហើយឫទ្ធិអំណាចរបស់ព្រះជាម្ចាស់ក៏នៅតែមានពេលបច្ចុប្បន្ននេះ ដូចជាពេលដែលព្រះយេស៊ូធ្លាប់រស់នៅលើផែនដីនេះផងដែរ។ ផ្នែកដ៏ល្អបំផុតដែលពួកគេបានប្រាប់ខ្ញុំគឺ អ្នកជឿ*ទាំងអស់*អាចទទួលពីធីនេះ ហើយពិធីនេះគឺសម្រាប់អស់អ្នកដែលចង់បានវា។

បន្ទាប់ពីខ្ញុំបានចូលរួមការសិក្សាព្រះគម្ពីរពីរបីសប្តាហ៍ក្រោយមក ពួកគេបានប្រាប់ខ្ញុំថាព័ន្ធកិច្ចមួយដែលមានឈ្មោះថា ស្ត្រីចែងចាំង បានរៀបចំការប្រជុំទូទាំងទីក្រុងមួយ។ ព័ន្ធកិច្ចស្ត្រីចែងចាំងនេះធ្លាប់ជា និងនៅតែជាអង្គការមួយដែលបង្រៀនអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ស្ត្រីក្នុងក្រុមការសិក្សាព្រះគម្ពីររបស់ខ្ញុំមានគម្រោងចូលរួមការប្រជុំនេះ ហើយពួកគេបានអញ្ជើញខ្ញុំឱ្យចូលរួមជាមួយពួកគេដែរ។ កាលសម័យនោះ មនុស្សមកពីគ្រប់និកាយទាំងអស់បានជួបជុំគ្នាដើម្បីស្តាប់ និងរីករាយជាមួយនឹងពិធីនេះ ហើយរហូតមកដល់ពេលនោះ គឺមានតែក្រុមជំនុំផេនធីខស់ទេដែលនិយាយអំពីពិធីនេះ។ វាជាសម័យដែលមនុស្សជាច្រើនហៅពិធីនេះថា ការបំពេញជាថ្មីដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលគ្រប់និកាយទាំងអស់យល់ស្របអំពីការបង្រៀនអំពីព្រះវិញ្ញាណដ៏វិសុទ្ធ។

នៅពេលខ្ញុំចូលរួមការប្រជុំរបស់ព័ន្ធកិច្ចស្ត្រីចែងចាំងនោះ ខ្ញុំបានឃើញស្ត្រីរាប់រយនាក់បានមកជួបជុំគ្នា។ ជាថ្មីម្តងទៀត ខ្ញុំគឺជាបុរសតែម្នាក់គត់ដែលបានចូលរួមការប្រជុំនោះ ហើយខ្ញុំក៏មានអារម្មណ៍ដឹងអំពីព្រះវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងបន្ទប់ប្រជុំនោះ។

ខ្ញុំមានអារម្មណ៍ប្លែកអស្ចារ្យ ពេលដែលឃើញមនុស្សទទួលបានការព្យាបាលពីព្រះជាម្ចាស់ និងបានដួលនៅលើដីបន្ទាប់ពីគេអធិស្ឋានឱ្យ។ ខ្ញុំមិនធ្លាប់បានឃើញការដូច្នេះពីមុនមកទេ ខ្ញុំមានអារម្មណ៍ឆ្ងល់ និងច្របូកច្របល់បន្តិចបន្តួចផងដែរ។ ខ្ញុំស្វែងយល់ថា គេហៅការនេះថា ការបំពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ ទោះបីតាមធម្មជាតិ វារៀងចម្លែកបន្តិចសម្រាប់ខ្ញុំ តែមនុស្សដែលបានទទួលបទពិសោធនេះហាក់ដូចជារីករាយ និងទទួលបានការប៉ះពាល់ពីព្រះជាម្ចាស់។ ក្រោយមកស្ត្រីក្នុងក្រុមការសិក្សាព្រះគម្ពីររបស់ខ្ញុំបានប្រាប់ខ្ញុំថា សាច់ឈាមរបស់មនុស្សយើងមិនអាចឃាត់អំណាចរបស់ព្រះជាម្ចាស់បានទេ ហើយអាចមានអារម្មណ៍លើសលប់(សន្លប់)ដោយសារ «ការចាក់ប្រេងតាំង»។

ពួកគេបានបង្ហាញខ្ញុំពីកន្លែងដែលការនេះបានកើតឡើងនៅក្នុងកិច្ចបម្រើរបស់ព្រះយេស៊ូ។ នៅក្នុង យ៉ូហាន ១៨:៤-៦ នៅពេលដែលទាហានបានមករកព្រះយេស៊ូ ដើម្បីចាប់ទ្រង់ ហើយទ្រង់បានសួរពួកគេថា៖

> *«អ្នករាល់គ្នាមករកនរណា? »។ គេទូលព្រះអង្គថា៖ «រកឈ្មោះយេស៊ូជាអ្នកភូមិណាសារ៉ែត»។ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «គឺខ្ញុំហ្នឹងហើយ»។ រីឯយូដាសជាអ្នកក្បត់ព្រះអង្គក៏នៅជាមួយពួកគេដែរ។ កាលព្រះយេស៊ូមានព្រះបន្ទូលទៅគេថា "គឺខ្ញុំហ្នឹងហើយ" ដូច្នេះគេថយក្រោយ ហើយដួលដាច់ផ្ងារទាំងអស់គ្នា។*

អំឡុងពេលថ្វាយបង្គំ ស្ត្រីនៅជុំវិញខ្ញុំទាំងអស់គ្នាមានអារម្មណ៍រំភើបជាខ្លាំង ហើយខ្ញុំបានឮស្ត្រីជាច្រើននិយាយ និងសរសើរតម្កើងព្រះជាម្ចាស់ដោយប្រើភាសាដទៃ។ នេះជាបទពិសោធថ្មីទាំងស្រុងសម្រាប់ខ្ញុំ ហើយភាគច្រើនខ្ញុំគ្រាន់តែឈរដោយការស្ងប់ស្ងៃង។ ទោះបីទិដ្ឋភាពជាច្រើននៃការប្រជុំនេះ ហាក់ដូចជាចម្លែកសម្រាប់ខ្ញុំបន្តិចក៏ដោយ ប៉ុន្តែខ្ញុំមិនអាចបដិសេធព្រះវត្តមានរបស់ព្រះជាម្ចាស់បានទេ។ ខ្ញុំពិតជារំភើបខ្លាំងណាស់ដែលបានដឹងអំពីការពិតនៃដំណឹងល្អ និងអំណាចរបស់ព្រះជាម្ចាស់ ដែលនៅតែមានដំណើរការនៅលើផែនដីនេះ ដូចសម័យព្រះគម្ពីរដែរ។

នៅថ្ងៃនោះ នៅចុងបញ្ចប់នៃការប្រជុំ អ្នកអធិប្បាយបានសុំឱ្យអស់អ្នកដែលចង់ទទួលព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ ឱ្យដើរមកខាងមុខ ដើម្បីទទួលការអធិស្ឋាន។ ដូច្នេះ ខ្ញុំបានដើរទៅខាងមុខ ដើម្បីទទួលការអធិស្ឋាន។ នៅពេលដែលគេអធិស្ឋានឱ្យខ្ញុំ ខ្ញុំទទួលអារម្មណ៍ដឹងអំពីព្រះវត្តមានរបស់ព្រះជាម្ចាស់កាន់តែខ្លាំងឡើងៗ។ នៅពេលខ្ញុំបន្ទន់តាមព្រះវត្តមានរបស់ទ្រង់ ខ្ញុំភ្ញាក់ផ្អើលជាខ្លាំងដែលបានឮខ្លួនឯងចាប់ផ្តើមអធិស្ឋាននៅក្នុងវិញ្ញាណ ហើយនិយាយភាសាដែលខ្ញុំមិនធ្លាប់និយាយពីមុនមក។ ខ្ញុំបានអធិស្ឋានជាភាសាដទៃនៅយប់នោះ។ ខ្ញុំពិតជារំភើបចិត្តជាខ្លាំងដោយសារបទពិសោធនេះ ដែលធ្វើឱ្យខ្ញុំចង់ប្រាប់មនុស្សគ្រប់គ្នាដែលខ្ញុំបានជួប អំពីអ្វីដែលបានកើតឡើងចំពោះខ្ញុំ! ប៉ុន្តែ ពេលដែលខ្ញុំបានចែករំលែករឿងនេះជាមួយមិត្តភក្តិរបស់ខ្ញុំនៅក្រុមជំនុំ ពួកគេមិនសូវជារំភើបណាស់ណាទេ។ ភាគច្រើនពួកគេនិយាយថា ភាសាដទៃមកពីអារក្ស ឬវាបានកន្លងហួសហើយ។ ពួកគេបានដាស់តឿនខ្ញុំ ឱ្យនៅឱ្យឆ្ងាយពីអ្នកដែលនិយាយភាសាដទៃទាំងនេះ!

មុនពេលព្រឹត្តការណ៍នៃការប្រជុំរបស់ព័ន្ធកិច្ចស្ត្រីថៃងចាំងនេះកើតឡើង ខ្ញុំត្រូវបានគេចាត់តាំងឱ្យមើលការខុសត្រូវលើក្រុមយុវជនក្នុងក្រុមជំនុំមេតូឌីស្មនោះ។ ខ្ញុំមិន

តម្រូវឱ្យធ្វើអ្វីច្រើនទេ គឺមានតែការប្រជុំយុវជនជារៀងរាល់ថ្ងៃអាទិត្យពេលយប់ នៅបន្ទប់ក្រោមដីរបស់ក្រុមជំនុំប៉ុណ្ណោះ។ ជាធម្មតាយើងលេងល្បែងកំសាន្តជាមួយគ្នា បន្ទាប់មកប្រកបអាហារសម្រន់ និងបញ្ចប់ដោយការសិក្សាព្រះគម្ពីរយ៉ាងសង្ខេបជាមួយគ្នា។ ខ្ញុំក៏ជាយុវជនម្នាក់ដែរ ក៏ប៉ុន្តែខ្ញុំមានចិត្តខ្នះខ្នែងចំពោះកិច្ចការរបស់ព្រះ និងមានចិត្តចង់ជួយ។

ជាធម្មតា មានយុវជនចំនួនប្រហែល១៥នាក់នៅក្នុងក្រុមនោះ ហើយបន្ទាប់ពីបទពិសោធរបស់ខ្ញុំនៅការប្រជុំរបស់ព័ន្ធកិច្ចស្ត្រីថែងចាំងនោះមក ខ្ញុំចង់ប្រាប់ពួកគេអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដែលខ្ញុំបានទទួល។ ខ្ញុំដឹងថា ដូចជាខ្ញុំដែរ ពួកគេភាគច្រើនមិនធ្លាប់ឮអំពីបទពិសោធនេះទេ ហើយខ្ញុំក៏ដឹងថាពួកគេនឹងមិនឮអំពីពិធីនេះ ក្នុងវេនថ្វាយបង្គំព្រឹកថ្ងៃអាទិត្យក្នុងក្រុមជំនុំរបស់យើងនោះដែរ។

មុនពេលខ្ញុំប្រាប់អ្នកអំពីអ្វីដែលបានកើតឡើងបន្ទាប់ទៀត ខ្ញុំគិតថាខ្ញុំគួរតែប្រាប់អ្នកអំពីផ្នត់គំនិតរបស់ខ្ញុំនៅពេលនោះជាមុនសិន។ ខ្ញុំមិនបានសុំការអនុញ្ញាតពីគ្រូគង្វាលដើម្បីចែករំលែករឿងនេះជាមួយក្រុមយុវជនទេ។ (ពេលនេះខ្ញុំដឹងថាខ្ញុំគួរតែសុំការអនុញ្ញាតជាមុនសិន) ហើយខ្ញុំក៏មិនបានប្រាប់រឿងនោះដល់គាត់ដែរ។

ខ្ញុំមិនបានព្យាយាមបះបោរប្រឆាំងនឹងក្រុមជំនុំរបស់ខ្ញុំទេ ហើយខ្ញុំក៏មិនព្យាយាមធ្វើអ្វីរំលងគ្រូគង្វាលរបស់ខ្ញុំដែរ។ ពេលនោះខ្ញុំគ្រាន់តែរំភើបពេក។ ហើយខ្ញុំក៏មិនបានដឹងអំពីភាពចម្រូងចម្រាសលើប្រធានបទនេះ ហើយខ្ញុំពិតជាមិនបានគិតថា គ្រូគង្វាលរបស់ខ្ញុំប្រឆាំងនឹងវានោះទេ។

នៅយប់ថ្ងៃអាទិត្យបន្ទាប់ពីខ្ញុំបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធហើយ ខ្ញុំមានគម្រោងប្រាប់ក្រុមយុវជនអំពីអ្វីដែលបានកើតឡើងចំពោះខ្ញុំ និងបង្ហាញពួកគេខគម្ពីរមួយចំនួនដែលបាននិយាយអំពីរឿងនេះនៅក្នុងសៀវភៅកិច្ចការ។ យើងនៅក្នុងបន្ទប់ក្រោមដីរបស់ក្រុមជំនុំ កំពុងតែអង្គុយជារង្វង់ ពេលដែលខ្ញុំបានចែករំលែកអំពីបទពិសោធរបស់ខ្ញុំជាមួយពួកគេ និងមើលខគម្ពីរមួយចំនួនជាមួយគ្នាដែលបញ្ជាក់អំពីបទពិសោធនោះ។

នៅល្ងាចនោះ គ្រូគង្វាលបានមកចូលរួមការប្រជុំជាមួយពួកយើងដែរ ហើយគាត់អង្គុយនៅខាងឆ្វេងដៃរបស់ខ្ញុំ ពេលដែលខ្ញុំកំពុងចែករំលែក។ ខ្ញុំមិនបារម្ភអំពីវត្តមានរបស់គ្រូគង្វាលរបស់ខ្ញុំនៅទីនោះជាមួយពួកយើងទេ។ ក្នុងនាមជាគ្រូគង្វាល ខ្ញុំគិតថា គាត់បានដឹងអំពីអ្វីៗទាំងអស់ដែលខ្ញុំនឹងចែករំលែកហើយ។

ដូច្នេះខ្ញុំក៏បានចែករំលែកជាមួយពួកគេអំពីការប្រជុំដែលខ្ញុំបានចូលរួម និងអ្វីដែលខ្ញុំបានឃើញ។ ខ្ញុំមិនបាននិយាយលម្អិតអំពីការនិយាយភាសាដទៃទេ។ ផ្ទុយទៅវិញ ខ្ញុំបានផ្ចង់ការយកចិត្តទុកដាក់របស់ខ្ញុំលើ កិច្ចការ ១:៨ ដែលខគម្ពីរនេះបានចែងថា យើងនឹងទទួលឫទ្ធានុភាពនៅពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិតលើយើង ដើម្បីធ្វើជាបន្ទាល់របស់ព្រះជាម្ចាស់។ នៅចុងបញ្ចប់នៃការប្រជុំ ខ្ញុំពិតជាមិនដឹងថាត្រូវបញ្ចប់មេរៀនរបស់ខ្ញុំដោយរបៀបណាទេ ដូច្នេះ ខ្ញុំគ្រាន់តែសុំឱ្យយុវជនដែលចង់ទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ លើកដៃឡើង។

ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទៀតទេនៅពេលនោះ ខ្ញុំមិនដែលធ្លាប់ឃើញនរណាម្នាក់អធិស្ឋានឱ្យនរណាម្នាក់ទៀតនៅក្នុងពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ លើកលែងតែអ្វីដែលខ្ញុំបានឃើញនៅក្នុងការប្រជុំរបស់ព័ន្ធកិច្ចស្ត្រីចែងចាំងនោះតែប៉ុណ្ណោះ។ ខ្ញុំគិតថាខ្ញុំប្រហែលជាស្គាល់ខគម្ពីរតែពីរឬបីទេដែលនិយាយអំពីរឿងនេះនៅពេលនោះ។

ដូច្នេះ ខ្ញុំគ្រាន់តែនិយាយថា «ប្រសិនបើអ្នកចង់ទទួលអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ សូមគ្រាន់តែលើកដៃឡើង ឱនក្បាលចុះ ហើយអធិស្ឋាន។» នេះជាអ្វីដែលខ្ញុំបាននិយាយ។ ខ្ញុំមិនបានប៉ះពួកគេ ឬបង្រៀនពួកគេអំពីរបៀបទទួលព្រះវិញ្ញាណដ៏វិសុទ្ធទេ។ យើងបានឱនក្បាលចុះ ហើយអធិស្ឋាន។ ពិតហើយ យើងក៏បានបិទភ្នែកនៅពេលអធិស្ឋាន ដូចគ្រិស្តបរិស័ទ«ល្អ»ពីនិកាយផ្សេងៗទាំងអស់បានធ្វើ។

ពេលដែលខ្ញុំនៅអង្គុយនៅទីនោះនៅឡើយ ហើយបន្ទាប់ពីបាននិយាយថា «អាម៉ែន» ខ្ញុំបានឮសំឡេងរំជើបរំជួលចេញពីចំណោមយុវជនទាំងនោះ។ ខ្ញុំបានបើកភ្នែកឡើង ហើយបានឃើញយុវជនខ្លះយំ ខ្លះទៀតញ័រខ្លួន និងយុវជនដទៃទៀតចាប់ផ្ដើមនិយាយភាសាដទៃ។ នៅពេលពួកគេនិយាយភាសាដទៃ ខ្ញុំក៏បានឃើញពន្លឺភ្លឺចែងចាំងលើផ្ទៃមុខរបស់ពួកគេ។ ពួកគេភ្លឺដូចជាអំពូលភ្លើងអ៊ីចឹង! ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលជាខ្លាំង!

គ្រូគង្វាលរបស់ខ្ញុំដែលមិនបាននិយាយអ្វីទាំងអស់ រហូតដល់ពេលនោះ បានទះស្មារបស់ខ្ញុំ ហើយសុំជួបនិយាយជាមួយខ្ញុំភ្លាមៗ។ យើងបានដើរទៅបន្ទប់ជាប់នោះ ហើយគាត់បានសម្លឹងមើលមកកែវភ្នែករបស់ខ្ញុំ ហើយនិយាយថា «នេះជាកិច្ចការរបស់អារក្ស។ អ្នកមិនអាចធ្វើជាអ្នកដឹកនាំយុវជននៅទីនេះទៀតទេ។ យើងនឹងមិនអនុញ្ញាតឱ្យការនេះកើតឡើងទៀតទេ។»

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្រ្ត

ខ្ញុំបានគិតក្នុងចិត្តថា *តើលោកគ្រូនិយាយថាវាជាកិច្ចការរបស់អារក្សយ៉ាងដូចម្តេច? ខ្ញុំចង់បានន័យថា សូមមើលពួកយុវជនទាំងនេះចុះ! ពួកគេមានពន្លឺភ្លឺថែងចាំង!* លោកគ្រូអាចឃើញការចាក់ប្រេងតាំងនៅលើរាងកាយរបស់ពួកគេ។ ពិតណាស់ ខ្ញុំមិនទាន់យល់អំពីអត្ថន័យនៃការចាក់ប្រេងតាំងនៅពេលនោះទេ។ ខ្ញុំគ្រាន់តែឃើញពួកគេមានពន្លឺភ្លឺ ហើយខ្ញុំមិនបានប៉ះពួកគេ ឬប្រាប់ពួកគេឱ្យធ្វើសកម្មភាពអីទេ។ ខ្ញុំមានអារម្មណ៍បាក់ទឹកចិត្ត និងច្របូកច្របល់ ពេលដែលគ្រូគង្វាលរបស់ខ្ញុំបានស្តីបន្ទោសឱ្យខ្ញុំដូច្នោះ ហើយខ្ញុំក៏មិនដឹងថាត្រូវធ្វើអ្វីដែរ។

ថ្ងៃអាទិត្យបន្ទាប់ ខ្ញុំបានទៅចូលរួមការថ្វាយបង្គំនៅក្រុមជំនុំជាធម្មតា ប៉ុន្តែខ្ញុំមិនបានអង្គុយនៅជួរខាងមុខដូចខ្ញុំធ្លាប់អង្គុយទេ ខ្ញុំទៅអង្គុយនៅជួរខាងក្រោយ។ ខ្ញុំដឹងថាខ្ញុំនិងគ្រូគង្វាលរបស់ខ្ញុំមិនទាន់ត្រូវគ្នាទេបន្ទាប់ពីការប្រជុំយុវជននៅយប់នោះមក ហើយខ្ញុំគិតថា ខ្ញុំគួរបន្ទាបខ្លួនបន្តិចក្នុងពេលកំពុងគិតរកដំណោះស្រាយ។

ក្នុងអំឡុងពេលថ្វាយបង្គំនាព្រឹកថ្ងៃអាទិត្យ ជាធម្មតាយើងមានពេលស្ងប់ស្ងៀមដើម្បីផ្ចង់ការគិតរបស់យើងទៅព្រះជាម្ចាស់។ នេះជាពេលសម្រាប់ការអធិស្ឋានដ៏ស្ងៀមស្ងាត់ និងគួរឱ្យគោរពនៅក្រុមជំនុំរបស់យើង។ គ្រប់គ្នាឱនក្បាលចុះ ហើយគ្មានសំឡេងអ្វីសូម្បីតែបន្តិចនៅពេលនោះ។ ប្រសិនបើមានអ្វីមួយកម្រើក អ្នកអាចឮសំឡេងវាបាន។ ស្រាប់តែពេលនោះខ្ញុំមានអារម្មណ៍ថា មាននរណាម្នាក់បានប៉ះស្មារបស់ខ្ញុំ។ ខ្ញុំឈរនៅជួរក្រោយគេបង្អស់ ហើយប្រាកដណាស់ បុគ្គលម្នាក់នោះកំពុងឈរនៅក្បែរខ្ញុំ ហើយបានទះស្មារបស់ខ្ញុំ។

ដំបូងខ្ញុំភ្ញាក់ផ្អើល ដោយសារមានមនុស្សដើរក្នុងពេលអធិស្ឋានដ៏ស្ងៀមស្ងាត់បែបនេះ។ ពេលដែលខ្ញុំងើបមុខឡើង ខ្ញុំបានឃើញយុវជនម្នាក់ដែលបានចូលរួមការប្រជុំយុវជនកាលពីសប្តាហ៍មុន។ ខ្ញុំក៏បានដឹងថា គាត់ជាយុវជនម្នាក់ក្នុងចំណោមយុវជនប្រាំពីរនាក់ទៀតដែលបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធកាលពីយប់នោះ។ គាត់សម្លឹងមើលមុខខ្ញុំ រួចនិយាយថា «តោះយើងទៅ!» ខ្ញុំគិតក្នុងចិត្តថា តោះទៅ? ទៅណា?

គាត់នៅតែមានពន្លឺភ្លឺយ៉ាងអស្ចារ្យ ដូចពេលយប់ដែលគាត់បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ហើយខ្ញុំដឹងថាព្រះជាម្ចាស់កំពុងតែធ្វើអ្វីមួយហើយ។ ប៉ុន្តែ ខ្ញុំមិនប្រាកដថា នេះជាពេល ឬជាកន្លែងដែលត្រូវធ្វើអ្វីនោះទេ ព្រោះខ្ញុំទើបតែមានបញ្ហាជាមួយគ្រូគង្វាលរបស់ខ្ញុំ។ ហើយខ្ញុំក៏ដឹងដែរថា យើងមិនអាចធ្វើអ្វីតាមតែចិត្តយើងចង់ធ្វើ នៅវេនថ្វាយបង្គំ

ពេលព្រឹកថ្ងៃអាទិត្យរបស់ក្រុមជំនុំទេ។ បន្ទាប់មកគាត់បាននិយាយថា «ខ្ញុំនឹងទៅអធិស្ឋានឱ្យម្ដាយខ្ញុំ»។

ឥឡូវនេះខ្ញុំចាប់ផ្ដើមយល់អំពីអ្វីដែលកំពុងតែកើតឡើងហើយ។ ខ្ញុំស្គាល់ម្ដាយរបស់គាត់។ គាត់ជាស្ត្រីម្នាក់ដែលមានមាឌតូចស្ដើង ហើយមានជំងឺយូរឆ្នាំហើយ។ ម្ដាយគាត់មានឆ្អឹងកងខ្នងចំនួនប្រាំដែលកំពុងតែពុក ហើយក្ដីសង្ឃឹមចុងក្រោយរបស់វេជ្ជបណ្ឌិតគឺ ភ្ជាប់ឆ្អឹងទាំងនេះបញ្ចូលគ្នា។ នេះជាការវះកាត់កម្រិតធ្ងន់ ហើយយុវជននេះជាកូនប្រុសតែម្នាក់គត់របស់គាត់។

បន្ទាប់ពីបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធមក គាត់មានអារម្មណ៍ជឿជាក់ថាព្រះយេស៊ូអាចព្យាបាលម្ដាយគាត់បាន។ ដូច្នេះពេលដែលគាត់និយាយថា «តោះយើងទៅ!» ខ្ញុំគិតថាគាត់នឹងទៅខាងមុខ ដាក់ដៃលើម្ដាយគាត់ ហើយអធិស្ឋានឱ្យគាត់យ៉ាងស្ងៀមស្ងាត់។ តែនោះមិនមែនជាអ្វីដែលគាត់បានធ្វើទេ។ គាត់បានទៅរកម្ដាយគាត់បានគ្រាម្ដាយគាត់ឡើង ហើយនាំគាត់ទៅមុខក្រុមជំនុំ។

គាត់បានដាក់ម្ដាយគាត់ឱ្យអង្គុយចុះ ហើយចាប់ផ្ដើមអធិស្ឋានជាភាសាដទៃយ៉ាងឮៗឱ្យម្ដាយគាត់។ សូមចាំថា ការនេះកើតឡើងអំឡុងពេលនៃការអធិស្ឋាន «ស្ងៀមស្ងាត់» និងការផ្ចង់ការគិតលើព្រះជាម្ចាស់ តែវាលែងជាពេលស្ងប់ស្ងាត់ទៀតហើយនៅថ្ងៃនោះ។ ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង! បន្ទាប់មកគាត់បានងាកមករកខ្ញុំ ហើយនិយាយថា «សូមអ្នកពន្យល់អំពីអ្វីដែលកំពុងតែកើតឡើង។»

ឥឡូវនេះខ្ញុំបានយល់ពីមូលហេតុដែលគាត់បានហៅខ្ញុំឱ្យមកជាមួយគាត់ហើយ។ គាត់គិតថា ខ្ញុំជាម្នាក់ដែលបានប្រាប់គាត់អំពីការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដូច្នេះ ខ្ញុំអាចប្រាប់ក្រុមជំនុំអំពីពិធីនេះ បន្ទាប់ពីពួកគេបានឮគាត់អធិស្ឋានជាភាសាដទៃឱ្យម្ដាយគាត់។

ដូច្នេះខ្ញុំក៏បានឈរនៅចំពោះមុខក្រុមជំនុំ ក្នុងនាមជាអ្នកនាំពាក្យរបស់គាត់ ហើយគាត់កំពុងតែអធិស្ឋានជាភាសាដទៃឱ្យម្ដាយគាត់។ ខ្ញុំពិតជាមិនដឹងថាត្រូវនិយាយអំពីអ្វីទេ ជាពិសេសពេលដែលខ្ញុំបានឃើញគ្រូគង្វាលរបស់ខ្ញុំកំពុងតែអង្គុយនៅទីនោះ ហើយសម្លឹងមើលមុខខ្ញុំ។ ខ្ញុំគ្រាន់តែប្រាប់ក្រុមជំនុំថា ម្ដាយរបស់គាត់ឈឺយូរហើយ ហើយគាត់កំពុងតែអធិស្ឋានឱ្យម្ដាយគាត់ជាភាសាដទៃដែលមានចែងនៅក្នុងព្រះគម្ពីរ។ ប៉ុន្តែ តើអ្នកដឹងថាមានរឿងអ្វីកើតឡើងទេ? ម្ដាយគាត់បានជាពីជំងឺនោះភ្លាមៗនៅព្រឹកនោះតែម្ដង!

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

នេះគឺជាជំនឿរបស់កូនប្រុសម្នាក់ដែលមិនបានខ្វល់ខ្វាយអំពីការគិតរបស់អ្នកដទៃទាក់ទងនឹងការអធិស្ឋានរបស់គាត់។ គាត់ជឿជាក់ថា ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះជន្មរស់ ហើយអាចព្យាបាលម្ដាយរបស់គាត់បាន។

ទោះបីជាម្ដាយគាត់បានជាសះស្បើយភ្លាមៗនៅពេលនោះក៏ដោយ ក៏ក្រុមជំនុំមិនអាចទទួលយកការនោះបានដែរ។ តាមពិត មានមនុស្សជាច្រើនបានមកជួបខ្ញុំ ហើយបាននិយាយថា «ខ្ញុំមិនប្រកាន់ពីការដែលគាត់បានអធិស្ឋានឱ្យម្ដាយគាត់ទេ ប៉ុន្តែខ្ញុំមិនអាចទទួលយកបានទេ ការដែលគាត់អធិស្ឋានជាភាសាដទៃ។» ខ្ញុំធានាថា អារក្សក៏ស្អប់ភាសាដទៃដែរ ហើយខ្ញុំសង្ឃឹមថានឹងជួយអ្នកឱ្យយល់ពីមូលហេតុដែលវាស្អប់ភាសាដទៃ មុនពេលចប់សៀវភៅនេះ។

ប្រហែលជាអ្នកធំឡើងនៅក្នុងក្រុមជំនុំដែលមិនប្រើភាសាដទៃ និងអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ឬប្រហែលជាអ្នកធំឡើងដោយបានទទួលការបង្រៀនថា ភាសាដទៃគឺមិនសម្រាប់ពេលនេះទេ ហើយវាបានកន្លងហួសទៅហើយ។ សំណួរដែលទាក់ទងនឹងប្រធានបទនេះមិនពិបាកឆ្លើយទេ ព្រោះព្រះគម្ពីរបានពន្យល់យ៉ាងច្បាស់។ ដូច្នេះ យើងនឹងមើលព្រះបន្ទូលទាំងអស់គ្នា ហើយស្វែងរកសេចក្តីពិតអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងនឹងត្រលប់ទៅមើលខគម្ពីរដែលយើងបានអាន នៅពេលចាប់ផ្ដើមជំពូកនេះ។

> *ទ្រង់ហាមគេមិនឱ្យចេញទៅណាឆ្ងាយពីក្រុងយេរូសាឡឹមឡើយ «គឺត្រូវរង់ចាំទទួលព្រះវិញ្ញាណ តាមព្រះបន្ទូលសន្យារបស់ព្រះបិតា ដូចខ្ញុំបានប្រាប់អ្នករាល់គ្នារួចមកហើយថា លោកយ៉ូហានបានធ្វើពិធីជ្រមុជឱ្យគេក្នុងទឹក ប៉ុន្តែ នៅប៉ុន្មានថ្ងៃទៀត អ្នករាល់គ្នានឹងទទួលពិធី<u>ជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ</u>»។*

កិច្ចការ ១:៤-៥

**«សេចក្តីដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នា មិនមែនចេញមកពីខ្ញុំផ្ទាល់ទេ គឺព្រះបិតាដែលស្ថិតនៅជាប់នឹងខ្ញុំ ទ្រង់បំពេញកិច្ចការរបស់ព្រះអង្គ។»**

**យ៉ូហាន ១៤:១០**

មានចំណុចសំខាន់ៗជាច្រើនដែលយើងអាចឃើញនៅក្នុងខគម្ពីរនេះ៖

១. ពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធខុសគ្នាពីពិធីជ្រមុជទឹក។

២. ព្រះយេស៊ូមានបន្ទូលថាពិធីនេះសំខាន់ខ្លាំងណាស់។ តាមពិត ទ្រង់បានបញ្ជាក់យ៉ាងច្បាស់ថា យើងមិនអាចធ្វើអ្វីបាន ដោយគ្មានវានោះទេ។

សូមចាំថា ព្រះយេស៊ូទើបតែប្រាប់ពួកសិស្សឱ្យទៅផ្សាយដំណឹងល្អដល់គ្រប់ជាតិសាសន៍ទាំងអស់ ប៉ុន្តែពួកគេមិនអាចបង្ហាញ ឬបញ្ជាក់អំពីនរគស្ថានសួគ៌ដោយគ្មានពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនេះទេ។ ដូច្នេះ ទ្រង់មានបន្ទូលថា «កុំចេញទៅណាឆ្ងាយរហូតទាល់តែអ្នកទទួលបានឫទ្ធានុភាពនេះសិន។»

> *ប៉ុន្តែ អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី»។*

កិច្ចការ ១:៨

*ឫទ្ធានុភាព!* ពាក្យ*ឫទ្ធានុភាព*ជាភាសាក្រិចនៅទីនេះគឺ *ឌូណាមីស* ហើយយើងបានពាក្យឌីណាមិកមកពីពាក្យនេះឯង។ ដូច្នេះ យើងឃើញថាឫទ្ធានុភាពរបស់ព្រះជាម្ចាស់យាងមកសណ្ឋិតលើយើង ដើម្បីឱ្យយើងអាចធ្វើកិច្ចការរបស់ទ្រង់។ មុននេះបន្តិចក្នុងកិច្ចបម្រើរបស់ព្រះយេស៊ូ ទ្រង់បានមានបន្ទូលថា ទ្រង់បានទទួលឫទ្ធានុភាព ឬការចាក់ប្រេងតាំងមកពីព្រះបិតា។

> *«សេចក្តីដែលខ្ញុំនិយាយប្រាប់អ្នករាល់គ្នា មិនមែនចេញមកពីខ្ញុំផ្ទាល់ទេ គឺព្រះបិតាដែលស្ថិតនៅជាប់នឹងខ្ញុំ ទ្រង់បំពេញកិច្ចការរបស់ព្រះអង្គ។»*

យ៉ូហាន ១៤:១០

> *«ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា ព្រះបុត្រាពុំអាចធ្វើអ្វីដោយព្រះអង្គផ្ទាល់បានឡើយ គឺព្រះបុត្រាធ្វើតែកិច្ចការណា ដែលទ្រង់បានឃើញព្រះបិតាធ្វើប៉ុណ្ណោះ។ (យ៉ូហាន ៥:១៩)*

អ្នកឃើញទេ ព្រះយេស៊ូក៏ត្រូវការឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធសម្រាប់ទ្រង់ផ្ទាល់ខ្លួនផងដែរ។ ពាក្យ *ចាក់ប្រេងតាំង* មានន័យថា «លាបលើ»។ ព្រះយេស៊ូបានទទួលការចាក់ប្រេងតាំង នៅទន្លេយ័រដាន់ពីព្រះបិតា នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកសណ្ឋិតលើទ្រង់ជារូបសត្វព្រាប។

បន្ទាប់ពីព្រះយេស៊ូបានទទួលការចាក់ប្រេងតាំងហើយ ទើបទ្រង់ធ្វើកិច្ចការនៃព្រះរាជ្យរបស់ព្រះជាម្ចាស់។ ប្រសិនបើព្រះយេស៊ូត្រូវការការចាក់ប្រេងតាំង យើងក៏ត្រូវការការ

ចាក់ប្រេងតាំងផងដែរ! ឫទ្ធានុភាពនេះនឹងផ្តល់សក្ខីភាព (ឬធ្វើជាបន្ទាល់) តាមរយៈការបង្ហាញដល់អ្នកដែលមិនទាន់ស្គាល់ទ្រង់ថា ពិតជាមានព្រះជាម្ចាស់ពិតមែន។

ព្រះគម្ពីរចែងថា អ្នកនឹងទទួលឫទ្ធានុភាព ពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមក**សណ្ឋិតលើអ្នក** មិនមែនពេលដែលទ្រង់យាងគង់ក្នុងអ្នក ពេលដែលអ្នកកើតជាថ្មីនោះទេ។

មនុស្សជាច្រើនភាន់ច្រឡំនៅពេលយើងនិយាយអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដោយគិតថាពួកគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធរួចហើយ ពេលដែលពួកគេទទួលជឿលើព្រះយេស៊ូគ្រិស្ត។ ហើយការពិតគឺថា ពួកគេមិនទាន់បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធពេញលេញនៅឡើយទេ ពេលពួកគេទទួលជឿលើព្រះយេស៊ូគ្រិស្ត។ ព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើឱ្យវិញ្ញាណរបស់ពួកគេមានជីវិតរស់ចំពោះព្រះជាម្ចាស់ និងរួមតែមួយជាមួយទ្រង់។

យើងមានជីវិតរស់ក្នុងព្រះអម្ចាស់ ដោយសារឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅក្នុងយើង នៅពេលយើងកើតជាថ្មី។ ប៉ុន្តែសូមកត់សម្គាល់អ្វីដែលខគម្ពីរនេះបានចែង នៅពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិត<u>លើ</u>អ្នក។ នេះជាការពិតដ៏សំខាន់មួយ ដែលយើងនឹងពិនិត្យមើលនៅពេលក្រោយក្នុងសៀវភៅនេះ ៖ ការកើតជាថ្មី និងការទទួលការចាក់ប្រេងតាំង ឬការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ គឺជាព្រឹត្តការណ៍ពីរផ្សេងគ្នា។ យើងអាចយល់កាន់តែច្បាស់អំពីរឿងនេះ ប្រសិនបើយើងមើលខគម្ពីរ យ៉ូហាន ២០:២១-២២។

> *ព្រះយេស៊ូមានព្រះបន្ទូលទៅគេសាជាថ្មីថា៖ «សូមឱ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត! ដូចព្រះបិតាបានចាត់ខ្ញុំឱ្យមកយ៉ាងណា ខ្ញុំចាត់អ្នករាល់គ្នាឱ្យទៅយ៉ាងនោះដែរ»។ បន្ទាប់ពីមានព្រះបន្ទូលហើយ ព្រះអង្គផ្លុំលើពួកគេ ទាំងមានព្រះបន្ទូលថា៖ «ចូរទទួលព្រះវិញ្ញាណ!។*

យើងឃើញថា បន្ទាប់ពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ទ្រង់បានទៅជួបពួកសិស្ស និយាយជាមួយពួកគេ និងផ្លុំលើពួកគេ ដោយប្រាប់ពួកគេឱ្យទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ នេះគឺជាពេលដែលពួកគេបានកើតជាថ្មី ហើយវិញ្ញាណរបស់ពួកគេមានជីវិតរស់ឡើងវិញចំពោះព្រះជាម្ចាស់។ តែព្រះយេស៊ូនៅតែមានបន្ទូលឱ្យពួកគេរង់ចាំពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនឹងយាងមកសណ្ឋិតលើពួកគេនៅពេលក្រោយទៀត។

ប្រសិនបើពួកគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធទាំងអស់នៅពេលដែលព្រះយេស៊ូបានផ្លុំលើពួកគេ ហេតុអ្វីទ្រង់ចាំបាច់ប្រាប់ពួកគេឱ្យចាំនៅក្រុងយេរូសាឡឹម រហូតទាល់តែពួកគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានសន្យាថានឹងយាងមកសណ្ឋិតលើពួកគេ? ជាថ្មីម្តងទៀត ទាំងនេះជាព្រឹត្តការណ៍ពីរផ្សេងគ្នា និងមានមុខងារពីរខុសគ្នា ប៉ុន្តែក្នុងព្រះវិញ្ញាណតែមួយ។ ដូចគ្នានេះផងដែរ ខ្ញុំចង់បញ្ជាក់ម្តងទៀតថា ព្រះយេស៊ូត្រូវតែទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីធ្វើ និងបំពេញកិច្ចបម្រើរបស់ទ្រង់យ៉ាងមានប្រសិទ្ធភាព។ មុនពេលទ្រង់ទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ មិនមានកំណត់ត្រានៃកិច្ចការអស្ចារ្យដែលទ្រង់បានធ្វើនោះទេ។ តើព្រះយេស៊ូបានធ្វើឱ្យចំនួននំប៉័ងពហុគុណឡើងនៅពេលទ្រង់កំពុងធំពេញវ័យ? តើទ្រង់បានធ្វើការអស្ចារ្យនៅពេលទ្រង់នៅជាទារក? តើទ្រង់បានធ្វើឱ្យអាហារទារករបស់ទ្រង់ពហុគុណឡើង នៅពេលអស់អាហារ ហើយទ្រង់នៅតែឃ្លាន? អត់ទេ! ទ្រង់មិនបានធ្វើការទាំងអស់នោះទេ។ ហេតុអ្វីទ្រង់មិនបានធ្វើ? ចម្លើយដ៏សាមញ្ញ និងស្មោះត្រង់គឺ៖ ទ្រង់*មិនអាច*ធ្វើវាបានទេ។

ទ្រង់មិនទាន់អាចធ្វើការអស្ចារ្យបាន រហូតទាល់តែបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធនៅឯទន្លេយ័រដាន់ជាមុនសិន ទើបទ្រង់អាចចាប់ផ្តើមធ្វើការអស្ចារ្យបាន។ អ្នកដឹងហើយថាព្រះយេស៊ូបានកើតមកជាមនុស្សម្នាក់។ ទ្រង់មិនបានយាងមក ជាព្រះរាជបុត្រានៃព្រះប្រកបទៅដោយឫទ្ធិអំណាច និងសេរីល្អរបស់ព្រះជាម្ចាស់ឡើយ។ ក្នុងនាមជាមនុស្សម្នាក់ទ្រង់មានដែនកំណត់ ដូចមនុស្សទាំងអស់គ្នាមានដែនកំណត់ផងដែរ។ ទ្រង់មិនអាចព្យាបាល ឬធ្វើការអស្ចារ្យ ដូចជាអ្នក និងខ្ញុំ យើងមិនអាចធ្វើការអស្ចារ្យណាមួយ ដោយខ្លួនឯងបានទេ។

ទោះជាយ៉ាងនេះក៏ដោយ ព្រះវិញ្ញាណរបស់ព្រះយេស៊ូមិនស្លាប់ចំពោះព្រះជាម្ចាស់ដូចជាវិញ្ញាណរបស់យើងទេ នៅពេលទ្រង់បានចាប់កំណើតជាទារក។ វិញ្ញាណរបស់ទ្រង់តែងតែរស់ចំពោះព្រះជាម្ចាស់។ ទ្រង់មិនចាំបាច់កើតជាថ្មីដូចជាពួកយើងទេ។ ទោះបីវិញ្ញាណរបស់ទ្រង់នៅរស់ចំពោះព្រះជាម្ចាស់ក្នុងនាមជាព្រះបុត្រា ទ្រង់នៅតែត្រូវទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ មុនពេលទ្រង់អាចចាប់ផ្តើមកិច្ចបម្រើរបស់ទ្រង់ ដូចគ្នាជាមួយពួកយើងផងដែរ។

> *ពេលព្រះយេស៊ូទទួលពិធីជ្រមុជទឹករួចហើយ ទ្រង់យាងឡើងពីទឹក ស្រាប់តែផ្ទៃមេឃបើកចំហ ព្រះអង្គទតឃើញព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងចុះដូចសត្វ*

*ព្រាប មកសណ្ឋិតលើព្រះអង្គ។ ពេលនោះ មានព្រះសូរសៀងពីលើមេឃមកថា៖ « នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់»។*

ម៉ាថាយ ៣:១៦-១៧

សូមចាំថា យើងគិតអំពីព្រះយេស៊ូ ជាស្តេចលើសអស់ទាំងស្តេច និងព្រះអម្ចាស់លើសអស់ទាំងអម្ចាស់ ប៉ុន្តែនេះមិនមែនជាទីកន្លែងនៃការចាប់ផ្តើមកិច្ចបម្រើរបស់ទ្រង់ទេ។ បន្ទាប់ពីព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកសណ្ឋិតលើទ្រង់នៅឯទន្លេយ័រដាន់ ទើបការអស្ចារ្យចាប់ផ្តើមកើតឡើង។

កិច្ចបម្រើរបស់អ្នក (ព្រោះអ្នកជឿ*ម្នាក់ៗ*ត្រូវបានត្រាស់ហៅឱ្យធ្វើកិច្ចការរបស់ព្រះយេស៊ូ) មិនទាន់អាចចាប់ផ្តើមបានទេ ទាល់តែអ្នកទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធជាមុនសិន អ្នកត្រូវការឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីបំពេញតាមកិច្ចបម្រើរបស់អ្នក។ ហើយអ្នកក៏ត្រូវការសមត្ថភាពក្នុងការអធិស្ឋានក្នុងព្រះវិញ្ញាណ ដើម្បីដឹងអំពីរបៀបធ្វើកិច្ចការនេះផងដែរ ដែលយើងនឹងពិភាក្សាអំពីវានៅពេលក្រោយ។

ជាការពិតណាស់ អ្នកអាចចែករំលែកបទពិសោធនៃការកើតជាថ្មីជាមួយមនុស្សដទៃ ដោយប្រាប់ពួកគេអំពីអ្វីដែលព្រះគម្ពីរបានចែងទាក់ទងនឹងការសង្គ្រោះ។ មានគ្រិស្តបរិស័ទជាច្រើនដែលមិនទាន់បានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ តែអាចចែករំលែកដំណឹងល្អបានយ៉ាងមានប្រសិទ្ធភាព ប៉ុន្តែពួកគេមិនមានឫទ្ធានុភាព ដើម្បីបង្ហាញព្រះរាជរបស់ព្រះ ដូចព្រះយេស៊ូបានធ្វើទេ។ ការនេះធ្វើឱ្យការអធិប្បាយរបស់ពួកគេមានលក្ខណៈខ្សោយ។

នៅពេលដែលព្រះយេស៊ូប្រឈមមុខនឹងពួកផារិស៊ីទាក់ទងនឹងការមិនជឿរបស់ពួកគេ ទ្រង់បានបញ្ជាក់អំពីការអស្ចារ្យដែលទ្រង់បានធ្វើ។ ទ្រង់មានបន្ទូលថា៖

*ពេលខ្ញុំនិយាយថា ខ្ញុំនៅក្នុងព្រះបិតា ហើយព្រះបិតានៅក្នុងខ្ញុំ ចូរជឿខ្ញុំចុះ បើមិនជឿសេចក្តីដែលខ្ញុំនិយាយនេះទេ ចូរជឿដោយឃើញកិច្ចការទាំងនោះទៅ។* (យ៉ូហាន ១៤:១១)

ព្រះយេស៊ូចង់មានព្រះបន្ទូលថា ការបង្ហាញអំពីព្រះរាជ្យរបស់ព្រះអាចបញ្ឈប់រាល់ការជជែកវែកញែកទាំងអស់។ បញ្ហាត្រូវបានដោះស្រាយ។ ជាការពិតណាស់ អ្នកជឿគ្រប់រូបមានសិទ្ធិស្របច្បាប់ពេញលេញ ទទួលបានអ្វីៗដែលព្រះយេស៊ូបានបង់ថ្លៃរួចរាល់ហើយ

រួមបញ្ចូលទាំងការព្យាបាល។ អ្នកជឿគ្រប់រូបទទួលបានរាល់ការសន្យារបស់ព្រះជាម្ចាស់ ដោយសេចក្តីជំនឿ (ដោយយល់ស្របជាមួយឋានសួគ៌) ហើយពួកគេមិនចាំបាច់ទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីទទួលវាពីព្រះជាម្ចាស់ទេ។

ប៉ុន្តែ ដើម្បីឱ្យឫទ្ធានុភាពនោះអាចហូរពីអ្នកទៅអ្នកដទៃ និងដើម្បីឱ្យអ្នកអាចរស់ក្នុងលំហូរនៃព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ ហើយរីករាយជាមួយអត្ថប្រយោជន៍នៃការដើរក្នុងអាថ៌កំបាំងឋានសួគ៌ តាមរយៈការអធិស្ឋានជាភាសាដទៃ អ្នកត្រូវតែមានឫទ្ធានុភាពនៃការចាក់ប្រេងតាំង! ខ្ញុំដឹងថា អ្នកប្រហែលជាមិនទាន់យល់អំពីអ្វីដែលខ្ញុំចង់និយាយ នៅពេលខ្ញុំនិយាយថា ការអធិស្ឋានជាភាសាដទៃទេ។ សូមកុំឱ្យវាបំភ័យអ្នក។ ខ្ញុំនឹងពន្យល់យ៉ាងពេញលេញនៅពេលក្រោយ។

កូនស្រីរបស់ខ្ញុំ អេមី ដឹកនាំវេនថ្វាយបង្គំនៅក្រុមជំនុំរបស់យើង គឺក្រុមជំនុំ Faith Life Church ក្នុងក្រុងញូអាល់បានី រដ្ឋអូហៃយ៉ូ។ អស់រយៈពេលពីរបីឆ្នាំនាងមានជំងឺមួយដែលធ្វើឱ្យយើងគ្រប់គ្នាងឿងឆ្ងល់ ពោះរបស់នាងចាប់ផ្តើមរីកធំឡើងបន្តិចម្តង និងកាន់តែធំជាងមុន។ ទោះបីយើងបានទៅជួបគ្រូពេទ្យជាច្រើនក៏ដោយ ក៏គ្មាននរណាម្នាក់អាចរកពីមូលហេតុនៃជំងឺរបស់គាត់ដែរ។ ពួកគេគ្រាន់តែនិយាយថា វាជាលក្ខណៈរាងកាយរបស់នាង។

ហើយពោះរបស់នាងកាន់តែបន្តរីកធំជាងមុន រហូតមើលទៅនាងហាក់ដូចជាមានផ្ទៃពោះ៦ខែអ៊ីចឹង។ នៅពេលនោះអេមីបានថតកាំរស្មីអ៊ិច ហើយរូបថតកាំរស្មីអ៊ិចបានបង្ហាញយ៉ាងច្បាស់ថា នាងមានដុំសាច់មួយយ៉ាងធំនៅក្នុងពោះរបស់នាង។ តាមរយៈកាំរស្មីអ៊ិចនេះ អេមីដឹងយ៉ាងច្បាស់ថាជំហានបន្ទាប់នៃការព្យាបាលជំងឺរបស់នាងជាអ្វី គឺនាងត្រូវធ្វើការវះកាត់។ ដោយសារតែនាងទើបតែរៀបការហើយ នាងដឹងថាការវះកាត់ប្រភេទនេះអាចរារាំង ឬអាចធ្វើឱ្យនាងមិនអាចមានកូនបាន។ នេះមិនមែនជាជម្រើសរបស់អេមីទេ។ នាងមានចិត្តប៉ងប្រាថ្នាចង់ក្លាយជាម្តាយគេ។ តាមរយៈរូបកាំរស្មីអ៊ិចនេះ យើងក៏មើលឃើញថា ដុំសាច់នោះបានធ្វើឱ្យសរីរាង្គដទៃទៀតរបស់នាងផ្លាស់ប្តូរទីកន្លែង ហើយវាបានធ្វើឱ្យអេមីមានបញ្ហាជាមួយការរំលាយអាហារ ព្រមទាំងបញ្ហាតម្រងនោមធ្ងន់ធ្ងរផងដែរ។ នាងបានសម្រេចចិត្តយកចិត្តទុកដាក់សិក្សាព្រះបន្ទូលរបស់ព្រះ និងចំណាយពេលផ្តោតអារម្មណ៍ទាំងស្រុងរបស់នាងលើព្រះបន្ទូលទាក់ទងនឹងការព្យាបាល។ ក្នុងអំឡុងសប្តាហ៍ទាំងនោះ ខ្ញុំកំពុងតែបង្រៀនមេរៀនជាស៊េរីអំពីការព្យាបាលនៅក្រុមជំនុំរបស់យើង។ នៅចុង

**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

បញ្ចប់នៃមេរៀនជាសេរីនោះ អេមីបានសុំឱ្យក្រុមអ្នកចាស់ទុំដាក់ដៃលើនាង និងអធិស្ឋានសម្រាប់ការព្យាបាល យោងតាមខគម្ពីរ យ៉ាកុប ៥:១៤-១៥ ហើយពួកយើងបានអធិស្ឋានឱ្យនាង។

> *ក្នុងចំណោមបងប្អូន បើនរណាមានជំងឺ ត្រូវអញ្ជើញព្រឹទ្ធាចារ្យរបស់ក្រុមជំនុំមកដើម្បីឱ្យលោកទាំងនោះអធិស្ឋានឱ្យគាត់ និងលាបប្រេងឱ្យក្នុងព្រះនាមព្រះអម្ចាស់។ ពាក្យអធិស្ឋានដែលផុសចេញមកពីជំនឿ នឹងសង្គ្រោះអ្នកជំងឺនោះ ហើយព្រះអម្ចាស់នឹងប្រោសគាត់ឱ្យក្រោកឡើងវិញ ប្រសិនបើគាត់បានប្រព្រឹត្តអំពើបាប ព្រះអង្គនឹងលើកលែងទោសឱ្យ។*
>
> យ៉ាកុប ៥:១៤-១៥

អេមីមានជំនឿលើព្រះបន្ទូលព្រះ នាងបានប្រកាសទទួលយកការព្យាបាលពីទ្រង់ នៅពេលពួកយើងដាក់ដៃអធិស្ឋានឱ្យនាង។ ទោះបីរូបកាយរបស់នាងមិនបានបង្ហាញអំពីការជាសះស្បើយនៅពេលយើងអធិស្ឋានឱ្យនាងក៏ដោយ នាងជឿជាក់ថានាងបានជាសះស្បើយហើយ។

ពីរសប្តាហ៍ក្រោយមក ពេលដែលនាងចូលគេង នាងមិនបានឃើញអ្វីប្រែប្រួលនៅលើរូបរាងកាយរបស់នាង ដែលបញ្ជាក់ថានាងបានជាសះស្បើយទេ ប៉ុន្តែពេលដែលនាងភ្ញាក់ពីដំណេកវិញនៅពេលព្រឹកថ្ងៃបន្ទាប់ នាងភ្ញាក់ផ្អើលជាខ្លាំង! នាងស្រកទំងន់អស់ប្រហែល៦គីឡូ ហើយចង្កេះរបស់នាងរួមតូចប្រហែល២៣សង់ទីម៉ែត្រ ក្នុងរយៈពេលតែ១យប់ប៉ុណ្ណោះ។ ខ្នងរបស់នាងដែលបានកោង ឥឡូវនេះបានត្រលប់មករកភាពធម្មតាវិញ។ នាងបានជាសះស្បើយភ្លាមៗ!



ពេលមុន ពេលក្រោយ

រូបភាពទាំងពីរនេះបង្ហាញអំពីការព្យាបាលដ៏អស្ចារ្យ។ រូបភាពខាងឆ្វេងដៃ ជារូបភាពពេលអេមីចូលគេង។ រីឯរូបភាពនៅខាងស្តាំដៃ ជារូបភាពពេលអេមីបានភ្ញាក់ឡើង។



**បរិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្រ្ត

អ្នកអាចឃើញរូបកាំរស្មីអិចនៅទីនេះ នៅខាងឆ្វេងដៃ ជារូបមុនពេលអេមីបានជាសះស្បើយ ហើយនៅខាងស្ដាំដៃ ជារូបដែលនាងបានថត១សប្តាហ៍បន្ទាប់ពីនាងបានជាសះស្បើយ។ សូមកត់សម្គាល់ការផ្លាស់ប្ដូរយ៉ាងខ្លាំងនៃឆ្អឹងខ្នងរបស់នាង!

នៅពេលនោះអេមីគឺជាអ្នកដឹកនាំថ្វាយបង្គំរបស់យើង ហើយនាងក៏នៅតែជាអ្នកដឹកនាំថ្វាយបង្គំនៅក្រុមជំនុំរបស់យើងដដែលទេ។ មែនហើយ អ្នកអាចនឹកស្រមៃថាមានរឿងអ្វីកើតឡើង ពេលដែលនាងទៅក្រុមជំនុំនៅព្រឹកថ្ងៃអាទិត្យបន្ទាប់ពីនាងបានជាសះស្បើយ មនុស្សនៅក្រុមជំនុំបានសម្លឹងមើលមកនាងគ្រប់គ្នា! ពួកគេបានឈប់នៅបន្ទប់រង់ចាំភ្ញៀវ ទាំងមានអារម្មណ៍ភ្ញាក់ផ្អើលជាខ្លាំង ហើយបាននិយាយថា «តើមានរឿងអ្វីកើតឡើងចំពោះអ្នក? តើអ្នកបានប្ដូររាងកាយថ្មីឬ?»។ មនុស្សនៅក្រុមជំនុំទាំងអស់គ្នាមានអារម្មណ៍ភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលអេមីដឹកនាំការថ្វាយបង្គំនៅព្រឹកថ្ងៃអាទិត្យនោះ ហើយការអស្ចារ្យនេះបាននាំមនុស្សជាច្រើនឱ្យចូលទៅជិតទ្រង់ និងបានព្យាបាលមនុស្សជាច្រើននាក់ទៀតផងដែរ។

អ្នកគួរតែព្រមទទួលស្គាល់ថា មនុស្សចង់ឃើញដំណើរការនៃព្រះរាជរបស់ព្រះជាម្ចាស់។ នៅក្នុង កិច្ចការ ១:១៨ យើងឃើញថាការចាក់ប្រេងតាំង ឬការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធពិតជាសំខាន់ខ្លាំងណាស់!

> *«ប៉ុន្តែ អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី»។*

កិច្ចការ ១:៨

យោងតាមការយកចិត្តទុកដាក់ និងព្រះបន្ទូលរបស់ព្រះយេស៊ូ វាជាការចាំបាច់ក្នុងការបង្ហាញអំពីព្រះរាជរបស់ព្រះ។

> *«អស់អ្នកដែលជឿនឹងធ្វើទីសម្គាល់ទាំងនេះ គឺគេនឹងដេញអារក្សក្នុងនាមខ្ញុំ គេនិយាយភាសាថ្មី។ ប្រសិនបើគេកាន់ពស់ ឬផឹកអ្វីដែលមានជាតិពុល ក៏គេពុំមានគ្រោះថ្នាក់អ្វីដែរ។ ប្រសិនបើគេដាក់ដៃលើអ្នកជំងឺអ្នកជំងឺនឹងបានជាសះស្បើយ»។*

ម៉ាកុស ១៦:១៦-១៧

ការកាន់សត្វពស់ និងផឹកអ្វីដែលមានជាតិពុល គឺសំដៅទៅលើនគររបស់មារសាតាំង ហើយវាទាក់ទងទៅនឹងសេចក្តីភ័យខ្លាច។ នគររបស់មារសាតាំងបានបរាជ័យហើយ។ ព្រះយេស៊ូមិនលើកទឹកចិត្តឱ្យយើងចាប់កាន់សត្វពស់ដែលមានពិស ឬផឹកជាតិពុលពិតមែននោះទេ ប៉ុន្តែទ្រង់បានប្រើឃ្លានេះ ជាឧទាហរណ៍នៃឫទ្ធានុភាពដែលយើងបានទទួល ដែលមានអំណាចលើមារសត្រូវ។ យើងត្រូវយកសិទ្ធិអំណាច និងឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ចូលក្នុងដែនគ្រប់គ្រងរបស់មារសាតាំង និងរំដោះមនុស្សឱ្យមានសេរីភាព!

សូមកត់សម្គាល់ ព្រះយេស៊ូមានបន្ទូលថា អ្នកជឿនឹងធ្វើ «**ទីសម្គាល់ទាំងនេះ**»។ នៅពេលមនុស្សឃើញទីសម្គាល់ (ការបង្ហាញ) នៃព្រះរាជរបស់ព្រះ ពួកគេនឹងសួរថា ការនេះកើតឡើងដោយរបៀបណា។ ទីសម្គាល់បង្ហាញអំពីអ្វីមួយ។ ទីសម្គាល់មិនមែនជាចម្លើយទេ ប៉ុន្តែវាចង្អុលបង្ហាញទៅព្រះយេស៊ូ វាបង្ហាញថាទ្រង់ជាអ្នកណា!

ទីសម្គាល់ទាំងនេះបញ្ឈប់រាល់ការជជែកវែកញែក ថាតើព្រះយេស៊ូជាព្រះអម្ចាស់មែន ឬមិនមែន? ទ្រង់ពិតជា**ព្រះអម្ចាស់**ពិតមែន! នៅពេលដែលមនុស្សដឹងថាទ្រង់ជានរណា ពួកគេនឹងកែប្រែចិត្តគំនិត ហើយបែមករកព្រះជាម្ចាស់វិញ។ នេះជាមូលហេតុដែលអ្នក និងខ្ញុំត្រូវការពិធីជ្រមុជក្នុងវិញ្ញាណដ៏វិសុទ្ធ ហើយយើងមិនអាចធ្វើកិច្ចការអ្វីដោយមានប្រសិទ្ធភាព ដោយគ្មានវាបានទេ!

ដូច្នេះ ពេលនេះយើងបានកសាងមូលដ្ឋានគ្រឹះ អំពីមូលហេតុដែលអ្នកត្រូវការពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយយើងនឹងពិនិត្យមើលបទគម្ពីរ ដែលទាក់ទងនឹងពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ឬការចាក់ប្រេងតាំងនៅជំពូកក្រោយ។

# ជំពូក ៥

# ភស្តុតាងពីបទគម្ពីរ

របៀបដ៏ល្អបំផុតមួយដើម្បីស្វែងយល់អំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ គឺពិនិត្យមើលអ្នកដែលបានទទួលវានៅបុណ្យថ្ងៃទីហាសិប ដែលបានចែងទុកក្នុងសៀវភៅកិច្ចការ។ នៅពេលយើងពិនិត្យមើលខគម្ពីរនីមួយៗ ជំនឿ និងទំនុកចិត្តរបស់អ្នកនឹងកាន់តែកើនឡើង អ្នកនឹងកាន់តែជឿជាក់ថាពិធីនេះក៏សម្រាប់អ្នកផងដែរ។

*នៅបុណ្យថ្ងៃទីហាសិប ពួកសិស្សបានរួមប្រជុំទាំងអស់គ្នា នៅកន្លែងតែមួយ។ រំពេចនោះ ស្រាប់តែមានឮស្នូរសន្ធឹកពីលើមេឃ ដូចខ្យល់បក់បោកយ៉ាងខ្លាំងពេញក្នុងផ្ទះដែលគេនៅ។ ពួកសិស្សបានឃើញហាក់ដូចជា មានអណ្ដាតភ្លើងបែកចេញពីគ្នា ចុះមកសណ្ឋិតលើពួកគេម្នាក់ៗ។ អ្នកទាំងនោះបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានឱ្យ។*

*ពេលនោះ មានជនជាតិយូដា ជាអ្នកគោរពប្រណិប័តន៍ព្រះជាម្ចាស់ មកពីប្រទេសនានា ក្នុងពិភពលោកទាំងមូល ស្នាក់នៅក្រុងយេរូសាឡឹមដែរ។ ពេលស្នូរសន្ធឹកលាន់ឮយ៉ាងខ្លាំងដូច្នោះ មហាជននាំគ្នារត់មកមើល ហើយភ្ញាក់ផ្អើលក្រៃលែងព្រោះម្នាក់ៗបានឮពួកសិស្សនិយាយភាសារបស់ខ្លួន។*

*អ្នកទាំងនោះងឿងឆ្ងល់ខ្លាំងណាស់ គេស្ងើចសរសើរទាំងពោលថា៖ «អ្នកដែលកំពុងនិយាយនេះ សុទ្ធតែជាអ្នកស្រុកកាលីឡេទេតើ។ ចុះហេតុដូចម្ដេចបានជាយើងឮគេនិយាយភាសារបស់យើងរៀងៗខ្លួនទៅវិញដូច្នេះ? គឺទាំងអ្នកស្រុកផាថុស ស្រុកមេឌី ស្រុកអេឡាំ ទាំងអ្នកស្រុកមេសូប៉ូតាមា ស្រុកយូដា ស្រុកកាប៉ាដូគា ស្រុកប៉ុនតុស ស្រុកអាស៊ី ស្រុកព្រីគា ស្រុកប៉ាមភីលា ស្រុកអេស៊ីប ស្រុកលីប៊ីដែលនៅក្បែរស្រុកគីរេន និងអស់អ្នកមកពីក្រុងរ៉ូម ទាំងជនជាតិយូដា ទាំងអ្នក*

*ចូលសាសនាយូដា ទាំងអ្នកមកពីកោះក្រែត ទាំងជនជាតិអារ៉ាប់ យើងបានឮគេថ្លែងអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ជាភាសាយើងទាំងអស់គ្នាផ្ទាល់!»។*

*អ្នកទាំងនោះងឿងឆ្ងល់ខ្លាំងណាស់ មិនដឹងគិតយ៉ាងណា គេសួរគ្នាទៅវិញទៅមកថា៖ «តើហេតុការណ៍នេះ មានន័យដូចម្ដេច?»។ ប៉ុន្តែ មានអ្នកខ្លះទៀតបែរជានិយាយចំអកថា៖ «ពួកអស់ហ្នឹងសុទ្ធតែស្រវឹងស្រាទេតើ!»។*

កិច្ចការ ២:១-១៣

រឿងទីមួយដែលខ្ញុំចង់ឱ្យអ្នកឃើញគឺ ព្រះគម្ពីរចែងថា**ពួកគេទាំងអស់គ្នា**បានបំពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ! រឿងទីពីរ គឺពួកគេ*ទាំងអស់គ្នា*បាននិយាយជាភាសាដទៃ។ ប្រហែលជាអ្នកធ្លាប់បានឮមនុស្សពណ៌នាអំពីបុណ្យថ្ងៃទីហាសិប និងពន្យល់អំពីមូលហេតុដែលពួកគេនិយាយជាភាសាដទៃ។ អ្នកខ្លះទទូចថា ក្រុមជំនុំមានបទពិសោធនោះតែម្ដងហ្នឹងទេ ដោយសារមានមនុស្សជាច្រើនមកពីគ្រប់ជាតិសាសន៍បានមកជួបជុំគ្នា ដូច្នេះវាជាការចាំបាច់ត្រូវតែមានភាសាដទៃ ដើម្បីផ្សាយដំណឹងល្អដល់មនុស្សទាំងអស់ដែលនិយាយភាសាផ្សេងៗគ្នា។

ប៉ុន្តែ ប្រសិនបើអ្នកពិនិត្យមើលព្រះគម្ពីរ អ្នកនឹងឃើញថា មនុស្ស១២០នាក់ដែលនៅបន្ទប់ខាងលើនោះ កំពុងតែនិយាយអំពីកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ ពួកគេមិនបានផ្សាយដំណឹងល្អទេ។ ពួកគេគ្រាន់តែសរសើរតម្កើងព្រះជាម្ចាស់តែប៉ុណ្ណោះ!

*«យើងបានឮគេថ្លែងអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ជាភាសាយើងទាំងអស់គ្នាផ្ទាល់!»។ អ្នកទាំងនោះងឿងឆ្ងល់ខ្លាំងណាស់ មិនដឹងគិតយ៉ាងណា គេសួរគ្នាទៅវិញទៅមកថា៖ «តើហេតុការណ៍នេះ មានន័យដូចម្ដេច?»។*

កិច្ចការ ២:១១-១២

មនុស្សដែលបានឈរនៅទីនោះ និងបានឮពួកគេសរសើរតម្កើងព្រះជាម្ចាស់ ជាភាសាកំណើតរបស់ពួកគេផ្ទាល់ បានភ្ញាក់ផ្អើល និងងឿងឆ្ងល់ជាខ្លាំង។ បន្ទាប់មក លោកពេត្រុសបានក្រោកឈរឡើង និងបានប្រកាសសារនៃសេចក្ដីសង្គ្រោះ ហើយមានមនុស្សចំនួន ៣,០០០នាក់ បានបន្ថែមទៅក្នុងក្រុមជំនុំនៅថ្ងៃនោះ។ ប្រសិនបើពួកសាវ័កកំពុងតែ*ប្រកាសព្រះបន្ទូល*ជាភាសាដទៃ នោះលោកពេត្រុសនឹងមិនចាំបាច់ក្រោកឈរឡើង ហើយប្រកាស

ព្រះបន្ទូលទេ។ ប៉ុន្តែ ទាល់តែលោកពេត្រុសក្រោកឈរដើម្បីប្រកាសព្រះបន្ទូល ទើបពួកគេយល់អំពីអត្ថន័យនៃអ្វីដែលពួកគេបានឮ។ ភាសាដទៃមិនត្រូវបានប្រើដើម្បីផ្សាយដំណឹងល្អនៅពេលនោះទេ ហើយវាក៏មិនត្រូវបានប្រើដើម្បីផ្សាយដំណឹងល្អនៅពេលបច្ចុប្បន្ននេះដែរ។ យើងនឹងមើលអត្ថប្រយោជន៍នៃភាសាដទៃនៅជំពូកក្រោយ ប៉ុន្តែសម្រាប់ជំពូកនេះ ខ្ញុំនឹងនិយាយអំពីការជជែកវែកញែករកហេតុផលជាទូទៅដែលខ្ញុំធ្លាប់ឮទាក់ទងនឹងភាសាដទៃ។

ជាថ្មីម្តងទៀត ខ្ញុំចង់បញ្ជាក់អំពីអ្វីដែលព្រះគម្ពីរចែង ពួកគេ*ទាំងអស់គ្នា*បានទទួល និងបាននិយាយជាភាសាដទៃ*ទាំងអស់គ្នា*។ ប្រសិនបើព្រះគម្ពីរបាននិយាយអំពីការនិយាយជាភាសាដទៃតែម្តងនោះទេ យើងអាចមានការសង្ស័យថាការនិយាយជាភាសាដទៃពិតជាសម្រាប់ក្រុមជំនុំទាំងមូលមែន ឬមិនមែន។ ប៉ុន្តែ ព្រះគម្ពីរមិនបាននិយាយអំពីភាសាដទៃតែម្តងនោះទេ។ ផ្ទុយទៅវិញ យើងឃើញហេតុអស្ចារ្យនេះនៅតែបន្តកើតឡើងចំពោះ*មនុស្សគ្រប់គ្នា*ដែលទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ បន្ទាប់ពីបុណ្យថ្ងៃទីហាសិបមក។

ខ្ញុំចង់ប្រាប់អ្នកអំពីបុរសម្នាក់ដែលមានវត្តមាននៅបុណ្យថ្ងៃទីហាសិបនោះដែរ គាត់ឈ្មោះភីលីព។

> *ពួកសិស្សដែលបែកខ្ញែកគ្នានោះ បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ទាំងផ្សព្វផ្សាយដំណឹងល្អអំពីព្រះបន្ទូល។ លោកភីលីពបានធ្វើដំណើរទៅក្រុងមួយនៅស្រុកសាម៉ារី ហើយប្រកាសប្រាប់អ្នកក្រុងអំពីព្រះគ្រិស្ត។ មហាជនរួមចិត្តគំនិតគ្នាពេញចិត្តនឹងពាក្យសម្ដីរបស់លោកភីលីព ព្រោះគេបានឮលោកមានប្រសាសន៍ និងបានឃើញទីសម្គាល់ដ៏អស្ចារ្យ ដែលលោកបានធ្វើ។*

កិច្ចការ ៨:៤-៦

នៅទីនេះ យើងឃើញលោកភីលីពកំពុងតែបង្ហាញទីសម្គាល់អំពីព្រះរាជរបស់ព្រះជាម្ចាស់ ហើយមនុស្សកំពុងតែស្ដាប់គាត់និយាយ។ នេះជាអ្វីដែលគួរតែកើតឡើងនាពេលបច្ចុប្បន្ននេះ! នៅពេលមនុស្ស*ឃើញ*ទីសម្គាល់ នៅពេលពួកគេ*ឃើញភស្តុតាង*នៃព្រះរាជរបស់ព្រះ ពួកគេនឹងយកចិត្តទុកដាក់ស្ដាប់អ្វីដែលអ្នកកំពុងតែនិយាយទៅកាន់ពួកគេ។

*គឺមានវិញ្ញាណអាក្រក់ចេញពីមនុស្សជាច្រើន ទាំងស្រែកខ្លាំងៗ និងមានមនុស្សខ្វិន មនុស្សស្លាប់ដៃជើងជាច្រើនបានជា។ ប្រជាជននៅក្រុងនោះ មានអំណរសប្បាយដ៏លើសលប់។*

កិច្ចការ ៨:៧-៨

សូមកត់សម្គាល់ថា លោកភីលីពកំពុងតែបង្ហាញឫទ្ធានុភាពដែលគាត់ទើបតែបានទទួលនៅក្រុងយេរូសាឡឹម។ គាត់បានធ្វើទីសម្គាល់ ដោយសារឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដែលមនុស្សគ្រប់គ្នាបានឃើញ។ គាត់បានទទួល*ឌូណាមីស* (ពាក្យជាភាសាក្រិចសម្រាប់ ឫទ្ធានុភាព) មកពីព្រះជាម្ចាស់។ ដូច្នេះ គាត់អាចធ្វើជាបន្ទាល់របស់ព្រះរាជរបស់ព្រះជាម្ចាស់បាន។

*ក្រុមសាវ័កនៅក្រុងយេរូសាឡឹមបានឮដំណឹងថា អ្នកស្រុកសាម៉ារីនាំគ្នាទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក៏ចាត់លោកពេត្រុស និងលោកយ៉ូហានឱ្យទៅជួបអ្នកទាំងនោះ។ លុះទៅដល់ស្រុកសាម៉ារី សាវ័កទាំងពីរក៏ទូលអង្វរព្រះជាម្ចាស់ សុំឱ្យពួកអ្នកជឿបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដ្បិតព្រះវិញ្ញាណពុំទាន់<u>យាងចុះមកសណ្ឋិត</u>លើអ្នកណាម្នាក់ ក្នុងចំណោមពួកគេនៅឡើយទេ គឺគេគ្រាន់តែបានទទួលពិធីជ្រមុជទឹក ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូប៉ុណ្ណោះ។ ពេលនោះ លោកពេត្រុស និងលោកយ៉ូហានបានដាក់ដៃលើគេ ហើយគេក៏បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។*

កិច្ចការ ៨:១៤-១៧

នៅពេលដែលពួកសាវ័កនៅក្រុងយេរូសាឡឹមបានឮថា អ្នកស្រុកសាម៉ារីបានទទួលជឿលើព្រះជាម្ចាស់ ពួកគេបានឱ្យលោកពេត្រុស និងលោកយ៉ូហាន ទៅជួបពួកគេ។ នៅពេលពួកគេទៅដល់ ពួកគេបានអធិស្ឋានឱ្យអ្នកស្រុកសាម៉ារី ដើម្បីឱ្យពួកគេទទួលបានព្រះវិញ្ញាណដ៏វិសុទ្ធ ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធ<u>មិនទាន់យាងចុះមកសណ្ឋិត</u>លើអ្នកណាម្នាក់នៅឡើយទេ។ តែព្រះគម្ពីរទើបតែបានប្រាប់ថា មានវិញ្ញាណអាក្រក់ចេញពីមនុស្ស មានមនុស្សជាច្រើនបានជា មានកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ទើបតែបានកើតឡើង ហើយមនុស្សជាច្រើនបានទទួលជឿលើព្រះយេស៊ូ និងបានទទួលពិធីជ្រមុជទឹក។ តែព្រះគម្ពីរក៏បានប្រាប់ផងដែរថា ព្រះវិញ្ញាណដ៏វិសុទ្ធមិនទាន់យាងចុះមក<u>**សណ្ឋិតលើ**</u>អ្នកណាម្នាក់នៅឡើយទេ!

អ្នកឃើញទេ លោកភីលីពបានអធិប្បាយអំពីសេចក្ដីសង្គ្រោះ ហើយពួកគេបានទទួលជឿ ប៉ុន្តែពួកគេមិនទាន់ទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនៅឡើយទេ។ ពួកគេបានកើតជាថ្មីហើយ ប៉ុន្តែមិនទាន់បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធនៅឡើយទេ សូមមើលការប្រើប្រាស់ពាក្យនៅទីនេះ៖ ព្រះវិញ្ញាណពុំទាន់«**យាងចុះមកសណ្ឋិតលើអ្នកណាម្នាក់**» ក្នុងចំណោមពួកគេនៅឡើយទេ។ ជាថ្មីម្ដងទៀត មានភាពខុសគ្នារវាង ការដែលព្រះវិញ្ញាណដ៏វិសុទ្ធគង់*ក្នុង*យើង (កើតជាថ្មី) និងការដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិត*លើ*យើង ជាមួយនឹងឫទ្ធានុភាពរបស់ព្រះជាម្ចាស់។

ព្រះគម្ពីរមិនបាននិយាយអំពីមូលហេតុដែលលោកភីលីពមិនបានអធិប្បាយអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធទេ។ វាអាចទៅរួចដែលថា គាត់បានចាកចេញពីក្រុងយេរូសាឡឹមភ្លាមៗ បន្ទាប់ពីបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធរួចហើយ ហើយនៅពេលនោះគាត់មិនបានដឹងថា ពិធីនេះសម្រាប់អ្នកជឿគ្រប់គ្នាទេ។ ទោះបីជាមានមូលហេតុអ្វីក៏ដោយ វាជាក់ស្ដែងខ្លាំងណាស់ដែលមនុស្សជាច្រើនបានទទួលជឿដំណឹងល្អ និងបានទទួលពិធីជ្រមុជទឹក ដូច្នេះពួកគេបានកើតជាថ្មីហើយ។ ក៏ប៉ុន្តែ សូមកត់សម្គាល់ថា វាមានសារៈសំខាន់ប៉ុណ្ណាចំពោះពួកសាវ័ក ដែលអ្នកស្រុកសាម៉ារីត្រូវទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលពួកគេត្រូវទទួលវាភ្លាមៗ។

កិច្ចការដំបូងដែលពួកសាវ័កបានប្រាប់ឱ្យពួកគេធ្វើ គឺមិនមែនអំពីរបៀបដែលពួកគេត្រូវស្លៀកពាក់ទេ។ ពួកសាវ័កមិនបាននិយាយថា «យើងនឹងប្រាប់ពួកគេអំពីរបៀបស្លៀកពាក់យ៉ាងសុចរិត ឬរបៀបដែលពួកគេត្រូវជួបជុំគ្នានៅក្រុមជំនុំ»។ ពួកសាវ័កមិនបានខ្វល់ខ្វាយអំពីច្បាប់នៃគោលលទ្ធិទេ។ តើកិច្ចការដំបូងបង្អស់ដែលពួកសាវ័កបានយកចិត្តទុកដាក់គឺជាអ្វី? គឺពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ! ដូច្នេះ ពួកគេបានព្យាយាមទៅដល់ស្រុកសាម៉ារីភ្លាមៗ ហើយប្រាប់ពួកគេអំពីពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។

បន្ទាប់មកលោកពេត្រុស និងលោកយ៉ូហានបានដាក់ដៃលើពួកគេ ហើយពួកគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ គឺពួកគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធនៅពេលនោះនៅកន្លែងនោះតែម្ដង។ តើមានភស្តុតាងអ្វីបញ្ជាក់អំពីការនេះ? ខ្ញុំជឿថាវាក៏ដូចជាអ្នកដទៃទៀតផងដែរ គឺពួកគេបានអធិស្ឋានជាភាសាដទៃ។

*កាលលោកស៊ីម៉ូនឃើញថា ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកអ្នកជឿ ដោយសាវ័កដាក់ដៃលើដូច្នោះ គាត់ក៏យកប្រាក់មកជូនសាវ័កទាំងពីរ ហើយពោលថា៖ « សូមលោកប្រគល់ឱ្យខ្ញុំមានអំណាចនេះផង ដើម្បីឱ្យខ្ញុំដាក់ដៃលើអ្នកណា អ្នកនោះនឹងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែរ»។*

*លោកពេត្រុសតបទៅគាត់វិញថា៖ «ចូរឱ្យប្រាក់របស់អ្នកវិនាសអន្តរាយជាមួយអ្នកទៅ អ្នកនឹកស្មានថា អាចយកប្រាក់មកទិញព្រះអំណោយទានរបស់ព្រះជាម្ចាស់បាន! អ្នកគ្មានចំណែក គ្មានសិទ្ធិអ្វីក្នុងកិច្ចការនេះឡើយ ដ្បិតចិត្តរបស់អ្នកមិនទៀងត្រង់ចំពោះព្រះជាម្ចាស់ទាល់តែសោះ។ ចូរលះបង់ចិត្តគំនិតអាក្រក់ចោលទៅ ហើយទូលអង្វរព្រះអម្ចាស់ ក្រែងលោព្រះអង្គលើកលែងទោសឱ្យអ្នកដែលមានចិត្តបែបនេះ ដ្បិតខ្ញុំឃើញថាអ្នកមានចិត្តខ្មៅ ហើយក៏នៅជាប់ចំណងអំពើទុច្ចរិតដែរ»។*

*លោកស៊ីម៉ូនតបទៅវិញថា៖ «សូមលោកទូលអង្វរព្រះអម្ចាស់ឱ្យខ្ញុំផង ដើម្បីកុំឱ្យមានហេតុអាក្រក់ណាមួយកើតឡើងចំពោះរូបខ្ញុំ ដូចលោកមានប្រសាសន៍នោះឡើយ»។*

កិច្ចការ ៨:១៨-២៤

នៅពេលដែលលោកស៊ីម៉ូនបានឃើញថា ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដល់អ្នកជឿដោយការដាក់ដៃ គាត់បានប្រគល់ប្រាក់ឱ្យពួកសាវ័ក ដើម្បីឱ្យគាត់អាចមានអំណាចដូចពួកគេដែរ។ លោកស៊ីម៉ូនច្បាស់ជាបានឃើញអ្វីមួយ ដែលពិតជាជាក់ស្តែង ដែលបានកើតឡើងនៅពេលពួកគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ គាត់ក៏ចង់បានអំណាចនោះដែរ។

ព្រះគម្ពីរមិនបានប្រាប់ថាពួកគេបាននិយាយជាភាសាដទៃ នៅពេលនោះភ្លាមៗទេ ប៉ុន្តែច្បាស់ជាមានអ្វីមួយដែលបានកើតឡើង ដែលជាក់ស្តែង ដែលពួកគេអាចមើលឃើញនឹងភ្នែក។ លោកស៊ីម៉ូនពិតជាបានឃើញអ្វីមួយ ដែលមានអំណាចខ្លាំងក្លា ដែលបានធ្វើឱ្យគាត់ចង់មានសមត្ថភាពអាចធ្វើដូច្នេះដែរ។ តាមរយៈពាក្យសម្តីរបស់គាត់ ខ្ញុំជឿថា ពួកគេបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដូចមនុស្សដទៃផងដែរ ហើយចាប់ផ្តើមនិយាយជាភាសាដទៃ។ ជាថ្មីម្តងទៀត ខ្ញុំចង់បញ្ជាក់ថា ពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធពិតជាសំខាន់ខ្លាំងណាស់ចំពោះក្រុមជំនុំនៅក្រុងយេរូសាឡឹម!

នៅពេលដែលលោកសូលបានប្រែចិត្តគំនិតជឿលើព្រះយេស៊ូ នៅតាមផ្លូវទៅទីក្រុងដាម៉ាស ព្រះជាម្ចាស់បានបញ្ជូនលោកអាណាណាសឱ្យទៅអធិស្ឋានឱ្យគាត់។

*លោកអាណាណាសក៏ចេញទៅ។ លុះទៅដល់ផ្ទះនោះហើយ គាត់ដាក់ដៃលើលោកសូល ហើយមានប្រសាសន៍ថា៖ «បងសូលអើយ! ព្រះអម្ចាស់យេស៊ូដែលបងបានឃើញ នៅតាមផ្លូវបងធ្វើដំណើរមកនោះ ទ្រង់បានចាត់ខ្ញុំមក ដើម្បីឱ្យបងអាចមើលឃើញឡើងវិញ និងឱ្យបងបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ»។*

កិច្ចការ ៩:១៧

ព្រះគម្ពីរមិនបានប្រាប់ថា លោកប៉ូលបាននិយាយជាភាសាដទៃនៅពេលគាត់បានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធទេ ក៏ប៉ុន្តែ យើងដឹងថាគាត់ពិតជាចេះនិយាយភាសាដទៃ ហើយខ្ញុំក៏ជឿថា គាត់បានទទួលវាដូចអ្នកដទៃទៀតបានទទួលផងដែរ។ អ្នកអាចសួរខ្ញុំថា ហេតុអ្វីបានជាខ្ញុំជឿដូច្នោះ។ វាងាយស្រួលបំផុត។ គឺដោយសារតែអ្វីដែលលោកប៉ូលបានសរសេរនៅ ១ កូរិនថូស ១៤:១៨។

*«ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ព្រោះខ្ញុំចេះនិយាយភាសាចម្លែកអស្ចារ្យលើសបងប្អូនទាំងអស់គ្នាទៅទៀត»* (១ កូរិនថូស ១៤:១៨)

ដូច្នេះ យើងអាចសន្និដ្ឋានបានថា លោកប៉ូលបាននិយាយភាសាដទៃ (ភាសាចម្លែកអស្ចារ្យ) នៅពេលគាត់បានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅពេលដែលអ្នកអានជំពូកផ្សេងៗក្នុងសៀវភៅកិច្ចការ អ្នកនឹងឃើញថាពិធីជ្រមុជនេះបន្តកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃទៀតទូទាំងក្រុមជំនុំ។ វាមិនគ្រាន់តែកើតឡើងនៅបុណ្យថ្ងៃទីហាសិបតែម្តងនោះទេ។

ក្រោយមក នៅក្នុងកិច្ចការជំពូក១០ ព្រះជាម្ចាស់បានបញ្ជូនលោកពេត្រុសឱ្យទៅផ្ទះរបស់សាសន៍ដទៃ ហើយបន្ទាប់មកគាត់បានផ្សាយដំណឹងល្អដល់ពួកគេ។ សូមចាំថាការនេះពិតជាមិនធម្មតាទេសម្រាប់លោកពេត្រុស ដែលជាសាសន៍យូដា ហើយទៅផ្ទះសាសន៍ដទៃ។ គាត់បានធ្វើដូច្នេះដោយសារគាត់បានទទួលនិមិត្តមកពីព្រះវិញ្ញាណដ៏វិសុទ្ធ។

*លោកពេត្រុសកំពុងមានប្រសាសន៍នៅឡើយ ស្រាប់តែព្រះវិញ្ញាណដ៏វិសុទ្ធយាងចុះមកសណ្ឋិតលើអស់អ្នកដែលស្តាប់ព្រះបន្ទូល។ ពួកអ្នកជឿជាសាសន៍យូដា ដែលមកជាមួយលោកពេត្រុស ងឿងឆ្ងល់ណាស់ ដោយព្រះជាម្ចាស់បានចាក់*

*បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឱ្យសាសន៍ដទៃដែរ ព្រោះគេបានឮសាសន៍ដទៃទាំងនោះនិយាយភាសាចម្លែកអស្ចារ្យ ព្រមទាំងលើកតម្កើងព្រះជាម្ចាស់ផង។*

*ពេលនោះ លោកពេត្រុសមានប្រសាសន៍ថា៖ «គ្មាននរណាអាចឃាត់យើង មិនឱ្យធ្វើពិធីជ្រមុជទឹកជូនអស់អ្នកដែលបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដូចជាយើងបានទទួលដែរនោះទេ»។ លោកក៏បញ្ជាឱ្យគេធ្វើពិធីជ្រមុជទឹកជូនអ្នកទាំងនោះក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។ បន្ទាប់មក ពួកគេសុំឱ្យលោកស្នាក់នៅជាមួយគេបានយូរថ្ងៃបន្តិចទៀត។*

កិច្ចការ ១០:៤៥-៤៨

នៅពេលដែលលោកពេត្រុសកំពុងតែផ្សាយដំណឹងល្អអំពីព្រះគ្រិស្តនៅផ្ទះរបស់សាសន៍ដទៃ ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងចុះមកសណ្ឋិតលើអស់អ្នកដែលកំពុងតែស្តាប់សាររបស់គាត់។ អ្នកមិនអាចមើលឃើញវិញ្ញាណរបស់ព្រះជាម្ចាស់ទេ បើអីញ្ចឹងតើពួកគេអាចដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកសណ្ឋិតលើពួកគេដោយរបៀបណា? អត្ថបទគម្ពីរនោះបានប្រាប់ថា អ្នកជឿកាត់ស្បែកដែលបានមកជាមួយលោកពេត្រុស ងឿងឆ្ងល់ជាខ្លាំង ដែលព្រះជាម្ចាស់បានចាក់បង្ហូរព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឱ្យសាសន៍ដទៃដែរ <u>ព្រោះគេបានឮសាសន៍ដទៃទាំងនោះនិយាយភាសាដទៃ ព្រមទាំងលើកតម្កើងព្រះជាម្ចាស់</u>។

តើមានភស្តុតាងអ្វីបញ្ជាក់ថាព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅទីនោះ? លោកពេត្រុសច្បាស់ជាស្គាល់អ្វីដែលជាភស្តុតាងបញ្ជាក់ថាព្រះជាម្ចាស់បានទទួលយកពួកគេ។ ភាពជាក់ស្តែងដែលគាត់បានឃើញពួកគេនិយាយជាភាសាដទៃ នៅពេលដែលគាត់មិនទាន់ទាំងបានអធិស្ឋានឱ្យពួកគេទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធផងនោះ គឺជាភស្តុតាងគ្រប់គ្រាន់សម្រាប់គាត់ហើយ។ លោកពេត្រុសបានដឹងថា ពួកគេបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដោយសារពួកគេបានទទួលដូចគាត់បានទទួលដែរ គឺពួកគេបានអធិស្ឋានជាភាសាដទៃ។

អ្នកនឹងឃើញភាពខុសគ្នាយ៉ាងខ្លាំង រវាងអ្វីដែលក្រុមជំនុំពេលបច្ចុប្បន្នចាត់ទុកថាជាការសំខាន់ និងអ្វីដែលក្រុមជំនុំជំនាន់ព្រះគម្ពីរចាត់ទុកថាជាការសំខាន់។ ខគម្ពីរមួយដែលខ្ញុំចូលចិត្តបំផុត ដែលបង្ហាញយ៉ាងច្បាស់ថា អ្នកជឿគ្រប់គ្នាគួរតែទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងបញ្ជាក់ដោយគ្មានការសង្ស័យថា វាជាកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដូចការកើតជាថ្មីដែរ គឺនៅកិច្ចការ ១៩:១-២។

*ពេលដែលលោកអប៉ូឡូសនៅក្រុងកូរិនថូស លោកប៉ូលបានឆ្លងកាត់តំបន់ខ្ពង់រាប ធ្វើដំណើរមកដល់ក្រុងអេភេសូ។ លោកបានជួបសិស្សខ្លះ ហើយសួរថា៖ «កាលបងប្អូនចាប់ផ្ដើមជឿនោះ តើបងប្អូនទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ហើយឬនៅ?»។ គេតបមកលោកវិញថា៖ «យើងខ្ញុំមិនដែលទាំងឮថា មានព្រះវិញ្ញាណដ៏វិសុទ្ធផង!»។*

កិច្ចការ ១៩:១-២

នៅពេលលោកប៉ូលចូលទៅទីក្រុងអេភេសូ គាត់បានជួបជាមួយសិស្សមួយចំនួន ហើយគាត់បានសួរពួកគេថា «តើអ្នកបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធហើយឬនៅ តាំងពីពេលអ្នកបានជឿមក?» នេះគឺជាការយកចិត្តទុកដាក់ដំបូងបង្អស់ដែលលោកប៉ូលមានពេលដែលគាត់បានជួបពួកគេ។

លោកប៉ូលបានដឹងអំពីភាពខុសគ្នារវាងការកើតជាថ្មី និងការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដោយមានការនិយាយជាភាសាដទៃជាភស្តុតាង។

ហេតុអ្វីបានជារឿងដំបូងបង្អស់ដែលគាត់បាននិយាយជាមួយពួកគេគឺជារឿងនេះ? ពីព្រោះថា វាក៏ដូចគ្នានឹងអ្វីដែលព្រះយេស៊ូបាននិយាយនៅក្នុងកិច្ចការ ១:៤ផងដែរ! ទ្រង់ចង់មានបន្ទូលថា «កុំទាន់ទៅណាឆ្ងាយពីក្រុងយេរូសាឡឹមឱ្យសោះ បើមិនទាន់បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធទេនោះ!» តើពួកសាវ័កបានធ្វើអ្វីនៅក្រុងយេរូសាឡឹម នៅពេលពួកគេបានឮដំណឹងថាអ្នកស្រុកសាម៉ារីបានទទួលជឿលើព្រះយេស៊ូ? ពួកគេបាននិយាយថា «បងប្អូនអើយ ចូរយើងចេញទៅស្រុកនោះឥឡូវនេះ។ យើងត្រូវតែប្រាកដថា ពួកគេក៏បានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែរ។» នៅពេលដែលលោកប៉ូលបានធ្វើដំណើរកាត់ក្រុងអេភេសូ គាត់បានជួបពួកសិស្សមួយចំនួននៅទីនោះ ហើយសំណួរដំបូងដែលគាត់បានសួរពួកគេគឺ «តើអ្នកបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធហើយឬនៅ តាំងពីពេលអ្នកបានជឿមក?»

នៅពេលពួកគេបានតបមកវិញថា «ទេ ពួកយើងមិនទាន់បានទទួលទេ។ ពួកយើងមិនដែលទាំងឮថាមានព្រះវិញ្ញាណដ៏វិសុទ្ធផង។» លោកប៉ូលបានសួរពួកគេអំពីពិធីជ្រមុជទឹកដែលពួកគេបានទទួល។ ពួកគេបានឆ្លើយថា «ពិធីជ្រមុជទឹករបស់លោកយ៉ូហាន។» លោកប៉ូលបានប្រាប់ពួកគេថា ពិធីជ្រមុជទឹករបស់លោកយ៉ូហាន ជាពិធីជ្រមុជទឹកនៃការកែប្រែចិត្តគំនិត និងបានប្រាប់ពួកគេឱ្យទទួលជឿលើព្រះអង្គម្ចាស់ដែលនឹងយាងមកបន្ទាប់ពីលោកយ៉ូហាន។ គឺទទួលជឿលើព្រះយេស៊ូ។

ពេលបានឮដូច្នេះ ពួកគេបានទទួលពិធីជ្រមុជក្នុងព្រះនាមព្រះអង្គម្ចាស់ព្រះយេស៊ូគ្រិស្ត (ពិធីជ្រមុជទឹក)។ បន្ទាប់មក នៅពេលដែលលោកប៉ូលបានដាក់ដៃលើពួកគេ ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងចុះមកសណ្ឋិតលើពួកគេ ហើយពួកគេបាននិយាយជាភាសាដទៃ។ សូមកត់សម្គាល់ថា នៅពេលលោកប៉ូលបានសួរសំណួរពួកគេ គាត់បានសន្មតថា ពួកគេបានជឿលើព្រះយេស៊ូ។ ហេតុនេះហើយទើបគាត់បានសួរពួកគេថា «តើអ្នកបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធហើយឬនៅ តាំងពីពេលអ្នកបានជឿមក?» គាត់បានដឹងច្បាស់ថា ពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ខុសគ្នាពីការកើតជាថ្មី។

**ខ្ញុំជឿថា រឿងនេះជាប្រធានបទដ៏ចម្រូងចម្រាសមួយនៅក្នុងក្រុមជំនុំជាច្រើន មិនមែនដោយសារតែវាមិនចែងនៅក្នុងព្រះគម្ពីរទេ តែដោយសារមារសាតាំងស្អប់វាយ៉ាងខ្លាំង។**

ខ្ញុំជឿថា រឿងនេះជាប្រធានបទដ៏ចម្រូងចម្រាសមួយនៅក្នុងក្រុមជំនុំជាច្រើន មិនមែនដោយសារតែវាមិនចែងនៅក្នុងព្រះគម្ពីរទេ តែដោយសារមារសាតាំងស្អប់វាយ៉ាងខ្លាំង។

ព្រោះថា ប្រសិនបើអំណាចនេះ ប្រសិនបើវាជាទ្វារដែលនាំទៅរកការផ្លាស់ប្រែនៃជីវិតមនុស្ស និងជាទីបន្ទាល់ទៅកាន់ពិភពលោកនេះ នោះយើងនឹងត្រូវតយុទ្ធប្រឆាំងនឹងព្រះនៃលោកិយនេះ ហើយយើងដឹងថាគំនិតរបស់ព្រះនៃលោកិយនេះមានលក្ខណៈបែបណា។ ពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធផ្តល់ឱ្យយើងនូវឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដើម្បីឱ្យយើងអាចបំពេញកិច្ចការរបស់ព្រះយេស៊ូ ដើម្បីសរសើរតម្កើងសិរីរុងរឿងព្រះជាម្ចាស់!

# ជំពូក ៦
# តើគ្រប់គ្នាសុទ្ធតែអធិស្ឋានជាភាសាដទៃឬ?

ប្រហែលជាអ្នកធ្លាប់បានឮនរណាម្នាក់និយាយថា ពួកគេមិននិយាយជាភាសាដទៃទេ ហើយពួកគេក៏មិនជឿថាអ្នកជឿគ្រប់គ្នាអាចនិយាយ ឬគួរតែនិយាយភាសាដទៃដែរ។ បន្ទាប់មកពួកគេលើកខគម្ពីរ ១ កូរិនថូស ១២:២៧-៣០ សម្រាប់ជាហេតុផលដែលពួកគេជឿដូច្នោះ។ ពួកគេនិយាយថា លោកប៉ូលក៏បាននិយាយថា គ្រប់គ្នាមិនសុទ្ធតែនិយាយជាភាសាដទៃទេ។ តោះយើងពិនិត្យមើលអត្ថបទគម្ពីរនេះជាមួយគ្នា ហើយមើលថាតើលោកប៉ូលពិតជានិយាយយ៉ាងដូច្នេះមែនឬយ៉ាងណា។

> *បងប្អូនជាព្រះកាយរបស់ព្រះគ្រិស្ត ហើយម្នាក់ៗជាសរីរាង្គនៃព្រះកាយនេះ តាមចំណែករៀងៗខ្លួន។ <u>ក្នុងក្រុមជំនុំ</u>មុនដំបូងបង្អស់ ព្រះជាម្ចាស់បានតែងតាំងឱ្យមានសាវ័ក បន្ទាប់មក ព្រះអង្គតែងតាំងអ្នកថ្លែងព្រះបន្ទូល បន្ទាប់មកទៀត ព្រះអង្គតែងតាំងអ្នកបង្រៀន។ បន្ទាប់ពីនោះ មានព្រះអំណោយទានខាងធ្វើការអស្ចារ្យ ព្រះអំណោយទានខាងប្រោសអ្នកជំងឺឱ្យជា ព្រះអំណោយទានខាងជួយអ្នកដទៃ ព្រះអំណោយទានខាងណែនាំព្រះអំណោយទានខាងនិយាយភាសាចម្លែកអស្ចារ្យ។ តើគ្រប់គ្នាសុទ្ធតែជាសាវ័កឬ? គ្រប់គ្នាសុទ្ធតែជាអ្នកថ្លែងព្រះបន្ទូលឬ? គ្រប់គ្នាសុទ្ធតែជាអ្នកបង្រៀនឬ? គ្រប់គ្នាសុទ្ធតែធ្វើការអស្ចារ្យឬ? តើគ្រប់គ្នាសុទ្ធតែទទួលព្រះអំណោយទានខាងប្រោសអ្នកជំងឺឱ្យជាឬ? <u>គ្រប់គ្នាសុទ្ធតែមានព្រះអំណោយទានខាងនិយាយភាសាចម្លែកអស្ចារ្យឬ?</u> <u>គ្រប់គ្នាសុទ្ធតែមានព្រះអំណោយទានខាងបកប្រែភាសាចម្លែកអស្ចារ្យឬ?</u>*
>
> ១ កូរិនថូស ១២:២៧-៣០

នៅក្នុងសំបុត្រនេះ លោកប៉ូលកំពុងតែប្រាប់ក្រុមជំនុំនៅទីក្រុងកូរិនថូស អំពីរបៀបដែលក្រុមជំនុំគួរជួបជុំគ្នាដោយមានរបៀបរៀបរយ ដើម្បីអាចបម្រើមនុស្សទាំងអស់

ដែលបានមកជួបជុំគ្នា។ នៅពេលនោះពួកគេទាំងអស់គ្នាព្យាយាមប្រជែងគ្នាទៅវិញទៅមក ជាមួយព្រះអំណោយទាន និងគ្រូអធិប្បាយដែលពួកគេចូលចិត្ត។ លោកប៉ូលកំពុងតែណែនាំពួកគេឱ្យចេះធ្វើការរួមគ្នា ប្រៀបដូចជាសរីរាង្គនៃរូបកាយតែមួយ ដោយសេចក្តីស្រលាញ់។ ឥឡូវនេះ យើងនឹងពិនិត្យមើលឱ្យកាន់តែច្បាស់ថែមទៀតនៅក្នុង ១កូរិនថូស ១២: ២៧-២៨៖

*បងប្អូនជាព្រះកាយរបស់ព្រះគ្រិស្ត ហើយម្នាក់ៗជាសរីរាង្គនៃព្រះកាយនេះ តាមចំណែករៀងៗខ្លួន។ក្នុងក្រុមជំនុំ [ខ្ញុំសូមណែនាំឱ្យអ្នកគូសបន្ទាត់ពីក្រោមឃ្លានេះ] មុនដំបូងបង្អស់ ព្រះជាម្ចាស់បានតែងតាំងឱ្យមានសាវ័ក បន្ទាប់មក ព្រះអង្គតែងតាំងអ្នកថ្លែងព្រះបន្ទូល បន្ទាប់មកទៀត ព្រះអង្គតែងតាំងអ្នកបង្រៀន។ បន្ទាប់ពីនោះ មានព្រះអំណោយទានខាងធ្វើការអស្ចារ្យ ព្រះអំណោយទានខាងប្រោសអ្នកជំងឺឱ្យជា ព្រះអំណោយទានខាងជួយអ្នកដទៃ ព្រះអំណោយទានខាងណែនាំព្រះអំណោយទានខាងនិយាយភាសាចម្លែកអស្ចារ្យ។*

លោកប៉ូលនៅបន្តនិយាយថែមទៀត ប៉ុន្តែខ្ញុំសូមឈប់ទីនេះសិន ពីព្រោះខ្ញុំចង់និយាយអំពីឃ្លានេះ «ក្នុងក្រុមជំនុំ»។ គាត់កំពុងតែនិយាយអំពីការជួបជុំក្នុងក្រុមជំនុំ ឬក្នុងវេនថ្វាយបង្គំ។ យើងអាចផ្ទៀងផ្ទាត់នៅក្នុងខគម្ពីរមួយទៀត គឺនៅក្នុង ១ កូរិនថូស ១៤: ១៨-១៩ ដែលលោកប៉ូលបានប្រើឃ្លានេះដូចគ្នា៖

*ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ព្រោះខ្ញុំចេះនិយាយភាសាចម្លែកអស្ចារ្យលើសបងប្អូនទាំងអស់គ្នាទៅទៀត ក៏ប៉ុន្តែ នៅក្នុងក្រុមជំនុំ ខ្ញុំចូលចិត្តនិយាយតែពាក្យប្រាំម៉ាត់ដែលគេយល់ ដើម្បីទូន្មានអ្នកឯទៀតៗជាជាងនិយាយភាសាចម្លែកអស្ចារ្យមួយម៉ឺនម៉ាត់ ដែលគ្មាននរណាស្ដាប់បាន។*

១ កូរិនថូស ១៤:១៨-១៩

លោកប៉ូលនិយាយថា «ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ព្រោះខ្ញុំចេះនិយាយភាសាចម្លែកអស្ចារ្យលើសបងប្អូនទាំងអស់គ្នាទៅទៀត «ក៏ប៉ុន្តែ **នៅក្នុងក្រុមជំនុំ**...» មានឃ្លានេះម្តងទៀតហើយ ហើយពេលនេះវាច្បាស់ណាស់ ដែលលោកប៉ូលកំពុងតែនិយាយអំពីការជួបជុំក្នុងក្រុមជំនុំ មិនមែនក្រុមជំនុំសកលដែលជាព្រះកាយទាំងមូលរបស់ព្រះគ្រិស្តទេ។ យើងទាំងអស់គ្នាយល់ស្របថា លោកប៉ូលគឺជាផ្នែកមួយនៃព្រះកាយរបស់ព្រះគ្រិស្តដែលជា «ក្រុមជំនុំ»។ ពិតណាស់ គាត់ពិតជាផ្នែកមួយនៃព្រះកាយរបស់ព្រះគ្រិស្ត ពិតមែន។

ហើយគាត់និយាយថា គាត់ត្រេកអរណាស់ដែលគាត់និយាយភាសាដទៃ ច្រើនជាងអ្នកជឿទាំងអស់នៅទីក្រុងកូរិនថូសទៅទៀត។ គាត់និយាយបែបនេះ ដោយសារតែក្រុមជំនុំនៅទីនោះមានភាពត្រេកអរចំពោះសមត្ថភាពថ្មីរបស់ពួកគេ ក្នុងការនិយាយជាភាសាដទៃ ហើយពួកគេទៅជាគ្មានសណ្តាប់ធ្នាប់ និងបង្កឱ្យមានភាពច្របូកច្របល់។

គាត់ចង់និយាយថា «អ្នកទាំងអស់គ្នា ខ្ញុំនិយាយភាសាដទៃច្រើនជាងអ្នកទាំងអស់គ្នាទៅទៀត ប៉ុន្តែមានរបៀបក្នុងការប្រើអំណោយទាននេះ«នៅក្នុងក្រុមជំនុំ» ដែលមិនបង្កឱ្យមានភាពច្របូកច្របល់។» គាត់បានបន្តនិយាយថា នៅក្នុងក្រុមជំនុំ (ការជួបជុំអ្នកជឿ) គាត់ចង់និយាយភាសាដែលមនុស្សអាចយល់បាន (ជាភាសាសាមញ្ញធម្មតារបស់ពួកគេ) ដើម្បីឱ្យអ្នកដទៃអាចទទួលការស្អាងឡើង។

នៅក្នុងការជួបជុំក្នុងក្រុមជំនុំ មានមនុស្សខ្លះបម្រើដោយប្រើភាសាដទៃ និងមនុស្សខ្លះទៀតបម្រើដោយប្រើការបកប្រែភាសាដទៃ ដូចបានចែងនៅក្នុង ១ កូរិនថូស ១២ ប៉ុន្តែ គ្រប់គ្នានឹងមិនប្រើ ឬមិនគួរប្រើតែព្រះអំណោយទាននេះ ដើម្បីស្អាងព្រះកាយទាំងមូល។ លោកប៉ូលថែមទាំងនិយាយអំពីការកំណត់ចំនួនមនុស្សដែលគួរបម្រើដោយការនិយាយជាភាសាដទៃ និងបកប្រែភាសាដទៃនៅក្នុងការជួបជុំក្នុងក្រុមជំនុំ ថាច្រើនបំផុតគឺមានគ្នាត្រឹមបីនាក់ប៉ុណ្ណោះ។

*បើបងប្អូននិយាយភាសាចម្លែកអស្ចារ្យ ត្រូវឱ្យពីរ ឬបីនាក់យ៉ាងច្រើននិយាយ ហើយនិយាយម្នាក់ម្តងៗ ដោយមានអ្នកបកប្រែផងដែរ។*(១ កូរិនថូស ១៤:២៧)

ដូច្នេះនៅពេលដែលលោកប៉ូលនិយាយថា គ្រប់គ្នាមិនត្រូវនិយាយជាភាសាដទៃទេ គាត់ចង់សំដៅលើ «នៅក្នុងក្រុមជំនុំ» ឬការជួបជុំនៅក្នុងក្រុមជំនុំ។

អ្នកត្រូវយល់ថា អ្នកជឿទាំងអស់គ្នានឹងមានសមត្ថភាពក្នុងការនិយាយជាភាសាដទៃ ប៉ុន្តែមិនមែនគ្រប់គ្នានឹងមានការចាក់ប្រេងតាំងដើម្បីបម្រើ ដោយប្រើការនិយាយជាភាសាដទៃ និងការបកប្រែភាសាដទៃនៅក្នុងការជួបជុំក្នុងក្រុមជំនុំទេ។ ប្រសិនបើអ្នកមានការចាក់ប្រេងតាំង ដើម្បីបម្រើដោយប្រើអំណោយទាននេះនៅពេលជួបជុំក្នុងក្រុមជំនុំ ព្រះគម្ពីរចែងថា អ្នកគួរតែអធិស្ឋានសុំឱ្យចេះបកប្រែផងដែរ។

*«ហេតុនេះ អ្នកដែលនិយាយភាសាចម្លែកអស្ចារ្យត្រូវអធិស្ឋានសុំឱ្យចេះបកប្រែន័យផង។»*(១ កូរិនថូស ១៤:១៣)

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

ខ្ញុំជឿថាអ្នកដែលមានអំណោយទាននិយាយជាភាសាដទៃនៅក្នុងការជួបជុំក្នុងក្រុមជំនុំ គឺជាអ្នកដែលទំនងបំផុតដែលត្រូវបកប្រែន័យផងដែរ ដោយសារពួកគេកំពុងតែទទួលសារនេះពីព្រះវិញ្ញាណ។

ហេតុអ្វីអ្នកគួរអធិស្ឋានជាភាសាដទៃ? អ្នកដឹងទេ មារសាតាំងស្អប់អ្នកជឿដែលចេះអធិស្ឋានដោយប្រើវិញ្ញាណ (ជាភាសាដទៃ) ហើយខ្ញុំចង់ប្រាកដថា អ្នកដឹងថាដោយសារមូលហេតុអ្វី។

នៅពេលដែលលោកប៉ូលនិយាយថា គាត់ត្រេកអរណាស់ដែលគាត់អធិស្ឋានជាភាសាដទៃច្រើនជាងអ្នកជឿដទៃទៀត ប្រាកដជាមានហេតុផលដែលគាត់មានអារម្មណ៍បែបនេះ។ លោកប៉ូលបានបញ្ចេញមតិយោបល់នៅក្នុង ១ កូរិនថូស ១៤ ដែលយើងគួរអានដើម្បីស្វែងយល់បន្ថែមទៀត។

*«អ្នកណានិយាយភាសាចម្លែកអស្ចារ្យ អ្នកនោះ**កសាង**តែខ្លួនឯងប៉ុណ្ណោះ រីឯអ្នកថ្លែងព្រះបន្ទូលវិញ **កសាង**ក្រុមជំនុំ។»* (១ កូរិនថូស ១៤:៤)

យើងនឹងពិនិត្យមើលឱ្យកាន់តែស៊ីជម្រៅជាងនេះបន្តិចទៀត។ តើការកសាងនៅក្នុងខគម្ពីរនេះ មានន័យយ៉ាងដូចម្តេច? ពាក្យកសាងមានន័យថា «ណែនាំ ឬផ្តល់ផលប្រយោជន៍ ជាពិសេសខាងសីលធម៌ ឬខាងវិញ្ញាណ។ វាក៏មានន័យថា លើកស្ទួយផងដែរ។»[2]

អ្នកអាចយល់ស្របថា ជាច្រើនលើកអ្នកត្រូវការការណែនាំ ដើម្បីដឹងថាត្រូវទៅផ្លូវណា ដើម្បីយល់អំពីស្ថានភាពមួយ ឬដើម្បីធ្វើការសម្រេចចិត្តត្រឹមត្រូវ។ ហើយការអធិស្ឋានជាភាសាដទៃ អាចជួយដល់អ្នកបាន៖ ដើម្បីកសាងអ្នក ឬផ្តល់ការណែនាំដល់ជីវិតអ្នក។ លោកប៉ូលបានបញ្ជាក់អំពីចំណុចនេះយ៉ាងច្បាស់នៅក្នុង រ៉ូម ៨:២៦-២៧៖

*យ៉ាងណាមិញ ព្រះវិញ្ញាណក៏យាងមកជួយ<u>យើងដែលទន់ខ្សោយ</u>នេះដែរ ដ្បិតយើងពុំដឹងអធិស្ឋានដូចម្តេច ដើម្បីឱ្យបានសមនោះឡើយ តែព្រះវិញ្ញាណផ្ទាល់ ទ្រង់ទូលអង្វរឱ្យយើង ដោយព្រះសូរសៀងដែលគ្មាននរណាអាចថ្លែងបាន។ រីឯព្រះជាម្ចាស់ដែលឈ្វេងយល់ចិត្តមនុស្ស ទ្រង់ជ្រាបព្រះបំណងរបស់ព្រះវិញ្ញាណ ព្រោះព្រះវិញ្ញាណទូលអង្វរឱ្យប្រជាជនដ៏វិសុទ្ធ ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។*

លោកប៉ូលប្រាប់ពួកយើងថា យើងមានបញ្ហា និងមានភាពខ្សោយ៖ «យើងពុំដឹងអធិស្ឋានដូចម្ដេច។» អ្នកអាចសួរថា «ហេតុអ្វីបានជាវាជាចំណុចខ្សោយ?» យើងអាចដឹងថាវាជាចំណុចខ្សោយ ដោយសារខគម្ពីរមួយទៀតនៅ ១ យ៉ូហាន ៥:១៤-១៥។

**«យ៉ាងណាមិញ ព្រះវិញ្ញាណក៏យាងមកជួយយើងដែលទន់ខ្សោយនេះដែរ ដ្បិតយើងពុំដឹងអធិស្ឋានដូចម្ដេច»**

**រ៉ូម ៨:២៦**

*ហេតុនេះហើយបានជាយើងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភក្ត្រព្រះអង្គ គឺថា ប្រសិនបើយើងទូលសូមអ្វី ស្របតាមព្រះហឫទ័យរបស់ព្រះអង្គ នោះទ្រង់នឹងព្រះសណ្ដាប់យើងជាមិនខាន។ បើយើងដឹងថា ព្រះអង្គទ្រង់ព្រះសណ្ដាប់យើង ទោះបីយើងទូលសូមអ្វីពីព្រះអង្គក៏ដោយ យើងដឹងថា យើងបានទទួលអ្វីៗដែលយើងទូលសូមនោះរួចហើយ។*

ប្រសិនបើយើងមិនដឹងអំពីព្រះហឫទ័យព្រះ ឬមិនមានទំនុកចិត្តថាអ្វីដែលយើងទូលសូមព្រះជាម្ចាស់ វាស្របតាមព្រះហឫទ័យរបស់ទ្រង់ ឬមិនស្រប នោះយើងនឹងមិនអាចទូលសូមដោយជំនឿ (យល់ស្របជាមួយព្រះជាម្ចាស់) បានទេ ហើយប្រសិនបើយើងមិនអាចទូលសូមទ្រង់ដោយជំនឿទេ នោះយើងកំពុងតែស្ថិតក្នុងសភាពទន់ខ្សោយហើយ ព្រោះថាយើងមិនអាចចូលក្នុងព្រះគុណ ឬអំណាចរបស់ព្រះជាម្ចាស់ ដោយគ្មានជំនឿបានទេ។ ដូច្នេះ លោកប៉ូលនិយាយថា នៅពេលយើងពុំដឹងថាត្រូវអធិស្ឋានដូចម្ដេច យើងកំពុងតែខ្សោយហើយ ហើយការអធិស្ឋានជាភាសាដទៃ អាចជួយយើងបាន។ យើងនឹងអានខគម្ពីរនេះម្ដងទៀត។

*យ៉ាងណាមិញ ព្រះវិញ្ញាណក៏យាងមកជួយយើងដែលទន់ខ្សោយនេះដែរ <u>ដ្បិតយើងពុំដឹងអធិស្ឋានដូចម្ដេច</u> ដើម្បីឱ្យបានសមនោះឡើយ។*

រ៉ូម ៨:២៦

ចំណុចខ្សោយរបស់យើងគឺ យើងមិនដឹងថាត្រូវអធិស្ឋានដូចម្ដេច! ព្រះគម្ពីរមិនបានប្រាប់យើងថា យើងគួរតែរៀបការជាមួយអ្នកណា គួរតែរស់នៅកន្លែងណា ឬគួរតែធ្វើការអ្វីទេ។ ប្រសិនបើយើងមិនដឹងអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ នោះយើងមិនអាចដឹង និងជឿជាក់ថាយើងទទួលបានអ្វីដែលយើងទូលសូមពីព្រះជាម្ចាស់ទេ។ ជាថ្មីម្ដងទៀត នេះជាចំណុចខ្សោយដ៏ធំមួយ! យើងគ្មានទំនុកចិត្តពេលយើងអធិស្ឋាន នៅពេលយើងមិនដឹង

អំពីព្រះហឫទ័យរបស់ព្រះ។ ប៉ុន្តែ មានរបៀបដែលយើងអាចដឹងអំពីព្រះហឫទ័យរបស់ព្រះ ក្នុងគ្រប់ស្ថានភាពរបស់យើង។ មានរបៀបមួយដែលយើងអាចដឹងប្រាកដអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីឱ្យយើងអាចអធិស្ឋានដោយមានជំនឿ និងទំនុកចិត្ត។

នេះហើយជាអ្វីដែលលោកប៉ូលចង់និយាយ។ ការកសាងដែលគាត់កំពុងតែនិយាយ គឺមានន័យថា យើងអាចទទួលបាននូវចំណេះដឹងមួយប្រភេទ ជាចំណេះដឹងដែលទទួលបានមកពីព្រះជាម្ចាស់។ ហើយយើងអាចទទួលចំណេះដឹងនេះបាន ដោយស្តាប់តាមការណែនាំរបស់ព្រះវិញ្ញាណ តាមរយៈការអធិស្ឋានដោយប្រើវិញ្ញាណ ឬការអធិស្ឋានជាភាសាដទៃ។ យើងអាចអានខគម្ពីរមួយទៀតនៅក្នុង រ៉ូម ៨:២៦-២៧ ដើម្បីស្វែងយល់បន្ថែមអំពីការណែនាំរបស់លោកប៉ូល៖

> *តែព្រះវិញ្ញាណផ្ទាល់ ទ្រង់ទូលអង្វរឱ្យយើង ដោយព្រះសូរសៀងដែលគ្មាននរណាអាចថ្លែងបាន។ រីឯព្រះជាម្ចាស់ដែលឈ្វេងយល់ចិត្តមនុស្ស ទ្រង់ជ្រាបព្រះបំណងរបស់ព្រះវិញ្ញាណ ព្រោះព្រះវិញ្ញាណទូលអង្វរឱ្យប្រជាជនដ៏វិសុទ្ធ ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។*

លោកប៉ូលនិយាយថា ព្រះវិញ្ញាណទូលអង្វរឱ្យយើង ដោយព្រះសូរសៀងដែលគ្មាននរណាអាចថ្លែងបាន សូមមើលខគម្ពីរដែលបានចែងមុននេះ ដើម្បីកាន់តែយល់អំពីអ្វីដែលគាត់កំពុងតែនិយាយ។

> *យើងដឹងហើយថា មកទល់ថ្ងៃនេះ ពិភពលោកទាំងមូល<u>កំពុងតែស្រែកថ្ងូរ និងឈឺចុកចាប់ដូចជាស្ត្រីដែលហៀបនឹងសំរាលកូន</u>។ មិនត្រឹមតែពិភពលោកប៉ុណ្ណោះទេ សូម្បីតែយើង ដែលបានទទួលព្រះអំណោយទានដំបូងរបស់ព្រះវិញ្ញាណ ក៏<u>ថ្ងូរក្នុងចិត្ត</u> ទាំងទន្ទឹងរង់ចាំព្រះជាម្ចាស់ប្រោសយើងឱ្យទៅជាបុត្ររបស់ព្រះអង្គ និងលោះរូបកាយយើងទាំងស្រុងដែរ ដ្បិតយើងបានទទួលការសង្គ្រោះតែក្នុងសេចក្តីសង្ឃឹមប៉ុណ្ណោះ។ ប្រសិនបើយើងបានអ្វីដែលយើងសង្ឃឹមចង់បាននោះ មិនមែនហៅថាសង្ឃឹមទៀតទេ ព្រោះអ្វីៗដែលយើងបានហើយ តើយើងសង្ឃឹមចង់បានដូចម្តេចទៀត!។ ផ្ទុយទៅវិញ ប្រសិនបើយើងសង្ឃឹមទៅលើអ្វីៗ ដែលយើងមិនទាន់មាន នោះយើងទន្ទឹងរង់ចាំដោយចិត្តព្យាយាម។*
>
> *<u>យ៉ាងណាមិញ ព្រះវិញ្ញាណក៏យាងមកជួយយើងដែលទន់ខ្សោយនេះដែរ</u> ដ្បិតយើងពុំដឹងអធិស្ឋានដូចម្តេច ដើម្បីឱ្យបានសមនោះឡើយ តែព្រះវិញ្ញាណផ្ទាល់*

*ទ្រង់ទូលអង្វរឱ្យយើង ដោយព្រះសូរសៀងដែលគ្មាននរណាអាចថ្លែងបាន។ រីឯព្រះជាម្ចាស់ដែលឈ្វេងយល់ចិត្តមនុស្ស ទ្រង់ជ្រាបព្រះបំណងរបស់ព្រះវិញ្ញាណ ព្រោះព្រះវិញ្ញាណទូលអង្វរឱ្យប្រជាជនដ៏វិសុទ្ធ ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។*

រ៉ូម ៨៖២២-២៧

លោកប៉ូលប្រើពាក្យស្រែកថ្ងូរនៅទីនេះ ជាឧទាហរណ៍ ឬជាការប្រៀបធៀបអំពីអ្វីដែលកំពុងតែកើតឡើងនៅក្នុងខ្លួនយើង។ យើងស្រែកថ្ងូរពីខាងក្នុង ប្រៀបដូចជាស្ត្រីដែលហៀបនឹងសម្រាលកូន។ វាប្រៀបដូចជា យើងកំពុងតែផ្ដល់កំណើតដល់អ្វីមួយពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលនៅខាងក្នុងយើង យើងនឹងទទួលបានអ្វីដែលថ្មី អ្វីដែលយើងមិនធ្លាប់មានពីមុនមក។ ឬយើងអាចនិយាយបានថា យើងទទួលបានអ្វីដែលមិនបានដោយសារសមត្ថភាពផ្ទាល់របស់យើងទេ។ ដូច្នេះ យើង «ផ្ដល់កំណើត»ដល់ចំណេះដឹងដែលយើងមិនធ្លាប់ដឹង ឬអ្វីដែលថ្មី ដែលចេញពីវិញ្ញាណរបស់យើង តាមរយៈការអធិស្ឋានជាភាសាដទៃ។ ព្រះគម្ពីរប្រាប់យើងថា ព្រះវិញ្ញាណទូលអង្វរឱ្យយើង ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ តាមរយៈវិញ្ញាណរបស់យើង។ ព្រះគម្ពីរប្រាប់យើងថា ព្រះជាម្ចាស់ផ្ទាល់ ទ្រង់អធិស្ឋានឱ្យយើង តាមរយៈវិញ្ញាណរបស់យើង ដោយព្រះសូរសៀងដែលគ្មាននរណាអាចថ្លែងបាន (ដែលមិនអាចបង្ហាញតាមពាក្យសម្ដីដែលយើងអាចយល់បាន)។

ដូច្នេះ តាមរយៈខគម្ពីរនេះ យើងស្វែងយល់ថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងទូលអង្វរឱ្យយើង ដោយការស្រែកថ្ងូរ (ផ្ដល់កំណើត) ដោយប្រើពាក្យដែលគ្មាននរណាអាចថ្លែងបាន ពាក្យដែលយើងមិនអាចយល់បាន (ឬភាសាដទៃ)។ រីឯព្រះជាម្ចាស់ដែលឈ្វេងយល់ចិត្តមនុស្ស ទ្រង់ជ្រាបព្រះបំណងរបស់ព្រះវិញ្ញាណ ព្រោះព្រះវិញ្ញាណ (ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់)ទូលអង្វរឱ្យប្រជាជនដ៏វិសុទ្ធ ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ទូលអង្វរឱ្យអ្នក សម្រាប់ស្ថានភាពនីមួយៗ ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ **តាមរយៈវិញ្ញាណរបស់អ្នក នៅពេលអ្នកអធិស្ឋានជាភាសាដទៃ**។

ដូច្នេះ យើងស្ថិតក្នុងសភាពទន់ខ្សោយ នៅពេលដែលយើងមិនដឹងអំពីព្រះហឫទ័យព្រះជាម្ចាស់។ យើងពិបាកអធិស្ឋានដោយមានជំនឿ លុះត្រាតែយើងដឹងអំពីព្រះហឫទ័យរបស់ទ្រង់។ លោកប៉ូលចង់និយាយថា ប្រសិនបើយើងអធិស្ឋានក្នុងវិញ្ញាណ នោះ

ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ផ្ទាល់នឹងទូលអង្វរឱ្យយើង សម្រាប់ស្ថានភាពជាក់លាក់ណាមួយ ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

នៅពេលដែលព្រះវិញ្ញាណរបស់ព្រះ អធិស្ឋានតាមរយៈវិញ្ញាណរបស់យើង ជាភាសាដទៃ តើយើងទទួលបានការកសាងបានយ៉ាងដូចម្ដេច បើយើងមិនទាំងដឹងថាយើងកំពុងតែនិយាយអំពីអ្វីផងនោះ? ចម្លើយទៅកាន់សំណួរនេះ មាននៅក្នុងសំបុត្រមួយទៀត ដែលលោកប៉ូលបានសរសេរ។

> *«អ្វីៗដែលភ្នែកមើលមិនឃើញ អ្វីៗដែលត្រចៀកស្ដាប់មិនឮ និងអ្វីៗដែលចិត្តមនុស្សនឹកមិនដល់នោះ ព្រះជាម្ចាស់បានរៀបចំទុកសំរាប់អស់អ្នកដែលស្រឡាញ់ព្រះអង្គ»។*
>
> *ព្រះជាម្ចាស់បានសំដែងឱ្យយើងដឹងអំពីគំពោងការដ៏លាក់កំបាំងនោះ តាមរយៈព្រះវិញ្ញាណ ដ្បិតព្រះវិញ្ញាណឈ្វេងយល់អ្វីៗទាំងអស់ សូម្បីតែជំរៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ក៏ទ្រង់ឈ្វេងយល់ដែរ។ ចំពោះមនុស្សលោក គ្មាននរណាយល់អំពីមនុស្សបាន ក្រៅពីវិញ្ញាណដែលនៅក្នុងខ្លួនគេនោះទេ។ រីឯព្រះជាម្ចាស់ក៏ដូច្នោះដែរ គ្មាននរណាម្នាក់យល់អំពីព្រះអង្គបាន ក្រៅពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នោះឡើយ។ ចំពោះយើង យើងពុំបានទទួលវិញ្ញាណលោកិយទេ គឺយើងបានទទួលព្រះវិញ្ញាណដែលមកពីព្រះជាម្ចាស់ ដើម្បីឱ្យស្គាល់អ្វីៗដែលព្រះអង្គប្រោសប្រទានមកយើង។ យើងនិយាយសេចក្ដីទាំងនេះ ដោយមិនប្រើពាក្យពេចន៍ដែលប្រាជ្ញារបស់មនុស្សបង្រៀននោះឡើយ គឺយើងប្រើតែពាក្យណាដែលព្រះវិញ្ញាណបង្រៀន ដើម្បីពន្យល់សេចក្ដីពិតខាងវិញ្ញាណដល់មនុស្សដែលបានទទួលព្រះវិញ្ញាណ។*

១ កូរិនថូស ២:៩-១៣

ដំបូងបង្អស់ លោកប៉ូលនិយាយថា យើងអាចឮអ្វីៗដែលត្រចៀកមិនធ្លាប់ឮ អាចមើលឃើញអ្វីៗដែលភ្នែកមិនធ្លាប់ឃើញ ហើយអាចដឹងអ្វីៗដែលចិត្តមនុស្សនឹកមិនដល់ ដូចដែលខ្ញុំបានចែករំលែកជាមួយអ្នករួចមកហើយ។ ប៉ុន្តែ គាត់បានបន្ត ហើយប្រាប់យើងអំពីរបៀបដែលការអស់ទាំងនេះកើតឡើង៖

*ចំពោះមនុស្សលោក គ្មាននរណាយល់អំពីមនុស្សបាន ក្រៅពីវិញ្ញាណដែលនៅក្នុងខ្លួនគេនោះទេ។ រីឯព្រះជាម្ចាស់ក៏ដូច្នោះដែរ គ្មាននរណាម្នាក់យល់អំពីព្រះអង្គបាន ក្រៅពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នោះឡើយ។*

១ កូរិនថូស ២:១១

មុនពេលខ្ញុំពន្យល់អំពីទិដ្ឋភាពនៃខគម្ពីរនេះ ជាដំបូងយើងត្រូវដឹងអំពីមេរៀនមូលដ្ឋាននៃធាតុផ្សំរបស់មនុស្សយើងជាមុនសិន។ យោងតាម ១ ថេស្សាឡូនិក ៥:២៣ មនុស្សយើងមានបីផ្នែក៖ វិញ្ញាណ ព្រលឹង និងរូបកាយ។

*សូមព្រះជាម្ចាស់ ជាប្រភពនៃសេចក្ដីសុខសាន្តប្រោសបងប្អូនឱ្យបានវិសុទ្ធទាំងស្រុង។ សូមព្រះអង្គថែរក្សាខ្លួនបងប្អូនទាំងមូល ទាំងវិញ្ញាណ ទាំងព្រលឹង ទាំងរូបកាយឱ្យបានស្អាតឥតសៅហ្មង នៅថ្ងៃព្រះយេស៊ូគ្រិស្តជាអម្ចាស់នៃយើងយាងមក។*

១ ថេស្សាឡូនិក ៥:២៣

វិញ្ញាណរបស់យើង គឺជាផ្នែកដែលព្រះជាម្ចាស់អាចមានទំនាក់ទំនងជាមួយយើង។ ព្រលឹងរបស់យើង គឺជាផ្នែកដែលមានគំនិត ឆន្ទៈ និងអារម្មណ៍របស់យើង។ ហើយរូបកាយរបស់យើង គឺជារូបកាយដែលយើងមើលឃើញនឹងភ្នែក។ លោកប៉ូលចង់និយាយថា ព្រលឹងរបស់យើង (គំនិត ឆន្ទៈ និងអារម្មណ៍) និងវិញ្ញាណរបស់យើងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នា ដែលវិញ្ញាណរបស់យើងអាចដឹងអំពីគំនិតរបស់យើងបាន។

ហើយការបញ្ច្រាសត្រលប់មកវិញក៏ជាការពិតផងដែរ។ គំនិតនៅក្នុងព្រលឹងយើងអាចដឹងអំពីគំនិតដែលមកពីវិញ្ញាណរបស់យើងដែរ។ លោកប៉ូលនិយាយថា វិញ្ញាណរបស់ព្រះដឹងអំពីគំនិតរបស់ព្រះជាម្ចាស់ ហើយដោយសារយើងបានទទួលព្រះវិញ្ញាណរបស់ព្រះ យើងក៏**<u>អាចដឹង</u>**អំពីអ្វីៗដែលព្រះជាម្ចាស់បានប្រោសប្រទានឱ្យយើង ដោយឥតគិតថ្លៃ។

*ចំពោះយើង យើងពុំបានទទួលវិញ្ញាណលោកិយទេ គឺយើងបានទទួលព្រះវិញ្ញាណដែលមកពីព្រះជាម្ចាស់ ដើម្បីឱ្យស្គាល់អ្វីៗដែលព្រះអង្គប្រោសប្រទានមកយើង។ យើងនិយាយសេចក្ដីទាំងនេះ ដោយមិនប្រើពាក្យពេចន៍ដែលប្រាជ្ញារបស់មនុស្សបង្រៀននោះឡើយ គឺយើងប្រើតែពាក្យណាដែលព្រះវិញ្ញាណបង្រៀន ដើម្បីពន្យល់សេចក្ដីពិតខាងវិញ្ញាណដល់មនុស្សដែលបានទទួលព្រះវិញ្ញាណ។*

១ កូរិនថូស ២:១២-១៣

លោកប៉ូលបន្តនិយាយទៀតថា ចំណេះដឹងដ៏លាក់កំបាំង ជាចំណេះដឹងដែលយើងមិនធ្លាប់បានដឹងពីមុនមក តែត្រូវបានសំដែងឱ្យយើងដឹង តាមរយៈព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ គឺជាអ្វីដែលយើងនិយាយ ដោយប្រើពាក្យដែលព្រះវិញ្ញាណបង្រៀន មិនមែនជាពាក្យដែលបានមកពីប្រាជ្ញារបស់មនុស្សឡើយ ប៉ុន្តែជាពាក្យដែលបានមកពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់វិញ។ យើងដឹងថា លោកប៉ូលកំពុងតែនិយាយអំពីការអធិស្ឋានជាភាសាដទៃ នៅពេលដែលគាត់និយាយអំពីការអធិស្ឋានដោយប្រើវិញ្ញាណ ពីព្រោះគាត់បានប្រើនិយមន័យដូចគ្នា ដើម្បីពិពណ៌នាអំពីការនិយាយជាភាសាដទៃ នៅក្នុង ១ កូរិនថូស ១៤:១៤-១៥៖

> *ប្រសិនបើខ្ញុំអធិស្ឋានជាភាសាចម្លែក វិញ្ញាណខ្ញុំនៅអធិស្ឋានពិតមែន ប៉ុន្តែ ប្រាជ្ញារបស់ខ្ញុំនៅស្ងៀម ឥតរិះគិតអ្វីទេ។ ដូច្នេះ តើខ្ញុំត្រូវធ្វើដូចម្ដេច? ខ្ញុំនឹងអធិស្ឋានដោយប្រើវិញ្ញាណរបស់ខ្ញុំ ហើយខ្ញុំក៏នឹងអធិស្ឋាន ដោយប្រើប្រាជ្ញារបស់ខ្ញុំផងដែរ។ ខ្ញុំនឹងច្រៀង ដោយប្រើវិញ្ញាណរបស់ខ្ញុំ ហើយខ្ញុំក៏នឹងច្រៀងដោយប្រើប្រាជ្ញារបស់ខ្ញុំផងដែរ។*

លោកប៉ូលកំពុងតែប្រើឃ្លា «អធិស្ឋានដោយប្រើវិញ្ញាណ» ដែលវាសំដៅលើការនិយាយជាភាសាដទៃ។ យើងអាចសន្មតថា លោកប៉ូលក៏ចង់សំដៅលើការនិយាយភាសាដទៃដូចគ្នា នៅពេលគាត់និយាយថាយើងនិយាយដោយប្រើពាក្យដែលដែលព្រះវិញ្ញាណបង្រៀន។

> *អ្នកណានិយាយភាសាចម្លែកអស្ចារ្យ អ្នកនោះនិយាយទៅកាន់ព្រះជាម្ចាស់ មិនមែននិយាយទៅកាន់មនុស្សទេ ដ្បិតគ្មាននរណាយល់ន័យ ព្រោះ<u>ព្រះវិញ្ញាណនាំចិត្តអ្នកនោះឱ្យថ្លែងពីសេចក្តីដ៏លាក់កំបាំង</u>។*

១ កូរិនថូស ១៤:២

ជាថ្មីម្តងទៀត លោកប៉ូលនិយាយថាវិញ្ញាណរបស់យើងមានសមត្ថភាពអាចនិយាយចេញ នូវអ្វីដែលយើងមិនធ្លាប់បានដឹងពីមុនមក ឬមានចំណេះដឹងពីមុនមក ឬដូចលោកប៉ូលនិយាយ «សេចក្តីដ៏លាក់កំបាំង»។ សូមកត់សម្គាល់ផងដែរថា លោកប៉ូល

**ខ្ញុំដឹងថាព្រះជាម្ចាស់ទ្រង់ស្មោះត្រង់នឹងព្រះបន្ទូលសន្យារបស់ទ្រង់ ហើយខ្ញុំក៏ដឹងថា ខ្ញុំត្រូវបោះជំហានដោយជំនឿ ដោយជឿជាក់ថាទ្រង់នឹងបង្ហាញផ្លូវ។**

និយាយថា យើងអធិស្ឋានពីសេចក្ដីលាក់កំបាំងនេះ ដោយប្រើវិញ្ញាណរបស់យើង មិនមែនវិញ្ញាណរបស់ព្រះជាម្ចាស់ទេ។ តើអ្វីដែលយើងមិនធ្លាប់បានដឹង អាចមាននៅក្នុងវិញ្ញាណរបស់យើងដោយរបៀបណា? ងាយយល់ណាស់! ដោយសារព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ដែលឥឡូវនេះរួមគ្នាតែមួយជាមួយវិញ្ញាណរបស់យើង។

*ចំពោះមនុស្សលោក គ្មាននរណាយល់អំពីមនុស្សបាន ក្រៅពីវិញ្ញាណដែលនៅក្នុងខ្លួនគេនោះទេ។ រីឯព្រះជាម្ចាស់ក៏ដូច្នោះដែរ គ្មាននរណាម្នាក់យល់អំពីព្រះអង្គបាន ក្រៅពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នោះឡើយ។*

១ កូរិនថូស ២:១១

នៅពេលដែលវិញ្ញាណរបស់យើងទទួលបានគំនិតពីព្រះជាម្ចាស់ គំនិតរបស់យើងក៏ទទួលបានគំនិតរបស់ព្រះជាម្ចាស់ផងដែរ។ នៅពេលដែលគំនិតរបស់យើងទទួលបានគំនិតរបស់ព្រះជាម្ចាស់ យើងហៅការនេះថា ទទួលបាន «ការបើកបង្ហាញ» ឬទទួលបាន «ការបំភ្លឺ» ឬដូចដែលលោកប៉ូលនិយាយថា ទទួលបាន «ការកសាង»។ ឥឡូវនេះ អ្នកបានដឹងអំពីមូលហេតុដែលលោកប៉ូលបាននិយាយថា គាត់មានចិត្តត្រេកអរណាស់ដែលគាត់និយាយភាសាដទៃច្រើនជាងអ្នកដទៃទៀត។ គាត់ទទួលបានប្រយោជន៍ពីការនិយាយជាភាសាដទៃ គឺគាត់អាចដឹងអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងគ្រប់ស្ថានភាពទាំងអស់។

នៅក្នុង ១ កូរិនថូស ២:១៥-១៦ បញ្ជាក់អំពីអ្វីដែលលោកប៉ូលចង់សំដៅលើ៖

*រីឯអ្នកដែលបានទទួលព្រះវិញ្ញាណ វិនិច្ឆ័យបានទាំងអស់ ហើយគ្មានអ្នកណាវិនិច្ឆ័យអ្នកនោះបានឡើយ ដ្បិតក្នុងគម្ពីរមានចែងថា៖ «តើអ្នកណាស្គាល់គំនិតរបស់ព្រះអម្ចាស់? តើអ្នកណាអាចថ្វាយយោបល់ព្រះអង្គបាន?»។ រីឯយើងវិញ យើងមានគំនិតរបស់ព្រះគ្រិស្ដហើយ។*

**បនិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្រ្ត

ការវិនិច្ឆ័យរបស់យើងមិនត្រូវបានកំណត់ដោយការវិនិច្ឆ័យដ៏សាមញ្ញរបស់មនុស្សទេ ប៉ុន្តែយើងអាចធ្វើការវិនិច្ឆ័យអំពីអ្វីៗទាំងអស់ ដោយមានជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធ។ នេះជាដំណឹងល្អ! យើងអាចមានសមត្ថភាពនេះ ដោយសារការអធិស្ឋានដោយប្រើវិញ្ញាណ(ជាភាសាដទៃ) ដើម្បីទទួលបានការបើកបង្ហាញឱ្យដឹងអំពីអ្វីដែលលាក់កំបាំង ឬអ្វីៗដែលយើងមិនធ្លាប់បានដឹងពីមុនមក។ ហើយដោយសារចំណេះដឹងនេះ យើងអាចធ្វើការវិនិច្ឆ័យ ឬធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ក្នុងគ្រប់ស្ថានភាពទាំងអស់!

ពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ គឺជាអាវុធសម្ងាត់របស់ព្រះជាម្ចាស់! ទ្រង់អាចធ្វើឱ្យព្រះហឫទ័យរបស់ទ្រង់បានសម្រេចនៅលើផែនដីនេះ ដោយមិនឱ្យមារសាតាំងដឹងថាមានអ្វីកំពុងតែកើតឡើង។ តាមពិត ការអធិស្ឋានដោយប្រើវិញ្ញាណ គឺជាផ្នែកមួយនៃគ្រឿងសឹកខាងវិញ្ញាណរបស់យើង ដូចបានចែងនៅក្នុង អេភេសូ ៦:១៨៖

> *ចូរអធិស្ឋានគ្រប់ពេលវេលា តាមការណែនាំរបស់ព្រះវិញ្ញាណ ដោយប្រើទាំងពាក្យអធិស្ឋាន ទាំងពាក្យអង្វរគ្រប់យ៉ាង។*

ការអធិស្ឋានដោយប្រើវិញ្ញាណ ជួយយើងទទួលបានយុទ្ធសាស្រ្ត ដែលអាចឱ្យយើងជាសផុតពីមារសត្រូវ ឬទទួលបានយុទ្ធសាស្រ្តដែលល្អឯក និងមិនធម្មតា។

អត្ថប្រយោជន៍មួយដែលបានបង្កប់នៅក្នុងនោះ គឺយើងអាចធ្វើការសម្រេចចិត្តត្រឹមត្រូវនៅក្នុងជីវិតរបស់យើង ដោយស្របតាមចិត្តគំនិតរបស់ព្រះគ្រិស្ត។ ខ្ញុំគិតថា អ្នកក៏យល់ស្របថា ការនេះជាការសំខាន់! សម្រាប់ខ្ញុំ ខ្ញុំយល់ថាការនេះសំខាន់ខ្លាំងណាស់!

ជាឧទាហរណ៍ ខ្ញុំអាចចាំបានពីពេលមួយដែលខ្ញុំត្រូវធ្វើការសម្រេចចិត្តដ៏សំខាន់មួយ ទាក់ទងនឹងអាជីវកម្មរបស់ខ្ញុំ។ អ្នកលក់ម្នាក់ដែលខ្ញុំបានធ្វើការជាមួយ ដែលជាតំណាងអ្នកលក់ឱ្យក្រុមហ៊ុនមួយដែលខ្ញុំធ្វើជំនួញជាមួយ បានគំរាមកំហែងប្តឹងក្រុមហ៊ុនរបស់ខ្ញុំទៅតុលាការ ដោយសារខ្ញុំមិនព្រមតាមគាត់ទៅក្រុមហ៊ុនថ្មីរបស់គាត់។ គាត់ចង់ឱ្យខ្ញុំបន្តធ្វើការជាមួយគាត់ទៀត ដោយសារគាត់បានឈប់ធ្វើការជាមួយក្រុមហ៊ុនដែលខ្ញុំតែងតែធ្វើជំនួញជាមួយ។ ខ្ញុំចូលចិត្តតំណាងអ្នកលក់នោះ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ភាពស្មោះត្រង់របស់ខ្ញុំគឺមានជាមួយក្រុមហ៊ុនដែលគាត់បានធ្វើការឱ្យ មិនមែនជាមួយគាត់ទេ។ ទោះបីក្រុមហ៊ុនរបស់គាត់បានប្រាប់គាត់ថា អតិថិជនទាំងអស់របស់គាត់អាចផ្ទេរទៅក្រុមហ៊ុនថ្មីរបស់គាត់បានក៏ដោយ ដូច្នេះ ខ្ញុំនឹងមិនធ្វើអ្វីខុស ប្រសិនបើខ្ញុំធ្វើជំនួញជាមួយក្រុមហ៊ុនថ្មីរបស់គាត់ ក៏ប៉ុន្តែ ខ្ញុំមិនមានអារម្មណ៍ល្អ នៅពេលដែលទទួលបានការបង្ខិតបង្ខំឱ្យ

ទៅធ្វើការជាមួយក្រុមហ៊ុនថ្មីរបស់គាត់។ ក្រុមហ៊ុនដែលគាត់ធ្លាប់ធ្វើការឱ្យ តែងតែផ្តល់ភាពយុត្តិធម៌ដល់ខ្ញុំ។

គាត់បានគំរាមកំហែងថានឹងប្តឹងខ្ញុំ ព្រោះពីរបីខែមុននេះ គាត់បានប្រាប់ខ្ញុំថា គាត់នឹងទៅធ្វើការជាមួយក្រុមហ៊ុនថ្មី ហើយគាត់បានសុំខ្ញុំឱ្យបន្តធ្វើការជាមួយគាត់នៅក្រុមហ៊ុនថ្មីរបស់គាត់។ ដោយសារខ្ញុំមិនទាន់បានគិតគូរវែងឆ្ងាយ ខ្ញុំក៏បានយល់ព្រមជាមួយគាត់។ គាត់បាននិយាយថា គាត់ពឹងផ្អែកលើក្រុមហ៊ុនរបស់ខ្ញុំ នៅពេលគាត់ធ្វើការសម្រេចចិត្តផ្លាស់ប្តូរទៅក្រុមហ៊ុនថ្មី។ ប៉ុន្តែ នៅពេលជិតដល់ថ្ងៃដែលគាត់ត្រូវចាកចេញពីក្រុមហ៊ុនចាស់របស់គាត់ ខ្ញុំស្រាប់តែមានអារម្មណ៍មិនសូវស្រួល។ ដូច្នេះ ខ្ញុំបានអធិស្ឋានដោយប្រើវិញ្ញាណជាច្រើនថ្ងៃ។ ក៏ប៉ុន្តែ ខ្ញុំនៅតែមិនបានឮចម្លើយដែលខ្ញុំត្រូវការ។

ឌ្រិនដា និងខ្ញុំចូលចិត្តនាំកូនៗរបស់យើងទៅលេងឧទ្យានកម្សាន្តមួយដែលមានចំងាយពីរបីម៉ោងពីផ្ទះរបស់យើង ឧទ្យាននោះមានឈ្មោះថា ស៊ីដាភ័ញ។ នៅឧទ្យាននោះមានរ៉ូលើខូសស្ទ័រ (រទេះភ្លើងកម្សាន្តលើអាកាស) ដែលធំជាងគេបង្អស់នៅសហរដ្ឋអាមេរិក ហើយជាធម្មតា យើងទៅទីនោះពីរបីដងក្នុងមួយឆ្នាំ។ ពេលនោះវាជាល្ងាចថ្ងៃសុក្រហើយ ហើយខ្ញុំត្រូវផ្តល់ចម្លើយនៅព្រឹកថ្ងៃច័ន្ទ។ ខ្ញុំបានគិតថា វាជាការល្អដែលខ្ញុំគួរធ្វើអ្វីដែលលំហែរចិត្តគំនិតរបស់ខ្ញុំបន្តិចសិន ហើយខ្ញុំក៏បានសម្រេចចិត្តនាំឌ្រិនដាទៅឧទ្យាននោះនៅល្ងាចថ្ងៃសុក្រនោះ។ នៅពេលដែលខ្ញុំកំពុងតែឈរតម្រង់ជួរ ដោយមិនបានគិតអំពីការសម្រេចចិត្តដែលខ្ញុំត្រូវធ្វើនៅព្រឹកថ្ងៃច័ន្ទ ស្រាប់តែភ្លាមៗនោះខ្ញុំបានដឹងថាត្រូវធ្វើអ្វី។ វាច្បាស់ដូចជាថ្ងៃអីញ្ចឹង។ ព្រះវិញ្ញាណដ៏វិសុទ្ធបានមានបន្ទូលមកកាន់ខ្ញុំ ហើយខ្ញុំបានសម្រេចចិត្តបន្តធ្វើជំនួញជាមួយក្រុមហ៊ុនចាស់របស់គាត់។ តើអ្នកដឹងទេ? ក្រុមហ៊ុនថ្មីរបស់តំណាងអ្នកលក់នោះ បានដួលរំលំតែក្នុងរយៈពេលពីរបីខែតែប៉ុណ្ណោះ។

ដូច្នេះ នេះគឺជាគន្លឹះយ៉ាងសំខាន់សម្រាប់ភាពជោគជ័យ គឺការអធិស្ឋាន! ហើយការអធិស្ឋានដោយប្រើវិញ្ញាណ ជាញឹកញាប់វាជួយឱ្យអ្វីៗមានដំណើរការល្អប្រសើរ ហើយអ្នកក៏អាចធ្វើការសម្រេចចិត្តត្រឹមត្រូវ ព្រមទាំងទទួលបានយុទ្ធសាស្ត្រដ៏លាក់កំបាំង ដែលអ្នកត្រូវការដើម្បីទទួលបានភាពជោគជ័យ។

«ចូរអធិស្ឋានឥតឈប់ឈរ» (១ ថេស្សាឡូនិក ៥:១៧)

# ជំពូក ៧
# កំណាប់ទ្រព្យ

ខ្ញុំនៅចាំថ្ងៃដែលខ្ញុំបានជួបខែនជាលើកដំបូង។ គាត់បានឈរនៅជួរក្រោយបង្អស់ក្នុងក្រុមជំនុំ ជាមួយបងប្អូនជីដូនមួយរបស់ខ្ញុំឈ្មោះ ជេននីហ្វឺ។ ក្រោយមកខ្ញុំបានដឹងថា ពួកគេកំពុងតែស្វែងយល់ចិត្តថ្លើមគ្នា។ តាមរយៈការបង្ហាញអាកប្បកិរិយារបស់ខែន ខ្ញុំដឹងថាគាត់មានអារម្មណ៍មិនស្រណុកក្នុងចិត្តទេ។ តាមការពិត គាត់មានអារម្មណ៍លើសពីមិនស្រណុកក្នុងចិត្តទៅទៀត។ ក្រោយមកខ្ញុំបានដឹងថា ក្រុមជំនុំរបស់យើងខុសប្លែកពីក្រុមជំនុំដែលគាត់បានចូលរួម។ ប៉ុន្តែ នៅពេលគាត់ចាប់ផ្តើមឮអំពីព្រះរាជ្យរបស់ព្រះ គាត់ចាប់ផ្តើមមានអារម្មណ៍ធូរបន្តិច ហើយនៅទីបំផុតគាត់ក៏បានរៀបការជាមួយបងប្អូនជីដូនមួយរបស់ខ្ញុំ។

នៅពេលនោះខែនមានចម្ការប្រហែល១,៨០០ហិកតា នៅកណ្តាលរដ្ឋអូហៃយ៉ូ ហើយវាកំពុងតែមិនមានដំណើរការល្អនោះទេ។ តាមពិត គាត់មិនអាចរកប្រាក់ចំណូលបានពីវា ហើយគាត់មានការព្រួយបារម្ភយ៉ាងខ្លាំង។ ប៉ុន្តែនៅពេលគាត់បន្តឮអំពីព្រះរាជ្យរបស់ព្រះ និងរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធអាចជួយដល់អ្នកជឿបាន គាត់បានជួបជេននីហ្វឺ ហើយបាននិយាយថា «បងចង់ថ្វាយតង្វាយទ្វេដង»។ ជេននីហ្វឺភ្ញាក់ផ្អើលយ៉ាងខ្លាំង ប៉ុន្តែក៏រំភើបផងដែរ។ ហើយពួកគេបានធ្វើដូច្នេះ។

នៅឆ្នាំនោះ ទិន្នផលរបស់ពួកគេនៅលើផ្ទៃដី១,៨០០ហិកតាដដែល បានទទួលផល១២៨%លើសពីឆ្នាំមុន។ តាមពិត ពួកគេទទួលបានទិន្នផលខ្ពស់ខ្លាំង រហូតដល់ពួកគេអាចទិញឡានថ្មី និងកសិដ្ឋានមួយទៀតដោយប្រើសាច់ប្រាក់សុទ្ធ មានន័យថាគាត់មានផ្ទៃដីធំជាងមុន ដើម្បីដាំដំណាំនៅឆ្នាំក្រោយ។ ខែនរំភើបខ្លាំងណាស់! គាត់បាននិយាយថាឪពុករបស់គាត់ត្រូវចំណាយពេល១០ឆ្នាំ ដើម្បីទិញកសិដ្ឋានថ្មីនោះ ហើយគាត់វិញអាច

ទិញវាដោយសាច់ប្រាក់សុទ្ធ។ ដូច្នេះ ខ្ញុំក៏បានសួរខែនថា រឿងនេះវាកើតឡើងយ៉ាងដូចម្ដេច ហើយសុំគាត់ប្រាប់រឿងនេះដល់ខ្ញុំ។

វាហាក់ដូចជា បន្ទាប់ពីខែននិងជេននីហ្វឺចាប់ផ្ដើមថ្វាយតង្វាយទ្វេដងមក ពួកគេក៏បានអធិស្ឋានសុំព្រះឱ្យបង្ហាញពួកគេអំពីអ្វីដែលពួកគេត្រូវធ្វើ។ ខែនបាននិយាយថា ថ្ងៃមួយនៅពេលដែលគាត់កំពុងតែមើលគំនរសំបុត្រដែលគាត់តែងតែទទួលបានជារៀងរាល់ថ្ងៃ ហើយភាគច្រើនវាជាការផ្សាយពាណិជ្ជកម្មដល់កសិករ គាត់បានបោះកាតតូចមួយចូលក្នុងធុងសំរាម ហើយគាត់ស្រាប់តែមានអារម្មណ៍ថា គួរតែរើសកាតនោះមកវិញ។ កាតនោះមិនមានអ្វីពិសេសទេ វាជាការផ្សាយពាណិជ្ជកម្មមួយទៀតអំពីឧបករណ៍កសិកម្ម។ កាតនោះអញ្ជើញកសិករឱ្យចូលរួមការប្រជុំមួយ ដើម្បីពិភាក្សាអំពីឧបករណ៍ថ្មីនោះ។

ខែនមានអារម្មណ៍ជំរុញយ៉ាងចម្លែកឱ្យចូលរួមការប្រជុំនោះ ហើយបន្ទាប់ពីគាត់បានទៅចូលរួមហើយ គាត់បានទិញឧបករណ៍ដែលគេបានផ្សាយពាណិជ្ជកម្មនោះ។ ឧបករណ៍នោះគឺជាផលិតផលថ្មីមួយនៅលើទីផ្សារដែលជាឧបករណ៍ជំនួយដល់ការដាំដុះដែលទាក់ទងនឹងការដាំគ្រាប់ពូជ និងការរៀបចំដី។ ខែនបានព្យាយាមពន្យល់ខ្ញុំ អំពីហេតុផលវិទ្យាសាស្ត្រដែលវាមានប្រសិទ្ធភាពក្នុងការបង្កើនទិន្នផលដំណាំ ប៉ុន្តែខ្ញុំតាមគាត់លែងទាន់បន្ទាប់ពីគាត់បានពន្យល់ខ្ញុំបានពាក់កណ្ដាលមក។ ប៉ុន្តែគាត់យល់អំពីវាច្បាស់ ហើយការនេះជាការសំខាន់។ ខែនបានប្រាប់ខ្ញុំថា គាត់ជាកសិករទីពីរដែលបានទិញឧបករណ៍ថ្មីនេះនៅរដ្ឋអូហៃយ៉ូនៅពេលនោះ។ មែនហើយ ឧបករណ៍ថ្មីនោះបានជួយដល់ខែន ជាលទ្ធផលគាត់ទទួលបានទិន្នផល១២៨%ច្រើនជាងឆ្នាំមុន។ ខែនបន្តទិញដីបន្ថែមទៀត ហើយសព្វថ្ងៃនេះគាត់មានចម្ការរាប់ពាន់ហិកតា។ ឥឡូវនេះ គាត់មានទីបន្ទាល់ជាច្រើនអំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធបានជួយដល់គាត់ ក្នុងការសម្រេចចិត្តដែលជួយជំរុញគាត់លឿនជាងអ្វីដែលគាត់បាននឹកស្មាន។

ដូច្នេះ តើខែនបានផ្លាស់ប្រែចម្ការដែលមិនផ្ដល់ប្រាក់កម្រៃ ទៅជាចម្ការដែលផ្ដល់ប្រាក់ចំណេញច្រើនដោយរបៀបណា? គាត់បានធ្វើតាមការណែនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ អ្វីដែលគួរឱ្យសោកស្ដាយនោះគឺថា មានគ្រិស្តបរិស័ទជាច្រើនដែលបានឮរឿងនេះហើយ ហើយពួកគេនៅតែមិនបានដឹងថា រឿងនេះវាបានកើតឡើងដោយរបៀបណា ហើយនេះជាមូលហេតុដែលខ្ញុំគិតថា វាជាការសំខាន់ដែលខ្ញុំត្រូវសរសេរសៀវភៅនេះ។ គ្រិស្តបរិស័ទភាគច្រើននឹងអបអរថា ព្រះជាម្ចាស់ពិតជាអស្ចារ្យខ្លាំងណាស់ ពួកគេទទួលស្គាល់ថា

រឿងនេះបានកើតឡើងដោយសារទ្រង់ ប៉ុន្តែមិនបានដឹងថា ត្រូវធ្វើវាឱ្យកើតឡើងម្តងទៀតដោយរបៀបណាទេ។ ហើយក៏មានគ្រិស្តបរិស័ទមួយចំនួនទៀតដែលបានយល់ខុសអំពីព្រះជាម្ចាស់ ហើយបានបន្ទោសទ្រង់សម្រាប់បញ្ហារបស់ពួកគេ។ ខ្ញុំបានឮពួកគេច្រើនតែនិយាយថា «តើព្រះនៅឯណា? ខ្ញុំមិនដឹងថា ហេតុអ្វីបានជាទ្រង់មិនជួយខ្ញុំនោះទេ។»

ខ្ញុំសង្ឃឹមថា មកដល់ពេលនេះអ្នកបានដឹងអំពីរបៀបរួចហើយ ប៉ុន្តែត្រូវចាំផងដែរថា ព្រះរាជ្យរបស់ព្រះមានដំណើរការដោយសារច្បាប់ មិនមែនដោយសារការប្រោសប្រណីទេ។ ព្រះជាម្ចាស់មិនបានជ្រើសរើសថា អ្នកណាទ្រង់នឹងប្រទានពរ ហើយអ្នកណាទ្រង់នឹងមិនប្រទានពរនោះទេ។ ខៃនមិនមែនជាម្នាក់ក្នុងចំណោមមនុស្សផ្សេងទៀតដែលព្រះជាម្ចាស់បានជ្រើសរើស ហើយគាត់ក៏មិនល្អពិសេសលើសជាងអ្នកនោះដែរ។ អ្នកមានសិទ្ធិស្របច្បាប់ដូចជាខៃនផងដែរ នៅក្នុងព្រះរាជ្យរបស់ព្រះ។ ដូចដែលអ្នកណាក៏មានសិទ្ធិសាបព្រោះគ្រាប់ពូជ និងដាំដំណាំ ទៅតាមច្បាប់នៃការសាបព្រោះ និងដាំដុះ នៅក្នុងព្រះរាជ្យរបស់ព្រះ អ្នកជឿដែលដឹងអំពីរបៀបប្រើប្រាស់ច្បាប់នៃព្រះរាជ្យរបស់ព្រះ ក៏ទទួលបានប្រយោជន៍ពីច្បាប់នេះផងដែរ។ អ្នកគឺជាសមាជិកម្នាក់នៃគ្រួសាររបស់ព្រះ និងជាពលរដ្ឋម្នាក់នៃព្រះរាជ្យរបស់ព្រះ ហើយអ្នកមានសិទ្ធិទទួលបានអ្វីៗទាំងអស់ដែលទ្រង់មាន។

**ដូច្នេះ ទុកឱ្យខ្ញុំប្រាប់អ្នកអំពីមូលហេតុដែលប្រជារាស្រ្តជាច្រើនរបស់ព្រះ ទទួលបានភាពបរាជ័យក្នុងជីវិតរបស់ពួកគេ។ ពួកគេមិនបានដឹងអំពីរបៀបព្រះរាជ្យរបស់ព្រះមានដំណើរការទេ ហើយពួកគេក៏មិនបានដឹងអំពីរបៀបស្តាប់ព្រះសូរសៀងរបស់ព្រះផងដែរ។**

> *ព្រះអម្ចាស់ជាព្រះដ៏វិសុទ្ធរបស់ជនជាតិអ៊ីស្រាអែល ដែលបានលោះ**អ្នក**មានព្រះបន្ទូលថាៈ យើងនេះហើយជាព្រះអម្ចាស់ជាព្រះ**របស់អ្នក** យើង**បង្រៀនប្រដៅអ្នក អំពីអ្វីដែលមានប្រយោជន៍**ដល់អ្នក យើងណែនាំ**អ្នក**ឱ្យដើរក្នុងមាគ៌ាដែល**អ្នក**កំពុងតែដើរ។*

អេសាយ ៤៨:១៧

ជោគជ័យរបស់ខៃនមិនមែនបានមកពីការគិតរបស់គាត់ទេ។ វាបានមកពីយុទ្ធសាស្រ្តល្អឯករបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ព្រោះខៃនបានឈានជំហានអនុវត្តតាមច្បាប់នៃព្រះរាជ្យរបស់ព្រះ ហើយគាត់ និងភរិយារបស់គាត់បានព្យាយាមចាំស្តាប់ការណែនាំរបស់ព្រះ

វិញ្ញាណដ៏វិសុទ្ធ និងការជួយរបស់ទ្រង់ទាក់ទងនឹងគម្រោងការ។ ខ្ញុំចង់ឱ្យអ្នកសរសេរចូលក្នុងសៀវភៅកំណត់ត្រារបស់អ្នកដូចខាងក្រោម៖

## ព្រះវិញ្ញាណដ៏វិសុទ្ធមានគម្រោងការ!

<u>**គ្មានអ្វីដែលខ្លាំងជាងការមានគម្រោងការដែលបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធទេ។ បើគ្មានគម្រោងការទេ សុបិននៅតែជាសុបិន ប៉ុន្តែបើមានគម្រោងការ យើងអាចកសាងសុបិនឱ្យលេចជារូបរាងឡើងបាន។**</u>

គ្រួសារមួយអាចស្រមៃថា ពួកគេមានផ្ទះដ៏ល្អប្រណិតមួយ ដែលមានបន្ទប់គេងច្រើន មានទីធ្លារស់នៅធំទូលាយ មានផ្ទះបាយដ៏ធំទំនើបមួយ និងមានការតុបតែងដ៏ស្រស់ស្អាត។ ប៉ុន្តែ ពេលនោះវាគ្រាន់តែជាការស្រមៃ ឬជារូបភាពមួយតែប៉ុណ្ណោះ។ រូបភាពនោះត្រូវតែបានគូររចនាឡើងឱ្យទៅជាប្លង់ ឬជាគម្រោងមួយ។ នៅពេលអ្នកសាងសង់មានប្លង់ហើយ គាត់អាចសាងសង់ផ្ទះនោះបាន។ ដោយសារហេតុផលណាមួយ គ្រិស្តបរិស័ទភាគច្រើនមានចិត្តគំនិតដូចប្រអប់សំបុត្រ។ នៅពេលដែលពួកគេអធិស្ឋាន និងសុំលុយដែលពួកគេត្រូវការពីព្រះជាម្ចាស់ ដូចតម្រូវការរបស់ខ្មែនផងដែរ ពួកគេគ្រាន់តែរំពឹងថា លុយដែលពួកគេត្រូវការនោះនឹងលេចឡើងនៅក្នុងប្រអប់សំបុត្ររបស់ពួកគេ ឬកាន់តែយ៉ាប់ជាងនេះទៅទៀតនោះ ពួកគេគ្រាន់តែរំពឹងថា នឹងមាននរណាម្នាក់ឱ្យលុយដល់ពួកគេ។ ពួកគេមិនបានដឹងអំពីដំណើរការដែលធ្វើឱ្យពួកគេទទួលបានអ្វីដែលពួកគេត្រូវការនោះទេ។

មែនហើយ ដំបូងយើងត្រូវមានរូបភាព។ ក៏ប៉ុន្តែ មានដំណើរការដែលធ្វើឱ្យរូបភាពនោះអាចក្លាយជាការពិត ដែលអ្នកពិតជាអាចរីករាយជាមួយវាបាន។ ដើម្បីឱ្យវាអាចកើតឡើងបាន គឺត្រូវមានគម្រោងការ ឬយុទ្ធសាស្ត្រ។ ទុកឱ្យខ្ញុំប្រាប់អ្នកឧទាហរណ៍មួយ។ ប្រសិនបើខ្ញុំប្រាប់អ្នកថា ខ្ញុំអាចជួយអ្នកដោះស្រាយបញ្ហាហិរញ្ញវត្ថុរបស់អ្នកបានយ៉ាងឆាប់រហ័ស និងឱ្យអ្នកយកក្រដាស និងប៊ិករបស់អ្នក ដើម្បីត្រៀមសរសេរអ្វីដែលអ្នកត្រូវធ្វើ នោះអ្នកនឹងយកក្រដាស និងប៊ិករបស់អ្នកចេញមក ហើយត្រៀមចាំស្តាប់ និងកត់អ្វីដែលខ្ញុំនឹងប្រាប់អ្នក។ ខ្ញុំចង់និយាយបន្តទៀតថា សម្រាប់មនុស្សភាគច្រើនដែលកំពុងតែអានសៀវភៅនេះ អ្វីដែលខ្ញុំនឹងប្រាប់អ្នក នឹងអាចបន្ធូរភាពតានតឹងផ្នែកហិរញ្ញវត្ថុរបស់អ្នក ព្រមទាំងអាចជួយអ្នកឱ្យមានសេរីភាពពីបំណុលមុនបំណាច់ឆ្នាំនេះ។ ឥឡូវនេះ អ្នកអាចកាន់ប៊ិកកាន់តែ

ណែនជាងមុន និងកាន់តែយកចិត្តទុកដាក់ស្តាប់ជាងមុន ដើម្បីកុំឱ្យរំលងអ្វីដែលខ្ញុំនឹងប្រាប់អ្នក។

ចម្លើយពិតជាសាមញ្ញខ្លាំងណាស់ ចាំខ្ញុំពន្យល់។ គ្រាន់តែរកប្រាក់ចំណេញសុទ្ធក្នុងឆ្នាំនេះឱ្យបាន១០លានដុល្លារ។ អ្នកមុខជាសម្លឹងមើលមុខខ្ញុំមួយសន្ទុះ ហើយចាប់ផ្តើមសើចតិចៗ។ បន្ទាប់មកខ្ញុំសន្មតថា ការដែលអ្នកសើចតិចៗបានន័យថា ១០លានដុល្លារវាមិនគ្រាន់ទេ ដូច្នេះខ្ញុំក៏និយាយបន្ថែមថា «មែនហើយ បើ១០លានដុល្លារមិនគ្រាន់ទេ អីញ្ចឹងរកឱ្យបាន២៥លានដុល្លារទៅ»។ មកដល់ចំណុចនេះ អ្នកមិនត្រឹមតែសើចតិចៗទេ គឺអ្នកសើចយ៉ាងឮៗតែម្តង។ ហេតុអ្វី? ទុកឱ្យខ្ញុំពន្យល់។ សម្រាប់មនុស្សភាគច្រើន ១០លានដុល្លារពិតជាអាចជួយពួកគេឱ្យមានសេរីភាពពីបំណុលបាន ប៉ុន្តែពួកគេសើចតិចៗ ពីព្រោះពួកគេមិនធ្លាប់នឹកស្រមៃថា ពួកគេអាចរកបាន១០លានដុល្លារក្នុងរយៈពេលតែ១ឆ្នាំទេ។ ពេលឮចំនួនដល់ទៅ២៥លានដុល្លារ វាធ្វើឱ្យពួកគេអស់សំណើច ដោយសារតែចំនួននេះកាន់តែឆ្ងាយលើសពីអ្វីដែលពួកគេគិតថា ពួកគេអាចមានលទ្ធភាពធ្វើបាន។

ប៉ុន្តែ សូមស្រមៃមើលថា ខ្ញុំមានក្រុមហ៊ុននាំចេញមួយ ហើយខ្ញុំផ្តល់ប្រាក់១,០០០ដុល្លារដល់អ្នក សម្រាប់ការវេចខ្ចប់បាល់ដាក់ក្នុងប្រអប់ ដើម្បីនាំចេញទៅក្រៅប្រទេស។ ឧបមាថា អ្នកអាចវេចខ្ចប់បាល់៥០០ប្រអប់ក្នុងមួយថ្ងៃ ហើយខ្ញុំចុះកិច្ចសន្យាជាមួយអ្នក ១២ខែ ដោយផ្តល់កម្រៃដដែល។ ឧទាហរណ៍មួយនេះ រឿងបំផ្លើសពីការពិតបន្តិចហើយ ក៏ប៉ុន្តែវានឹងជួយឱ្យអ្នកយល់។

ឥឡូវនេះ សន្មតថា អ្នកពិតជាមានកិច្ចសន្យានេះពិតមែន ហើយខ្ញុំនៅតែនិយាយដដែលដូចដែលខ្ញុំបាននិយាយលើកដំបូង គឺថាអ្នកត្រូវរកប្រាក់ចំណូលសុទ្ធឱ្យបាន១០លានដុល្លាររហូតដល់ឆ្នាំក្រោយ តើអ្នកនឹងឆ្លើយតបយ៉ាងម៉េចវិញ? ឥឡូវនេះ ប្រហែលជាអ្នកមិនសើចតិចៗទៀតទេ។ ផ្ទុយទៅវិញ អ្នកនឹងស្រែកដោយអំណរ និងការរំភើបជំនួសវិញ។ ហេតុអ្វី? ពីព្រោះអ្នកអាចរកប្រាក់ចំនួន១០លានដុល្លារយ៉ាងងាយស្រួល ជាមួយកិច្ចសន្យាបែបនោះ។ ការពិត ការរកប្រាក់ឱ្យបាន២៥លានដុល្លារក៏អាចជាការងាយស្រួល ហើយការរកប្រាក់ឱ្យបាន១០០លានដុល្លារក៏អាចទៅរួចបានដែរ។ តើអ្វីបានផ្លាស់ប្តូរ? អ្វីតែមួយគត់ដែលផ្លាស់

**ខ្ញុំចង់និយាយម្តងទៀត ខ្ញុំគិតថាអ្នកត្រូវតែឮវាជាថ្មីម្តងទៀត៖ ព្រះជាម្ចាស់មានផែនការសម្រាប់អ្នក!**

ប្ដូរគឺ អ្នកមានគម្រោង។ ដូចអ្វីដែលខ្ញុំធ្លាប់បាននិយាយរួចមកហើយ អ្នកណាក៏អាចចាប់ត្រីបានដែរ ឱ្យតែព្រះយេស៊ូបង្ហាញទីកន្លែង និងរបៀបដែលត្រូវរកត្រី។ ឥឡូវនេះ ដល់វេនអ្នកវិញម្ដង។ ពេលណាអ្នកមានគម្រោង ជាគម្រោងដែលជួយអ្នក ឱ្យអាចឃើញខ្លួនឯងធ្វើអ្វីមួយបាន នោះអ្នកអាចដោះស្រាយបញ្ហារបស់អ្នកបានហើយ។

*យើងស្គាល់ច្បាស់នូវគម្រោងការដែលយើងបានគ្រោងទុក សំរាប់អ្នករាល់គ្នា ជាគម្រោងការដែលផ្ដល់សេចក្ដីសុខសាន្តដល់អ្នករាល់គ្នា គឺមិនមែនឱ្យអ្នករាល់គ្នាត្រូវវេទនាទេ។ យើងនឹងផ្ដល់សេចក្ដីសង្ឃឹម និងអនាគតល្អឱ្យអ្នករាល់គ្នា - នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់*(យេរេមា ២៩:១១)។

ខ្ញុំចង់និយាយម្ដងទៀត ខ្ញុំគិតថាអ្នកត្រូវតែឮវាជាថ្មីម្ដងទៀត ៖ ព្រះជាម្ចាស់មានផែនការសម្រាប់**អ្នក**!

ពីរបីខែមុននេះ ខ្ញុំបានមានឯកសិទ្ធិជួបជាមួយដៃគូរបស់ខ្ញុំម្នាក់ នៅក្រុមជំនុំរបស់យើង ពេលដែលខ្ញុំកំពុងតែបង្រៀន។ ពួកគេបានមកជួបខ្ញុំនៅពេលចប់វេនថ្វាយបង្គំ ហើយបានសួរសំណួរខ្ញុំមួយ ឬខ្ញុំគួរតែនិយាយថាជាការថ្លែងមួយ។ «វាមិនមានប្រសិទ្ធភាពទេ។ ខ្ញុំបានសាបព្រោះគ្រាប់ពូជរបស់ខ្ញុំ ហើយបានព្រមព្រៀងគ្នាជាមួយស្វាមីខ្ញុំ ថាយើងនឹងទទួលបានសត្វប្រើសឈ្មោលមួយក្បាល តែខ្ញុំមិនបានទទួលវាទេ។» គាត់បានប្រាប់ខ្ញុំអំពីរបៀបដែលគាត់បានសាបព្រោះ ដើម្បីបានសត្វប្រើសមួយក្បាល ជាប្រើសឈ្មោល និងជាប្រើសដែលងាយស្រួលបាញ់។ ដូច្នេះ ខ្ញុំក៏សួរសំណួរបន្ថែម ហើយចុងក្រោយបានសួរគាត់ថា តើគាត់បានឃើញប្រើសនោះ មុនថ្ងៃដែលគាត់បានទៅបរបាញ់ដែរឬទេ។ គាត់បានឆ្លើយថា ៖ «ចាស មានសត្វប្រើសមួយដូចសត្វប្រើសដែលខ្ញុំបានសាបព្រោះចង់បាន បានមកឈរនៅចំពោះមុខរបស់ខ្ញុំ ក្នុងចម្ងាយដែលខ្ញុំអាចបាញ់វាបាន។»

បន្ទាប់ពីបានឮដូច្នេះ ខ្ញុំមានការភ្ញាក់ផ្អើលបន្តិច ហើយខ្ញុំបានសួរគាត់ថាមានរឿងអ្វីកើតឡើងបន្ទាប់មកទៀត។ គាត់បាននិយាយថា គាត់បានតម្រង់ចំសត្វប្រើសនោះហើយ ប៉ុន្តែគាត់បានសុំឱ្យមិត្តរបស់គាត់ជួយសេរ៉េកាំភ្លើងបាញ់សត្វរបស់គាត់ ដោយគាត់បានសន្មតថាមិត្តគាត់បានសេរ៉េវារួចហើយ គាត់មិនបានពិនិត្យមើលវាម្ដងទៀតទេ ហើយគាត់ក៏បានបាញ់ខុស។ ពេលបានឮដូច្នេះ ខ្ញុំយល់ថាវាច្បាស់ណាស់ វាពិតជាមានប្រសិទ្ធភាព ប៉ុន្តែសម្រាប់គាត់ វាមិនដូច្នោះទេ។

ខ្ញុំគិតថាមានអ្នកជឿជាច្រើនបានមកដល់កន្លែងនេះ។ ដោយសារហេតុផលណាមួយ ពួកគេមិនបានយល់ច្បាស់អំពីដំណើរការ ជាផ្នែកដែលពួកគេត្រូវធ្វើ ក្នុងពេលប្រមូលផល។ ខ្ញុំបានពន្យល់គាត់ថា ព្រះជាម្ចាស់បានធ្វើផ្នែករបស់ទ្រង់រួចហើយ ប៉ុន្តែ គាត់បានធ្វើខុសផ្នែករបស់គាត់។ អ្នកឃើញទេ ព្រះជាម្ចាស់អាចប្រទានគម្រោងការមកឱ្យអ្នក ប៉ុន្តែអ្នកត្រូវធ្វើផ្នែករបស់អ្នក ដើម្បីឱ្យគម្រោងការនោះបានសម្រេច។ វាជាកិច្ចការរួមគ្នារវាងព្រះជាម្ចាស់ និងអ្នក!

*ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបីដូចជាកំណប់ដែល**គេកប់ទុក**នៅក្នុងស្រែមួយ។ មានបុរសម្នាក់រកកំណប់នោះឃើញ ហើយកប់ទុកវិញ។ គាត់មានចិត្តត្រេកអរជាខ្លាំង ក៏ចេញទៅលក់ទ្រព្យសម្បត្តិទាំងប៉ុន្មានដែលគាត់មាន យកប្រាក់ទិញដីស្រែនោះ។*

ម៉ាថាយ១៣:៤៤

មានសេចក្តីពិតជាច្រើនអំពីព្រះរាជ្យរបស់ព្រះនៅក្នុងខគម្ពីរនេះ! ជាដំបូង យើងកំណត់និយមន័យនៃពាក្យកំណប់ជាមុនសិន។ យោងតាមវចនានុក្រម កំណប់គឺជាទ្រព្យដ៏មានតម្លៃគ្រប់ប្រភេទ។ ដូច្នេះកំណប់មិនមែនសុទ្ធតែជាមាសនោះទេ។ វាអាចជាអ្វីដែលអ្នកត្រូវការនៅពេលនេះ។ ដូច្នេះ ខគម្ពីរនេះចង់និយាយថា ព្រះរាជ្យនៃស្ថានបរមសុខប្រៀបបីដូចជាកំណប់ ឬអ្នកអាចនិយាយថា អ្វីៗគ្រប់យ៉ាងដែលអ្នកត្រូវការសម្រាប់ជីវិត គឺមាននៅក្នុងព្រះរាជ្យរបស់ព្រះ។ តើព្រះរាជ្យរបស់ព្រះនៅឯណា? នៅក្នុងខគម្ពីរនេះ ព្រះយេស៊ូមានបន្ទូលថា គេកប់ទុកនៅក្នុងស្រែមួយ។ រ៉ោវ! តើអ្នកមិនចង់ដឹងថាស្រែនោះនៅឯណាទេឬ? មែនហើយ ដំណឹងល្អគឺថា ព្រះយេស៊ូបានប្រាប់យើងថាស្រែនោះនៅឯណា និងរបៀបរកកំណប់ដែលបានកប់ទុកនៅក្នុងស្រែនោះ។

ប្រសិនបើយើងទៅមើលរឿងប្រៀបប្រដូចអំពីគ្រាប់ពូជ នៅម៉ាកុស ៤ យើងឃើញថា ព្រះយេស៊ូបង្រៀនអំពីរបៀបដែលជំនឿដុះឡើងនៅក្នុងចិត្តរបស់មនុស្ស។ ទ្រង់បានប្រៀបធៀបចិត្តរបស់មនុស្សទៅនឹងដី ហើយព្រះបន្ទូលរបស់ព្រះទៅនឹងគ្រាប់ពូជដែលបានសាបព្រោះទៅក្នុងដី។ ដោយប្រើការប្រៀបធៀបដូចគ្នា ខ្ញុំអាចសន្មតថា ដីនៅក្នុងម៉ាថាយ ១៣ មានអត្ថន័យដូចគ្នា គឺតំណាងឱ្យចិត្តរបស់មនុស្ស។ ខ្ញុំចង់ចំណាយពេលមួយភ្លែត ដើម្បីរំលឹកអ្នកអំពីមេរៀនដែលយើងបានរៀននៅជំពូកទី៦ យើងទាំងអស់គ្នាបានកើតជាថ្មីខាងឯវិញ្ញាណ វិញ្ញាណមនុស្សរបស់យើងបានក្លាយជាតែមួយជាមួយព្រះវិញ្ញាណរបស់ព្រះ

អនុញ្ញាតឱ្យយើងអាចយល់ពីគំនិតរបស់ព្រះជាម្ចាស់បាន។ ដូច្នេះ យើងអាចទទួលបានកំណប់ដែលបានកប់ទុកនៅក្នុងស្រែ ហើយវាក៏រួមបញ្ចូលអ្វីៗទាំងអស់ដែលព្រះជាម្ចាស់មានផងដែរ ដូចដែលយើងបានរួមគ្នាតែមួយជាមួយទ្រង់ក្នុងវិញ្ញាណ។

> *«អ្វីៗដែលភ្នែកមើលមិនឃើញ អ្វីៗដែលត្រចៀកស្តាប់មិនឮ និងអ្វីៗដែលចិត្តមនុស្សនឹកមិនដល់នោះ ព្រះជាម្ចាស់បានរៀបចំទុកសំរាប់អស់អ្នកដែលស្រឡាញ់ព្រះអង្គ»។ ព្រះជាម្ចាស់បានសំដែងឱ្យយើងដឹងអំពីគម្រោងការដ៏លាក់កំបាំងនោះតាមរយៈព្រះវិញ្ញាណ ដ្បិតព្រះវិញ្ញាណឈ្វេងយល់អ្វីៗទាំងអស់ សូម្បីតែជំរៅព្រះហឫទ័យរបស់ព្រះជាម្ចាស់ក៏ទ្រង់ឈ្វេងយល់ដែរ។ ចំពោះមនុស្សលោក គ្មាននរណាយល់អំពីមនុស្សបាន ក្រៅពីវិញ្ញាណដែលនៅក្នុងខ្លួនគេនោះទេ។ រីឯព្រះជាម្ចាស់ក៏ដូច្នោះដែរ គ្មាននរណាម្នាក់យល់អំពីព្រះអង្គបាន ក្រៅពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នោះឡើយ។ ចំពោះយើង យើងពុំបានទទួលវិញ្ញាណលោកីយ៍ទេ គឺយើងបានទទួលព្រះវិញ្ញាណដែលមកពីព្រះជាម្ចាស់ ដើម្បីឱ្យស្គាល់អ្វីៗដែលព្រះអង្គប្រោសប្រទានមកយើង។*

១ កូរិនថូស ២:៩-១២

បន្ទាប់មកនៅ ១ កូរិនថូស ២:១៦ បានបន្ថែមថា យើងមានចិត្តគំនិតរបស់ព្រះគ្រិស្ត! ព្រះយេស៊ូបានបញ្ជាក់ថា កំណប់នេះនៅកន្លែងណា នៅក្នុង លូកា ១៧:២០-២១។

> *ព្រះរាជ្យព្រះជាម្ចាស់មិនមែនមក តាមបែបដែលមនុស្សអាចមើលឃើញនឹងភ្នែកបានឡើយ...ចូរដឹងថា ព្រះរាជ្យព្រះជាម្ចាស់ស្ថិតនៅកណ្តាលចំណោមអ្នករាល់គ្នាហើយ។*

លូកា ១៧:២០-២១

> *បងប្អូនមិនជ្រាបទេឬថា រូបកាយរបស់បងប្អូន ជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅក្នុងបងប្អូន ជាព្រះវិញ្ញាណដែលបងប្អូនបានទទួលពីព្រះជាម្ចាស់។ បងប្អូនមិនមែនជាម្ចាស់លើខ្លួនឯងទៀតទេ ដ្បិតព្រះអង្គបានបង់ថ្លៃយ៉ាងច្រើនលើសលប់ ដើម្បីលោះបងប្អូន។ ហេតុនេះចូរប្រើរូបកាយរបស់បងប្អូន ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។*

១ កូរិនថូស ៦:១៩-២០

ដូច្នេះ ខ្ញុំសូមសង្ខេបនូវអ្វីដែលខ្ញុំចង់និយាយ៖

## **មានកំណប់នៅក្នុងអ្នក!**

តើមានកំណប់ច្រើនប៉ុណ្ណាទៅ? មានកំណប់ច្រើនលើសហួសពីក្ដីសុបិនដ៏មហិមារបស់អ្នកទៅទៀត! មានកំណប់ច្រើនរាប់មិនអស់!

*ព្រះជាម្ចាស់អាចធ្វើអ្វីៗទាំងអស់ ហួសពីសេចក្ដីសុំ និងហួសពីអ្វីៗដែលយើងនឹកគិត ដោយសារឫទ្ធានុភាពរបស់ព្រះអង្គដែលបំពេញសកម្មភាពនៅក្នុងយើង។*

អេភេសូ ៣:២០

**មិត្តសម្លាញ់អើយ កំណប់ទាំងនេះជារបស់អ្នកហើយ គឺព្រះរាជ្យរបស់ព្រះទាំងមូល! ព្រះជាម្ចាស់មិនបន្ថែមអ្វីទៀតទៅលើអ្វីដែលទ្រង់បានប្រទានដល់អ្នករួចហើយទេ។ អ្នកមានវាទាំងអស់រួចហើយ!**

ឥឡូវនេះ យើងត្រូវបង្រៀនខ្លួនឯងឱ្យធ្វើអ្វីខុសប្លែកពីមុន។ កំណប់ទ្រព្យនេះលើសពីអ្វីដែលយើងអាចនឹកស្មានដល់! ជាធម្មតា នៅពេលយើងត្រូវការអ្វីមួយ ឬត្រូវការជំនួយ យើងបានបង្រៀនខ្លួនឯងឱ្យទៅរកវានៅខាងក្រៅខ្លួនយើង។ ប៉ុន្តែ ឥឡូវនេះ ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះជាម្ចាស់ ទ្រង់គង់នៅក្នុងយើង ហើយទ្រង់ជាជំនួយរបស់យើង។ យើងបានពិភាក្សារួចហើយ អំពីរបៀបដែលយើងអាចទទួលបានការណែនាំ និងការលាក់កំបាំង តាមរយៈការអធិស្ឋានដោយប្រើវិញ្ញាណ ឬការអធិស្ឋានជាភាសាដទៃ។ ប៉ុន្តែមានមនុស្សជាច្រើនពិបាកយល់អំពីសារៈសំខាន់នៃជំនួយដែលមិនអាចកាត់ថ្លៃបានមួយនេះ ឬពិបាកយល់ថាព្រះជាម្ចាស់ពិតជាចង់ក្លាយជាចម្លើយនៅក្នុងគ្រប់ផ្នែកនៃជីវិតរបស់ពួកគេមែនឬ។

ប៉ុន្តែនៅពេលអ្នកកើតជាថ្មី អ្នកបានក្លាយទៅជាសមាជិកនៃគ្រួសាររបស់ព្រះជាម្ចាស់ និងក្លាយជាប្រជារាស្ត្រនៃព្រះរាជ្យរបស់ទ្រង់។ ទ្រង់បានប្រទានអ្វីៗគ្រប់យ៉ាងដែលទ្រង់មានឱ្យអ្នករួចហើយ! តាមការពិត នៅលូកា ១២:៣២ និយាយថា គ្មានហេតុផលអ្វីដែលអ្នកត្រូវភ័យខ្លាច ឬភិតភ័យទេ ព្រោះព្រះវរបិតារបស់អ្នកសព្វព្រះហឫទ័យប្រទានព្រះរាជ្យមកឱ្យអ្នករាល់គ្នាហើយ។ ព្រះរាជ្យអ្វីទៅ? គឺព្រះរាជ្យរបស់ព្រះជាម្ចាស់!

**បនិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្រ្ត

*«កុំខ្លាចអី ក្រុមដ៏តូចរបស់ខ្ញុំអើយ! ព្រះបិតារបស់អ្នករាល់គ្នា សព្វព្រះហឫទ័យប្រទានព្រះរាជ្យមកឱ្យអ្នករាល់គ្នាហើយ។»* (លូកា ១២:៣២)

មិត្តសម្លាញ់អើយ កំណប់ទាំងនេះជារបស់អ្នកហើយ គឺព្រះរាជ្យរបស់ព្រះទាំងមូល! ព្រះជាម្ចាស់មិនបន្ថែមអ្វីទៀត ទៅលើអ្វីដែលទ្រង់បានប្រទានដល់អ្នករួចហើយទេ។ អ្នកមានអ្វីៗទាំងអស់រួចហើយ! មានមនុស្សជាច្រើនធ្វើហាក់ដូចជាពួកគេរំខានព្រះជាម្ចាស់ណាស់ ប្រសិនបើពួកគេឱ្យទ្រង់ពាក់ព័ន្ធជាមួយជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ប៉ុន្តែ នេះជាភាពល្ងង់ខ្លៅ។ ប្រសិនបើខ្ញុំប្រាប់អ្នកថា អ្នកជាពលរដ្ឋអាមេរិក ហើយអ្នកនិយាយថា «អូខ្ញុំអត់ដឹងផង។ បើខ្ញុំបើកហាងមួយនៅកន្លែងនេះ ខ្ញុំខ្លាចរំខានដល់គេ ខ្ញុំខ្លាចទាយយកប្រយោជន៍ស្របច្បាប់ក្នុងនាមជាពលរដ្ឋម្នាក់ ដែលអនុញ្ញាតឱ្យខ្ញុំបើកហាងមួយនៅទីនេះ។» ក្នុងនាមជាពលរដ្ឋម្នាក់ អ្នកមានសិទ្ធិស្របច្បាប់ និងឯកសិទ្ធិទាំងអស់ដែលប្រទេសទាំងមូលផ្តល់ឱ្យអ្នក។ ទាំងអស់គឺជារបស់អ្នក! ចូរកុំរារែក។ ចូរទទួលយកប្រយោជន៍ស្របច្បាប់ទាំងអស់ដែលជារបស់អ្នក!

**ហេតុអ្វីបានជាព្រះរាជ្យរបស់ព្រះប្រៀបប្រដូចទៅនឹងកំណប់?**

ព្រោះប្រសិនបើអ្នកទទួលបានចំណេះដឹងពីស្ថានសួគ៌ អ្នកអាចដឹងថាត្រូវធ្វើអ្វីក្នុងគ្រប់ស្ថានភាពទាំងអស់ ដោយទទួលបានយុទ្ធសាស្រ្តល្អឯក និងមិនធម្មតាពីទ្រង់។ ខ្ញុំនឹងប្រាប់ឧទាហរណ៍មួយទៀតដែលបង្ហាញអំពីរបៀបដែលវាមានដំណើរការ។

នៅពេលឌ្រិនដា និងខ្ញុំចាប់ផ្តើមរៀនអំពីព្រះរាជ្យរបស់ព្រះ ជីវិតរបស់យើងបានផ្លាស់ប្រែយ៉ាងខ្លាំង។ ការទទួលបានសេរីភាពពីបំណុល ប្រៀបដូចជាបានទទួលខ្យល់អាកាសបរិសុទ្ធ ហើយជីវិតរបស់យើងបានបំពេញដោយក្លិនក្រអូបថ្មីទាំងស្រុង។ ការទិញដីដែលមានទំហំ៥៥ហិចតាដោយសាច់ប្រាក់សុទ្ធ ហាក់ដូចជាការយល់សប្តិមួយ វាពិតជាអស្ចារ្យមែនទែន ប៉ុន្តែយើងនៅតែត្រូវការផ្ទះមួយខ្នងនៅលើដីនោះ ហើយយើងពិតជាមិនដឹងថាត្រូវចាប់ផ្តើមពីណាទៅទេ។ ប៉ុន្តែ យើងបានចាប់ផ្តើមអធិស្ឋាន និងស្វែងរករបៀបដែលយើងអាចមានផ្ទះនៅលើដីនោះ។ យើងជឿជាក់ថាព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយយើង។

ដោយមិនចង់ជំពាក់បំណុលគេទាំងស្រុង យើងចាប់ផ្តើមស្វែងយល់អំពីរបៀបផ្សេងៗដើម្បីសាងសង់ផ្ទះ។ របៀបមួយក្នុងចំណោមរបៀបជាច្រើនទៀតដែលយើងអាចមានផ្ទះដ៏ល្អមួយ ដោយមានតម្លៃថោកជាង គឺការទិញផ្ទះម៉ូឌុលពីរោងចក្រ។ ផ្ទះម៉ូឌុលមិនមែនជាផ្ទះដែលអាចចល័តបានទេ វាជាផ្ទះសាងសង់ឡើងតាមផ្នែកផ្សេងៗនៅរោងចក្រ

បន្ទាប់មកគេយកផ្នែកទាំងនោះផ្គុំចូលគ្នានៅលើដីរបស់យើង។ ផ្ទះទាំងនេះមានគុណភាពល្អដូចផ្ទះដែលសាងសង់តាមរបៀបធម្មតា ប៉ុន្តែវាមានតម្លៃថោកជាង ដោយសារវិធីសាស្ត្រសាងសង់ប្រកបដោយប្រសិទ្ធភាពដែលគេប្រើនៅរោងចក្រ។ ដូច្នេះ យើងបានជ្រើសរើសក្រុមហ៊ុនសាងសង់ផ្ទះម៉ូឌុលពីរបីក្រុមហ៊ុន និងមើលម៉ូតផ្ទះម៉ូឌុលដែលពួកគេមាន។ បន្ទាប់ពីការស្រាវជ្រាវ និងបានមើលផ្ទះម៉ូឌុលមួយចំនួនមក យើងមានអារម្មណ៍ថាយើងនឹងទិញផ្ទះម៉ូឌុលមួយ ហើយបានជ្រើសរើសក្រុមហ៊ុន និងម៉ូតផ្ទះដែលយើងចង់បាន ដែលយើងគិតថាវាល្អនៅលើដីរបស់យើង។ យើងបានត្រៀមខ្លួនរួចរាល់ដើម្បីចុះហត្ថលេខា បន្ទាប់ពីយើងត្រលប់មកផ្ទះវិញ ក្រោយពីបានអធិប្បាយនៅសន្និបាតការបង្រៀនកូននៅផ្ទះនៅរដ្ឋវឺជីនៀ។ យើងបានយកគម្រោងទិញផ្ទះនោះទៅជាមួយយើង ព្រោះយើងគិតថាយើងអាចពិភាក្សាកន្លែងលម្អិតណាមួយដែលយើងអាចរំលង ហើយដើម្បីប្រាកដថាយើងពិតជាទិញផ្ទះនោះពិតមែន មុនពេលយើងចុះហត្ថលេខាលើកិច្ចសន្យានោះ។

ខ្ញុំមិនបានចាំថាគេបានអញ្ជើញយើងឱ្យទៅអធិប្បាយនៅសន្និបាតនៅរដ្ឋវឺជីនៀនោះដោយរបៀបណាទេ ប៉ុន្តែខ្ញុំចាំថាគេបានអញ្ជើញយើងឱ្យស្នាក់នៅជាមួយគ្រួសារមួយដែលបង្រៀនកូននៅផ្ទះ នៅពេលយើងនៅទីនោះ។ ពេលយើងទៅដល់ផ្ទះដ៏ល្អប្រណិតរបស់ពួកគេ និងបានជួបពួកគេជាលើកដំបូង យើងបានសរសើរផ្ទះរបស់ពួកគេ។ ពេលយើងជជែកលេងជាមួយពួកគេ ខ្ញុំបានដឹងថាពួកគេបានសាងសង់ផ្ទះនេះដោយខ្លួនឯង។ ដំបូង ខ្ញុំភ្ញាក់ផ្អើលជាខ្លាំង។ ខ្ញុំបានសួរពួកគេថា «តើអ្នកជាអ្នកម៉ៅការសាងសង់ផ្ទះឬ?»។ ពួកគេឆ្លើយថា «អត់ទេ»។ បុរសជាប្ដីបានប្រាប់យើងថាគាត់ជាគណនេយ្យករនៅក្រុមហ៊ុនដ៏ធំមួយនៅក្នុងស្រុក។ ខ្ញុំបានសួរគាត់ថា «តើអ្នកដឹងអំពីរបៀបសាងសង់ផ្ទះដោយខ្លួនឯងដោយរបៀបណា?»។

ពួកគេចាប់ផ្ដើមប្រាប់យើងរឿងរ៉ាវផ្សេងៗ ហើយនៅក្នុងការសន្ទនារបស់យើង ខ្ញុំបានប្រាប់ពួកគេថាយើងក៏កំពុងតែសាងសង់ផ្ទះរបស់យើងផងដែរ ហើយយើងនឹងចុះហត្ថលេខាលើកិច្ចសន្យាបន្ទាប់ពីយើងត្រលប់ទៅផ្ទះវិញ។ ពួកគេរំភើបពេលបានឮដូច្នោះ ហើយចាប់ផ្ដើមសួរយើងអំពីផ្ទះថ្មីរបស់ពួកយើង។ យើងចាប់ផ្ដើមប្រាប់ពួកគេអំពីព្រះរាជ្យរបស់ព្រះ និងការផ្លាស់ប្រែនៃជីវិតរបស់យើង។ យើងបានចែករំលែកអំពីការដែលយើងបានទិញដី៥៥ហិកតាដោយសាច់ប្រាក់សុទ្ធ និងចិត្តរំភើបរបស់យើងជាមួយនឹងផ្ទះថ្មីនៅលើដីនោះ។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្រ្ត

យើងបានប្រាប់ពួកគេថា យើងបានយកគម្រោងផ្ទះថ្មីនោះមកជាមួយយើងដែរ ហើយពួកគេបានសុំយើងមើលគម្រោងផ្ទះថ្មីនោះ។ យើងមានចិត្តរីករាយក្នុងការបង្ហាញវា និងស្តាប់មតិយោបល់របស់ពួកគេទាក់ទងនឹងគម្រោងផ្ទះថ្មីរបស់យើង។ ដូច្នេះ យើងបានទៅយកគម្រោងនោះ លាវាដាក់លើតុផ្ទះបាយ និងអង្គុយមើលវាទាំងអស់គ្នានៅទីនោះ។ មិនយូរប៉ុន្មាន ភរិយារបស់គាត់បាននិយាយថា «ទេ កន្លែងនេះតូចពេកហើយ។» «អ្នកត្រូវការផ្ទះបាយធំជាងនេះ» «តើអ្នកមានបានគិតអំពីផ្ទះនេះ ពេលកូនៗរបស់អ្នកធំឡើងដែរឬទេ? ក្នុងនាមជាគ្រូគង្វាល អ្នកត្រូវការទីកន្លែងកម្សាន្តធំជាងនេះ»។ ជាទូទៅអ្វីដែលសំខាន់នោះគឺ ពួកគេបានបង្ហាញយើងថាផ្ទះនេះមិនមែនជាផ្ទះដែលយើងត្រូវសាងសង់ទេ ហើយយើងយល់ស្របជាមួយគ្រប់ចំណុចដែលពួកគេបានលើកឡើង។ «អីញ៉ឹង តើយើងអាចសាងសង់ផ្ទះដែលធំជាងនេះជាមួយទឹកប្រាក់ដែលយើងមាន បានយ៉ាងដូចម្តេចទៅ?» ពួកគេបាននិយាយថា «វាងាយស្រួលទេ»។ «សាងសង់វាដោយខ្លួនឯង!» ពេលខ្ញុំបានឮដូច្នោះ ខ្ញុំចង់តែសើច។ «ខ្ញុំសាងសង់ផ្ទះដោយខ្លួនឯង?» ខ្ញុំបាននិយាយដូច្នោះ ព្រោះខ្ញុំដឹងថាខ្ញុំគ្មានបទពិសោធអ្វីទាក់ទងនឹងការសាងសង់ផ្ទះទេ! ប៉ុន្តែ ពួកគេចាប់ផ្តើមលើកទឹកចិត្តពួកយើង ដោយប្រាប់ពួកយើងថា វាមិនពិបាកពេកទេ។ ពួកគេបានប្រាប់យើងអំពីសៀវភៅមួយក្បាលដែលមានចំណងជើងថា *សន្សំប្រាក់បានរហូតដល់៥០,០០០ដុល្លារ ឬច្រើនជាងនេះ ដោយធ្វើជាអ្នកម៉ៅការទូទៅរបស់អ្នកផ្ទាល់៖ របៀបរៀបចំគម្រោង ម៉ៅការបន្ត និងសាងសង់ផ្ទះក្នុងក្តីសុបិនរបស់អ្នក* ដោយ រ៉ិន រី ដេហ្គី។

ដូច្នេះ នៅពេលយើងត្រលប់មកដល់ផ្ទះវិញ យើងបានសម្រេចចិត្តមិនចុះហត្ថលេខាលើកិច្ចសន្យាសាងសង់ផ្ទះម៉ូឌុលនោះ។ យើងបានកម្មង់ទិញសៀវភៅនោះ និងបានអានវា ដោយគិតអំពីជំពូកនីមួយៗដែលយើងបានអាន។ យើងក៏ចាប់ផ្តើមមើលគម្រោងផ្ទះផ្ទាល់ខ្លួនផងដែរ។ ទីបំផុតយើងបានរកឃើញគម្រោងផ្ទះដែលយើងស្រលាញ់ ហើយបានចាប់ផ្តើមបែងចែកវាឱ្យទៅជាផែនការមួយជំហានម្តងៗ។ យើងក៏បាននិយាយជាមួយមិត្តភក្តិ និងមនុស្សដទៃទៀតដែលធ្លាប់សាងសង់ផ្ទះផងដែរ។ នៅទីបំផុត យើងបានសម្រេចចិត្តថា យើងអាចធ្វើវាបាន! យើងបានមើលគម្រោងសាងសង់ផ្ទះ ហើយសួរខ្លួនឯងថា «តើយើងអាចធ្វើអ្វីដោយខ្លួនឯង ដើម្បីអាចសាងសង់ផ្ទះនេះតាមគម្រោងថវិការបស់យើង?»។ មិនគួរឱ្យជឿ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំអាចតភ្លើងក្នុងផ្ទះទាំងមូលបាន សូម្បីតែខ្ញុំមិនដែលធ្លាប់តភ្លើងពីមុនមកសោះ។ មិត្តរបស់ខ្ញុំម្នាក់ដែលចេះតភ្លើង បានប្រាប់ខ្ញុំថា វាងាយស្រួលទេ ហើយគាត់នឹងបង្ហាញខ្ញុំអំពីរបៀបតភ្លើង។

ដោយសារខ្ញុំជាប់រវល់ជាមួយមុខជំនួញរបស់ខ្ញុំ គ្រិនដាបានសម្រេចចិត្តថាគាត់នឹងធ្វើជាអ្នកម៉ៅការទូទៅ ធ្វើការជាមួយអ្នកម៉ៅការបន្តរបស់យើង។ យើងបានជួលអ្នកម៉ៅការបន្ត សាងសង់គ្រោងផ្ទះរបស់យើង ហើយអ្វីដែលនៅសេសសល់គឺស្រេចលើយើង។ អ្វីដែលបានកើតឡើងបន្ទាប់ទៀត គឺជាពេលវេលាដ៏តានតឹងបំផុត ហើយក៏រំភើបបំផុតនៅក្នុងជីវិតរបស់យើងផងដែរ។ សង្ខេបឱ្យខ្លីមក យើងបានសាងសង់ផ្ទះមួយដែលមានទំហំទ្វេដងលើសពីផ្ទះម៉ូឌុល។ យើងមានទ្វារធ្វើអំពីឈើ កម្រាលឥដ្ឋធ្វើអំពីឈើ ទូដាក់ចានដ៏ស្រស់ស្អាតធ្វើអំពីឈើនៅក្នុងផ្ទះបាយ ព្រមទាំងមានឧបករណ៍ផ្ទះបាយថ្មីៗដែលធ្វើពីដែកអ៊ីណុក។ យើងបានធ្វើការប៉ាន់ប្រមាណចំនួនទឹកប្រាក់ដែលយើងបានសន្សំ ដោយការសាងសង់ផ្ទះដោយខ្លួនឯង ដែលមានចំនួនជាង ២០០,០០០ដុល្លារ!

**ខ្ញុំតែងតែនិយាយថា ការលាក់កំបាំងរបស់ព្រះជាម្ចាស់ បានលាក់ទុកសម្រាប់អ្នក មិនមែនលាក់បាំងពីអ្នកនោះទេ! មារសាតាំងរស់នៅក្នុងទីងងឹត វាមិនបានដឹងអំពីគម្រោងការរបស់ព្រះជាម្ចាស់ទេ!**

ថ្ងៃនេះខ្ញុំសប្បាយចិត្តណាស់ ដែលយើងបានសុំជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធទាក់ទងនឹងគម្រោងសង់ផ្ទះនេះ។ លទ្ធផលដែលយើងទទួលបាន គឺលើសពីអ្វីដែលយើងអាចស្រមៃថាយើងអាចធ្វើបានដោយខ្លួនឯង។ ខ្ញុំនៅតែមានអារម្មណ៍ស្ញប់ស្ញែង អំពីរបៀបដែលព្រះជាម្ចាស់បានរៀបចំដំណើររបស់យើងទៅរដ្ឋវីជីនៀ និងឱ្យយើងជួបប្ដីប្រពន្ធដែលទើបតែសាងសង់ផ្ទះរបស់ពួកគេរួច។ ខ្ញុំជឿជាក់ថា បើមិនមានការនេះកើតឡើងទេ យើងប្រហែលជាបានសាងសង់ផ្ទះម៉ូឌុលជាមិនខានទេ។ ខ្ញុំមិនចង់និយាយថាផ្ទះម៉ូឌុលនោះមិនល្អទេ ក៏ប៉ុន្តែមិនយូរប៉ុន្មានវានឹងតូចពេកសម្រាប់យើង។ ផ្ទះដែលយើងបានសាងសង់នៅតែជាទីបន្ទាប់ដែលខ្ញុំប្រើ ដើម្បីបង្ហាញអំពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយដល់អ្នក ក្នុងគ្រប់ស្ថានភាព ផ្ដល់ឱ្យអ្នកនូវគម្រោងការ និងការណែនាំដែលលើសពីការរំពឹងទុករបស់អ្នក!

ដូច្នេះ ខ្ញុំសូមនិយាយម្ដងទៀត...

**ព្រះជាម្ចាស់មានគម្រោងការសម្រាប់<u>អ្នក</u>!**

ប៉ុន្តែ អ្នកអាចនិយាយថា «លោកគ្រូហ្គារី រឿងនេះពិតជាល្អទាំងអស់ ប៉ុន្តែនៅម៉ាថាយ ១៣:៤៤ ចែងថា គម្រោងនេះត្រូវបានលាក់ទុក!» បាទ ត្រឹមត្រូវហើយ ហើយវាបាន

លាក់ទុក ដើម្បីជាប្រយោជន៍ដល់អ្នក។ សូមមើលអ្វីដែលព្រះយេស៊ូមានបន្ទូល នៅម៉ាថាយ ១៣:១០-១១។

> *ពេលនោះ ពួកសិស្សនាំគ្នាចូលមកជិតព្រះអង្គទូលសួរថា៖ «ហេតុដូចម្ដេចបានជាព្រះគ្រូមានព្រះបន្ទូលទៅកាន់បណ្ដាជន ដោយប្រើពាក្យប្រស្នាដូច្នេះ?»។ ព្រះអង្គតបទៅគេវិញថា៖ «មកពីព្រះជាម្ចាស់**<u>បានប្រោសប្រទានឱ្យអ្នក</u>**រាល់គ្នាយល់គម្រោងការដ៏លាក់កំបាំងរបស់ព្រះរាជ្យ នៃស្ថានបរមសុខ រីឯអ្នកដទៃវិញ ព្រះអង្គមិនប្រទានឱ្យយល់ឡើយ។*

ម៉ាថាយ ១៣:១០-១១

ចំណេះដឹងដ៏លាក់កំបាំងនេះ គឺសម្រាប់អ្នក វាមិនមែនសម្រាប់មារសាតាំង ឬសម្រាប់មនុស្សអាក្រក់ដែលប្រើវាខុស ឬរារាំងគម្រោងការរបស់ព្រះជាម្ចាស់នោះឡើយ។ ព្រះគម្ពីរនិយាយថា មារសាតាំងនឹងផ្លាស់ប្ដូរយុទ្ធសាស្ត្ររបស់វា ប្រសិនបើវាបានដឹងអំពីអ្វីដែលព្រះជាម្ចាស់កំពុងតែធ្វើ។

> *យើងប្រៀនប្រដៅអំពីប្រាជ្ញារបស់ព្រះជាម្ចាស់ ដែលព្រះអង្គបង្កប់ន័យទុកតាមគម្រោងការដ៏លាក់កំបាំងរបស់ព្រះអង្គ តាំងពីមុនកំណើតពិភពលោកមកម្ល៉េះ គឺព្រះអង្គបានគ្រោងទុកថានឹងប្រទានសិរីរុងរឿងមកយើង។ គ្មាននរណាម្នាក់ក្នុងចំណោមអ្នកគ្រប់គ្រងមនុស្សលោកនេះបានស្គាល់ប្រាជ្ញារបស់ព្រះអង្គទេ។ <u>ប្រសិនបើគេពិតជាបានស្គាល់មែន</u> <u>គេមិនឆ្កាងព្រះអម្ចាស់ប្រកបដោយសិរីរុងរឿងនោះឡើយ</u>។*

១ កូរិនថូស ២:៧-៨

ខ្ញុំតែងតែនិយាយថា ការលាក់កំបាំងរបស់ព្រះជាម្ចាស់ បានលាក់ទុកសម្រាប់អ្នក មិនមែនលាក់បាំងពីអ្នកនោះទេ! មារសាតាំងរស់នៅក្នុងទីងងឹត វាមិនបានដឹងអំពីគម្រោងការរបស់ព្រះជាម្ចាស់ទេ! វាគ្រាន់តែអាចមានប្រតិកម្មចំពោះកិច្ចការដែលព្រះកំពុងធ្វើតែប៉ុណ្ណោះ។ នៅពេលវាបានដឹងថាមានអ្វីកំពុងតែកើតឡើង វាយឺតពេលបាត់ទៅហើយ! ដូច្នេះពេលក្រោយ ពេលដែលអ្នកមានអារម្មណ៍ព្រួយបារម្ភ ដោយសារជិតដល់អគ្រាត្រទៅហើយ ហើយអ្នកនៅតែមិនទាន់ទទួលបានចម្លើយដែលអ្នកត្រូវការទៀត សូមចាំថា ព្រះជាម្ចាស់

មិនដែលឃើតពេលទេ ហើយអ្វីដែលអ្នកយល់ថា ជាការពន្យាពេល គឺដើម្បីជាប្រយោជន៍ដល់អ្នក ចម្លើយនោះនឹងរក្សាទុក រហូតដល់ពេលដែលត្រូវបង្ហាញឱ្យអ្នកដឹង។

> *ព្រះរាជ្យនៃស្ថានបរមសុខ ប្រៀបបីដូចជាកំណប់ដែលគេ**កប់ទុក**នៅក្នុងស្រែមួយ។ មានបុរសម្នាក់រកកំណប់នោះឃើញ ហើយ**<u>កប់ទុកវិញ</u>**។ គាត់មានចិត្តត្រេកអរជាខ្លាំង ក៏ចេញទៅលក់ទ្រព្យសម្បត្តិទាំងប៉ុន្មានដែលគាត់មាន យកប្រាក់ទិញដីស្រែនោះ។*
>
> ម៉ាថាយ ១៣:៤៤

យើងបានពិភាក្សាអំពីអ្វីជាស្រែ ហើយវានៅកន្លែងណា និងហេតុអ្វីបានជាកំណប់ត្រូវលាក់ទុកនៅទីនោះ។ យើងក៏បានពិភាក្សាអំពីរបៀបយើងអាចស្ដាប់ឮការអាថ៌កំបាំងនៃព្រះរាជ្យរបស់ព្រះ តាមរយៈការអធិស្ឋានដោយប្រើវិញ្ញាណ ឬការអធិស្ឋានជាភាសាដទៃ និងការស្ដាប់ព្រះសូរសៀងព្រះវិញ្ញាណដ៏វិសុទ្ធ។ ប៉ុន្តែ នៅមានគោលការណ៍សំខាន់មួយទៀតដែលអ្នកត្រូវដឹង ដែលមាននៅក្នុងព្រះគម្ពីរ។ ការមិនធ្វើតាមគោលការណ៍នេះ បណ្ដាលឱ្យគម្រោងការដ៏ល្អ និងថ្លៃថ្នូជាច្រើនមិនអាចកើតឡើង ហើយអាចបណ្ដាលឱ្យមានការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ជីវិតរបស់មនុស្សជាច្រើនផងដែរ។ ប្រសិនបើអ្នកកត់សម្គាល់នៅក្នុងខគម្ពីរនេះ អ្នកឃើញថា នៅពេលបុរសនោះឮអំពីកំណប់នោះ ឬគំនិតនោះ ឬការណែនាំនោះ ឬគម្រោងការមកពីព្រះ គាត់បានកប់វាទុកវិញ។ គាត់មិនបានធ្វើសកម្មភាពភ្លាមៗទេ! គាត់មិនបានចាប់ផ្ដើមប្រាប់មិត្តភក្តិ និងអ្នកជិតខាងរបស់គាត់ អំពីអ្វីដែលគាត់បានឮពីព្រះជាម្ចាស់ ឬអំពីគម្រោងការថ្មីដ៏គួរឱ្យរំភើបរបស់គាត់ភ្លាមៗទេ។ ព្រះគម្ពីរប្រាប់ថា គាត់បានកប់វាទុកវិញ ហើយចេញទៅ និងលក់អ្វីៗទាំងអស់ដែលគាត់មាន ហើយបន្ទាប់មកទិញដីស្រែនោះ។ បើនិយាយយ៉ាងសាមញ្ញ គាត់មិនចង់បង្ហាញទីតាំងនៃកំណប់ដល់អ្នកដទៃឡើយ រហូតទាល់តែគាត់បានក្លាយជាម្ចាស់ពិតនៃកំណប់នោះសិន។ តាមរយៈការរង់ចាំរហូតទាល់តែគាត់ក្លាយជាម្ចាស់របស់វាសិន គាត់ចង់ធានាថាគ្មាននរណាម្នាក់លួចវាពីគាត់។

ព្រះគម្ពីរក៏បង្ហាញថា នៅពេលដែលគាត់រកឃើញកំណប់នោះពីដំបូង គាត់មិនទាន់មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីទិញដីដែលមានកំណប់នោះទេ ហើយគាត់ត្រូវឆ្លងកាត់ដំណើរការមួយដែលរៀបចំគាត់ឱ្យរួចរាល់ ដើម្បីគាត់អាចទិញដីស្រែនោះបាន។ គោលការណ៍មួយនេះ លើសពីលុយកាក់ និងការគ្រាន់តែទិញអ្វីមួយ។ វាបង្រៀនយើងពីគោល

ការណ៍ជីវិតដ៏សំខាន់មួយ និងរបៀបដែលអ្នកត្រូវឆ្លើយតបចំពោះអ្វីដែលព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញដល់អ្នក ប្រសិនបើអ្នកចង់ទទួលបានជោគជ័យ។

ព្រះគម្ពីរប្រាប់ថា នៅពេលអ្នកបានឮគំនិតមួយ ឬការណែនាំមួយ អ្នកមិនត្រូវបន្តធ្វើដំណើរទៅមុខទេ រហូតទាល់តែអ្នកមានសមត្ថភាពកាន់កាប់វាសិន។ ខ្ញុំគិតថា វាងាយស្រួលយល់អំពីគោលការណ៍នេះ ជាមួយលុយកាក់។ ប្រសិនបើអ្នកមិនទាន់មានលុយគ្រប់គ្រាន់ដើម្បីទិញដីដែលមានកំណប់ទេ អ្នកមុខជាមិនប្រាប់នរណាម្នាក់ថាដីនោះមានកំណប់ទេ។ ប្រសិនបើដំណឹងនេះលេចឮទៅក្រៅ នោះនឹងមានអ្នកដទៃទិញដីនោះមុនអ្នកជាមិនខាន។ ផ្ទុយទៅវិញ អ្នកនឹងចេញទៅ ហើយធ្វើអ្វីដែលអ្នកអាចធ្វើបាន ដើម្បីបានលុយគ្រប់គ្រាន់ទិញដីនោះ ដោយរក្សាការសម្ងាត់អំពីកំណប់នោះ។

គោលការណ៍នេះអាចប្រើបានជាមួយគោលដៅ ឬការណែនាំដែលព្រះជាម្ចាស់បានប្រទានដល់អ្នក។ ជាច្រើនលើក គ្រិស្តបរិស័ទរំលងគោលការណ៍នេះតាំងពីពេលចាប់ផ្តើម។ ជាច្រើនលើក ព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញគំនិតមួយដល់យើង មិនមែនដើម្បីឱ្យយើងធ្វើសកម្មភាពភ្លាមៗទេ ក៏ប៉ុន្តែ ដើម្បីឱ្យយើងត្រៀមខ្លួនទុកជាមុន ដូច្នេះនៅពេលឱកាសនោះមកដល់ យើងពិតជាអាចចាប់យកឱកាសនោះបាន។ ដំណាក់កាលនៃការរៀបចំគឺជាដំណើរការដ៏សំខាន់បំផុត នៃដំណើរការទាំងមូល។ នៅក្នុងកីឡា ការប្រកួតឈ្នះ ឬចាញ់អាស្រ័យលើរបៀបដែលក្រុមទាំងមូលធ្វើការហ្វឹកហាត់មុនពេលចូលប្រកួត នៅពេលដែលមិនទាន់មាននរណាម្នាក់មើលពួកគេនៅឡើយ។ ប៉ុន្តែ អ្នកយល់ស្របថា ការហ្វឹកហាត់មិនសប្បាយទេ។ វាគួរឱ្យហត់នឿយ និងអស់កម្លាំងខ្លាំងណាស់។ យ៉ាងណាមិញ មនុស្សគ្រប់គ្នាចូលចិត្តភាពរំភើបរីករាយនៃការប្រកួត មានហ្វូងមនុស្សធំ មានពន្លឺភ្លើងភ្លឺ និងមានភាពរំភើបនៃជ័យជំនះ។

ជាអកុសល ក្តីសុបិនទាំងនោះប្រែក្លាយជាការឈឺចាប់ និងទុក្ខព្រួយ នៅពេលមិនបានយកចិត្តទុកដាក់ចំពោះការរៀបចំ។ ខ្ញុំមិនអាចប្រាប់អ្នកអស់ពីមនុស្សដែលខ្ញុំបានឃើញ ដែលជីវិតរបស់ពួកគេបានលិចលង់ ដោយសារមិនបានដឹងអំពីគោលការណ៍មួយនេះ។ ខ្ញុំធ្លាប់ឃើញមនុស្សដែលពិតជាទទួលបានការត្រាស់ហៅពីព្រះជាម្ចាស់ មនុស្សដែលទទួលបានការចាក់ប្រេងតាំង ចេញទៅ និងចាប់ផ្តើមក្រុមជំនុំ នៅពេលដែលពួកគេមិនទាន់បានត្រៀមខ្លួនរួចរាល់ផ្នែកអារម្មណ៍ ឬផ្នែកហិរញ្ញវត្ថុ ត្រូវបញ្ចប់ដោយគ្រោះមហន្តរាយជំនួសឱ្យភាពជោគជ័យនៃសុបិននិមិត្តដែលពួកគេមាន។ ខ្ញុំធ្លាប់ឃើញមនុស្សដែលទទួល

បានគំនិតអំពីជំនួញពីព្រះជាម្ចាស់ ហើយជឿជាក់ថាពួកគេនឹងទទួលបានជោគជ័យ បានចាកចេញពីការងារពេញពេលរបស់ពួកគេ ដោយមិនធ្វើតាមជំហានត្រឹមត្រូវ ឬការរៀបចំខ្លួនឱ្យបានត្រឹមត្រូវ ហើយទីបំផុត ពួកគេបញ្ចប់ដោយការក្ស័យធន។ ផ្នែកដ៏ក្រៀមក្រំនៃរឿងអស់ទាំងនេះ គឺថាពួកគេបានបន្ទោសព្រះជាម្ចាស់ ហើយមនុស្សដែលពាក់ព័ន្ធ ពួកគេបានយល់ខុសមិនត្រឹមតែចំពោះខ្លួនឯងទេ ក៏បានយល់ខុសចំពោះព្រះជាម្ចាស់ផងដែរ។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាមនុស្សជាច្រើនគិតថា ជោគជ័យអាចកើតឡើងក្នុងរយៈពេលតែមួយព្រព្រិចភ្នែក។ ប៉ុន្តែ មនុស្សយើងត្រូវតែទទួលការបង្រៀនអំពីដំណើរការនៃភាពជោគជ័យ ដែលមាននៅក្នុងខគម្ពីរដ៏សាមញ្ញមួយនេះ។

មានមនុស្សបានមកជួបខ្ញុំ ហើយនិយាយថា «លោកគ្រូ ព្រះជាម្ចាស់បានប្រាប់ខ្ញុំថា ក្រុមជំនុំនេះជាក្រុមជំនុំរបស់ខ្ញុំ»។ បន្ទាប់មកយើងលែងឃើញគាត់មកក្រុមជំនុំទៀត។ «លោកគ្រូ ព្រះជាម្ចាស់បានប្រទានគំនិតអាជីវកម្មដ៏ល្អមួយដល់ខ្ញុំ»។ បន្ទាប់មកយើងបានឮថាផ្ទះរបស់ពួកគេបានចុះក្នុងបញ្ជី ផ្ទះលក់របស់តំរួតក្នុងតំបន់ ហើយឡានរបស់ពួកគេត្រូវបានក្រុមហ៊ុនរឹបអូសយកវិញ។ ព្រះជាម្ចាស់មិនសព្វព្រះហឫទ័យឱ្យរឿងទាំងនេះកើតឡើងចំពោះអ្នកទេ។

នៅពេលដែលយើងបានឮគំនិតមួយពីព្រះវិញ្ញាណដ៏វិសុទ្ធ វាមិនមានន័យថា យើងត្រូវធ្វើសកម្មភាពតាមភ្លាមៗនោះទេ។ ភាគច្រើន យើងត្រូវលាក់ទុកក្តីសុបិននោះសិន ហើយត្រូវត្រៀមខ្លួន ដើម្បីអាចកាន់កាប់ក្តីសុបិននោះបាន។ តាមធម្មតា យើងមិនទាន់មានគ្រប់អ្វីទាំងអស់ដែលយើងត្រូវការ ដើម្បីធ្វើឱ្យក្តីសុបិននោះក្លាយជាការពិតទេ។ ការរៀបចំអាចត្រូវការពេលវេលាមួយសប្តាហ៍ ឬរាប់ឆ្នាំ វាអាស្រ័យលើអ្វីដែលព្រះជាម្ចាស់បានបង្ហាញអ្នកឱ្យធ្វើ។ អ្នកត្រូវតែយល់ថា ការរៀបចំ និងពេលវេលាមានសារៈសំខាន់ដូច ឬមានសារៈសំខាន់ជាងគំនិតដែលអ្នកទទួលបានពីព្រះជាម្ចាស់ទៅទៀត!

សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំទទួលការត្រាស់ហៅឱ្យប្រកាសដំណឹងល្អតាំងពីអាយុ១៩ឆ្នាំ។ ខ្ញុំនិមិត្តឃើញរូបភាពមួយដែលខ្ញុំកំពុងតែកាន់ព្រះគម្ពីរ ហើយព្រះអង្គម្ចាស់មានបន្ទូលមកកាន់ខ្ញុំថា «យើងត្រាស់ហៅឯង ឱ្យប្រកាសព្រះបន្ទូលរបស់យើង» ចំនួនបីដង។ វាជាបទពិសោធដ៏ពិតសម្រាប់ខ្ញុំ ហើយវាមានឥទ្ធិពលខ្លាំងណាស់។ ប៉ុន្តែ ព្រះជាម្ចាស់មិនបានប្រាប់ខ្ញុំឱ្យទៅចាប់ផ្តើមប្រកាសព្រះបន្ទូលនៅពេលនោះភ្លាមៗទេ។ ផ្ទុយទៅវិញ ទ្រង់បានប្រាប់ខ្ញុំឱ្យបន្តការសិក្សានៅមហាវិទ្យាល័យ។ អ្នកដឹងទេ ខ្ញុំបានចេញពីវិទ្យាល័យដោយមានមធ្យម

ភាគ១.៣។ ខ្ញុំជាមនុស្សម្នាក់ដែលខ្មាស់អៀនខ្លាំង ហើយជាសវាងនៅក្បែរមនុស្សច្រើន។ ខ្ញុំចង់បញ្ជាក់ឱ្យច្បាស់ថា ខ្ញុំមិនទាន់មានភាពចាស់ទុំគ្រប់គ្រាន់ ដើម្បីមើលថែរក្សាមនុស្សទេ! ដូច្នេះ ខ្ញុំបានចូលរៀនបន្តនៅមហាវិទ្យាល័យ ហើយវាពិបាក ពិតជាពិបាកខ្លាំង ប៉ុន្តែខ្ញុំបានតស៊ូ ហើយបានបញ្ចប់ការសិក្សារយៈពេល៥ឆ្នាំរបស់ខ្ញុំ។

នៅពេលចេញពីមហាវិទ្យាល័យ ខ្ញុំឆ្ងល់ថា តើវាដល់ពេលដែលខ្ញុំត្រូវប្រកាសព្រះបន្ទូលហើយឬនៅ។ ប៉ុន្តែ ព្រះអង្គម្ចាស់បានប្រាប់ខ្ញុំថា ទ្រង់ចង់ឱ្យខ្ញុំធ្វើការជាមួយក្រុមហ៊ុនហិរញ្ញវត្ថុក្នុងស្រុកមួយ ដែលលក់ការធានារ៉ាប់រង និងសន្តិសុខ។ ទោះបីជាខ្ញុំមិនសូវយល់ក៏ដោយ ខ្ញុំដឹងថាវាជាសម្លេងរបស់ព្រះជាម្ចាស់ ហើយខ្ញុំក៏ព្រមធ្វើការនៅទីនោះ។ ការងារនោះពិបាកជាងការសិក្សានៅមហាវិទ្យាល័យទៅទៀត។ ខ្ញុំត្រូវទូរស័ព្ទទៅអតិថិជនជារៀងរាល់ថ្ងៃ ហើយរៀនយកឈ្នះភាពភ័យខ្លាចរបស់ខ្ញុំចំពោះមនុស្ស។ ការរស់នៅដោយពឹងផ្អែកលើកម្រៃជើងសារពិតជាពិបាកខ្លាំងណាស់ បើនិយាយឱ្យត្រង់ទៅ ខ្ញុំចង់លាឈប់ពីការងារនោះសឹងតែរាល់ថ្ងៃ ប៉ុន្តែ ខ្ញុំដឹងថា ខ្ញុំមិនត្រូវលាឈប់ទេ។ ទីបំផុត បន្ទាប់ពីពីរបីឆ្នាំក្រោយមក ខ្ញុំពូកែធ្វើការងារនោះណាស់។ តាមពិត ឌ្រិនដា និងខ្ញុំបានបង្កើតការិយាល័យមួយដែលទទួលបានចំណាត់ថ្នាក់លេខមួយ ក្នុងចំណោមការិយាល័យ៥,០០០ទូទាំងប្រទេសជាមួយក្រុមហ៊ុនដែលយើងបានធ្វើការជាមួយ។

នៅពេលនោះហើយដែលព្រះជាម្ចាស់បានប្រាប់ខ្ញុំថា វាដល់ពេលដែលខ្ញុំត្រូវចាប់ផ្តើមដឹកនាំក្រុមជំនុំហើយ។ ពេលនោះ ខ្ញុំមានអាយុ៤០ឆ្នាំ។ វាត្រូវការពេល២១ឆ្នាំ ដើម្បីឱ្យព្រះជាម្ចាស់រៀបចំខ្ញុំឱ្យរួចរាល់ ដើម្បីបំពេញតាមសុបិននិមិត្តដែលខ្ញុំបានទទួលកាលពីអាយុ១៩ឆ្នាំ។ នៅពេលដែលខ្ញុំចាប់ផ្តើមដឹកនាំក្រុមជំនុំ ទើបខ្ញុំដឹងថា ហេតុអ្វីបានជាចាំបាច់ត្រូវមានការរៀបចចំច្រើនម្ល៉េះ។ ការធ្វើជាគ្រូគង្វាល ពិបាកជាងអ្វីដែលខ្ញុំធ្លាប់គិតទៅទៀត។ ប៉ុន្តែ ដោយសារខ្ញុំបានទទួលការហ្វឹកហ្វឺនក្នុងការធ្វើការជាមួយមនុស្ស និងការដោះស្រាយជាមួយការបដិសេធនៅក្នុងអាជីវកម្មរបស់ខ្ញុំ ខ្ញុំអាចបន្តស្មោះត្រង់ចំពោះការត្រាស់ហៅរបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់ខ្ញុំបាន។ មិនមែនគ្រប់កិច្ចការទាំងអស់ត្រូវការពេលវេលា២១ឆ្នាំដើម្បីរៀបចំខ្លួនឱ្យរួចរាល់ដើម្បីអាចធ្វើវានោះទេ ប៉ុន្តែ គោលការណ៍នៃការរៀបចំគឺដូចគ្នា។

ដោយសារគោលការណ៍នៃការរៀបចំ ខ្ញុំចូលចិត្តសម្រាយខគម្ពីរនៅ ម៉ាថាយ ១៣: ៤៤ ដូចខាងក្រោម៖

*<u>ព្រះរាជ្យនៃស្ថានបរមសុខ</u>ដែលនៅក្នុងអ្នក ផ្តល់ឱ្យអ្នកនូវចំណេះដឹង ឬឱ្យអ្នកអាចទទួលបានចំណេះដឹងដ៏អាថ៌កំបាំង ឬអ្វីដែលលាក់កំបាំងដែលព្រះជាម្ចាស់ទ្រង់*

*ជ្រាបដឹង។ អ្នកអាចទទួលបានចំណេះដឹងនេះ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះជាម្ចាស់ ដែលគង់នៅក្នុងអ្នក។ នៅពេលបុរសម្នាក់រកឃើញ ឬឮអំពីចំណេះដឹងដ៏អាថ៌កំបាំងនេះ វាប្រៀបដូចជាកំណប់ទ្រព្យសម្រាប់គាត់ ឬជាចម្លើយដែលគាត់ត្រូវការ គាត់កប់វាទុកវិញនៅក្នុងចិត្ត និងគំនិតរបស់គាត់។ ហើយបន្ទាប់មកដោយមានចិត្តត្រេកអរជាខ្លាំង គាត់ក៏ចេញទៅដោយមានកម្លាំងខ្លាំងក្លា ជាមួយការរៀបចំដ៏ប្រយ័ត្នប្រយែង ដើម្បីបន្តស្វែងរកទិសដៅ និងការណែនាំដែលបើកបង្ហាញឱ្យគាត់ដឹង ដូច្នេះគាត់អាចកាន់ និងចាប់យកចម្លើយដែលគាត់ត្រូវការបាន។*

# ជំពូក ៨
# កន្លែងដ៏ពិបាកនៃការដំឡើងតំណែង

មិត្តរបស់ខ្ញុំម្នាក់ឈ្មោះ លោកគ្រូតីតធី និងភរិយារបស់គាត់ឈ្មោះ បិវ ដែលជាគ្រូគង្វាលនៅក្រុមជំនុំដ៏ធំមួយនៅប្រទេសនូវែលហ្សេឡង់ បានមកលេងសហរដ្ឋអាមេរិករយៈពេលខ្លី។ ពេលនោះគឺចំរដូវបុណ្យណូអែល ហើយពួកគមានគម្រោងឈប់សម្រាកនៅរដ្ឋខូឡូរ៉ាដូស្ព្រីង នៅសណ្ឋាគារប្រ៊ដមួរ ដើម្បីលំហែកាយ និងរីករាយជាមួយទេសភាពណូអែលនៅទីនោះ។ ប្រសិនបើអ្នកមិនធ្លាប់បានទៅសណ្ឋាគារប្រ៊ដមួរទេ វាគឺជារមណីយដ្ឋានដ៏ល្អប្រណិតមួយនៅសហរដ្ឋអាមេរិក ដែលនៅទល់មុខនោះមានភ្នំថ្មជាច្រើន ហើយនៅទីនោះពួកគេល្បីខាងការតុបតែងសម្រាប់បុណ្យណូអែល។ លោកគ្រូតីតធីបានទូរស័ព្ទមកពួកយើង និងប្រាប់ពួកយើងថាពួកគាត់នឹងទៅទីនោះ ហើយបានសួរពួកយើងថាតើយើងចង់ចូលរួមជាមួយពួកគាត់ដែរឬទេ។ យើងបានឆក់យកឱកាសនេះ ហើយបានចំណាយពេលបីថ្ងៃយ៉ាងរីករាយនៅទីនោះជាមួយពួកគាត់។

នៅពេលខ្ញុំនៅជាមួយលោកគ្រូតីតធី ភាគច្រើនយើងចំណាយពេលជាច្រើននិយាយអំពីព័ន្ធកិច្ចរបស់យើង ដោយសារគាត់ជាម្នាក់នៅក្នុងក្រុមប្រឹក្សាភិបាលរបស់យើង ហើយនេះក៏ជាគោលបំណងមួយនៃដំណើររបស់គាត់លើកនេះផងដែរ។ យើងទាំងពីរបាននិយាយអំពីគម្រោងសម្រាប់ឆ្នាំខាងមុខ ហើយគ្រាន់តែចែករំលែកគំនិតផ្សេងៗជាមួយគ្នា។ នៅទីបំផុត ដល់ពេលដែលយើងត្រូវលាគ្នា វាជាពេលដ៏ក្រៀមក្រំសម្រាប់យើង ដោយសារយើងជាមិត្តល្អនឹងគ្នា។ ជាធម្មតា ឌ្រិនដា និងខ្ញុំទៅលេងពួកគាត់នៅប្រទេសនូវែលហ្សេឡង់មួយឆ្នាំម្តង ឬយ៉ាងហោចណាស់ពីរឆ្នាំម្តង ក៏ប៉ុន្តែ ឆ្នាំនេះខ្ញុំរវល់ខ្លាំងមែនទែន ហើយមិនបានមានគម្រោងទៅលេងពួកគាត់ទេ។

ដូច្នេះ យើងបានត្រលប់មកផ្ទះវិញ ដោយមានក្តីរំពឹងទុកដ៏ល្អអស្ចារ្យសម្រាប់ឆ្នាំថ្មី។ គួរឱ្យចាប់អារម្មណ៍ នៅថ្ងៃទី៩ ខែមករា ខ្ញុំទទួលបានសុបិននិមិត្តមួយ ហើយនៅក្នុង

សុបិននោះ គេប្រាប់ខ្ញុំថាលោកគ្រូតីតធីនឹងអញ្ជើញខ្ញុំឱ្យទៅអធិប្បាយនៅក្រុមជំនុំរបស់គាត់ក្នុងខែគុម្ភៈនេះ។ ខ្ញុំចាំថា ខ្ញុំធ្លាប់គិតថាវាមិនអាចទៅរួចទេ ព្រោះខ្ញុំទើបតែបានចំណាយពេលបីថ្ងៃជាមួយគាត់ ហើយគាត់មិនបាននិយាយប្រាប់ខ្ញុំអំពីរឿងនេះទេ ហើយនៅសល់តែប៉ុន្មានសប្តាហ៍ទៀតប៉ុណ្ណោះដល់ខែគុម្ភៈហើយ។ ខ្ញុំបានប្រាប់ឌ្រិនដាអំពីរឿងនេះ ពេលដែលខ្ញុំដើរទៅផ្ទះបាយ ដើម្បីញ៉ាំអាហារពេលព្រឹក។

កំព្យូទ័ររបស់ខ្ញុំនៅលើតុផ្ទះបាយ ហើយខ្ញុំបានបើកវាដោយចៃដន្យ។ នៅពេលដែលខ្ញុំកំពុងតែផឹកកាហ្វេ ខ្ញុំក៏ទទួលបានអ៊ីមែលមួយពីលោកគ្រូតីតធី។ នៅពេលខ្ញុំបើកអ៊ីមែលនោះ ខ្ញុំក៏ភ្ញាក់ផ្អើល ដោយសារលោកគ្រូតីតធីអញ្ជើញខ្ញុំឱ្យទៅអធិប្បាយនៅក្នុងសន្និបាតហិរញ្ញវត្ថុប្រចាំឆ្នាំរបស់គាត់ ដែលនឹងកើតឡើងក្នុងរយៈពេលបីសប្តាហ៍ខាងមុខនេះ។ ពិតណាស់ ខ្ញុំពិតជាភ្ញាក់ផ្អើល តែមិនភ្ញាក់ផ្អើលខ្លាំងពេកទេ ដោយសារខ្ញុំបានទទួលសុបិននិមិត្ត ហើយបានដឹងអំពីការនេះរួចហើយ។ ខ្ញុំបានក្រឡេកមើលកាលវិភាគរបស់ខ្ញុំ ដើម្បីមើលថាវាអាចទៅរួចដែរឬទេ ដោយសារខ្ញុំមានគម្រោងធ្វើដំណើរទៅច្រើនកន្លែង នៅអំឡុងពេលដែលលោកគ្រូតីតធីអញ្ជើញខ្ញុំទៅប្រទេសនូវែលហ្សេឡង់។ ឌ្រិនដា និងខ្ញុំមានគម្រោងនឹងទៅទីក្រុងប៊ុយនូសហ្សែរី ប្រទេសអាហ្សង់ទីនពីរបីថ្ងៃ មុនពេលដែលខ្ញុំត្រូវទៅដល់ទីក្រុងអូកឡិន ប្រទេសនូវែលហ្សេឡង់។ វិធីតែមួយគត់ដែលខ្ញុំអាចទៅដល់ទីនោះទាន់ពេល គឺ ត្រូវចាកចេញពីសន្និបាតនៅទីក្រុងប៊ុយនូសហ្សែរីភ្លាមៗ ហើយធ្វើដំណើរទៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី បន្ទាប់មកធ្វើដំណើរទៅទីក្រុងអូកឡិនតែម្តង។ ខ្ញុំមិនដែលរៀបចំដំណើរបែបនេះទេ ប៉ុន្តែ ដោយសារព្រះអង្គម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំ ខ្ញុំដឹងថាខ្ញុំត្រូវតែធ្វើដូច្នេះ។

ការធ្វើដំណើររបស់យើងទៅប្រទេសអាហ្សង់ទីន គឺជាដំណើរសាជីវកម្មរបស់ក្រុមហ៊ុនដែលឧបត្ថម្ភដោយអ្នកលក់ម្នាក់ដែលក្រុមហ៊ុនរបស់យើងធ្វើអាជីវកម្មជាមួយ។ វាជាដំណើរដ៏ល្អ និងជាដំណើរដ៏រីករាយជាមួយមិត្តភក្តិដែលពួកយើងជាធម្មតាជួបជុំគ្នាម្តងមួយឆ្នាំ។ នៅពេលនោះប្រទេសអាហ្សង់ទីនកំពុងតែដោះស្រាយជាមួយវិបត្តិហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរគួរសមមួយ ហើយក៏មានកុបកម្មខ្លះកើតឡើងនៅទីនោះ ប៉ុន្តែ សរុបសេចក្តីទៅវាជាដំណើរដ៏ល្អមួយ ដោយសារខ្ញុំមិនធ្លាប់បានទៅទីនោះពីមុនមកទេ។ ការធ្វើដំណើររបស់យើងទៅទីក្រុងស៊ីដនីមានរយៈពេល១៦ម៉ោង នៅលើអាកាស វាជាការធ្វើដំណើរដ៏យូរបំផុតដែលខ្ញុំធ្លាប់ធ្វើ។ យន្តហោះនោះហោះឆ្លងកាត់ប៉ូលខាងត្បូងដែលខ្ញុំគិតថាវាពិតជាអស្ចារ្យ ដោយសារខ្ញុំចង់ឃើញផ្នែកនេះនៃពិភពលោកនេះពីលើអាកាស។

ក្នុងអំឡុងពេលនៃការហោះហើររបស់យើង ខ្ញុំបានសំឡឹងមើលក្រោបង្អួច ខ្ញុំគ្មានឃើញអ្វីក្រៅពីទឹកកក និងព្រិលទេនៅខាងក្រោមខ្ញុំ។ ខ្ញុំក៏ភ្ញាក់ខ្លួនថា ខ្ញុំកំពុងតែធ្វើដំណើរតាមយន្តហោះរបស់ប្រទេសអាហ្សង់ទីន ជាក្រុមហ៊ុនអាកាសចរណ៍មួយដែលកំពុងតែមានបញ្ហាហិរញ្ញវត្ថុ នៅក្នុងប្រទេសមួយដែលកំពុងជួបវិបត្តិសេដ្ឋកិច្ច។ ស្រាប់តែមានគំនិតមួយចូលក្នុងការគិតរបស់ខ្ញុំ ចុះប្រសិនបើក្រុមហ៊ុននេះមិនបានថែរក្សាយន្តហោះរបស់ពួកគេឱ្យបានល្អ ហើយយើងត្រូវចុះចតនៅផ្នែកមួយនេះនៃពិភពលោក នោះវាពិតជាមិនស្រួលនោះទេ។ ប៉ុន្តែ ខ្ញុំក៏ដឹងថាខ្ញុំកំពុងស្ថិតក្នុងព្រះហស្តដ៏មានសុវត្ថិភាពរបស់ព្រះអង្គម្ចាស់ ព្រោះទ្រង់ផ្ទាល់បានណែនាំខ្ញុំឱ្យធ្វើដំណើរមួយនេះ។

ពេលមកដល់ទីក្រុងស៊ីដនី យើងបានទូរស័ព្ទទៅលោកគ្រូភីតធី និងបិវ ហើយយើងរន្ធត់មែនទែន ដោយបានឮថា លោកគ្រូភីតធីកំពុងតែនៅក្នុងមន្ទីរពេទ្យ ព្រោះគាត់ទើបតែគាំងបេះដូង។ គាត់មិនអាចអធិប្បាយនៅក្នុងសន្និបាតហិរញ្ញវត្ថុរបស់គាត់ពេលចុងសប្តាហ៍នេះបានទេ ហើយគាត់បានសុំខ្ញុំឱ្យបង្រៀនក្នុងសន្និបាតនេះទាំងមូល។ ឥឡូវនេះ ខ្ញុំបានដឹងអំពីមូលហេតុដែលព្រះជាម្ចាស់បានបង្គាប់ខ្ញុំ ឱ្យមកប្រទេសនូវែលហ្សេឡង់នេះហើយ ហើយខ្ញុំពិតជាកោតសរសើរចំពោះរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំជំហានរបស់យើង។ នេះជាការរំលឹកដ៏ល្អអស្ចារ្យ ដែលបានចែងនៅក្នុង រ៉ូម ៨:១៤។

**«ដ្បិតអស់អ្នកដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ណែនាំ សុទ្ធតែជាបុត្ររបស់ព្រះជាម្ចាស់។»**

**រ៉ូម ៨:១៤**

*«ដ្បិតអស់អ្នកដែលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ណែនាំ សុទ្ធតែជាបុត្ររបស់ព្រះជាម្ចាស់។»* (រ៉ូម ៨:១៤)

ជាថ្មីម្តងទៀត យើងកំពុងតែនិយាយអំពីសមត្ថភាពក្នុងការស្តាប់តាមការណែនាំគំនិត និងរបៀបគិត មកពីព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងព្រះគម្ពីរ គ្មានរឿងណាដែលបង្ហាញអំពីរបៀបក្នុងការស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបានចម្លើយដែលអ្នកត្រូវការ ល្អជាងរឿងរបស់លោកដានីយ៉ែលទេ។ សូមតានដានរឿងរបស់លោកដានីយ៉ែល ដោយចាប់ផ្តើមពីដានីយ៉ែល ២:១-៦។

*នៅឆ្នាំទីពីរ នៃរជ្ជកាលព្រះចៅនេប៊ូក្នេសា ទ្រង់បានយល់សុបិននិមិត្ត ដែលធ្វើឱ្យទ្រង់ខ្វល់ព្រះហឫទ័យមិនអាចផ្ទំលក់ទៀតបានឡើយ។ ព្រះមហាក្សត្របានកោះហៅពួកគ្រូមន្តអាគម ហោរា គ្រូធ្មប់ និងគ្រូទាយមក ដើម្បីកាត់ស្រាយសុបិនថ្វាយព្រះរាជា គេក៏នាំគ្នាចូលមកគាល់ស្ដេច។ ព្រះមហាក្សត្រមានរាជឱង្ការថា៖ « យើងបានសុបិននិមិត្ត ហើយខ្វល់ខ្វាយក្នុងចិត្តណាស់ ព្រោះយើងចង់ដឹងថាបានសុបិនឃើញអ្វី»។*

*ពួកគ្រូទាយទូលស្ដេចវិញជាភាសាអារ៉ាមថា៖ «បពិត្រព្រះរាជាសូមទ្រង់មានព្រះជន្មគង់នៅជាយូរអង្វែងតរៀងទៅ! សូមព្រះករុណាមានរាជឱង្ការឱ្យយើងខ្ញុំដឹងផងថា ព្រះករុណាទ្រង់សុបិនយ៉ាងណា យើងខ្ញុំនឹងកាត់ស្រាយអត្ថន័យថ្វាយ»។*

*ព្រះមហាក្សត្រមានរាជឱង្ការទៅកាន់គ្រូទាយទាំងនោះវិញថា៖ «យើងបានសំរេចចិត្តដូចតទៅៈ ប្រសិនបើអ្នករាល់គ្នាមិនប្រាប់ឱ្យយើងដឹងអំពីសុបិន ព្រមទាំងកាត់ស្រាយអត្ថន័យទេនោះ យើងនឹងកាប់ចិញ្ច្រាំអ្នករាល់គ្នា ហើយដុតផ្ទះអ្នករាល់គ្នាឱ្យទៅជាផេះទៀតផង។ ផ្ទុយទៅវិញ ប្រសិនបើអ្នករាល់គ្នាប្រាប់ឱ្យយើងដឹងអំពីសុបិន ព្រមទាំង<u>កាត់ស្រាយន័យ យើងនឹងឱ្យរង្វាន់ដ៏មានតម្លៃ និងយសស័ក្តិដ៏ខ្ពង់ខ្ពស់ដល់អ្នករាល់គ្នាទៀតផង</u>។ ដូច្នេះ អ្នករាល់គ្នាត្រូវតែប្រាប់ឱ្យយើងដឹងអំពីសុបិន និងអត្ថន័យរបស់វា»។*

ដានីយ៉ែល ២:១-៦

*គ្រូទាយទាំងនោះទូលព្រះមហាក្សត្រថា៖ «បពិត្រព្រះរាជា នៅលើផែនដីពុំមាននរណាម្នាក់អាចធ្វើតាមបញ្ជារបស់ព្រះករុណាបានឡើយ។ គ្មានស្ដេចណាមួយទោះបីជាស្ដេចដ៏ធំឧត្តុង្គឧត្ដម និងមានឫទ្ធិអំណាចយ៉ាងណាក្ដី ធ្លាប់បង្គំគ្រូមន្តអាគម ហោរា និងគ្រូទាយឱ្យធ្វើការអ្វីដូចព្រះករុណាបានបង្គាប់នេះទេ។ ព្រះករុណាបញ្ជាដូច្នេះហួសពីសមត្ថភាពដែលមនុស្សអាចធ្វើបាន ក្រៅពីព្រះដែលមិនស្ថិតនៅក្នុងចំណោមសត្វលោកនេះគ្មាននរណាម្នាក់អាចធ្វើតាមបញ្ជារបស់ព្រះករុណាបានទេ»។ ពេលឮដូច្នេះព្រះរាជាក្រេវក្រោធយ៉ាងខ្លាំងឥតឧបមា ទ្រង់ក៏ចេញបញ្ជាឱ្យគេប្រហារជីវិតអ្នកប្រាជ្ញទាំងប៉ុន្មាននៅស្រុកបាប៊ីឡូន។ គេបានប្រកាសផ្សាយរាជបញ្ជា ហើយពួកអ្នកប្រាជ្ញត្រូវគេនាំយកទៅ បម្រុងនឹងប្រហារជីវិត។ គេក៏រកចាប់លោកដានីយ៉ែល និងមិត្តភក្តិរបស់លោក យកទៅសម្លាប់ដែរ។*

ដានីយ៉ែល ២:១-៦

*បន្ទាប់មក លោកទៅផ្ទះវិញ ជំរាបលោកហាណានា លោកមីសាអែល និងលោកអសារាជាមិត្តភក្តិឱ្យបានជ្រាបពីហេតុការណ៍នេះ ហើយបបួលគ្នាទូលអង្វរព្រះជាម្ចាស់នៃស្ថានបរមសុខ សូមទ្រង់អាណិតមេត្តាបំភ្លឺលោកឱ្យយល់អាថ៌កំបាំងនេះ កុំឱ្យគេប្រហារជីវិតលោក និងមិត្តភក្តិ ព្រមទាំងអ្នកប្រាជ្ញឯទៀតៗនៅស្រុកបាប៊ីឡូនឡើយ។ ពេលនោះ ព្រះជាម្ចាស់បានបំភ្លឺលោកដានីយ៉ែលឱ្យដឹងការអាថ៌កំបាំងនេះ តាមរយៈនិមិត្តហេតុដ៏អស្ចារ្យនៅពេលយប់។ លោកដានីយ៉ែលក៏លើកតម្កើងព្រះជាម្ចាស់នៃស្ថានបរមសុខ។ លោកពោលថា៖ «សូមលើកតម្កើងព្រះនាមព្រះជាម្ចាស់ អស់កល្បជាអង្វែងតរៀងទៅ! ព្រះអង្គប្រកបដោយព្រះប្រាជ្ញាញាណ និងព្រះចេស្តា ព្រះអង្គធ្វើឱ្យពេលវេលា និងរដូវកាល ផ្លាស់ប្តូរជាបន្តបន្ទាប់គ្នា ព្រះអង្គទម្លាក់ស្តេចនានាពីរាជបល្ល័ង្ក ព្រះអង្គលើកស្តេចនានាឱ្យឡើងគ្រងរាជ្យ ព្រះអង្គប្រទានប្រាជ្ញាដល់ពួកអ្នកប្រាជ្ញ និងប្រទានចំណេះដល់អ្នកដែលចេះពិចារណា <u>**ព្រះអង្គសម្តែងឱ្យស្គាល់អ្វីៗដែលមានអត្ថន័យជ្រៅជ្រះ និងលាក់កំបាំងព្រះអង្គឈ្វេងយល់អ្វីៗដែលស្ថិតនៅក្នុងភាពងងឹត ដ្បិតមានពន្លឺស្ថិតនៅជាមួយព្រះអង្គ**</u>។*

ដានីយ៉ែល ២:១៧-២២

ដានីយ៉ែលកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ខ្លាំង អាចរស់ ឬស្លាប់។ ប៉ុន្តែ នេះជាគន្លឹះដ៏សំខាន់សម្រាប់ការដំឡើងតំណែងរបស់អ្នក។ ព្រះជាម្ចាស់បានប្រើឱកាសនេះ ដើម្បីរៀបចំការដំឡើងតំណែងឱ្យគាត់ មិនមែនធ្វើឱ្យគាត់ធ្លាក់ចុះនោះទេ។ ដានីយ៉ែលអាចប្រាប់អំពីក្តីសុបិន និងការបកស្រាយនៃសុបិននោះដល់ស្តេចនេប៊ូក្នេសា ដោយសារចំណេះដឹងដ៏លាក់កំបាំងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះមហាក្សត្រមានសេចក្តីត្រេកអរ ដូចយើងឃើញនៅក្នុងអត្ថបទគម្ពីរខាងក្រោម៖

*ពេលនោះ ព្រះចៅនេប៊ូក្នេសាក្រាបចុះ អោនព្រះភក្ត្រដល់ដី ថ្វាយបង្គំលោកដានីយ៉ែល ហើយបញ្ជាឱ្យគេធ្វើយញ្ញបូជា និងដុតគ្រឿងក្រអូបដើម្បីគោរពលោក។ ព្រះរាជាមានរាជឱង្ការមកលោកដានីយ៉ែលថា៖ «ព្រះរបស់អស់លោកពិតជាព្រះលើព្រះនានា និងជាព្រះអម្ចាស់លើព្រះអម្ចាស់នានាមែន! មានតែព្រះអង្គទេដែលសម្តែងគម្រោងការដ៏លាក់កំបាំងទាំងឡាយ ហេតុនេះហើយបានជាលោករកឃើញគម្រោងការដ៏លាក់កំបាំងនេះ»។*

*<u>បន្ទាប់មក ព្រះរាជាបានលើកតម្កើងលោកដានីយ៉ែល ព្រមទាំងប្រទានរង្វាន់ដ៏មានតម្លៃយ៉ាងច្រើនដល់លោក។ ស្ដេចក៏ប្រទានឱ្យលោកត្រួតត្រាលើអាណាខេត្តបាប៊ីឡូនទាំងមូល និងឱ្យលោកធ្វើជាប្រមុខលើពួកអ្នកប្រាជ្ញទាំងអស់នៅស្រុកបាប៊ីឡូន។</u> លោកដានីយ៉ែលទូលអង្វរស្ដេច សូមទ្រង់ប្រទានឱ្យលោកសាដ្រាក់ លោកមែសាក់ និងលោកអបេឌ-នេកោ គ្រប់គ្រងលើអាណាខេត្តបាប៊ីឡូន ហើយខ្លួនលោកផ្ទាល់នៅបម្រើព្រះមហាក្សត្រក្នុងព្រះបរមរាជវាំង។*

ដានីយ៉ែល ២:៤៦-៤៩

តើអ្វីជាលទ្ធផលនៃការដែលដានីយ៉ែលអាចស្ដាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់? ការដំឡើងតំណែង និងទ្រព្យសម្បត្តិ!

យើងអាចឃើញលទ្ធផលដូចគ្នា នៅក្នុងរឿងមួយទៀតក្នុងព្រះគម្ពីរផងដែរ គឺរឿងរបស់លោកយ៉ូសែប។ លោកយ៉ូសែបបានប្រឈមនឹងស្ថានភាពស្រដៀងគ្នាដូចលោកដានីយ៉ែលដែរ គឺគាត់បានមានឱកាសក្នុងការបកស្រាយសុបិនរបស់ស្ដេចផារ៉ោន។ បន្ទាប់ពីបានបកស្រាយសុបិនយ៉ាងជោគជ័យមក គេក៏ឱ្យគាត់រៀបចំផែនការផ្នែករដ្ឋបាល ដើម្បីជួយសង្គ្រោះប្រទេសអេហ្ស៊ីបពីគ្រោះរាំងស្ងួតដែលបានបង្ហាញនៅក្នុងក្ដីសុបិន។ យើងអាចឃើញការឆ្លើយតបរបស់ស្ដេចផារ៉ោននៅក្នុង លោកុប្បត្តិ ៤១:៣៩-៤០៖

*ព្រះចៅផារ៉ោនមានរាជឱង្ការមកកាន់លោកយ៉ូសែបថា៖ «ព្រះជាម្ចាស់បានបង្ហាញឱ្យលោកដឹងហេតុការណ៍ទាំងនេះហើយ គឺគ្មាននរណាម្នាក់មានប្រាជ្ញាវាងវៃដូចលោកទេ។ ដូច្នេះ យើងសុំតែងតាំងលោកឱ្យគ្រប់គ្រងលើស្រុកអេស៊ីប ហើយប្រជារាស្ត្ររបស់យើងទាំងមូលនឹងស្ថិតនៅក្រោមបញ្ជារបស់លោក។ មានតែព្រះរាជបល្ល័ង្កមួយប៉ុណ្ណោះ ដែលធ្វើឱ្យយើងមានឋានៈខ្ពស់ជាងលោក»។*

លោកុប្បត្តិ ៤១:៣៩-៤០

នៅក្នុងរឿងទាំងពីរនេះ ពិតជាមានមានភាពអស់សង្ឃឹមពេលចាប់ផ្ដើមដំបូង ប៉ុន្តែលទ្ធផលដែលពួកគេទទួលបានគឺ ការដំឡើងតំណែង និងទ្រព្យសម្បត្តិ។ បើនិយាយឱ្យសាមញ្ញទៅ ពិតពលោកនេះនឹងផ្ដល់ប្រាក់ជាច្រើនដល់មនុស្សដែលចេះដោះស្រាយបញ្ហាធំៗ។ ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងអ្នក ចូលចិត្តដាក់អ្នកនៅក្នុងស្ថានភាពដែលមានបញ្ហាធំៗ! សូមកុំភ័យខ្លាចនៅពេលការនេះកើតឡើងចំពោះអ្នក ប៉ុន្តែផ្ទុយទៅវិញ សូមចាប់ផ្ដើមសរសើរតម្កើងព្រះជាម្ចាស់ ព្រោះថាទ្រង់នឹងជួយអ្នក ដូចដែលទ្រង់បានជួយដានីយ៉ែល

និងយ៉ូសែបដែរ! ខ្ញុំតែងតែនិយាយថា ព្រះជាម្ចាស់ទទួលបានសិរីល្អ ហើយខ្ញុំវិញទទួលបានប្រាក់ឈ្នួល! ខ្ញុំចូលចិត្តអ្វីដែលលោកដានីយ៉ែលបាននិយាយអំពីព្រះជាម្ចាស់៖ «**ព្រះអង្គសម្តែងឱ្យស្គាល់អ្វីៗ ដែលមានអត្ថន័យជ្រៅជ្រះ និងលាក់កំបាំងព្រះអង្គឈ្វេងយល់អ្វីៗដែលស្ថិតនៅក្នុងភាពងងឹត ដ្បិតមានពន្លឺស្ថិតនៅជាមួយព្រះអង្គ**»។ លោកដានីយ៉ែលនិយាយថា មានពន្លឺស្ថិតនៅជាមួយទ្រង់។ ការនេះមានន័យថា ពេលដែលអ្នកដើរនៅទីងងឹត អ្នកបើកភ្លើងឡើង ដើម្បីឱ្យអ្នកអាចមើលឃើញផ្លូវ! ពន្លឺឈ្នះសេចក្តីភ័យខ្លាចដោយសារអ្នកដឹងថាអ្នកគួរដើរតាមផ្លូវណា។ លោកប៉ូលបញ្ជាក់នៅក្នុងខគម្ពីរខាងក្រោមថា ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់យើង ព្រមទាំងជួយយើងក្នុងគ្រាលំបាក។

*«បងប្អូនជ្រាបស្រាប់ហើយថា កាលបងប្អូនមិនទាន់ស្គាល់ព្រះអង្គនៅឡើយបងប្អូនបានបណ្តោយខ្លួនទៅគោរពព្រះក្លែងក្លាយដែលមិនចេះនិយាយ។»*
(១ កូរិនថូស ១២:២)

លោកប៉ូលនិយាយថា រូបព្រះមិនចេះនិយាយទេ តែព្រះជាម្ចាស់របស់យើងវិញទ្រង់មានព្រះបន្ទូលមកកាន់យើង!

ឥឡូវនេះអ្នកប្រហែលជាឆ្ងល់ហើយ ថាហេតុអ្វីបានជាខ្ញុំដាក់ចំណងជើងជំពូកនេះ «កន្លែងដ៏ពិបាកនៃការដំឡើងតំណែង»។ ចម្លើយគឺដោយសារតែនៅកន្លែងដ៏ពិបាកព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅក្នុងអ្នកមានចម្លើយសម្រាប់អ្នក។ ដោយសារតែកន្លែងដ៏ពិបាកនេះហើយ ដែលអ្នកមានឱកាសដ៏ល្អឥតខ្ចោះ ក្នុងការនាំយកដំណោះស្រាយ។ កន្លែងដ៏ពិបាកគឺជាការរៀបចំដ៏ល្អឥតខ្ចោះ សម្រាប់ការដំឡើងតំណែងរបស់អ្នក! ជាអកុសល មានអ្នកជឿជាច្រើននាក់ចៀសវាងពីកន្លែងដ៏ពិបាក។ តាមពិត ពួកគេគិតថា ប្រសិនបើពួកគេនៅកន្លែងដ៏ពិបាក ពួកគេប្រហែលជាបានធ្វើអ្វីមួយរំលងព្រះជាម្ចាស់ហើយ។

ខ្ញុំចាំបានថា នៅពេលយើងចាប់ផ្តើមធ្វើកម្មវិធីទូរទស្សន៍ជាលើកដំបូង យើងត្រូវបង់ថ្លៃប្រហែល៩,០០០ដុល្លារក្នុងមួយខែ។ ខ្ញុំគិតថាថ្លៃចំណាយនេះវាច្រើនណាស់ បន្ទាប់មកថ្លៃចំណាយរបស់យើងបានឡើងដល់២០,០០០ដុល្លារក្នុងមួយខែ ហើយបន្ទាប់មកទៀតវាបានឡើងដល់៥០,០០០ដុល្លារក្នុងមួយខែ។ ថ្ងៃមួយនៅពេលដែលយើងកំពុងតែអធិស្ឋាន អេមីកូនស្រីរបស់ខ្ញុំ ចាប់ផ្តើមថ្លែងពាក្យទំនាយ៖

«ការប្រមូលផលវាច្រើនសន្ធឹកសន្ធាប់ពេកសម្រាប់អ្នក។ យើងកំពុងតែពង្រីកជំនឿរបស់អ្នក។ អ្នកអាចយល់អំពីអ្វីដែលនឹងកើតឡើង ដោយសារតែព្រះវិញ្ញាណរបស់

យើងតែប៉ុណ្ណោះ! តើអ្នកព្រមបោះជំហានចេញក្រៅដែរឬទេ? តើអ្នកព្រមឱ្យយើងនាំអ្នកទៅដល់កន្លែងដ៏ពិបាកៗ ដែលហួសពីការយល់ដឹងរបស់អ្នក ជារឿងដែលអ្នកគិតថាមិនអាចទៅរួចដែរឬទេ?»

មុនពេលដែលខ្ញុំចែករំលែករឿងនេះជាមួយអ្នក តាមរយៈអ្វីដែលអ្នកបានដឹងរហូតមកដល់ពេលបច្ចុប្បន្ននេះ តើអ្នកអាចប្រាប់ខ្ញុំបានទេអំពីរបៀបដែលយើងត្រូវបកស្រាយអំពីរឿងនេះ? រឿងដែលទាក់ទងនឹងការដំឡើងតំណែង! ខ្ញុំចូលចិត្ត ពេលដែលព្រះជាម្ចាស់ឱ្យជម្រើសមួយដល់ខ្ញុំ។ ទ្រង់សួរខ្ញុំជាមុនថាខ្ញុំសុខចិត្តបោះជំហានឆ្ងាយជាងមុនជាមួយទ្រង់ដែរឬទេ? ទ្រង់ចង់បានការយល់ស្របពីខ្ញុំ។ ប្រសិនបើខ្ញុំនិយាយថា «ទេ» នោះទ្រង់នឹងទៅរកអ្នកផ្សេងទៀតជាមិនខានទេ។ ប៉ុន្តែ ខ្ញុំចង់បានការដំឡើងតំណែងនោះសម្រាប់ខ្លួនខ្ញុំផ្ទាល់ ជាជាងឱ្យវាទៅអ្នកដទៃ មិនថាអ៊ីចឹង?

ពិតហើយ ខ្ញុំបានឆ្លើយតបទៅកាន់ទ្រង់វិញថា «បាទ! ព្រះអង្គម្ចាស់ ទ្រង់ជ្រាបដឹងថា ខ្ញុំនឹងយល់ព្រម»។ ពីរបីសប្តាហ៍បន្ទាប់ពីពេលនោះមក ស្ថានីយ៍ទូរទស្សន៍ដេស្តាបានផ្តល់ចន្លោះម៉ោងចាក់ផ្សាយកម្មវិធីរបស់យើងជារៀងរាល់ថ្ងៃ ដែលនៅពេលនោះយើងចាក់ផ្សាយកម្មវិធីរបស់យើងជារៀងរាល់សប្តាហ៍តែប៉ុណ្ណោះ។ ប្រសិនបើយើងព្រមយកចន្លោះម៉ោងដែលគេផ្តល់ឱ្យនោះ នោះថ្លៃចំណាយការផ្សាយតាមទូរទស្សន៍របស់យើងនឹងឡើងដល់២០០,០០០ដុល្លារក្នុងមួយខែ។ មែនហើយ ដោយសារតែពាក្យទំនាយ និងការទទួលប្រេងតាំងពីព្រះវិញ្ញាណដ៏វិសុទ្ធនៅខាងក្នុង ខ្ញុំក៏យល់ព្រម។ គ្រប់គ្នាបានប្រាប់ខ្ញុំថា ពីរបីខែដំបូងខ្ញុំអាចបង់ថ្លៃចំណាយយឺតពេល រហូតទាល់តែមនុស្សមើលកម្មវិធីរបស់យើងជាប់លាប់។ វាបានកើតឡើងដូច្នេះមែន ហើយថែមទាំងធ្ងន់ធ្ងរជាងការរំពឹងទុករបស់យើងទៅទៀត។ ក្នុងរយៈពេល៥ខែដំបូង ខ្ញុំបានបង់ថ្លៃចំណាយយឺត ដែលមានចំនួនទឹកប្រាក់៥០០,០០០ដុល្លារ។ តាមពិត អ្នកទិញម៉ោងផ្សាយកម្មវិធីរបស់យើង បានផ្ញើអ៊ីមែលមកខ្ញុំថា មេធាវីរបស់គាត់មានការព្រួយបារម្ភអំពីការទូទាត់យឺតយ៉ាវរបស់យើង។

ខ្ញុំបានចាប់ផ្តើមតយុទ្ធជាមួយនឹងព្រះជាម្ចាស់អំពីរឿងនេះ ដោយសារឈ្មោះនៃការផ្សាយកម្មវិធីរបស់យើងគឺ *ដោះស្រាយរឿងលុយកាក់!* ខ្ញុំចាប់ផ្តើមបាក់ទឹកចិត្ត ហើយនិយាយទៅកាន់គ្រីនដាថា ខ្ញុំប្រហែលត្រូវកាត់បន្ថយការផ្សាយកម្មវិធីទូរទស្សន៍ហើយ។ ប៉ុន្តែ គាត់បានឆ្លើយតបមកខ្ញុំវិញថា «តើព្រះជាម្ចាស់បានមានព្រះបន្ទូលយ៉ាងដូចម្តេច? ទ្រង់បាននិយាយថា ទ្រង់នឹងចេញថ្លៃចំណាយសម្រាប់កម្មវិធីនេះ តើត្រូវទេបង?» ពីរបីថ្ងៃ

ជាប់គ្នា ពេលដែលខ្ញុំនិយាយរឿងនេះជាមួយគាត់ គាត់តែងតែឆ្លើយតបបែបនេះមកកាន់ខ្ញុំវិញ។ ពិតហើយ យើងបានអធិស្ឋាន ហើយបើទោះបីជាខ្ញុំមិនទាន់បានឮចម្លើយនៅពេលនោះក៏ដោយ ខ្ញុំនៅតែមានអារម្មណ៍សន្តិភាពពីព្រះជាម្ចាស់នៅក្នុងចិត្ត។ នៅសប្តាហ៍នោះ ខ្ញុំទទួលបានសុបិននិមិត្តមួយ ខ្ញុំបានឃើញមូលប្បទានប័ត្រមួយជង់។ ហើយអ្វីដែលចម្លែកជាងនេះទៅទៀតនោះ គឺខ្ញុំមិនត្រឹមតែបានឃើញមូលប្បទានប័ត្រតែមួយជង់នោះទេ ខ្ញុំថែមទាំងបានឃើញចំនួនទឹកប្រាក់នៅលើមូលប្បទានប័ត្រទាំងនោះ ព្រមទាំងអ្នកដែលបានសរសេរនៅលើវាផងដែរ។ ពេលដែលខ្ញុំភ្ញាក់ឡើង ខ្ញុំដឹងប្រាកដថាថ្លៃចំណាយសម្រាប់កម្មវិធីទូរទស្សន៍នោះបានបង់រួចរាល់ហើយ ហើយខ្ញុំមានសន្តិភាពនៅក្នុងចិត្ត។ មែនហើយ នៅចុងសប្តាហ៍នោះ ដែលជាចុងសប្តាហ៍ធម្មតា ទឹកប្រាក់ចំនួន៥០០,០០០ដុល្លារបានមកដល់ដូចនៅក្នុងសុបិននិមិត្តដែលខ្ញុំបានទទួលអ៊ីចឹង។ ទាំងចំនួនទឹកប្រាក់ និងអ្នកដែលបានសរសេរមូលប្បទានប័ត្រទាំងនោះ គឺដូចគ្នាទាំងអស់។

អ្នកឃើញទេ កន្លែងដ៏ពិបាកៗមិនមែនជារឿងអាក្រក់ទេ! វាជាកន្លែងសម្រាប់ការដំឡើងតំណែង។ មានមនុស្សប្រាប់ខ្ញុំថា ពួកគេខ្លាច មិនហានបោះជំហានចូលកន្លែងដ៏ពិបាកទេ ព្រោះពួកគេខ្លាចធ្វើខុស។ ប៉ុន្តែ ព្រះវិញ្ញាណដ៏វិសុទ្ធអាចព្រមានអ្នកពីកំហុសដែលអាចកើតមាន ប្រសិនបើអ្នកចេះស្តាប់ទ្រង់។

ខ្ញុំចាំបានថា នៅពេលដែលខ្ញុំបើកក្រុមហ៊ុនប្រាក់កម្ចីទិញផ្ទះកាលពីប៉ុន្មានឆ្នាំមុននេះ មានអតិថិជនម្នាក់ចង់ខ្ចីដើមទុនចេញពីផ្ទះរបស់គាត់ ដើម្បីវិនិយោគជាមួយក្រុមហ៊ុនមួយដែលខ្ញុំមិនសូវមានអារម្មណ៍ល្អជាមួយ។ ខ្ញុំចាំបានថា ខ្ញុំកំពុងតែឡើងជណ្តើរនៅក្នុងការិយាល័យរបស់យើង ហើយអ្នកតំណាងម្នាក់របស់ខ្ញុំបាននិយាយជាមួយខ្ញុំអំពីរឿងនេះ។ ភ្លាមៗនោះ ខ្ញុំមានអារម្មណ៍អំពីព្រះវិញ្ញាណដ៏វិសុទ្ធ ប្រាប់ខ្ញុំនូវអ្វីដែលខ្ញុំត្រូវធ្វើទាក់ទងនឹងករណីមួយនេះ។ ខ្ញុំបានប្រាប់អ្នកតំណាងរបស់ខ្ញុំថា «អ្នកអាចធ្វើកិច្ចព្រមព្រៀងជាមួយគាត់បាន ប៉ុន្តែសូមឱ្យអតិថិជនចុះហត្ថលេខាលើលិខិតមួយដែលជាមួយផ្នែកនៃកញ្ចប់ប្រាក់កម្ចីនេះ ដោយបញ្ជាក់ថាយើងមិនមែនជាផ្នែកមួយនៃក្រុមហ៊ុនវិនិយោគនេះទេ ប៉ុន្តែគ្រាន់តែផ្តល់ប្រាក់កម្ចីតាមសំណើររបស់អតិថិជនប៉ុណ្ណោះ។» យើងបានបញ្ជាក់បន្ថែមថា យើងមិនទទួលខុសត្រូវចំពោះសុវត្ថិភាព ឬដំណើរការនៃការវិនិយោគនេះទេ ហើយក៏មិនបានណែនាំអតិថិជនឱ្យវិនិយោគក្នុងក្រុមហ៊ុននេះដែរ។ មែនហើយ ប្រាំមួយខែ

**អ្នកអាចទុកចិត្តព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីជួយ និងដឹកនាំអ្នកឆ្លងកាត់គ្រប់ស្ថានភាព។**

ក្រោយមក រឿងទាំងមូលបានផ្ទុះឡើង។ ក្រុមហ៊ុនវិនិយោគនោះបានធ្វើឱ្យប្រាក់របស់អតិថិជនម្នាក់នោះបាត់បង់ទាំងអស់។ មានពាក្យបណ្តឹងមួយបានប្តឹងក្រុមហ៊ុនវិនិយោគនោះ និងក្រុមហ៊ុនរបស់យើងផងដែរ។ យ៉ាងណាមិញ នៅពេលដែលមេធាវីរបស់ពួកគេបានឃើញលិខិតដែលមានហត្ថលេខារបស់អតិថិជន គេក៏ដកឈ្មោះក្រុមហ៊ុនយើងពីពាក្យបណ្តឹង។

គឺជាព្រះវិញ្ញាណដ៏វិសុទ្ធដែលជាអ្នកប្រាប់ខ្ញុំ ឱ្យប្រាប់អ្នកតំណាងក្រុមហ៊ុនរបស់យើងនូវអ្វីដែលយើងត្រូវធ្វើជាមួយអតិថិជនម្នាក់នោះ។ អ្នកអាចទុកចិត្តព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីជួយ និងដឹកនាំអ្នកឆ្លងកាត់គ្រប់ស្ថានភាពរបស់អ្នក។ ដូចដែលព្រះយេស៊ូបានមានព្រះបន្ទូលថា «ចូរកុំខ្លាចអ្វីសោះឡើយ»។

ខ្ញុំធ្លាប់ប្រាប់រឿងនេះនៅសៀវភៅផ្សេងទៀតរបស់ខ្ញុំ ប៉ុន្តែខ្ញុំត្រូវលើកវាមកនិយាយម្តងទៀត ក្នុងការពិភាក្សាមួយនេះ។ ថ្ងៃមួយគ្រួសាររបស់ខ្ញុំត្រូវធ្វើដំណើរទៅក្រៅពីរបីថ្ងៃនៅចុងសប្តាហ៍មួយ។ គ្រប់គ្នាបានចូលក្នុងឡានវែនរបស់យើងរួចហើយ ហើយនៅពេលដែលខ្ញុំចាប់ផ្តើមបញ្ឆេះម៉ាស៊ីនឡាន ភ្លាមៗនោះព្រះវិញ្ញាណដ៏វិសុទ្ធបានប្រាប់ខ្ញុំ ឱ្យយកឡានតូចរបស់យើងចេញពីផ្លូវ។ យើងមានឡានតូចមួយទៀតដែលចតនៅក្បែរឡានវែនរបស់យើង។ ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រាប់ខ្ញុំឱ្យចតឡានតូចនោះនៅលើវាលស្មៅវិញ។ ខ្ញុំមានអារម្មណ៍ថាវាចម្លែក។ ខ្ញុំបានគិតក្នុងចិត្តថា «ហេតុអ្វីបានជាព្រះវិញ្ញាណដ៏វិសុទ្ធប្រាប់ខ្ញុំ ឱ្យចតឡានតូចរបស់យើងនៅលើស្មៅទៅវិញ?» ខ្ញុំមិនយល់ទេ។ ប៉ុន្តែខ្ញុំមានអារម្មណ៍ខ្លាំងមែនទែន! ដូច្នេះ ខ្ញុំបានប្រាប់ឌ្រិនដាអំពីអ្វីដែលខ្ញុំនឹងធ្វើ ហើយក៏បានបើកឡានតូចរបស់យើងទៅចតនៅលើស្មៅ។ បន្ទាប់ពីនោះមក ខ្ញុំមិនបានគិតអ្វីច្រើនអំពីការនេះទេ រហូតទាល់តែយើងបានត្រលប់មកដល់ផ្ទះវិញនៅយប់ថ្ងៃអាទិត្យ។ កន្លែងដែលយើងបានចតឡានតូចរបស់យើងពីមុននោះ មានដើមម៉េផលដ៏ធំមួយបានរលំចំកន្លែងនោះតែម្តង។ ឯឡានតូចរបស់យើងវិញឥឡូវនេះនៅលើវាលស្មៅ ហើយដើមឈើនោះបានរលំមិនចំឡានរបស់យើងទេ។ បើយើងមិនបានផ្លាស់ប្តូរកន្លែងចតវាទេ វាមុខជាខ្ទេចមិនខាន។

ជាការពិត ឌ្រិនដា និងខ្ញុំធ្លាប់ជាគំរូមិនល្អទាក់ទងនឹងរឿងលុយកាក់។ ប៉ុន្តែ អ្វីដែលយើងត្រូវការគឺយុទ្ធសាស្ត្រដ៏អាថ៌កំបាំងមួយចំនួន និងប្រាជ្ញាដ៏លាក់កំបាំង ដើម្បីជួយយើងឱ្យនៅខ្ពស់ជាងកាលៈទេសៈរបស់យើង។ ឥឡូវនេះ ខ្ញុំមានស្នាមញញឹមនៅលើផ្ទៃមុខដោយសារមនុស្សទូទាំងពិភពលោកអាចមើលកម្មវិធីទូរទស្សន៍របស់យើង ដែលមានឈ្មោះថា *ដោះស្រាយរឿងលុយកាក់!*

ឱមិត្តសម្លាញ់អើយ ជោគវាសនារបស់អ្នកគឺនៅថ្ងៃនេះឯង។

*«មានកម្លាំងឡើងវិញនៅពេលធ្លាក់ខ្លួនឈឺ ខ្លាំងពូកែនៅពេលច្បាំង ធ្វើឱ្យខ្មាំងសត្រូវបាក់ទ័ព។»* (ហេប្រឺ ១១:៣៤)

កន្លែងដែលអ្នកគិតថា វាពិបាក និងមិនអាចទៅរួច ក្លាយជាកន្លែងដែលមិនពិបាក និងអាចទៅរួច នៅពេលអ្នកដឹងចម្លើយ!

# ជំពូក ៩
# សំឡេងតូចឆ្មារ

នៅពេលខ្ញុំចាប់ផ្ដើមបង្រៀនអំពីព្រះសូរសៀងនៃព្រះវិញ្ញាណដ៏វិសុទ្ធ មានមនុស្សជាច្រើនបានប្រាប់ខ្ញុំថា ពួកគេមិនធ្លាប់បានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ពីមុនមកទេ។ ប៉ុន្តែ ខ្ញុំតែងតែប្រាប់ពួកគេវិញថា «បាទ! អ្នកធ្លាប់ឮព្រះសូរសៀងរបស់ទ្រង់!» ប្រសិនបើអ្នកមានអារម្មណ៍ដូចមនុស្សភាគច្រើនដែរ គឺមិនដែលធ្លាប់បានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ទេ សូមមើលនៅក្នុងខគម្ពីរ ១ ពង្សាវតារក្សត្រ ១៩:១១-១២។

> *ព្រះអង្គមានព្រះបន្ទូលថា៖ «ចូរចេញទៅក្រៅ ហើយឈរលើភ្នំ នៅចំពោះព្រះភក្ត្រព្រះអម្ចាស់»។*
>
> *ព្រះអង្គយាងកាត់តាមនោះមានខ្យល់បក់បោកយ៉ាងខ្លាំង ធ្វើឱ្យកក្រើកភ្នំ បំបែកថ្ម នៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ប៉ុន្តែ ព្រះអម្ចាស់មិនគង់នៅក្នុងខ្យល់នោះទេ។ បន្ទាប់ពីខ្យល់ មានរញ្ជួយដី ប៉ុន្តែ ព្រះអម្ចាស់មិនគង់នៅក្នុងដីដែលរញ្ជួយនោះទេ។ ក្រោយពីរញ្ជួយដី មានភ្លើង ប៉ុន្តែ ព្រះអម្ចាស់មិនគង់នៅក្នុងភ្លើងនោះទេ។ បន្ទាប់ពីភ្លើងមានឮសូរសំឡេងស្រាលៗយ៉ាងស្រទន់។*

១ ពង្សាវតារក្សត្រ ១៩:១១-១២

ទោះបីជាខ្ញុំបានឮព្រះសូរសៀងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ទៅតាមកម្រិតសំឡេងខុសប្លែកពីគ្នា ប៉ុន្តែជាធម្មតាសំឡេងរបស់ទ្រង់គឺជាសំឡេងខ្សឹបដ៏ស្រទន់។ វាជាសំឡេងតូចឆ្មារ។ ដូចដែលខ្ញុំធ្លាប់បាននិយាយពីមុនមកហើយ ជាធម្មតាសំឡេងរបស់ព្រះជាម្ចាស់ ស្ដាប់ទៅហាក់ដូចជាគំនិតមួយដែលមានសូរក្សួរខុសប្លែកពីសំឡេងធម្មតា។ ដូចដែលអ្នកអាចស្គាល់សំឡេងកូនរបស់អ្នកនៅក្នុងហ្វូងមនុស្ស អ្នកក៏អាចចាប់ផ្ដើមស្គាល់ព្រះសូរសៀងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធកាន់តែច្បាស់ និងកាន់តែស្គាល់សំឡេងរបស់ទ្រង់នៅពេលទ្រង់

មានព្រះបន្ទូលផងដែរ។ ប៉ុន្តែ នៅក្នុងជំពូកនេះ ខ្ញុំចង់និយាយជាមួយអ្នកអំពីព្រះសូរសៀងរបស់ព្រះជាម្ចាស់ ដែលគ្មាននរណាម្នាក់ធ្លាប់គិតដល់ ប៉ុន្តែយើងទាំងអស់គ្នាធ្លាប់ឮ។

នៅពេលដែលខ្ញុំកំពុងសិក្សានៅសាកលវិទ្យាល័យអូរ៉ាល់រ៉ូប៊ឺត ខ្ញុំបានសិក្សាវគ្គទេវវិទ្យាជាច្រើន ដោយសារមុខវិជ្ជាដែលខ្ញុំជ្រើសរើសគឺសម្ពន្ធមេត្រីចាស់។ មានព័ត៌មានជាច្រើនដែលខ្ញុំមិនធ្លាប់បានដឹងពីមុនមក។ តាមពិត សឹងតែទាំងអស់ខ្ញុំមិនធ្លាប់បានរៀនពីមុនមកទេ។ ដោយសារកង្វះទម្លាប់ល្អក្នុងការសិក្សាតាំងពីនៅវិទ្យាល័យ ខ្ញុំមានសម្ពាធយ៉ាងខ្លាំងដើម្បីរៀនឱ្យទាន់គេ ជាពិសេសនៅសប្តាហ៍ចុងក្រោយ។ នៅក្នុងថ្នាក់មួយនោះ ខ្ញុំត្រូវសរសេរកិច្ចការជាផ្លូវការមួយលើប្រធានបទមួយពីគម្ពីរសម្ពន្ធមេត្រីចាស់ ដែលខ្ញុំចាំមិនបានអំពីប្រធានបទនោះជាអ្វីទេពេលនេះ។ ប៉ុន្តែ ការសរសេរកិច្ចការជាផ្លូវការធ្វើឱ្យខ្ញុំភ័យខ្លាច។ តាមពិតទៅ ក្នុងឆ្នាំទីមួយនៅសាកលវិទ្យាល័យ ខ្ញុំត្រូវសរសេរកិច្ចការជាផ្លូវការលើកដំបូង ហើយនៅពេលដែលខ្ញុំទទួលបានវាត្រលប់មកវិញ ខ្ញុំបានឃើញអក្សរ «F» ពណ៌ក្រហមយ៉ាងធំនៅពីលើវា ហើយមានចារអក្សរពណ៌ក្រហមនៅខាងក្រោមអក្សរ «F» នោះថា «តើអ្នកពិតជាបានចូលរៀននៅវិទ្យាល័យមែនឬ?»។ ភាសាអង់គ្លេស និងវេយ្យាករណ៍របស់ខ្ញុំពិតជាអន់ខ្លាំងណាស់ ដែលធ្វើឱ្យគ្រូភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលខ្ញុំអាចចូលរៀននៅសាកលវិទ្យាល័យនោះបាន ហើយខ្ញុំត្រូវរៀនភាសាអង់គ្លេសបន្ថែមនៅឆ្នាំដំបូងនោះ។

ឥឡូវនេះ ដល់សប្តាហ៍ចុងក្រោយ ដែលខ្ញុំត្រូវប្រគល់កិច្ចការរបស់ខ្ញុំឱ្យគ្រូ។ អូហ៎ ខ្ញុំពិតជាភ័យខ្លាំងណាស់។ ខ្ញុំបានអង្គុយចុះ ហើយចាប់ផ្តើមសរសេរ ប៉ុន្តែខ្ញុំមិនធ្លាប់បានរៀនអំពីរបៀបសរសេរកិច្ចការជាផ្លូវការទេ។ ដូច្នេះ ខ្ញុំគ្រាន់តែមើលឯកសារពីប្រភពផ្សេងៗ ហើយចម្លងពាក្យចូលដោយគ្រាន់តែកែសម្រួលបន្តិចបន្តួចប៉ុណ្ណោះ ដើម្បីកុំឱ្យគេដឹងថាខ្ញុំបានចម្លងពីឯកសារទាំងនោះ។ ចំណែកឯដួងចិត្តរបស់ខ្ញុំវិញ ខ្ញុំយល់ឃើញថាខ្ញុំមិនបានធ្វើអ្វីខុសទេ ហើយខ្ញុំពិតជាបានសរសេរឡើងវិញនូវអ្វីដែលខ្ញុំបានអាន ដោយប្រើពាក្យរបស់ខ្ញុំពិតមែន។ ប៉ុន្តែការពិតនៃបញ្ហារបស់ខ្ញុំ គឺខ្ញុំពិតជាមិនចេះរបៀបសរសេរជាផ្លូវការទេ។

មែនហើយ ពេលនោះខ្ញុំគ្មានពេលទៀតទេ។ ខ្ញុំបានឃើញមិត្តរបស់ខ្ញុំម្នាក់ដែលបានរៀនវគ្គដូចគ្នា តែម៉ោងខុសគ្នា នៅសាលខាងក្រោម ។ គ្រប់គ្នាត្រូវសរសេរអំពីប្រធានបទតែមួយដូចគ្នា ដូច្នេះ ខ្ញុំក៏បានសុំមិត្តខ្ញុំមើលរបៀបគាត់សរសេរកិច្ចការរបស់គាត់ ហើយគាត់ក៏បានឱ្យខ្ញុំមើល។ ពេលដែលខ្ញុំបានឃើញកិច្ចការរបស់គាត់ ខ្ញុំដឹងថាខ្ញុំមិនអាចសរសេរឱ្យបានល្អដូចគាត់ទេ ហើយខ្ញុំក៏សម្រេចចិត្តចម្លងកិច្ចការរបស់គាត់។ ខ្ញុំដឹងថា អ្នក

មុខជាភ្ញាក់ផ្អើលពេលដែលខ្ញុំប្រាប់អ្នកអំពីរឿងនេះ។ ប៉ុន្តែ សូមចាំថា ពេលនោះខ្ញុំនៅជាទារកក្នុងសេចក្តីជំនឿនៅឡើយទេ។ ខ្ញុំមិនបានចម្លងកិច្ចការរបស់គាត់ទាំងស្រុងទេ ប៉ុន្តែខ្ញុំបានចម្លងវាប្រហែលពាក់កណ្តាលចូលក្នុងកិច្ចការរបស់ខ្ញុំ។ នៅចុងបញ្ចប់នៃសប្តាហ៍ចុងក្រោយនោះ ខ្ញុំបានប្រគល់កិច្ចការឱ្យទៅសាស្ត្រាចារ្យរបស់ខ្ញុំ ដោយមានអារម្មណ៍ធូរស្បើយដែលកិច្ចការនោះបានចប់។ ប៉ុន្តែអ្វីដែលកើតឡើងបន្ទាប់ពីនេះបានបង្រៀនខ្ញុំនូវមេរៀនមួយដ៏មានតម្លៃអំពីការស្តាប់ព្រះសូរសៀងរបស់ព្រះជាម្ចាស់។

នៅពេលដែលខ្ញុំចូលគេងនៅយប់នោះ ខ្ញុំគេងមិនលក់ទេ។ មនសិការរបស់ខ្ញុំបាននិយាយមកកាន់ខ្ញុំយ៉ាងខ្លាំងៗ ដែលធ្វើឱ្យខ្ញុំមិនអាចគេងលក់បាន។ ខ្ញុំដឹងខ្លួនថា អ្វីដែលខ្ញុំបានធ្វើគឺខុស ខ្ញុំបានលួចចម្លង បន្ទាប់មកទៀតខ្ញុំបានកុហកគេ។ ខ្ញុំមិនបានផ្តល់ការគោរពដល់មិត្តរបស់ខ្ញុំ ហើយបានធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់គាត់។ ខ្ញុំមានអារម្មណ៍ពិបាកខ្លាំងមែនទែន! នៅម៉ោង៣ទៀបភ្លឺ ខ្ញុំបានចុះទៅសាលខាងក្រោម ទៅបន្ទប់មិត្តរបស់ខ្ញុំ ហើយបានដាស់គាត់ឱ្យភ្ញាក់ឡើង បានប្រាប់គាត់នូវអ្វីដែលខ្ញុំបានធ្វើ ហើយបានសុំទោសគាត់។ គាត់មើលមកកាន់ខ្ញុំទាំងងងុយគេង ហើយនិយាយថា «ទៅដេកវិញទៅ ហ្គារី»។ បន្ទាប់មកគាត់គ្រាន់តែត្រលប់ខ្លួន ហើយបានគេងលក់វិញ។

នៅថ្ងៃបន្ទាប់ ខ្ញុំបានទៅជួបសាស្ត្រាចារ្យរបស់ខ្ញុំ ហើយបានសារភាពកំហុសរបស់ខ្ញុំ។ ពិតណាស់ គាត់ត្រូវដាក់ពិន្ទុ «F» លើកិច្ចការរបស់ខ្ញុំ ប៉ុន្តែគាត់បានញញឹមដាក់ខ្ញុំ ហើយនិយាយថា គាត់កោតសរសើរខ្ញុំដែលខ្ញុំបានប្រាប់គាត់អំពីរឿងនេះ។ បន្ទាប់មកគាត់បាននិយាយថា ដោយសារខ្ញុំបានមកជួបគាត់ ហើយប្រាប់គាត់អំពីរឿងនេះ គាត់នៅតែឱ្យពិន្ទុ «B»ដល់ខ្ញុំសម្រាប់មុខវិជ្ជារបស់គាត់នៅឆ្នាំនោះ។ ខ្ញុំមានអារម្មណ៍ធូរស្បើយខ្លាំងមែនទែន ហើយកាន់តែប្រសើរជាងនេះទៅទៀតនោះ សំឡេងនៃការថ្កោលទោសបានស្ងប់ស្ងាត់ទៅវិញ ហើយខ្ញុំមានអារម្មណ៍អំពីសេរីភាព និងសន្តិភាពនៅក្នុងចិត្ត។

ដូច្នេះ ខ្ញុំសូមសួរសំណួរមួយដល់អ្នក «ហេតុអ្វីបានជាមិត្តរបស់ខ្ញុំអាចត្រលប់ខ្លួន ហើយគេងលក់វិញ នៅពេលដែលខ្ញុំកំពុងតែមានអារម្មណ៍តានតឹងក្នុងខ្លួនខ្លាំងបែបនេះ? ហេតុអ្វីបានជាគាត់មិនមានអារម្មណ៍តានតឹងក្នុងខ្លួនដូចខ្ញុំ? ហេតុអ្វីបានជាខ្ញុំមិនអាចគេងលក់ ហើយមានអារម្មណ៍ពិបាកវេទនាបែបនេះ?»។ មានសំឡេងមួយនិយាយមកកាន់ខ្ញុំនៅពេលដែលខ្ញុំបានព្យាយាមគេង។ សំឡេងនោះបានផ្តន្ទាទោសខ្ញុំ វាជាសំឡេងនៃ

មនសិការរបស់ខ្ញុំ! ពាក្យមនសិការមានន័យថា៖ ការដឹងដោយសតារតិ អំពីអ្វីដែលត្រូវ និងអ្វីដែលខុស។ ពាក្យនេះមានន័យថា «ដឹងអំពី» ឬ «មានចំណេះដឹងអំពី»។

ប្រៀបដូចជាទៀន ពន្លឺរបស់មនសិការចាំង ដើម្បីបង្ហាញពីភាពងងឹត។ មនសិការរក្សានូវកំណត់ត្រាដ៏ល្អឥតខ្ចោះ នៃគំនិត និងទង្វើដែលអ្នកបានធ្វើ។ ប្រៀបដូចជាសាក្សីនៅក្នុងបន្ទប់សវនាការ មនសិការជាសក្ខីភាពអំពីអ្វីដែលលាក់កំបាំងបំផុត។ វានិយាយ និងរំលឹកអ្នកឱ្យធ្វើអ្វីដែលត្រឹមត្រូវ និងឱ្យអ្នកជាសវាងអ្វីដែលមិនត្រឹមត្រូវ។ មនសិការគឺជាសំឡេងពីខាងក្នុងរបស់ព្រះជាម្ចាស់ ដែលមាននៅក្នុងមនុស្សម្នាក់ៗ។ មនសិការតម្រូវឱ្យបុរស និងស្ត្រីម្នាក់ៗ ទទួលខុសត្រូវចំពោះសកម្មភាពទាំងអស់របស់ពួកគេ។ ដូចនៅក្នុងបន្ទប់សវនាការ មនសិការកោះហៅមនុស្សម្នាក់ៗ ឱ្យប្រាប់អំពីដំណើររឿងរបស់ពួកគេនៅចំពោះព្រះជាម្ចាស់។ ប្រៀបដូចជាសាក្សីម្នាក់ដែលត្រូវផ្តល់ភស្តុតាង មនសិការរបស់យើងនិយាយជំនួសយើង (ការពារ) ឬថ្កោលទោស (ចោទប្រកាន់) យើង។

ការសិក្សាដែលចេញដោយការបង្ហាញខាងវេជ្ជសាស្ត្របានបញ្ជាក់អំពីការពិតទាំងនេះ៖

«ទ្រឹស្តីដែលកំពុងតែរីករាលដាលពេលបច្ចុប្បន្ននេះ ស្តីអំពីការអភិវឌ្ឍរបស់មនុស្ស គឺថាមនុស្សយើងចាប់ផ្តើមជីវិតរបស់ខ្លួន ដោយ«ស្ថានភាពសីលធមិទទេស្អាត» ក៏ប៉ុន្តែ ការស្រាវជ្រាវថ្មីបានបង្ហាញទស្សនៈផ្ទុយពីនេះ។ អ្នកស្រាវជ្រាវបានរកឃើញថា ទារកដែលមានអាយុត្រឹមតែ៦ខែបានធ្វើការវិនិច្ឆ័យខាងសីលធម៌រួចទៅហើយ ហើយពួកគេគិតថាមនុស្សយើងអាចកើតមកជាមួយក្រមសីលធមិដែលមានជាប់នៅក្នុងខួរក្បាលរបស់យើង។»[3]

*ត្រង់ហ្នឹងហើយដែលយើងដឹងថា យើងកើតមកពីសេចក្តីពិត ហើយចិត្តយើងមិនភ័យខ្លាចនៅចំពោះព្រះភក្ត្រព្រះអង្គទេ។ ហេតុនេះ ប្រសិនបើចិត្តគំនិតរបស់យើងដាក់ទោសយើង នោះព្រះជាម្ចាស់ដែលធំជាងចិត្តរបស់យើង ទ្រង់ឈ្វេងយល់ទាំងអស់។ កូនចៅជាទីស្រឡាញ់អើយ ប្រសិនបើចិត្តគំនិតរបស់យើងមិនដាក់ទោសយើងទេ នោះយើងនឹងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភក្ត្រព្រះអង្គ។ អ្វីៗក៏ដោយឱ្យតែយើងទូលសូម យើងមុខជាទទួលពីព្រះអង្គមិនខាន ព្រោះយើងកាន់តាមបទបញ្ជារបស់ព្រះអង្គ និងប្រព្រឹត្តអំពើណាដែលគាប់ព្រះហឫទ័យព្រះអង្គ។*

១ យ៉ូហាន ៣:១៩-២២

**មនសិការគឺជាព្រះសូរសៀងរបស់ព្រះជាម្ចាស់ នៅក្នុងមនុស្សប្រុស និងមនុស្សស្ត្រីគ្រប់ៗគ្នា វាគឺជាការបោះពុម្ពរបស់ព្រះអាទិករ និងជាតម្រូវការរបស់ទ្រង់ ដើម្បីឱ្យមនុស្សអាចរស់រានមានជីវិត ទៅតាមព្រះហឫទ័យរបស់ទ្រង់។**

មនសិការគឺជាព្រះសូរសៀងរបស់ព្រះជាម្ចាស់ នៅក្នុងមនុស្សប្រុស និងមនុស្សស្ត្រីគ្រប់ៗគ្នា វាគឺជាការបោះពុម្ពរបស់ព្រះអាទិករ និងជាតម្រូវការរបស់ទ្រង់ ដើម្បីឱ្យមនុស្សអាចរស់រានមានជីវិត ទៅតាមព្រះហឫទ័យរបស់ទ្រង់។ គ្មាននរណាម្នាក់អាចគេចផុតពីមនសិការរបស់ពួកគេបានឡើយ។ ខ្ញុំធ្លាប់ភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលមនុស្សម្នាក់ដែលបានសម្លាប់មនុស្សម្នាក់ទៀត ឬបានប្លន់ធនាគារ ហើយបានគេចខ្លួនបាត់ ប៉ុន្តែក្រោយមកបានមកសារភាពកំហុសរបស់ខ្លួន។ ប៉ុន្តែ ឥឡូវនេះខ្ញុំដឹងហើយថា គ្មានការធ្វើទារុណកម្មណាធ្ងន់ធ្ងរជាង ការធ្វើទារុណកម្មរបស់មនសិការដែលកំពុងតែចោទប្រកាន់បុគ្គលនោះថា គាត់ជាជនមានទោស! លោកប៉ូលបាននិយាយនៅក្នុង ២ កូរិនថូស ១:១២ ថា មនសិការរបស់យើងបញ្ជាក់ប្រាប់យើង បានន័យថាមនសិការចេះនិយាយ។

> *សតិសម្បជញ្ញៈរបស់យើងបានបញ្ជាក់ប្រាប់យើងថា ឥរិយាបថដែលយើងប្រកាន់យកក្នុងលោកនេះពិតជាត្រូវមែន ជាពិសេស របៀបដែលយើងប្រព្រឹត្តចំពោះបងប្អូនដោយចិត្តស្មោះសរ និងដោយសុទ្ធចិត្តចេញមកពីព្រះជាម្ចាស់។ យើងមិនបានធ្វើតាមប្រាជ្ញារបស់លោកីយ៍ទេតែធ្វើតាមព្រះគុណរបស់ព្រះជាម្ចាស់វិញ ត្រង់នេះហើយដែលធ្វើឱ្យយើងបានខ្ពស់មុខ។*
>
> ២ កូរិនថូស ១:១២

អ្នកអាចសួរថា «តើមនសិការមានសិទ្ធិអំណាចអ្វី? ហេតុអ្វីបានជាសក្ខីភាពរបស់វាមាននៅក្នុងតុលាការខាងវិញ្ញាណ?»។ ចម្លើយគឺ៖ មនសិការជាព្រះសូរសៀងរបស់ព្រះជាម្ចាស់។ ជាថ្មីម្តងទៀត លោកប៉ូលបានប្រាប់យើងនៅក្នុង រ៉ូម ២:១៤-១៥ ថា មនសិការនិយាយជាមួយយើងយ៉ាងសកម្ម។

> *ពេលសាសន៍ដទៃដែលពុំស្គាល់ក្រឹត្យវិន័យ នាំគ្នាប្រតិបត្តិតាមសេចក្តីដែលក្រឹត្យវិន័យចែងទុកដោយមិនដឹងខ្លួន គឺខ្លួនគេនោះហើយជាក្រឹត្យវិន័យ ទោះបីគេមិនស្គាល់ក្រឹត្យវិន័យក៏ដោយ។ ត្រង់នេះគេបង្ហាញឱ្យឃើញថា កិច្ចការដែលគម្ពីរវិ*

*ន័យចែងទុកឱ្យធ្វើនោះ មានចារឹកនៅក្នុងដួងចិត្តរបស់គេស្រាប់ហើយ។ មនសិការរបស់គេ ព្រមទាំងការរិះគិតរបស់គេ ដែលនាំឱ្យមានការចោទប្រកាន់ខ្លួន ឬដោះសាខ្លួន ក៏ផ្ដល់សក្ខីភាពអំពីការនេះដែរ។)*

រ៉ូម ២:១៤-១៥

មនុស្សគ្រប់រូបមានមនសិការ។ អ្នកប្រហែលជាមិនយល់ស្របទេ។ អ្នកប្រហែលជាស្គាល់នរណាម្នាក់ដែលគាត់ហាក់ដូចជាគ្មានអារម្មណ៍ ឬគ្មានមនសិការ។ ប៉ុន្តែ ខ្ញុំសូមធានាថា ពួកគេមិនបានចាប់ផ្ដើមឡើងដោយមានលក្ខណៈបែបនេះទេ។ ប្រសិនបើនរណាម្នាក់បន្តប្រឆាំងនឹងសំឡេងនៃមនសិការរបស់ពួកគេ សំឡេងនោះនឹងកាន់តែស្ងាត់ជាងមុនបន្តិចម្ដងៗ រហូតដល់ពេលមួយគាត់ហាក់ដូចជាគ្មានមនសិការតែម្ដង។

*«គេចាញ់បោកពុតត្បុតរបស់មេបោកប្រាស់។ មនសិការរបស់អ្នកទាំងនោះជាប់ជាខ្ញុំបំរើរបស់អារក្ស។»* (១ ធីម៉ូថេ ៤:២)

លោកប៉ូលនិយាយថា មនុស្សទាំងនេះបានធ្វើឱ្យមនសិការរបស់ពួកគេខូច ឬធ្វើឱ្យខ្លួនឯងមិនអាចមានអារម្មណ៍ដឹង ឬឮមនសិការរបស់ខ្លួន ដោយសារពួកគេមានចិត្តរឹងរូសប្រឆាំងនឹងវា។ សូមគិតអំពីស្បែករបស់អ្នក។ ប្រសិនបើអ្នកធ្វើឱ្យវារលាក (បើអ្នកដុតវា) នោះវាមិនទាន់អាចមានអារម្មណ៍បានភ្លាមៗទេ រហូតទាល់តែស្បែកថ្មីលូតលាស់ឡើង ហើយស្បែកចាស់ដែលរឹងជ្រុះចេញសិន។ រីឯមនសិការរបស់មនុស្សយើងវិញក៏ដូចគ្នាផងដែរ។ មនសិការមិនអាចបង្ខំអ្នកឱ្យធ្វើអ្វីបានទេ វាគ្រាន់តែនិយាយមកកាន់អ្នក។ អ្នកអាចមិនអើពើនឹងវា ឬប្រឆាំងនឹងវា។ ប៉ុន្តែ លោកប៉ូលបានព្រមានថា ប្រសិនបើអ្នកមិនអើពើនឹងមនសិការរបស់អ្នកទេ អ្នកអាចមានបញ្ហាធំ ឬដូចគាត់បាននិយាយថា អ្នកអាចធ្វើឱ្យជីវិតអ្នកលិចលង់បាន។

*ធីម៉ូថេ កូនសម្លាញ់អើយ ខ្ញុំសូមផ្ដាំផ្ញើមកអ្នកស្របតាមព្រះបន្ទូលដែលគេថ្លែងទុកអំពីអ្នកស្រាប់។ ចូរពឹងផ្អែកលើព្រះបន្ទូលនេះ ដើម្បីពុះពារតយុទ្ធឱ្យបានល្អប្រសើរ ដោយមានជំនឿ និងមានមនសិការល្អ។ អ្នកខ្លះលែងមានមនសិការល្អបែបនេះ បណ្ដាលឱ្យជំនឿរបស់គេលិចលង់។*

*១ ធីម៉ូថេ ១:១៨-១៩*

ជាទូទៅមនុស្សដែលមានចិត្តរឹងរូស ដែលប្រឆាំងនឹងសំឡេងនៃមនសិការរបស់ពួកគេ បានបាត់បង់សមត្ថភាព ក្នុងការដឹកនាំជីវិតរបស់ពួកគេ។ ត្រីវិស័យរបស់ពួកគេបានខូច ហើយមិនមានដំណើរការដូចប្រក្រតីទេ។ ពួកគេមិនអាចប្រាប់បានថាពួកគេកំពុងតែទៅទិសដៅណាទេ។ លោកប៉ូលនិយាយថា យើងត្រូវប្រកាន់ខ្ជាប់នូវមនសិការល្អ ជាមនសិការដែលស្អាតស្អំ ដើម្បីប្រាកដថាយើងកំពុងតែធ្វើដំណើរតាមផ្លូវត្រឹមត្រូវ។ ពីព្រោះដោយសារយើងអាចមានចិត្តរឹងរូស និងអាចធ្វើឱ្យសមត្ថភាពនៃការដឹងខុសត្រូវរបស់យើងខូច លោកប៉ូលនិយាយថា វាជាការសំខាន់ដែលយើងត្រូវធ្វើតាមច្បាប់ និងធ្វើអ្វីដែលត្រឹមត្រូវ។

*«ដូច្នេះ ត្រូវស្តាប់បង្គាប់អាជ្ញាធរ មិនមែនដោយខ្លាចទទួលទណ្ឌកម្មប៉ុណ្ណោះទេ គឺធ្វើដោយមានមនសិការផង។»* (រ៉ូម ១៣:៥)

ប្រសិនបើអ្នកធ្វើខុសច្បាប់ មនសិការរបស់អ្នកនឹងថ្កោលទោសអ្នក។ ដូច្នេះ លោកប៉ូលប្រាប់ថា ត្រូវគោរពច្បាប់ និងធ្វើអ្វីដែលត្រឹមត្រូវ ដើម្បីឱ្យមនសិការរបស់អ្នកនៅតែស្អាតស្អំ ហើយអាចមានដំណើរការប្រក្រតីដូចព្រះជាម្ចាស់សព្វព្រះហឫទ័យឱ្យវាមានដំណើរការដើម្បីការពារអ្នកពីគ្រោះថ្នាក់ផ្សេងៗ។

ទាក់ទងនឹងមនសិការ ខ្ញុំនឹកចាំរឿងដ៏ឆោតល្ងង់មួយដែលខ្ញុំបានធ្វើ ដែលវាបង្ហាញពីគោលការណ៍មួយនេះ។ រឿងនេះបានកើតឡើងមុនពេលខ្ញុំធ្វើជាគ្រូគង្វាល។ បន្ទាប់ពីអ្នកបានដឹងរឿងនេះហើយ អ្នកនឹងដឹងអំពីមូលហេតុដែលព្រះជាម្ចាស់មិនទាន់ឱ្យខ្ញុំដឹកនាំក្រុមជំនុំភ្លាមៗ។ រឿងនេះទាក់ទងនឹងឡានចាស់របស់ខ្ញុំ។ ឡាននោះម៉ាកពូហ្សូ៥០៥ ជាឡានដែលខ្ញុំស្រលាញ់ខ្លាំងបំផុត។ ថ្ងៃមួយ មានបុរសម្នាក់បានជ្រុលមកបុកឡានខ្ញុំពេលភ្លើងក្រហម។ ឃ្លុបឡានខាងមុខរបស់ខ្ញុំខ្ទេចអស់ ស៊ុមឡានឡើងកោង ហើយក៏មានការខូចខាតដល់តួឡានផងដែរ។ ភ្នាក់ងារធានារ៉ាប់រងរបស់បុរសដែលបានបុកឡានខ្ញុំ បានមកមើលឡានខ្ញុំនៅផ្ទះរបស់ខ្ញុំ ដើម្បីផ្តល់ការប៉ាន់ស្មានថ្លៃខូចខាតដល់ខ្ញុំ។

មុនពេលខ្ញុំប្រាប់អ្នកអំពីអ្វីដែលបានកើតឡើងនៅពេលគាត់មកពិនិត្យឡានខ្ញុំនៅផ្ទះរបស់ខ្ញុំ ខ្ញុំត្រូវប្រាប់អ្នកជាមុនសិនថា ពីរបីសប្តាហ៍មុនពេលមានគ្រោះថ្នាក់នេះកើតឡើង បំពង់ស៊ីម៉ាំងឡានខ្ញុំបានបាក់ ហើយម៉ូទ័រសម្រាប់បើកដំបូលឡានដែលនៅក្នុងឃ្លុបឡានខាងមុខក៏បានខូចដែរ។ នៅពេលភ្នាក់ងារធានារ៉ាប់រងបានមកត្រួតពិនិត្យរថយន្តរបស់ខ្ញុំ គាត់បានសួរខ្ញុំថា បំពង់ស៊ីម៉ាំងឡានដែលគាត់បានឃើញនៅលើដីក្បែរឡានខ្ញុំ (ខ្ញុំបានដាក់

វានៅទីនោះ ដើម្បីឱ្យគាត់ឃើញ) បានបាក់ដោយសារគ្រោះថ្នាក់នេះឬ? ខ្ញុំបានឆ្លើយតបថា « បាទ! លោក» ទាំងមានអារម្មណ៍ថាបានធ្វើខុស។ បន្ទាប់មកគាត់បានសួរខ្ញុំថា ម៉ូរទ័រសម្រាប់បើកដំបូលឡានបានខូចដោយសារគ្រោះថ្នាក់នេះដែរឬយ៉ាងណា។ ម្តងទៀត ខ្ញុំបានឆ្លើយថា «បាទ»។

នៅក្នុងវិញ្ញាណរបស់ខ្ញុំ ខ្ញុំបានឮមនសិការរបស់ខ្ញុំស្រែកដាក់ខ្ញុំថា «ហ្គារី តើឯងកំពុងធ្វើអីហ្នឹង? ឯងកំពុងតែនិយាយកុហក!»។ ឥឡូវនេះ សូមស្តាប់អំពីរបៀបដែលខ្ញុំបានបញ្ឆោតខ្លួនឯង។ ខ្ញុំពិតជានៅចាំបានថា ខ្ញុំបានគិតមកកាន់ខ្លួនឯងថា បើខ្ញុំគ្រាន់តែមិនអើពើនឹងសំឡេងនោះ នោះវានឹងបាត់ទៅវិញដោយខ្លួនឯង។ ថ្ងៃនេះ ខ្ញុំសឹងតែមិនជឿថា ខ្ញុំពិតជាបានគិតដូច្នោះមែននៅពេលនោះ។ វ៉ាវ តើអ្នកមិនរីករាយទេឬអី ដែលខ្ញុំមិនទាន់ដឹកនាំក្រុមជំនុំនៅពេលនោះ? ខ្ញុំជឿថា ព្រះជាម្ចាស់ពិតជារីករាយ!

ទោះយ៉ាងណាក៏ដោយ គេបានយកឡានខ្ញុំទៅជួសជុល ហើយពីរបីសប្តាហ៍ក្រោយមក គេបានហៅខ្ញុំឱ្យទៅយកឡានវិញ។ នៅពេលដែលខ្ញុំបានឃើញឡានរបស់ខ្ញុំនៅហាងជួសជុលឡាន ខ្ញុំពិតជាសប្បាយចិត្តមែនទែន។ វាមើលទៅស្អាតល្អឥតខ្ចោះ! ខ្ញុំបានបើកវាត្រលប់ទៅផ្ទះវិញ ដោយមានចិត្តរីករាយដែលគេបានជួសជុលវាទាំងអស់។ មួយសប្តាហ៍ក្រោយមក នៅពេលបាយថ្ងៃត្រង់ ខ្ញុំបានសម្រេចចិត្តទៅផ្ទះដើម្បីញ៉ាំបាយជាមួយឌ្រិនដា និងកូនៗ។ ផ្ទះរបស់យើងមានចំងាយត្រឹមតែបីគីឡូម៉ែត្រជាងពីការិយាល័យដែលខ្ញុំបានជួលសម្រាប់ក្រុមហ៊ុនហិរញ្ញវត្ថុរបស់យើង។ ខ្ញុំបានចតឡានក្បែរទ្វារផ្ទះខាងមុខ បានចូលក្នុងផ្ទះ ហើយបានបរិភោគបាយថ្ងៃត្រង់យ៉ាងរីករាយ។

នៅពេលដែលខ្ញុំកំពុងតែចេញពីផ្ទះ និងដើរឆ្ពោះទៅទ្វារខាងមុខផ្ទះរបស់យើង ខ្ញុំសង្កេតឃើញថាឡានរបស់ខ្ញុំមិននៅមុខផ្ទះទេ។ ខ្ញុំមានអារម្មណ៍ឆ្ងល់។ តើឡានរបស់ខ្ញុំទៅណាហ្នឹង? ខ្ញុំបានសំឡឹងរកមើលវា ហើយក៏បានឃើញវា។ ផ្ទះរបស់យើងនៅលើកំពូលភ្នំ ហើយប្រហែលជាខ្ញុំភ្លេចដាក់ហ្វ្រាំងហើយមើលទៅ ទើបវារមាលទៅក្រោមភ្នំវិញ។ ទោះបីខ្ញុំមិនដែលភ្លេចធ្វើដូច្នេះពីមុនមកក៏ដោយ ក៏ប៉ុន្តែ លើកនេះខ្ញុំមុខជាបានភ្លេចពិតមែនហើយ ហើយឡានរបស់ខ្ញុំបានបុកដើមឈើមួយដើមនៅខាងក្រោមភ្នំ។ នៅពេលដែលខ្ញុំដើរចុះទៅមើលឡានរបស់ខ្ញុំ ខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ឃ្លុបឡានខាងមុខកំពិតខ្ទេចអស់ ហើយការខូចខាតគឺដូចគ្នានឹងការខូចខាតពេលដែលមានគ្រោះថ្នាក់ចរាចរណ៍ដែរ។ ស៊ុមឡានឡើងកោងដូចពេលមុន បំពង់ស៊ីមាំងបានបាក់ ហើយម៉ូរទ័រសម្រាប់បើកដំបូលឡានក៏ខូចផងដែរ។

អ្វីៗគ្រប់យ៉ាងគឺមានសភាពដូចមុនពេលយកឡាននោះទៅហាងជួសជុលបន្ទាប់ពីគ្រោះថ្នាក់ចរាចរណ៍អីញ្ចឹងដែរ។

នៅពេលខ្ញុំឈរនៅទីនោះ ភ្លាមៗនោះខ្ញុំក៏យល់ ហើយក៏ចាប់ផ្ដើមសើច។ ព្រះជាម្ចាស់កំពុងតែបង្រៀនមេរៀនមួយដល់ខ្ញុំ ជាមេរៀនដែលខ្ញុំត្រូវរៀនមុនពេលដឹកនាំក្រុមជំនុំ។ ខ្ញុំមិនបានយកឡានខ្ញុំទៅជួសជុលម្ដងទៀតទេ ខ្ញុំគ្រាន់តែលក់វាដូចគ្រឿងបន្លាស់។ ខ្ញុំអាចចាំបានតែពេលមួយផ្សេងទៀត នៅក្នុងជីវិតរបស់ខ្ញុំដែលមនសិការរបស់ខ្ញុំបានស្រែកប្រាប់ខ្ញុំឱ្យឈប់យ៉ាងខ្លាំង។ ខ្ញុំហៅរឿងដែលបានកើតឡើងថា រឿងកង់។

ខ្ញុំសង្ឃឹមថា ការចែករំលែករឿងទាំងនេះបានជួយដល់អ្នក។ ខ្ញុំដឹងថា អ្នកមិនដែលធ្លាប់គិតថា ខ្ញុំធ្លាប់ធ្លាក់ខ្លួនធ្វើរឿងបែបនេះទេ ប៉ុន្តែអ្នកគិតខុសហើយ។ ខ្ញុំពិតជាសប្បាយចិត្តដែលខ្ញុំបានទទួលការសង្គ្រោះ ព្រោះខ្ញុំមានអារម្មណ៍ថាជីវិតរបស់ខ្ញុំនឹងមានសភាពខុសប្លែកពីពេលនេះ ប្រសិនបើខ្ញុំមិនបានទទួលការសង្គ្រោះទេនោះ។

រឿងកង់បានកើតឡើងពីរបីឆ្នាំក្រោយមកទៀត ហើយពេលនោះខ្ញុំបានចាប់ផ្ដើមដឹកនាំក្រុមជំនុំដ៏ថ្មីស្រឡាងមួយរួចហើយ។ នៅរសៀលថ្ងៃសៅរ៍មួយ ខ្ញុំបានបើកឡានទៅលេងផ្ទះឪពុកខ្ញុំ ហើយពេលនោះខ្ញុំកំពុងតែចាកចេញពីផ្ទះរបស់គាត់ កំពុងតែថយឡានឌុចខារ៉ាវែនពណ៌ទឹកប្រាក់របស់យើងទៅលើផ្លូវជាតិវិញ។ ផ្ទះរបស់ឪពុកខ្ញុំនៅក្រោមភ្នំ នៅជាប់ផ្លូវជាតិ។ ដោយសារហេតុផលណាមួយ ខ្ញុំមិនបានឃើញអ្នកជិះកង់ម្នាក់ដែលកំពុងតែជិះកង់ចុះពីលើភ្នំទេ។ ខ្ញុំថយឡានយឺតៗ ហើយគាត់មិនបាននៅពីក្រោយឡានរបស់ខ្ញុំទេ ប៉ុន្តែដោយសារគាត់ជិះកង់ចុះពីលើភ្នំ គាត់អាចមានល្បឿនលឿន ដូច្នេះគាត់បានមកដល់ពេលដែលឡានខ្ញុំហៀបនឹងបើកទៅមុខនៅលើផ្លូវជាតិ។

គ្រប់ពេលទាំងនេះខ្ញុំមិនបានដឹងអំពីវត្តមានរបស់គាត់ទេ ប៉ុន្តែ រំពេចភ្លាមៗនោះ ខ្ញុំបានឮសំឡេងគេទះឡានរបស់ខ្ញុំ ទាំង ទាំង ទាំង។ ខ្ញុំបានមើលតាមកញ្ចក់មើលក្រោយ ហើយខ្ញុំបានឃើញអ្នកជិះកង់ម្នាក់នៅពីក្រោយឡានខ្ញុំ គាត់លើកដៃទាំងពីររបស់គាត់ឡើងបង្ហាញម្រាមដៃជាសញ្ញាជេរដល់ខ្ញុំ និងបានជេរខ្ញុំយ៉ាងខ្លាំងៗ។ ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលយ៉ាងខ្លាំង ព្រមទាំងទទួលបានការប្រមាថទាំងស្រុងពីបុរសជិះកង់ម្នាក់នោះដែលបានធ្វើសកម្មភាពបែបនេះដាក់ខ្ញុំ។ ខ្ញុំដឹងថាគាត់អាចបន្ថយល្បឿនបានយ៉ាងងាយស្រួលពេលគាត់ចុះពីលើភ្នំ ហើយបានឃើញខ្ញុំកំពុងតែថយឡាន។ ហើយខ្ញុំក៏ដឹងផងដែរថា ប្រសិនបើ

គាត់ចង់ គាត់ក៏អាចគ្រាន់តែជិះកង់របស់គាត់ក្រវែលក្បែរឡានរបស់ខ្ញុំជាមួយល្បឿនដែលគាត់កំពុងតែជិះចុះពីលើភ្នំមក។ ប៉ុន្តែផ្ទុយទៅវិញ គាត់បែរជាធ្វើសកម្មភាពបែបនេះទៅវិញ។

ខ្ញុំពិតជាភ្ញាក់ផ្អើលខ្លាំងដែលគាត់គិតថា គាត់អាចជែងជាមួយរថយន្តបាន។ អីញ្ចឹងហើយ ខ្ញុំក៏គិតថាត្រូវតែមាននរណាម្នាក់បង្រៀនមេរៀនមួយដល់គាត់ ដូច្នេះ ខ្ញុំក៏បន្ថយល្បឿនឡានរបស់ខ្ញុំ ដើម្បីឱ្យគាត់អាចតាមទាន់ឡានរបស់ខ្ញុំ បន្ទាប់មកខ្ញុំបានជាន់ហ្វ្រាំងភ្លាមៗ។ ខ្ញុំមានអារម្មណ៍សប្បាយចិត្ត នៅពេលឃើញគាត់ព្យាយាមចាប់ហ្វ្រាំងភ្លាមៗ ដើម្បីកុំឱ្យកង់គាត់បុកគូទឡានរបស់ខ្ញុំ។ មែនហើយ វាធ្វើឱ្យគាត់កាន់តែខឹងខ្លាំងជាងមុន និងកាន់តែជេរញាប់មាត់ជាងមុនទៅទៀត ដែលខ្ញុំមិនធ្លាប់បានឃើញ និងបានឮពីមុនមកទេ។

ខ្ញុំបានបើកឡានយឺតៗ ហើយបែរទិសដៅទៅរកអ្នកជិះកង់វិញ។ ពេលដែលគាត់បានឃើញខ្ញុំនៅរង់ចាំគាត់ តម្រង់ឡានវ៉ែនរបស់ខ្ញុំនៅចំពីមុខគាត់ ស្រាប់តែគាត់ត្រលប់ទៅជាស្ងាត់ស្ងៀម។ ខ្ញុំគិតថា ទីបំផុតគាត់បានយល់ហើយថាគាត់កំពុងតែជិះកង់ ហើយរថយន្តធំជាងកង់គាត់ឆ្ងាយណាស់។ ខ្ញុំបានចុចកញ្ចក់បង្អួចឡានចុះ ហើយរង់ចាំគាត់ឱ្យមកជិតឡានរបស់ខ្ញុំ។ នៅពេលដែលគាត់មកជិតដល់ឡានខ្ញុំ ខ្ញុំបានស្រែកប្រាប់គាត់ថា បើខ្ញុំបានឃើញគាត់នៅលើផ្លូវនេះម្តងទៀត ខ្ញុំនឹងបើកឡានបុកគាត់ជាមិនខានទេ។ និយាយរួចហើយ ខ្ញុំក៏បើកឡានទៅមុខតម្រង់ទៅរកគាត់ដែលមានចំងាយប្រហែលប្រាំម៉ែត្រ។ ខ្ញុំមានអារម្មណ៍ថាឡានវ៉ែនរបស់ខ្ញុំបានកោសកង់របស់គាត់បន្តិច ដោយសារខ្ញុំគ្រាន់តែចង់ព្រមានដល់គាត់តែប៉ុណ្ណោះ។ ខ្ញុំក៏មានអារម្មណ៍ថាខ្ញុំមិនបានធ្វើខុសទេ។ ខ្ញុំបានគិតថា ខ្ញុំបានបង្រៀនមេរៀនមួយដល់គាត់ ប៉ុន្តែមិនបានយូរប៉ុន្មានទេ។

ចេញពីចិត្តរបស់ខ្ញុំ ខ្ញុំបានឮព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកកាន់ខ្ញុំដោយសំឡេងយ៉ាងមានអំណាចថា «ហ្គារី តើឯងកំពុងតែធ្វើអីហ្នឹង?»។ គ្រាន់តែឮពាក្យទាំងនេះភ្លាម ខ្ញុំមានអារម្មណ៍ថា ខ្ញុំហៀបនឹងបានសម្លាប់បុរសម្នាក់នោះ។ ខ្ញុំបានសំឡឹងមើលតាមកញ្ចក់មើលក្រោយ ខ្ញុំឃើញគាត់នៅទីនោះ កំពុងធ្វើចលនាយឺតៗ ឱនមុខចុះ ហើយមើលទៅមិនមានរបួសអីទេ ឬហាក់ដូចជាគ្រាន់តែភ្ញាក់ផ្អើលដែលគាត់នៅរស់រានមានជីវិតនៅឡើយ។ ខ្ញុំមិនច្បាស់ទេ។ ខ្ញុំបន្តបើកឡានតាមផ្លូវ ប៉ុន្តែមនសិការរបស់ខ្ញុំមិនទុកឱ្យខ្ញុំនៅតែម្នាក់ឯងទ។ ក្នុងនាមជាគ្រូគង្វាលថ្មីថ្មោង ខ្ញុំដឹងថាអាចមានរឿងអ្វីកើតឡើង។ ខ្ញុំអាចឃើញកាសែតចេញផ្សាយថា «គ្រូគង្វាលនៅក្រុមជំនុំជីវិតនៃជំនឿបានបើកឡានបុកអ្នកជិះកង់ម្នាក់ ដោយសារឧប្បត្តិហេតុនៃការផ្ទុះកំហឹងនៅតាមផ្លូវ»។ ព្រះវិញ្ញាណដ៏វិសុទ្ធបានរំលឹកខ្ញុំ

ថា ដោយសារតែមនុស្សដែលមានលក្ខណៈដូចជាបុរសនេះហើយ ទើបទ្រង់បានត្រាស់ហៅខ្ញុំ ឱ្យចាប់ផ្ដើមក្រុមជំនុំនៅសហគមន៍នេះ។ ខ្ញុំពិតជាភ្ញាក់ផ្អើលចំពោះសកម្មភាពដែលខ្ញុំបានធ្វើ ហើយខ្ញុំបានកែប្រែចិត្តគំនិតនៅចំពោះមុខព្រះជាម្ចាស់ទាំងទឹកភ្នែក។

ដូច្នេះ សូមអ្នកយល់ស្របជាមួយខ្ញុំទៅថា អ្នកពិតជាធ្លាប់បានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់។ ក៏ប៉ុន្តែ អ្នកចង់រក្សាមនសិការរបស់អ្នកឱ្យនៅតែទន់ និងមិនអនុញ្ញាតឱ្យវាក្លាយទៅជារឹង ដើម្បីឱ្យអ្នកនៅតែអាចឮពីព្រះជាម្ចាស់បាន។ ព្រះគម្ពីរបានចែងថា ប្រជាជនអ៊ីស្រាអែលបានមានចិត្តរឹងរូសប្រឆាំងនឹងព្រះជាម្ចាស់ ហើយមិនអាចចូលក្នុងទឹកដីសន្យាបានឡើយ។ អ្នកនិពន្ធសៀវភៅហេព្រើបានព្រមានយើងដែលជាអ្នកជឿក្នុងសម្ពន្ធមេត្រីថ្មី កុំឱ្យយើងយកតម្រាប់តាមពួកគេ។

*ហេតុនេះដូចព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលថា៖ «ថ្ងៃនេះប្រសិនបើអ្នករាល់គ្នាឮព្រះសូរសៀងរបស់ព្រះអង្គ មិនត្រូវមានចិត្តរឹងរូសដូចនៅគ្រាបះបោរ ក្នុងថ្ងៃដែលគេល្បងលព្រះអង្គនៅវាលរហោស្ថាននោះឡើយ។»*

ហេព្រើ ៣:៧-៨

មានការព្រមានដូចគ្នានេះ យ៉ាងហោចណាស់បីដង នៅក្នុងជំពូកទីបី និងទីបួន។ ហេតុអ្វីបានជាមានការព្រមានបែបនេះ? ពីព្រោះព្រះជាម្ចាស់ចង់ប្រទានពរដល់អ្នក និងចង់ឱ្យអ្នកមានអ្វីៗទាំងអស់ដែលព្រះយេស៊ូបានបង់ថ្លៃរួចរាល់ហើយសម្រាប់អ្នក។

**«ថ្ងៃនេះប្រសិនបើអ្នករាល់គ្នាឮព្រះសូរសៀងរបស់ព្រះអង្គ មិនត្រូវមានចិត្តរឹងរូសដូចនៅគ្រាបះបោរ ក្នុងថ្ងៃដែលគេល្បងលព្រះអង្គនៅវាលរហោស្ថាននោះឡើយ។»**

**ហេព្រើ ៣:៧-៨**

និយាយអំពីការមានចិត្តរឹងរូស ធ្វើឱ្យខ្ញុំនឹកឃើញកូនសេះរបស់ខ្ញុំដែលខ្ញុំធ្លាប់ចិញ្ចឹមកាលពីនៅក្មេង។ កូនសេះនោះកាចខ្លាំងណាស់ ហើយក៏ឆ្លាតផងដែរ។ មានតែខ្ញុំម្នាក់គត់ដែលអាចជិះវាបាន ឬគួរតែនិយាយថា មានតែខ្ញុំទេដែលហ៊ានជិះវា។ ខ្ញុំចាំបានថា មានថ្ងៃមួយនោះមានមិត្តម្នាក់បានមកលេងខ្ញុំ ហើយគាត់បានអះអាងថា គាត់ស្រលាញ់សត្វសេះ ហើយអាចគ្រប់គ្រងសត្វសេះណាក៏បាន។ គាត់ទទូចចង់ជិះអាតូនី (ជាឈ្មោះកូនសេះរបស់ខ្ញុំ)។ មួយសន្ទុះក្រោយមក គាត់អាចបញ្ចុះបញ្ចូលខ្ញុំបាន ហើយខ្ញុំបានយល់ព្រម និងបានដាក់កែបសេះលើអាតូនី។ មិត្តរបស់ខ្ញុំឈ្មោះជេកគី ហើយខ្ញុំចាំមិន

ភ្លេចនូវអ្វីដែលបានកើតឡើងនៅពេលដែលដេកគីជិះលើអាតូនី។ នៅពេលដែលដេកគីបានដាក់គូទអង្គុយលើអាតូនី ភ្លាមៗនោះអាតូនីបានរត់យ៉ាងលឿន។ វាបោះពួយយ៉ាងលឿនសំដៅទៅស្រះទឹកដែលមានចំងាយប្រហែល៨១ម៉ែត្រពីផ្ទះរបស់ខ្ញុំ។ ដេកគីព្យាយាមទាញបង្ហៀរសេះ និងស្រែកយ៉ាងខ្លាំង ឱ្យអាតូនីឈប់ ប៉ុន្តែវាមិនយកចិត្តទុកដាក់នឹងដេកគីទេ។ ផ្ទុយទៅ វារត់ពេញមួយទំហឹងសំដៅទៅរកស្រះទឹកនោះ ហើយមួយរំពេចនោះស្រាប់តែវាឈប់ភ្លាមៗ ដោយឱនក្បាលវាទាបទៅនឹងមាត់ទឹក។ ពិតហើយ ដេកគីបានហោះរំលងអាតូនី ហើយបានធ្លាក់ចូលក្នុងស្រះទឹក។ បន្ទាប់មកអាតូនីគ្រាន់តែបែរខ្លួន ហើយចាប់ផ្តើមស៊ីស្មៅធ្វើព្រងើយ ហាក់ដូចជាគ្មានរឿងអ្វីបានកើតឡើង។

អ្នកឃើញទេ ទោះបីដេកគីបានទាញបង្ហៀរសេះជាប់មាត់អាតូនីខ្លាំងយ៉ាងណាក៏ដោយ ក៏វានៅតែមិនយកចិត្តទុកដាក់ស្តាប់ដេកគីដែរ។ វារឹងរូសខ្លាំងណាស់ ហើយក៏មិនយកចិត្តទុកដាក់នឹងការឈឺចាប់ដែរ។ អាតូនីជាកូនសេះដែលគ្មានប្រយោជន៍អ្វីដល់អ្នកណាផ្សេងទៀតក្រៅពីខ្ញុំទេ។ ហេតុអ្វីទៅ? ពីព្រោះដូចដែលខ្ញុំបាននិយាយរួចហើយថា អាតូនីវាឆ្លាត។ ខ្ញុំគឺជាអ្នកចិញ្ចឹមវា។ ខ្ញុំបានបង្រៀនវា របៀបតែមួយគត់ដែលវាអាចចេញពីក្រោលសេះទៅស្រូបយកខ្យល់អាកាសនៅខាងក្រៅ និងទៅវាលស្មៅពណ៌បៃតងខ្ចីដែលវាចូលចិត្តស៊ី គឺវាត្រូវឱ្យខ្ញុំជិះ។ ក៏ប៉ុន្តែ ខ្ញុំត្រូវតែតាមដានវា។ វាដើរដោយផ្អៀងក្បាលបន្តិចដើម្បីវាអាចមើលឃើញខ្ញុំពេលដែលខ្ញុំកំពុងតែជិះលើវា។ នៅពេលដែលខ្ញុំបែរមុខចេញទៅទិសផ្ទុយពីវា វាងាកទៅក្រោយហើយខាំច្បិចៗនៅលើជើងខ្ញុំ។ ពេលវាខាំខ្ញុំម្តងៗ វាពិតជាឈឺខ្លាំងណាស់ ដូច្នេះខ្ញុំតែងតែប្រយ័ត្នប្រយែង។ ប៉ុន្តែ បើនិយាយពីការមានប្រយោជន៍ វាមិនមានប្រយោជន៍អីទេ។

ប្រសិនបើយើងបណ្តោយឱ្យចិត្តរបស់យើងទៅជារឹងរូស យើងនឹងមិនមានប្រយោជន៍អ្វីចំពោះព្រះជាម្ចាស់ ដូចអាតូនីអីញ្ចឹង។ ថ្ងៃមួយ យើងបានចងអាតូនីនៅខាងក្រៅដោយខ្សែច្រវ៉ាក់។ ឪពុកខ្ញុំកំពុងតែចាក់ទឹកក្នុងធុងឱ្យអាតូនី។ នៅពេលដែលឪពុកខ្ញុំងាកដើរចេញ អាតូនីបានខាំគាត់ពីក្រោយខ្នង។ ឪពុកខ្ញុំមិនទាន់ទទួលការសង្គ្រោះទេ ហើយគាត់ឆាប់ខឹង។ នៅក្បែរធុងទឹក មានដុំអំបិលមួយដុំធំ ហើយគាត់បានលើកដុំអំបិលនោះ គប់ទៅអាតូនី។ អាតូនីមិនស្លាប់ទេ។ តើខ្ញុំទុកចិត្តវាទេ? អត់ទេ!

ហើយនេះជារបៀបដែលចិត្តរឹងរូសអាចរីកចម្រើនឡើងនៅក្នុងជីវិតមនុស្សយើង។ មនុស្សអាចគិតថា ពួកគេនឹងគ្រាន់តែមិនស្តាប់តាមមនសិការរបស់ពួកគេតែម្តងប៉ុណ្ណោះ

ប៉ុន្តែ អ្វីដែលពួកគេមិនបានដឹងគឺថា គ្រប់ពេលដែលពួកគេមិនស្តាប់តាមមនសិការរបស់ពួកគេ ពួកគេកំពុងតែធ្វើឱ្យចិត្តរបស់ពួកគេរឹងបន្តិចម្តងៗ។ ហើយថ្ងៃណាមួយពួកគេនឹងមានចិត្តរឹងរូសខ្លាំងដូចអាតូនី ហើយមិនមានអារម្មណ៍ឈឺចាប់ ឬវិប្បដិសារី ប្រសិនបើពួកគេជ្រើសរើសមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ឬមិនធ្វើតាមអ្វីដែលទ្រង់មានបន្ទូលឱ្យពួកគេធ្វើ។ មធ្យោបាយដោះស្រាយគឺ ត្រូវឆាប់កែប្រែចិត្តគំនិត នៅពេលអ្នកដឹងថា អ្នកបានធ្វើអ្វីផ្ទុយពីមនសិការរបស់អ្នក។

ស្តេចដាវីឌបានសរសេរទំនុកតម្កើង ៥១ បន្ទាប់ពីគាត់បានប្រព្រឹត្តអំពើបាបជាមួយនាងបាតសេបា។ វាជាទំនុកតម្កើងនៃការកែប្រែចិត្តគំនិត។

> *ឱព្រះជាម្ចាស់អើយ! សូមប្រណីសន្តោសទូលបង្គំផង ដ្បិតព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ សូមលើកលែងទោសឱ្យទូលបង្គំផង ដ្បិតព្រះអង្គមានព្រះហឫទ័យអាណិតមេត្តាដ៏ទូលំទូលាយ។ សូមលុបលាងកំហុសទូលបង្គំឱ្យបានស្អាតទាំងស្រុង សូមជម្រះទូលបង្គំឱ្យបានបរិសុទ្ធ រួចពីបាប!ទូលបង្គំទទួលសារភាពថា ទូលបង្គំបានធ្វើខុសហើយ អំពើបាបរបស់ទូលបង្គំដិតជាប់នៅក្នុងអារម្មណ៍ទូលបង្គំជានិច្ច។ ទូលបង្គំបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះហឫទ័យព្រះអង្គ គឺទាស់នឹងព្រះអង្គតែមួយគត់ ដ្បិតទូលបង្គំបានប្រព្រឹត្តអំពើមួយដែលព្រះអង្គចាត់ទុកថាជាអំពើអាក្រក់។ ទោះបីព្រះអង្គកាត់ទោសទូលបង្គំយ៉ាងណាក្តី ក៏ព្រះអង្គនៅតែសុចរិត ហើយទោះបីព្រះអង្គធ្វើទោសទូលបង្គំយ៉ាងណាក្តី ក៏ព្រះអង្គនៅតែឥតកំហុសដដែល។ ទូលបង្គំមានកំហុសតាំងពីកំណើតមក ហើយទូលបង្គំមានបាបតាំងពីនៅក្នុងផ្ទៃម្តាយមកម្ល៉េះ! ក៏ប៉ុន្តែ ព្រះអង្គសព្វព្រះហឫទ័យនឹងសេចក្តីពិតនៅក្នុងជំរៅចិត្តមនុស្ស។ សូមប្រោសប្រទានឱ្យទូលបង្គំមានប្រាជ្ញានៅក្នុងជំរៅដួងចិត្តផង សូមជម្រះទូលបង្គំ ដោយស្លឹកហ៊ីសុប នោះទូលបង្គំនឹងបានបរិសុទ្ធ សូមលាងសំអាតទូលបង្គំ នោះទូលបង្គំនឹងបានសជាងសំឡីទៅទៀត។ សូមប្រាប់ឱ្យទូលបង្គំដឹងថា ព្រះអង្គអត់ទោសទូលបង្គំហើយ នោះទូលបង្គំមានអំណរសប្បាយ ហើយចិត្តសោកសង្រេងរបស់ទូលបង្គំនឹងបានរីករាយឡើងវិញ។ ព្រះអង្គអើយ សូមកុំទតមើល អំពើបាបរបស់ទូលបង្គំឡើយ តែសូមលុបបំបាត់កំហុសទាំងប៉ុន្មានរបស់ទូលបង្គំទៅ។ ឱព្រះជាម្ចាស់អើយ!__សូមប្រោសប្រទានឱ្យទូលបង្គំមានចិត្តបរិសុទ្ធ__ សូមប្រទានចិត្តគំនិតថ្មីដ៏រឹងប៉ឹងមកទូលបង្គំផង។ សូមកុំបោះបង់ទូលបង្គំឱ្យនៅឆ្ងាយពីព្រះអង្គ សូមកុំដកព្រះ*

*វិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គចេញពីទូលបង្គំឡើយសូមប្រោសប្រទានឱ្យទូលបង្គំមានអំណរ ព្រោះតែព្រះអង្គសង្គ្រោះទូលបង្គំសូមគាំទ្រទូលបង្គំ ដោយប្រទានឱ្យទូលបង្គំមានចិត្តទូលាយមកពីព្រះវិញ្ញាណ។*

ទំនុកតម្កើង ៥១:១-១២

*ព្រះអង្គមិនសព្វព្រះហឫទ័យឱ្យទូលបង្គំថ្វាយយញ្ញបូជាទេ ទោះបីតង្វាយដុតទាំងមូល ក៏មិនគាប់ព្រះហឫទ័យព្រះអង្គដែរ។ យញ្ញបូជាដែលព្រះអង្គសព្វព្រះហឫទ័យឱ្យទូលបង្គំថ្វាយ គឺចិត្តសោកស្ដាយ ព្រះអង្គតែងតែទទួលចិត្តសោកស្ដាយ និងចិត្តលៃងមានអំនួត។*

ទំនុកតម្កើង ៥១:១៦-១៧

ស្ដេចដាវីឌកំពុងតែអង្វររកព្រះជាម្ចាស់ ដើម្បីឱ្យទ្រង់ប្រោសប្រទានឱ្យគាត់មានចិត្តបរិសុទ្ធ វិញ្ញាណដែលខ្ជេចខ្ជាំ និងដួងចិត្តដែលកែប្រែចិត្តគំនិត។ ជាទូទៅ ស្ដេចដាវីឌចង់និយាយថា គាត់ចង់មានចិត្តដែលអាចដឹងខុសត្រូវម្ដងទៀត។ ប៉ុន្តែស្ដេចដាវីឌនឹងមិនបានជួបបញ្ហាដែលគាត់កំពុងតែជួបប្រទះទេ ប្រសិនបើគាត់បានស្ដាប់តាមមនសិការរបស់គាត់។ ដូច្នេះ សូមចាំថា ប្រសិនបើអ្នកធ្វើអ្វីដែលរំលងមនសិការរបស់អ្នក អ្នកនឹងធ្វើឱ្យចិត្តរបស់អ្នករឹងរូស ហើយវានឹងកាន់តែងាយស្រួលឱ្យអ្នកធ្វើខុសម្ដងទៀតនៅពេលក្រោយ ហើយពេលក្រោយមួយទៀត និងពេលក្រោយបន្ទាប់មកទៀត រហូតទាល់តែអ្នកលែងឮព្រះសូរសៀងរបស់ព្រះជាម្ចាស់តែម្ដង។

មនសិការគឺគ្រាន់តែជារបៀបមួយដែលអ្នកអាចឮព្រះសូរសៀងរបស់ព្រះជាម្ចាស់បាន។ ពិតណាស់ ព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកកាន់យើងដោយផ្ទាល់ ជាមួយការណែនាំ និងទិសដៅដែលយើងត្រូវទៅ។ ហើយដូចដែលខ្ញុំធ្លាប់ប្រាប់អ្នករួចមកហើយថា ខ្ញុំបានឮព្រះវិញ្ញាណដ៏វិសុទ្ធ កែតម្រូវខ្ញុំដោយសំឡេងដែលមានអំណាច និងឮខ្លាំង ហើយខ្ញុំក៏បានឮសំឡេងទ្រង់ដែលមានសំនៀងតូចឆ្មារ។ ខ្ញុំក៏ធ្លាប់ឮទ្រង់មានបន្ទូលតាមរយៈសុបិន និងនិមិត្តផងដែរ ដែលខ្ញុំនឹងរៀបរាប់នៅជំពូកបន្ទាប់។ ប៉ុន្តែ នៅក្នុងជំពូកនេះ យើងបានរៀនថា ប្រសិនបើយើងចង់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ យើងត្រូវរក្សាមនសិការរបស់យើងឱ្យស្អាតស្អំពីការចោទប្រកាន់ផ្សេងៗ ហើយឆាប់កែប្រែចិត្តគំនិត ដើម្បីរក្សាវាឱ្យនៅតែទន់ ដូច្នេះយើងអាចនៅតែឮព្រះសូរសៀងរបស់ព្រះជាម្ចាស់!

# ជំពូក ១០
# និមិត្ត និងសុបិននិមិត្ត

ខ្ញុំបានភ្ញាក់ពីដំណេកភ្លាមៗ និងបានប្រាប់ឌ្រិនដាថា «អូនមានផ្ទៃពោះហើយ កូននោះជាកូនស្រី!»។

ក្នុងចំណោមកូនទាំងប្រាំនាក់របស់យើង មានតែកូនម្នាក់គត់ដែលព្រះជាម្ចាស់បានប្រាប់ពួកយើងជាមុនអំពីភេទរបស់គាត់ គឺជាកូនទីបួនដែលមានឈ្មោះថា ប៉ូលី។ ខ្ញុំជឿថា ព្រះជាម្ចាស់បានប្រាប់យើងឱ្យដឹងជាមុន ដោយសារទ្រង់ចង់បញ្ជាក់ប្រាប់យើងថា យើងនឹងមាននាង ដោយសារគ្រួសាររបស់យើងបានជួបគ្រោះថ្នាក់ចរាចរណ៍មួយ នៅពេលឌ្រិនដាកំពុងពពោះប៉ូលីបានប្រហែលបាន៦ខែ។ ពេលនោះ យើងកំពុងតែបើកបរក្នុងល្បឿនប្រហែល៩០គីឡូម៉ែត្រក្នុងមួយម៉ោង នៅលើផ្លូវមួយដែលមានរថយន្តទៅមក ស្រាប់តែមានយុវជនម្នាក់បានបើកឡានរបស់គាត់លយចេញមកក្រៅនៅចំពីមុខយើង។ យើងគ្មានពេលគ្រប់គ្រាន់ដើម្បីបញ្ឈប់ឡានរបស់យើងទេ ហើយក៏បានបុកឡានរបស់គាត់ពេញមួយទំហឹង។ គ្មាននរណាម្នាក់មានរបួសធ្ងន់ធ្ងរទេ ប៉ុន្តែយើងទាំងអស់គ្នាបានទៅមន្ទីរពេទ្យ។ ខ្សែក្រវ៉ាត់សុវត្ថិភាពបានធ្វើឱ្យឌ្រិនដាមានរបួស និងប៉ះពាល់ដល់ពោះរបស់នាង។ គាត់ព្រួយបារម្ភពីប៉ូលី។ តែដោយសារតែព្រះជាម្ចាស់បានមានបន្ទូលមកកាន់យើងអំពីប៉ូលី យើងមានអារម្មណ៍សន្តិភាព និងដឹងថាប៉ូលីមិនអីទេ ហើយនាងពិតជាមិនអីមែន។

និយាយអំពីប៉ូលីវិញ ខ្ញុំនៅចាំបានពេលដែលនាងបានរៀបការរួចហើយ ហើយកំពុងតែពពោះកូនដំបូងរបស់នាង។ ឌ្រិនដា និងខ្ញុំត្រូវធ្វើដំណើរទៅក្រៅប្រទេស ដើម្បីអាជីវកម្មរបស់យើង។ ជាអកុសល កាលបរិច្ឆេទនៃការសម្រាលកូនរបស់ប៉ូលី គឺនៅចំពេលធ្វើដំណើរអាជីវកម្មរបស់យើង។ ប្រសិនបើអ្នកស្គាល់ភរិយារបស់ខ្ញុំច្បាស់ អ្នកមុខជាដឹងថា គាត់នឹងមិនឱ្យខកខានការសម្រាលកូនរបស់កូនស្រីគាត់ឡើយ។ ដូច្នេះ យើងកំពុងតែគិត

ថា យើងគួរតែលុបចោលការធ្វើដំណើររបស់យើងឬយ៉ាងណា។ ខ្ញុំបានចំណាយពេលអធិស្ឋានអំពីរឿងនេះ ហើយព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកកាន់ខ្ញុំថា កាលបរិច្ឆេទនៃការសម្រាលកូននេះមិនត្រឹមត្រូវទេ ហើយកូននោះនឹងកើតមក បន្ទាប់ពីយើងបានត្រលប់មកពីដំណើរអាជីវកម្មរបស់យើងវិញ។ ខ្ញុំបានប្រាប់ឌ្រិនដាអំពីអ្វីដែលព្រះអម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំទាក់ទងនឹងកាលបរិច្ឆេទនោះ ហើយយើងបានសម្រេចចិត្តនៅតែធ្វើដំណើរ។ បន្ទាប់ពីយើងបានត្រលប់មកដល់ផ្ទះវិញ ប៉ូលីបានសម្រាលកូនតាមពេលកំណត់ ដូចដែលព្រះអម្ចាស់បានមានបន្ទូលពិតមែន។ អាយវីរី ដែលជាចៅស្រីរបស់ខ្ញុំ បានកើតមកទៅតាមពេលវេលានោះ។

រឿងទាំងនេះគឺជាឧទាហរណ៍នៃរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកកាន់យើងអំពីបញ្ហាផ្សេងៗនៃជីវិត ដោយពាក្យរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ចេញពីវិញ្ញាណរបស់យើងផ្ទាល់។ ប៉ុន្តែ ក៏មានរបៀបផ្សេងទៀតដែលព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកកាន់យើង ដែលយើងត្រូវដឹងផងដែរ។

> *ព្រះអម្ចាស់មានព្រះបន្ទូលថា : ក្រោយមកទៀត យើងនឹងចាក់បង្ហូរព្រះវិញ្ញាណរបស់យើងមកលើមនុស្សលោកទាំងអស់។ កូនប្រុសកូនស្រីរបស់អ្នករាល់គ្នានឹងថ្លែងព្រះបន្ទូល ពួកចាស់ទុំរបស់អ្នករាល់គ្នានឹងយល់សុបិននិមិត្ត ហើយពួកយុវជននឹងនិមិត្តឃើញការអស្ចារ្យ។ ក្រោយមកសូម្បីតែអ្នកបម្រើប្រុសស្រីក៏យើងនឹងចាក់បង្ហូរព្រះវិញ្ញាណរបស់យើងទៅលើពួកគេដែរ។*

យ៉ូអែល ២:២៨-២៩

ព្យាការីយ៉ូអែលបានថ្លែងព្រះបន្ទូលថា ថ្ងៃណាមួយនឹងមកដល់ ជាពេលដែលព្រះជាម្ចាស់នឹងចាក់បង្ហូរព្រះវិញ្ញាណរបស់ទ្រង់មកលើមនុស្សលោកទាំងអស់។ ឥឡូវនេះ យើងកំពុងតែរស់នៅក្នុងពេលនោះហើយ។ នៅបុណ្យថ្ងៃទី៥០ ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកសណ្ឋិតលើអស់អ្នកដែលកំពុងរង់ចាំទ្រង់នៅបន្ទប់ខាងលើ។ បណ្តាជនដែលបានឃើញអស់អ្នកដែលនៅបន្ទប់ខាងលើនិយាយជាភាសាដទៃ និងសរសើរតម្កើងព្រះជាម្ចាស់ បានគិតថាពួកគេប្រហែលជាស្រវឹងស្រា ហើយបានសួរថា «តើមានរឿងអ្វីកើតឡើងហ្នឹង?»។ លោកពេត្រុសបានក្រោកឈរឡើង ហើយបាននិយាយទៅកាន់បណ្តាជនទាំងនោះ។

> *លោកពេត្រុសក៏ក្រោកឈរឡើងជាមួយសាវ័កដប់មួយរូបទៀត ហើយមានប្រសាសន៍ទៅកាន់បណ្តាជនថា៖ «បងប្អូនយូដា និងបងប្អូនទាំងអស់ដែលស្នាក់*

*នៅក្រុងយេរូសាឡឹមអើយ! សូមបងប្អូនជ្រាប ហើយផ្ទៀងត្រចៀកស្តាប់ពាក្យរបស់ខ្ញុំ។ អ្នកទាំងនេះមិនមែនស្រវឹងស្រាដូចបងប្អូនស្មាននោះទេ ព្រោះទើបតែម៉ោងប្រាំបួនព្រឹកប៉ុណ្ណោះ!។ ហេតុការណ៍នេះកើតមាន ស្របតាមសេចក្តីដែលព្យាការីយ៉ូអែលបានថ្លែងទុកមកថា៖ «ព្រះជាម្ចាស់មានព្រះបន្ទូលថា នៅគ្រាចុងក្រោយបង្អស់ យើងនឹងយកវិញ្ញាណយើងមកចាក់បង្ហូរលើមនុស្សលោកផងទាំងពួង។ កូនប្រុសកូនស្រីរបស់អ្នករាល់គ្នានឹងថ្លែងព្រះបន្ទូល ពួកយុវជននឹងនិមិត្តឃើញការអស្ចារ្យ ហើយពួកចាស់ទុំរបស់អ្នករាល់គ្នានឹងយល់សុបិននិមិត្ត។ នៅគ្រានោះ យើងពិតជាយកវិញ្ញាណយើងមកចាក់បង្ហូរលើអ្នកបម្រើទាំងប្រុសទាំងស្រីរបស់យើង ហើយគេនឹងថ្លែងព្រះបន្ទូល។*

កិច្ចការ២:១៤-១៨

និមិត្ត និងសុបិននិមិត្ត គឺជាផ្នែកដ៏ធំមួយនៃរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកកាន់យើង។ ខ្ញុំក៏មិនប្រាកដអំពីមូលហេតុដែលពេលខ្លះព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលដោយសំឡេងតូចឆ្មារ ហើយពេលខ្លះទៀតទ្រង់មានបន្ទូលតាមរយៈសុបិននោះដែរ។ ខ្ញុំគិតថា អាចដោយសារពួកយើងទាំងអស់គ្នារវល់ខ្លាំង ហើយនៅពេលដែលយើងស្ងាត់ស្ងៀម ទ្រង់អាចទាញចំណាប់អារម្មណ៍របស់យើងបាន ឬអាចមកពីយើងស្ថិតក្នុងស្ថានភាពច្របូកច្របល់ ឬស្ថិតក្នុងកាលៈទេសៈដែលពិបាកស្តាប់សំឡេងតូចឆ្មារ ទើបទ្រង់មានបន្ទូលមកកាន់យើងតាមរយៈនិមិត្ត និងសុបិននិមិត្ត។ ព្រះវិញ្ញាណដ៏វិសុទ្ធគ្រាន់តែធ្វើយ៉ាងណាឱ្យប្រាកដថា យើងពិតជាបានទទួលសារពីទ្រង់។ យ៉ាងណាមិញ រូបភាពមួយអាចបង្ហាញរាប់ពាន់ពាក្យសំដី។ ទោះបីជាមានហេតុផលអ្វីក៏ដោយ ខ្ញុំអរព្រះគុណព្រះជាម្ចាស់សម្រាប់និមិត្ត និងសុបិននិមិត្ត។ និមិត្ត និងសុបិននិមិត្តមានលក្ខណៈស្រដៀងគ្នា។ ទាំងពីរគឺជារូបភាពដែលយើងអាចមើលឃើញ យើងឃើញនិមិត្តនៅពេលយើងភ្ញាក់ដឹងខ្លួនធម្មតា ហើយយើងឃើញសុបិននិមិត្តនៅពេលយើងគេងលក់។

ទាក់ទងនឹងនិមិត្ត ខ្ញុំធ្លាប់ទទួលបាននិមិត្តពីរបីដង ដែលខ្ញុំហៅវាថានិមិត្តបើកចំហ។ វាជានិមិត្តដែលអ្នកឃើញរូបភាពនៅពេលអ្នកភ្ញាក់ដឹងខ្លួនធម្មតា និងឃើញវាដូចជាការពិតជាក់ស្តែង។ និមិត្តដ៏សំខាន់បំផុតសម្រាប់ខ្ញុំ គឺពេលដែលខ្ញុំទទួលបានការត្រាស់ហៅឱ្យប្រកាសព្រះបន្ទូលព្រះ នៅពេលខ្ញុំមានអាយុ១៩ឆ្នាំ។ ខ្ញុំទទួលបាននិមិត្តនេះ បន្ទាប់ពីខ្ញុំបានទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធប្រហែលបានមួយខែ ឬមួយខែជាង។ ពិត

ណាស់ ទាំងអស់នេះគឺថ្មីសម្រាប់ខ្ញុំ ដោយសារក្រុមជំនុំដែលខ្ញុំចូលរួមមិនបានបង្រៀនច្រើន អំពីព្រះវិញ្ញាណដ៏វិសុទ្ធទេ។

ពេលនោះចំថ្ងៃខួបកំណើតរបស់ខ្ញុំ គេបានអញ្ជើញខ្ញុំឱ្យញ៉ាំអាហារពេលល្ងាច យ៉ាងសប្បាយរីករាយជាមួយមិត្តភក្តិដទៃទៀតរបស់ខ្ញុំ។ នៅពេលដែលយើងអង្គុយចុះ ដើម្បីញ៉ាំអាហារ និងបន្ទាប់ពីបានអធិស្ឋានអរព្រះគុណព្រះសម្រាប់អាហារទាំងនោះមក ខ្ញុំ មានអារម្មណ៍អំពីព្រះវត្តមានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើខ្ញុំយ៉ាងខ្លាំង។ ជាថ្មីម្តង ទៀត រឿងទាំងនេះថ្មីសម្រាប់ខ្ញុំ ប៉ុន្តែខ្ញុំអាចដឹងថាវាមានអារម្មណ៍បែបណានៅពេលព្រះ វិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើខ្ញុំ តាមរយៈបទពិសោធពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដែលខ្ញុំ បានទទួល។ ពេលនោះខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងដូចម្តេចទេ ដូច្នេះ ខ្ញុំក៏បានសុំអនុគ្រោះពីអ្នក ដែលកំពុងតែអង្គុយនៅតុអាហារ ដើម្បីចេញទៅក្រៅតាមទ្វារមួយដែលនៅពីក្រោយខ្នងខ្ញុំ។

នៅពេលខ្ញុំចេញទៅក្រៅ ខ្ញុំមានអារម្មណ៍អំពីព្រះវត្តមានរបស់ព្រះជាម្ចាស់កាន់តែ ខ្លាំងជាងមុន ហើយខ្ញុំបានឃើញនិមិត្តបើកចំហមួយ ដែលខ្ញុំចង់បានន័យថា ខ្ញុំពិតជាបាន ឃើញវាដោយផ្ទាល់ភ្នែករបស់ខ្ញុំ ដូចដែលខ្ញុំកំពុងតែសម្លឹងមើលអ្វីមួយនៅពេលនេះ តាម លក្ខណៈធម្មជាតិផងដែរ។ ខ្ញុំបានឃើញខ្លួនឯង កំពុងតែឈរនៅពីក្រោយជើងសម្រាប់ដាក់ ទ្រសម្ភារៈគ្រូអធិប្បាយ និងកំពុងតែនិយាយទៅកាន់មនុស្សមួយក្រុមដែលកំពុងតែអង្គុយ នៅក្នុងបន្ទប់ប្រជុំមួយ។ បន្ទប់ប្រជុំនោះមានមនុស្សប្រហែលពី៣៥ ទៅ៤០នាក់ ដែលកំពុង តែអង្គុយលើកៅអីបត់។ ខ្ញុំអាចប្រាប់ថា ពេលនោះគឺជាពេលយប់ ដោយសារខ្ញុំឃើញនៅ ខាងក្រៅបង្អួចបន្ទប់នោះគឺខ្មៅទាំងអស់។ មានសំឡេងមួយបាននិយាយមកកាន់ខ្ញុំថា « យើងត្រាស់ហៅអ្នក ឱ្យប្រកាសព្រះបន្ទូលរបស់យើង»។ ខ្ញុំបានឮសំឡេងនោះនិយាយដដែ លៗចំនួនបីដង បន្ទាប់មករូបភាពនោះក៏បាត់ទៅវិញ ហើយការចាក់ប្រេងតាំងក៏រសាយទៅ វិញផងដែរ។ នៅពេលដែលខ្ញុំដើរចូលខាងក្នុងវិញ មិត្តរបស់ខ្ញុំបានសួរខ្ញុំថាមានរឿងអ្វីកើត ឡើង ហើយខ្ញុំបានឆ្លើយតបវិញថា «ខ្ញុំគិតថា ខ្ញុំទើបតែបានទទួលការត្រាស់ហៅឱ្យ អធិប្បាយព្រះបន្ទូលព្រះ!»។

ខ្ញុំចាំបានថា ពេលខ្ញុំត្រលប់ទៅផ្ទះវិញពេលយប់នោះ ខ្ញុំបានប្រាប់ឪពុករបស់ខ្ញុំ អំពីអ្វីដែលបានកើតឡើង។ គាត់បានប្រាប់ខ្ញុំវិញថា ធ្វើជាគ្រូគង្វាលមិនសូវរកលុយបាន ច្រើនទេ។ គាត់គ្រាន់តែនិយាយតែប៉ុណ្ណឹងឯង។ នៅពេលនោះ គាត់មិនទាន់ជាគ្រិស្តបរិស័ទ

នៅឡើយទេ ប៉ុន្តែអរព្រះគុណព្រះ គាត់បានទទួលទ្រង់ពេលគាត់មានអាយុ៨០ឆ្នាំ ហើយឥឡូវនេះគាត់បានទៅនៅជាមួយទ្រង់វិញនៅស្ថានសួគ៌។

នៅក្នុងករណីនេះ ខ្ញុំជឿថាព្រះវិញ្ញាណដ៏វិសុទ្ធមានបន្ទូលមកកាន់ខ្ញុំតាមរយៈនិមិត្តបើកចំហ ដោយសារតែខ្ញុំនៅក្មេង។ ទ្រង់ដឹងថាខ្ញុំនឹងត្រូវប្រឈមនឹងការបៀតបៀនជាច្រើននៅក្នុងគ្រួសាររបស់ខ្ញុំ ដោយសារការបម្រើទ្រង់ ហើយខ្ញុំត្រូវការនិមិត្តនេះជាយុថ្កា ដើម្បីអាចធ្វើដំណើរទៅមុខបាន។ ហើយនិមិត្តនេះពិតជាជួយជំរុញទឹកចិត្តខ្ញុំអស់រយៈពេលជាច្រើនឆ្នាំ។

និមិត្តបើកចំហមួយទៀតដែលខ្ញុំបានទទួល គឺនៅផ្ទះចម្ការចាស់របស់យើង។ យើងបានរស់នៅផ្ទះចម្ការដ៏ចាស់បាក់បែកមួយអស់រយៈពេលជិត៩ឆ្នាំ ភាគច្រើនយើងរស់ក្នុងភាពក្រីក្រ។ ប៉ុន្តែ នៅពេលដែលយើងចាប់ផ្តើមរៀនអំពីរបៀបព្រះរាជ្យរបស់ព្រះមានដំណើរការ យើងក៏ចាប់ផ្តើមរីកចម្រើន ហើយបានរួចផុតពីបំណុល។

នៅក្នុងកំឡុងពេលនោះហើយ ដែលព្រះជាម្ចាស់បានធ្វើឱ្យនិមិត្តដែលខ្ញុំបានទទួលពេលខ្ញុំអាយុ១៩ឆ្នាំ បានសម្រេច។ វាមានរយៈពេល២១ឆ្នាំបន្ទាប់ពីខ្ញុំបានទទួលនិមិត្ត ដែលទ្រង់បានត្រាស់ហៅខ្ញុំឱ្យប្រកាសព្រះបន្ទូលរបស់ទ្រង់ ទើបទ្រង់បានប្រាប់ខ្ញុំឱ្យចាប់ផ្តើមដឹកនាំក្រុមជំនុំ។ មុនពេលខ្ញុំចាប់ផ្តើមដឹកនាំក្រុមជំនុំ ខ្ញុំបានចូលរៀននៅមហាវិទ្យាល័យ បានធ្វើការនៅក្នុងវិស័យហិរញ្ញវត្ថុអស់រយៈពេល២១ឆ្នាំ។ នៅពេលខ្ញុំមានវ័យ៤០ឆ្នាំ ព្រះជាម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំ ឱ្យខ្ញុំចាប់ផ្តើមដឹកនាំក្រុមជំនុំ។

យើងបានចាប់ផ្តើមក្រុមជំនុំរបស់យើងនៅក្នុងបន្ទប់ក្រោមដីរបស់ស្ថានីយ៍វិទ្យុគ្រិស្តបរិស័ទមួយ ហើយនៅយប់ដំបូងដែលយើងបានជួបជុំគ្នា គឺដូចគ្នានឹងនិមិត្តដែលខ្ញុំបានទទួលពីព្រះជាម្ចាស់កាលពី២១ឆ្នាំមុនអីញ្ចឹងដែរ។ នៅវេនថ្វាយបង្គំនាយប់ដំបូងនោះ ខ្ញុំបានឃើញមនុស្សអង្គុយលើកៅអីបត់ និងបានឃើញបង្អួចដែលមើលទៅខាងក្រៅឃើញភាពងងឹត ដោយសារតែវាជាពេលយប់។ ខ្ញុំក៏បានឃើញវេទិកាតូចដូចគ្នាផងដែរ។

ឌ្រិនដា និងខ្ញុំបានចាប់ផ្តើមក្រុមជំនុំរបស់យើង ហើយយើងមានចិត្តរំភើបខ្លាំងណាស់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ដែលយើងមិនសូវខ្វល់ខ្វាយអំពីកន្លែងដែលយើងកំពុងតែរស់នៅប៉ុន្មានទេ។ យើងដឹងថា យើងនឹងត្រូវចាកចេញពីផ្ទះចម្ការរបស់យើង ដោយសារគ្រួសាររបស់យើងកាន់តែរីកធំឡើង យើងមានកូនរហូតដល់ប្រាំនាក់ ហើយមិនមានបន្ទប់គ្រប់គ្រាន់សម្រាប់កូនៗរបស់យើងទេ។ យ៉ាងណាមិញ យើងរវល់ខ្លាំងណាស់

ជាមួយអាជីវកម្មដ៏រីកចម្រើនរបស់យើង ព្រមទាំងក្រុមជំនុំដែលយើងមានចិត្តរីករាយក្នុងការដឹកនាំ។

ប៉ុន្តែមានថ្ងៃមួយនោះ ពេលដែលខ្ញុំត្រលប់មកពីក្រុមជំនុំវិញ ខ្ញុំបានដើរចូលបន្ទប់ទទួលភ្ញៀវរបស់យើង ហើយអង្គុយនៅលើសាឡុង។ នៅពេលដែលខ្ញុំអង្គុយចុះ ស្រាប់តែខ្ញុំបានឃើញបន្ទប់នៅជុំវិញខ្ញុំរលាយបាត់ ហើយបានឃើញបន្ទប់ដដែលនោះឡើងវិញ ប៉ុន្តែគ្មានគ្រឿងសង្ហារិមទេ។ ទ្វារដែលខ្ញុំទើបបានដើរចូលអម្បាញ់មិញនេះ បើកឡើងចូលដល់បន្ទប់បរិភោគអាហារ ហើយសាឡុងដែលខ្ញុំកំពុងតែអង្គុយលើ បែរមុខចំទ្វារនោះ។ ខ្ញុំអាចមើលឃើញបន្ទប់បរិភោគអាហារ ពីបន្ទប់ទទួលភ្ញៀវដែលជាកន្លែងដែលខ្ញុំកំពុងតែអង្គុយ។ ដូច្នេះទាំងបន្ទប់បរិភោគអាហារ និងបន្ទប់ទទួលភ្ញៀវ គឺទទេស្អាតទាំងស្រុង។ ខ្ញុំឃើញនិមិត្តនោះរយៈពេលប្រហែល៥វិនាទី ហើយនៅពេលដែលខ្ញុំសម្លឹងមើលវា ខ្ញុំបានដឹងថា វាដល់ពេលដែលយើងត្រូវចាកចេញពីផ្ទះចម្ការរបស់យើងហើយ។

ជាថ្មីម្តងទៀត ខ្ញុំជឿជាក់ថា ក្នុងករណីនេះ ខ្ញុំទទួលបាននិមិត្តនេះពីព្រះជាម្ចាស់ គឺដើម្បីឱ្យខ្ញុំដឹងច្បាស់អំពីគម្រោងការរបស់ទ្រង់។ យើងរវល់ខ្លាំងណាស់ ហើយវាងាយស្រួលឱ្យយើងចង់ពន្យាពេល។ ប៉ុន្តែ និមិត្តនេះចង់ប្រាប់ខ្ញុំអំពីភាពបន្ទាន់របស់វា «ដល់ពេលដែលត្រូវចាកចេញហើយ!!!»។ ពេលក្រោយមកទើបខ្ញុំដឹងថាហេតុអ្វីបានជាវាបន្ទាន់យ៉ាងនេះ។ យើងបានជួលផ្ទះចម្ការនោះរយៈពេលជិត៩ឆ្នាំមកហើយ ហើយយើងដឹងថា យើងនឹងត្រូវចាកចេញពេលដែលគេចាប់ផ្តើមអនុវត្តគម្រោងអភិវឌ្ឍលំនៅដ្ឋាននៅទីនោះ ប៉ុន្តែគ្មាននរណាដឹងថាគេនឹងចាប់ផ្តើមវានៅពេលណាទេ។

ដូច្នេះ ដើម្បីសង្ខេបរឿងនេះ ព្រះជាម្ចាស់បាននាំយើងឱ្យទិញដីដ៏ធំស្អាតមួយកន្លែង ដែលយើងកំពុងសាងសង់ផ្ទះរបស់យើងនៅទីនោះ។ គម្រោងរបស់យើងគឺសង់ផ្ទះនោះជាបណ្តើរៗ ហើយដើម្បីយើងអាចមានពេលវេលាដើម្បីសាងសង់វា យើងប្រហែលត្រូវចំណាយពេលពីមួយឆ្នាំ ទៅពីរឆ្នាំ។ យ៉ាងណាមិញ បន្ទាប់ពីយើងបានសាងសង់ផ្ទះនោះបាន៦ខែមក ម្ចាស់ផ្ទះចម្ការរបស់យើងបានទូរស័ព្ទប្រាប់យើងថា យើងត្រូវចាកចេញពីផ្ទះរបស់គាត់ក្នុងរយៈពេល១ខែ។ យើងបានប្រាប់គាត់វិញថា យើងកំពុងតែសាងសង់ផ្ទះថ្មីរបស់យើង ហើយបានសុំគាត់ឱ្យពន្យារពេលការចាកចេញពីផ្ទះគាត់រយៈពេលពីរបីខែសិនបានទេ គាត់បានយល់ព្រម ប៉ុន្តែ គាត់ក៏បាននិយាយថា គ្មានការអនុគ្រោះបន្ទាប់ពីនោះទេ។

មែនហើយ យើងបានប្រញាប់ប្រញាល់សាងសង់ផ្ទះរបស់យើងឱ្យរួចរាល់ ហើយបានរើចូលផ្ទះថ្មីរបស់យើងទាន់ពេលដែលគេបានអនុគ្រោះឱ្យ។ ប្រសិនបើព្រះជាម្ចាស់មិនបានប្រាប់យើងឱ្យចាកចេញ ពេលដែលយើងត្រូវចាកចេញទេ យើងមុខជាត្រូវរើផ្ទះពីរបីដងអំឡុងពេលនោះ។ ដោយសារយើងកំពុងតែរវល់ផង ហើយត្រូវរើផ្ទះពីរបីដងទៀត យើងមុខជាមានបញ្ហាជាមិនខានទេ។

ពិតណាស់ រឿងអ័ព្ទពណ៌ខៀវដែលខ្ញុំបានប្រាប់នៅដើមដំបូងនៃសៀវភៅនេះ ក៏ជានិមិត្តបើកចំហផងដែរ វាជាព្រឹត្តការណ៍ដែលផ្លាស់ប្រែជីវិត។ និមិត្តនោះមានលក្ខណៈខុសប្លែកគ្នាបន្តិច នៅក្នុងនិមិត្តនោះខ្ញុំមិនបានឃើញរូបភាពនៃអនាគតរបស់ខ្ញុំទេ ប៉ុន្តែ ខ្ញុំបានអង្គុយនៅក្នុងអ័ព្ទពណ៌ខៀវនោះ ហើយបានឮព្រះសូរសៀងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងច្បាស់ ត្រាស់ហៅខ្ញុំឱ្យឃោងចាប់ប្រជាជាតិនានា។

ខ្ញុំប្រាកដថា ខ្ញុំបានទទួលនិមិត្តបើកចំហពីរបីផ្សេងទៀតផងដែរ ប៉ុន្តែ ខ្ញុំទទួលបានសុបិននិមិត្តច្រើនជាង។ មួយសប្តាហ៍មុនពេលខ្ញុំទៅប្រទេសអាល់បានី ខ្ញុំបានទទួលសុបិននិមិត្តទាក់ទងនឹងការធ្វើដំណើរនោះ។ នៅពេលនោះ ខ្ញុំមិនធ្លាប់ធ្វើដំណើរទៅប្រទេសណាផ្សេង ដូចខ្ញុំធ្វើដំណើរទៅដូចពេលបច្ចុប្បន្ននេះទេ។ មុនពេលព្រះជាម្ចាស់បានមានបន្ទូលមកកាន់ខ្ញុំនៅថ្ងៃនោះ ខ្ញុំមិនធ្លាប់ចាប់អារម្មណ៍ក្នុងការធ្វើដំណើរទៅប្រទេសណាផ្សេងទេ។

ខ្ញុំបានទទួលសុបិននិមិត្តនេះ មួយសប្តាហ៍មុនពេលខ្ញុំធ្វើដំណើរទៅប្រទេសនោះ។ នៅក្នុងសុបិននោះ ខ្ញុំកំពុងតែនៅក្នុងបន្ទប់គ្រូពេទ្យ កំពុងតែដេកលើគ្រែពិនិត្យសុខភាព ខ្ញុំបានឃើញគិលានុបដ្ឋាយិកាម្នាក់បានចូលក្នុងបន្ទប់នោះ ហើយប្រាប់ខ្ញុំថា គាត់ត្រូវការបូមឈាមខ្ញុំ ដើម្បីយកទៅពិនិត្យ។ ដូច្នេះ នាងបានកាន់ដៃខ្ញុំ ហើយបានបូមឈាមពីម្រាមដៃកណ្តាលរបស់ខ្ញុំ ដែលខ្ញុំគិតថាវាហាក់ដូចជាចម្លែក។ ប៉ុន្តែអ្នកអាចដឹងហើយថា នៅក្នុងសុបិនអាចមានលក្ខណៈចម្លែកៗបែបនេះឯង។

ហើយនៅក្នុងសុបិននោះ ខ្ញុំគ្រាន់តែដឹងថា មុនពេលខ្ញុំចាកចេញពីតពផែនដីនេះ គេត្រូវជួសឈាមពីគ្រប់ម្រាមដៃរបស់ខ្ញុំ។ សុបិននេះមានអត្ថន័យចំពោះខ្ញុំ ដោយសារនៅសាលាព្រះគម្ពីរ យើងបានរៀនថាយើងអាចប្រើដៃ ដើម្បីរំលឹកអំពីមុខងារទាំង៥របស់ក្រុមជំនុំ៖ មេដៃជាសាវ័ក ចង្អុលដៃជាព្យាការី ដៃកណ្តាលជាអ្នកផ្សាយដំណឹងល្អ ម្រាមដៃពាក់ចិញ្ចៀនជាគ្រូគង្វាល ហើយកូនដៃជាអ្នកបង្រៀន ដែលធ្វើការជិតស្និទ្ធជាមួយគ្រូគង្វាល។

**បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

ដូច្នេះ ខ្ញុំអាចយល់អំពីអ្វីដែលគិលានុបដ្ឋាយិកាក្នុងក្តីសុបិនចង់ប្រាប់ខ្ញុំ។ ខ្ញុំដឹងថា ក្នុងអំឡុងពេលនៃជីវិតរបស់ខ្ញុំ យ៉ាងហោចណាស់នៅចំណុចណាមួយនៃជីវិតខ្ញុំ ខ្ញុំនឹងប្រើគ្រប់មុខងារទាំងអស់នៃក្រុមជំនុំ។ ពិតណាស់ ខ្ញុំគឺជាគ្រូគង្វាល និងជាអ្នកដឹកនាំ ប៉ុន្តែខ្ញុំក៏មានព្រះអំណោយទាននៃការថ្លែងពាក្យទំនាយសម្រាប់ក្រុមជំនុំ ទាក់ទងនឹងព្រះរាជ្យរបស់ព្រះ និងហិរញ្ញវត្ថុផងដែរ។ នេះជាអ្វីដែលព្រះយេស៊ូសព្វព្រះហឫទ័យឱ្យខ្ញុំធ្វើ សម្រាប់ការធ្វើដំណើរទៅប្រទេសអាល់បានី។ នៅក្នុងសុបិននោះ គិលានុបដ្ឋាយិកាបានជួសឈាមពីម្រាមដៃកណ្តាលរបស់ខ្ញុំ ដូច្នេះខ្ញុំដឹងថាទ្រង់បញ្ជូនខ្ញុំទៅប្រទេសអាល់បានី ក្នុងនាមជាអ្នកផ្សាយដំណឹងល្អរបស់ទ្រង់។ នៅពេលនោះ ខ្ញុំទើបតែចាប់ផ្តើមដំណើរការ និងទើបតែបោះជំហានចូលមុខងារជាសាវ័កនៅក្នុងដំណើរជីវិតគ្រិស្តបរិស័ទរបស់ខ្ញុំ។

យ៉ាងណាមិញ នៅក្នុងសុបិននោះ បន្ទាប់ពីនាងបានជួសឈាមពីម្រាមដៃកណ្តាលរបស់ខ្ញុំហើយ នាងបានយកដៃទាំងពីររបស់នាងដាក់ចូលគ្នា ដូចក្មេងនៅពេលពួកគេអធិស្ឋានអីញ្ចឹង ហើយបានប្រើមាត់និយាយពាក្យអធិស្ឋាន។ នាងមិនបាននិយាយពាក្យអធិស្ឋាននេះឱ្យឮៗទេ នាងគ្រាន់តែប្រើមាត់និយាយពាក្យនេះ ដូចពេលដែលអ្នកស្ថិតក្នុងស្ថានភាពមួយដែលមិនអាចនិយាយបាន។ តាមរយៈសុបិននេះ ខ្ញុំយល់ថា ខ្ញុំត្រូវបានគេបញ្ជូនជាអ្នកផ្សាយដំណឹងល្អទៅកាន់ប្រទេសអាល់បានី ហើយខ្ញុំគួរតែអធិស្ឋានសម្រាប់ការធ្វើដំណើរមួយនេះ។

ខ្ញុំបានទទួលសុបិននិមិត្តច្រើន ច្រើនពេកស្ទើរតែរាប់មិនអស់ ឬមិនអាចប្រាប់អ្នកអស់នៅទីនេះបាន ប៉ុន្តែ ខ្ញុំចង់បញ្ជាក់ថា សុបិននិមិត្តគឺជាព្រះសូរសៀងនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ខ្ញុំធ្លាប់បានជួបមនុស្សដែលមានសុបិនជារៀងរាល់យប់ ហើយស្តាប់ទៅហាក់ដូចជាអ្វីៗទាំងអស់សុទ្ធតែទាក់ទងនឹង«វិញ្ញាណ»។ ជាការពិតណាស់ ខ្ញុំជឿថាអ្នកត្រូវចេះថ្លឹងថ្លែងសុបិនដែលអ្នកមាន ហើយមនុស្សខ្លះដែលចង់ឱ្យគេឃើញខ្លួនថា ជាមនុស្សខាងវិញ្ញាណបានបណ្តោយឱ្យខ្លួនគេមានមោទនភាពខាងវិញ្ញាណ ជ្រុលហួសហេតុ និងមើលឃើញអ្វីៗដែលមិនមែនមកពីព្រះជាម្ចាស់។ យ៉ាងណាមិញ ខ្ញុំមិនទទួលបានសុបិននិមិត្តញឹកញាប់ពេកទេ។ ក្នុងមួយឆ្នាំ ខ្ញុំទទួលបានសុបិននិមិត្តពី៨ទៅ១២ ដែលខ្ញុំដឹងថាវាមកពីព្រះជាម្ចាស់ ហើយទ្រង់ចង់ប្រាប់ខ្ញុំអំពីអ្វីដែលសំខាន់។ ពិតណាស់ ឆ្នាំខ្លះខ្ញុំទទួលបានសុបិននិមិត្តតិចជាងនេះ ហើយឆ្នាំខ្លះទៀតខ្ញុំទទួលបានច្រើនជាងនេះ។ ខ្ញុំមិនគិតថាចំនួនសុបិននិមិត្តដែលអ្នកបានទទួលជាការសំខាន់នោះទេ តែអ្វីដែលពិតជាសំខាន់នោះ គឺការដែលអ្នករៀនបានពីសុបិននិមិត្តទាំងនេះ។

ខ្ញុំទទួលបានសុបិននិមិត្តមួយដែលបានផ្លាស់ប្រែជីវិតខ្ញុំ នៅពេលដែលព្រះជាម្ចាស់បានប្រាប់ខ្ញុំ ឱ្យចាកចេញពីក្រុមហ៊ុនហិរញ្ញវត្ថុមួយដែលខ្ញុំធ្លាប់ធ្វើការនៅទីនោះអស់រយៈពេល៨ឆ្នាំ ហើយចាប់ផ្ដើមក្រុមហ៊ុនខ្លួនឯង ដើម្បីជួយមនុស្សដទៃទៀតឱ្យរួចពីបំណុល។ សុបិននិមិត្តមួយនោះពិតជាសំខាន់ខ្លាំងណាស់។

បន្ទាប់មកក៏មានសុបិននិមិត្តដែលជាការព្រមាន។ ខ្ញុំអាចចាំសុបិនមួយយ៉ាងចម្លែកដែលជាការព្រមាន។ វាកើតឡើងនៅពេលហិរញ្ញវត្ថុរបស់ព័ន្ធកិច្ចយើងមានកម្រិតទាប និងពេលដែលមានសម្ពាធផ្នែកហិរញ្ញវត្ថុ។ នៅក្នុងសុបិននោះ ខ្ញុំកំពុងតែដេកនៅលើគ្រែ ហៀបនឹងដេកលក់ទៅហើយ។ ទ្វារបន្ទប់របស់ខ្ញុំបើកចំហ ខ្ញុំបានឮសំឡេងតិចតួចនៅខាងក្រៅបន្ទប់ខ្ញុំ (ក្នុងសុបិនរបស់ខ្ញុំ) ហើយខ្ញុំបានសម្លឹងមើលទៅក្រៅទ្វារ។ បន្ទាប់មកខ្ញុំបានឃើញអារក្សតូចមួយដែលមានកម្ពស់ប្រហែលមួយម៉ែត្រ កំពុងតែអូសថង់ក្រណាត់មួយដែលមានលុយនៅពីក្រោយវា។ ថង់ក្រណាត់នោះមើលទៅដូចជាថង់ក្រណាត់ដែលតាណូអែលប្រើអីញ៉ឹង។ អារក្សតូចនោះកំពុងតែអូសថង់ក្រណាត់នោះពីក្រោយវា ហើយថង់ក្រណាត់នោះពេញសុទ្ធតែលុយ ដូច្នេះអារក្សតូចនោះត្រូវអូសថង់ក្រណាត់នោះនៅលើដី។ វាមិនចេញទៅខាងក្រៅផ្ទះទេ ប៉ុន្តែខ្ញុំបានឮវាបត់នៅកាច់ជ្រុង ហើយឡើងទៅជាន់ទីបីនៃផ្ទះរបស់យើង។ នៅពេលដែលខ្ញុំភ្ញាក់ឡើង ហើយគិតអំពីសុបិននោះ ខ្ញុំយល់ថាព្រះជាម្ចាស់កំពុងតែបង្ហាញខ្ញុំថា មានគេកំពុងតែលួចលុយ ឬយើងកំពុងតែខាតបង់លុយ។

វាគួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់ដែលនៅក្នុងសុបិននោះ ខ្ញុំដឹងអំពីចំនួនលុយដែលនៅក្នុងថង់ក្រណាត់នោះ។ ខ្ញុំចាំបានថា នៅក្នុងសុបិននោះខ្ញុំគិតថាវាមានចំនួន ២៥,០០០ដុល្លារ។ ខ្ញុំក៏មានអារម្មណ៍ដឹងថា ដោយសារអារក្សនោះវាមិនចេញទៅក្រៅផ្ទះ ប៉ុន្តែគ្រាន់តែយកលុយទៅជាន់ខាងលើ នោះជន ឬពួកអ្នកដែលកំពុងតែលួចលុយ ឬកំពុងតែប្រើប្រាស់លុយខុស គឺជាសមាជិកនៅក្នុងផ្ទះ ហើយផ្ទះនោះគឺជាព័ន្ធកិច្ចរបស់យើង។ ពិតហើយ កិច្ចការដំបូងដែលខ្ញុំបានធ្វើនៅថ្ងៃបន្ទាប់គឺ ទូរស័ព្ទទៅក្រុមអភិបាលជាន់ខ្ពស់របស់យើង ហើយប្រាប់គាត់ឱ្យពិនិត្យមើលសៀវភៅបញ្ជីនៅក្នុងផ្នែកហិរញ្ញវត្ថុ។ តាមរយៈការពិនិត្យមើលសៀវភៅបញ្ជីនោះ យើងបានឃើញថា មានការចំណាយដែលមិនចាំបាច់ជាច្រើនដែលគេបានមើលរំលង។ នៅពេលដែលយើងបានបូកសរុបការចំណាយមិនចាំបាច់អស់ទាំងនេះ យើងឃើញថាចំនួនសរុបរបស់វា គឺជិត២៥,០០០ដុល្លារក្នុងមួយខែ។ យើងបានកំណត់ថា គ្មាននរណាម្នាក់ពិតជាលួចលុយនោះទេ ប៉ុន្តែវាជាការធ្វេសប្រហែស ដែលធ្វើឱ្យខ្ជះខ្ជាយចំនួនលុយទាំងនោះ ឬយើងអាចកាត់បន្ថយការចំណាយអស់ទាំងនោះ ដើម្បីឱ្យ

យើងអាចមានលុយប្រើប្រាស់កន្លែងដែលចាំបាច់វិញ។ យើងពិតជាត្រូវការលុយក្នុងរដូវកាលនោះ ព្រោះថាវាជារដូវកាលតឹងតែងខ្លាំង។

ព្រះជាម្ចាស់អាចប្រើសុបិននិមិត្ត ដើម្បីបង្ហាញអ្នកនូវយុទ្ធសាស្ត្រដែលអ្នកត្រូវការផងដែរ។ កាលពីឆ្នាំមុន នៅឆ្នាំ២០១៨ ខ្ញុំទទួលបានសុបិននិមិត្តដ៏សាមញ្ញមួយ ដែលខ្ញុំបានឮតែពាក្យថា «កោះហៅកប៉ាល់មក» នៅក្នុងសុបិននោះ។ ខ្ញុំបានសរសេរវាទុក ប៉ុន្តែមិនទាន់យល់អំពីអត្ថន័យរបស់វាទេ។ ខ្ញុំបន្តសួរព្រះជាម្ចាស់អំពីក្តីសុបិននោះ ហើយមិនបានប្រាប់នរណាម្នាក់ផ្សេងទៀតក្រៅពីគ្រិនដាទេ។ នៅក្នុងកិច្ចប្រជុំបុរសរបស់យើងក្នុងខែមករា ខ្ញុំកំពុងតែរៀបចំអាណត្តិរបស់ខ្ញុំសម្រាប់ឆ្នាំនោះ។ ខ្ញុំបានគិតអំពីគម្រោងក្រុមតូចទូទាំងប្រទេសរយៈពេលពីរបីឆ្នាំមកហើយ ហើយឆ្នាំនេះខ្ញុំគិតថាជាឆ្នាំដែលយើងគួរតែធ្វើវា។ បន្ទាប់ពីចប់ប្រជុំ មានបុរសម្នាក់បានដើរមករកខ្ញុំ ហើយបានប្រាប់ខ្ញុំថា គាត់មានអារម្មណ៍ថាវាហាក់ដូចជាចម្លែកដែលត្រូវប្រាប់ខ្ញុំ នូវអ្វីដែលគាត់មានអារម្មណ៍ថាត្រូវនិយាយប្រាប់ខ្ញុំ រួចគាត់ក៏និយាយថា «ព្រះអម្ចាស់មានបន្ទូលថា អ្នកដូចជាព្រះនាងហេឡេននៃទីក្រុងត្រយអីញ៉ឹង»។ ខ្ញុំមិនបានយល់អំពីអ្វីដែលគាត់កំពុងតែនិយាយទេ ដូច្នេះគាត់បានចាប់ផ្តើមពន្យល់ខ្ញុំអំពីអ្វីដែលគាត់ចង់មានន័យ។ ខ្ញុំបានសុំគាត់ឱ្យផ្ញើអ៊ីមែលមកខ្ញុំ រៀបរាប់ឡើងវិញអំពីអ្វីដែលគាត់បានពន្យល់ប្រាប់ខ្ញុំ។ ហើយខាងក្រោមនេះជាអ៊ីមែលរបស់គាត់។

**ព្រះជាម្ចាស់អាចប្រើសុបិននិមិត្ត ដើម្បីបង្ហាញអ្នកនូវយុទ្ធសាស្ត្រដែលអ្នកត្រូវការផងដែរ។**

*ស្តេចម៉េណេឡាស ស្តេចរបស់រដ្ឋស្ប៉ាតា បានបញ្ជាកប៉ាល់ចំនួន១,០០០គ្រឿង ឱ្យបើកចេញទៅ ដើម្បីជួយសង្គ្រោះភរិយារបស់ទ្រង់ ព្រះនាងហេឡេនពីមនុស្សនៅទីក្រុងត្រយ។ «ព្រះភ័ក្រដែលបណ្តាលឱ្យកប៉ាល់មួយពាន់គ្រឿងចេញដំណើរទៅ» គឺជាតួអង្គសន្មកថាដ៏ល្បី និងចង់សំដៅលើព្រះនាងហេឡេននៃទីក្រុងត្រយ។*

*ថ្ងៃពុធ ទី៣០ ខែមករា ឆ្នាំ២០១៩ នៅពេលលោកគ្រូគង្វាលកំពុងតែនិយាយនៅកិច្ចប្រជុំបុរសអេតិច ព្រះអម្ចាស់បានមានបន្ទូលថា គាត់ដូចជាព្រះនាងហេឡេននៃទីក្រុងត្រយ ព្រះមហាក្សត្របានបញ្ជាឱ្យកប៉ាល់ចំនួន១,០០០គ្រឿង ធ្វើដំណើរ*

*ចេញទៅ ដើម្បីជួយសង្គ្រោះមនុស្សដែលបាត់បង់ បាត់បង់ជំនឿ បាត់បង់គ្រួសារ និងបាត់បង់ហិរញ្ញវត្ថុ។*

*ពីខ្ញុំ ក្នុងនាមជាអ្នកបម្រើរបស់ទ្រង់*

*អេរ៉ុន*

នៅថ្ងៃបន្ទាប់ គាត់បានផ្ញើអីមែលមួយទៀតមកខ្ញុំ។

*លោកគ្រូ!*

*ខ្ញុំចង់ចែករំលែកទស្សនៈផ្នែកយោធា ដែលទាក់ទងនឹងព្រះនាងហេឡេននៃទីក្រុងត្រយ។ សម្រាប់មនុស្សភាគច្រើន ពួកគេយល់ថា វាជារឿងរបស់ស្ដេចមួយអង្គដែលបានបញ្ជាឱ្យកប៉ាល់១,០០០គ្រឿងចេញទៅ ដើម្បីជួយសង្គ្រោះភរិយារបស់ទ្រង់ពីមនុស្សនៅទីក្រុងត្រយ។ ប៉ុន្តែ សម្រាប់មនុស្សដែលមានការគិតបែបយោធា រឿងនេះគឺជាការត្រៀមប្រយុទ្ធដោយការពង្រាយទ័ពដែលមានឈ្មោះថា ប្រតិបត្តិការជួយសង្គ្រោះព្រះនាងហេឡេនពីទីក្រុងត្រយ។ រាល់ការត្រៀមប្រយុទ្ធដោយការពង្រាយទ័ព ត្រូវតែមានឈ្មោះសម្រាប់ប្រតិបត្តិការនោះ។ ឧទាហរណ៍៖ ការត្រៀមប្រយុទ្ធដោយការពង្រាយទ័ព នៅពេលក្រុម SEAL Team Six បានវាយឆ្មក់បរិវេណអូសាម៉ាប៊ីនឡាដិន គេដាក់ឈ្មោះវាថា ប្រតិបត្តិការលំពែងណិបទូន។ ខ្ញុំធ្លាប់ចូលរួមប្រតិបត្តិការដែលមានឈ្មោះចម្រុះពណ៌ ដូចជា៖ ប្រតិបត្តិការហ្វរើដម៉ែ ប្រតិបត្តិការអិលវីសម៉ាសល ប្រតិបត្តិការតោណូអែល។*

*គេត្រូវដាក់ឈ្មោះឱ្យប្រតិបត្តិការទាំងនេះ ដើម្បីកុំឱ្យអ្នកដទៃអាចកំណត់អត្តសញ្ញាណរបស់វាបាន ឬដើម្បីបញ្ជាក់អំពីប្រភេទនៃប្រតិបត្តិការនេះ ហើយអ្នកណាគេជាអ្នកទទួលធ្វើ ឬអនុវត្តប្រតិបត្តិការនេះ។ នៅពេលព្រះអម្ចាស់មានបន្ទូលថា លោកគ្រូដូចជាព្រះនាងហេឡេននៃទីក្រុងត្រយ តាមគំនិតយោធារបស់ខ្ញុំ ខ្ញុំយល់ឃើញថា លោកគ្រូហ្គារីកំពុងតែអនុវត្តប្រតិបត្តិការព្រះនាងហេឡេននៃទីក្រុងត្រយ ជាបេសកម្មដែលបញ្ជាឱ្យកប៉ាល់១,០០០គ្រឿងចេញដំណើរទៅ ដើម្បីជួយសង្គ្រោះមនុស្សដែលបាត់បង់ បាត់បង់ជំនឿ បាត់បង់គ្រួសារ និងបាត់បង់ហិរញ្ញវត្ថុ។*

*បន្ថែមពីនេះទៅទៀត នៅពេលដែលខ្ញុំឮអំពីការដាក់ពង្រាយកប៉ាល់ចំនួន ១,០០០គ្រឿង ខ្ញុំក៏គិតអំពីចំនួនអ្នកចម្បាំង បុគ្គលិកដែលគាំទ្រ វគ្គបណ្តុះបណ្តាល ការចំណាយផ្សេងៗ និងដំណើរការរដ្ឋបាល ដើម្បីដាក់ពង្រាយកប៉ាល់នីមួយៗផងដែរ។ គ្មាននរណាម្នាក់ផ្សេងទៀតដែលមានសមត្ថភាពអាចបញ្ជាកម្លាំងនេះ និងដាក់ពង្រាយកងទ័ព ដើម្បីព្រះរាជ្យរបស់ព្រះជាម្ចាស់ជាងលោកគ្រូទេ។ លោកគ្រូបានចំណាយពេលជាច្រើនឆ្នាំ ដើម្បីបណ្តុះបណ្តាលពួកយើងសម្រាប់ពេលនេះ។ ក្រុមគ្រួសាររបស់ខ្ញុំ ហើយខ្ញុំក៏ប្រាកដថាអ្នកដទៃទៀតដែលជាព្រះកាយរបស់ព្រះគ្រិស្ត មានចិត្តរីករាយក្នុងការចូលរួមប្រតិបត្តិការនេះ។*

*ពីខ្ញុំ ក្នុងនាមជាអ្នកបម្រើរបស់ទ្រង់*

*អេរ៉ុន*

អេរ៉ុនគឺជាមេបញ្ជាការកងទ័ពជើងទឹក គាត់ធ្លាប់ចូលរួមការត្រៀមប្រយុទ្ធដោយការពង្រាយទ័ពចំនួន៩ដង នៅពេលគាត់បម្រើការក្នុងជួរយោធារយៈពេល២១ឆ្នាំ។ គាត់មានទីបន្ទាល់ដ៏អស្ចារ្យនៃការផ្លាស់ប្រែយ៉ាងខ្លាំង ដោយសារអំណាចឈើឆ្កាង។ គាត់មិនបានដឹងអំពីសុបិននិមិត្តរបស់ខ្ញុំ ដែលព្រះអម្ចាស់បានមានបន្ទូល ឱ្យខ្ញុំកោះហៅកប៉ាល់ទេ។ ប៉ុន្តែ «ពាក្យនៃការចេះដឹង» របស់គាត់បានបញ្ជាក់ប្រាប់ខ្ញុំថា ខ្ញុំពិតជាបានឮត្រឹមត្រូវពិតមែនហើយ ហើយបានជួយខ្ញុំឱ្យដើរលើផ្លូវដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឱ្យខ្ញុំដើរ។ គោលដៅរបស់យើង គឺបង្កើតក្រុមតូចទូទាំងប្រទេសឱ្យបានចំនួន១,០០០ក្រុមតូច ដើម្បីផ្សព្វផ្សាយដំណឹងល្អនៃព្រះរាជ្យរបស់ព្រះ។ ប្រសិនបើអ្នកចង់ក្លាយជាផ្នែកមួយនៃក្រុមនេះ សូមទាក់ទងមកខ្ញុំតាមរយៈគេហទំព័ររបស់ខ្ញុំ Garykeesee.com។

ខ្ញុំគិតថា ពេលនេះអ្នកបានយល់ហើយ។ សុបិននិមិត្តគឺជារបៀបដ៏មានឥទ្ធិពលមួយដែលព្រះជាម្ចាស់អាចមានបន្ទូលទៅកាន់ប្រជារាស្ត្ររបស់ទ្រង់ ដើម្បីជួយបង្ហាញទិសដៅ យុទ្ធសាស្ត្រ ការព្រមាន និងការលួងលោម។

មុនពេលបញ្ចប់ជំពូកនេះ ខ្ញុំសូមបន្ថែមវិធីសាស្ត្រមួយទៀតដែលព្រះជាម្ចាស់ប្រើដើម្បីជួយបង្ហាញយុទ្ធសាស្ត្រ ហើយវិធីសាស្ត្រនេះគឺ អំណោយទាននៃការថ្លែងពាក្យទំនាយ។ អេរ៉ុនទទួលបានពាក្យនៃការចេះដឹង ទាក់ទងនឹងគម្រោងការរបស់ខ្ញុំ ក្នុងការបង្កើតគំនិតផ្តួចផ្តើមថ្មីមួយ។ ពាក្យនៃការចេះដឹង គឺដូចជាអ្វីដែលយើងអានវាអីញ្ចឹង វាជាពាក្យនៃការចេះដឹង។ វាជាចំណេះដឹងដែលអ្នកទទួលបានពីព្រះវិញ្ញាណរបស់ព្រះ វាជាអ្វីដែលអ្នក

មិនអាចដឹងដោយខ្លួនឯងបានទេ។ ពាក្យនៃការចេះដឹងនេះ មាននៅក្នុងគម្ពីរ ១ កូរិនថូស ១២ ដែលជាអំណោយទានមួយ ក្នុងចំណោយអំណោយទានទាំង៩នៃព្រះវិញ្ញាណដ៏វិសុទ្ធ។ គោលបំណងរបស់ខ្ញុំគឺមិនបង្រៀនគ្រប់អំណោយទានទាំងអស់ក្នុងសៀវភៅនេះទេ ប៉ុន្តែខ្ញុំពិតជាចង់និយាយអំពីអំណោយទានមួយក្នុងចំណោមអំណោយទានទាំងនេះ គឺពាក្យនៃការថ្លែងពាក្យទំនាយ។

**«ផ្ទុយទៅវិញ អ្នកណាថ្លែងព្រះបន្ទូល អ្នកនោះនិយាយទៅកាន់មនុស្ស ដើម្បីជួយកសាង ដាស់តឿន និងលើកទឹកចិត្តគេ។»**

**១ កូរិនថូស ១៤:៣**

មានមនុស្សជាច្រើនធ្វើឱ្យជីវិតរបស់ពួកគេរញ៉េរញ៉ៃ ដោយសារការយល់ច្រឡំអំពីអំណោយទាននេះដែលខ្ញុំគិតថា ខ្ញុំគួរតែនិយាយអំពីវា។ នៅពេលនិយាយអំពីការថ្លែងពាក្យទំនាយ ពួកគេគិតអំពីព្យាការីម្នាក់ដែលហៅពួកគេឱ្យចេញមកក្រៅ ចង្អុលម្រាមដៃចំមុខពួកគេ ហើយនិយាយមកកាន់ពួកគេថា «អ្នកត្រូវទៅប្រទេសអាហ្វ្រិក» ឬ «អ្នកត្រូវបានត្រាស់ហៅឱ្យធ្វើជាគ្រូគង្វាល»។ ការថ្លែងទាំងពីរនេះអាចតំណាងឱ្យការថ្លែងពាក្យទំនាយដ៏ត្រឹមត្រូវ ប៉ុន្តែ វាក៏អាចខុសទាំងស្រុងផងដែរ។ វាអាស្រ័យលើរបៀបដែលអ្នកទទួលយកវា។ ប្រសិនបើអ្នកទទួលយកវា ទុកដូចជាទិសដៅ វាអាចខុស ប៉ុន្តែ ប្រសិនបើអ្នកទទួលយកវា ជាការបញ្ជាក់ វាអាចត្រឹមត្រូវ។ លោកប៉ូលបានពន្យល់ពីគោលបំណងនៃការថ្លែងពាក្យទំនាយ។

*«ផ្ទុយទៅវិញ អ្នកណាថ្លែងព្រះបន្ទូល អ្នកនោះនិយាយទៅកាន់មនុស្ស ដើម្បីជួយកសាង ដាស់តឿន និងលើកទឹកចិត្តគេ។»* (១ កូរិនថូស ១៤:៣)

ដូចបានចែងនៅទីនេះស្រាប់ គ្មានពាក្យណានៅក្នុងខគម្ពីរនេះដែលបង្ហាញថាអ្នកគួរតែរកទិសដៅ តាមរយៈការថ្លែងពាក្យទំនាយទេ ប៉ុន្តែ នេះជារបៀបដែលមនុស្សភាគច្រើនយល់ឃើញអំពីការថ្លែងពាក្យទំនាយ។ ប៉ុន្តែ យោងតាមប្រសាសន៍របស់លោកប៉ូល ការថ្លែងពាក្យទំនាយគឺគ្រាន់តែបញ្ជាក់អំពីទិសដៅ មិនមែនផ្តល់ទិសដៅនោះទេ។ អ្នកយល់ទេ នៅពេលដែលអ្នកកើតជាថ្មីខាងវិញ្ញាណ ព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅក្នុងអ្នក នឹងក្លាយជាអ្នកដែលប្រាប់អ្នកអំពីអ្វីដែលអ្នកត្រូវធ្វើ។ មិនចាំបាច់មានបុរស ឬស្ត្រីណាផ្សេងទៀត មកប្រាប់អ្នកអំពីការត្រាស់ហៅរបស់អ្នក ឱ្យអ្នកធ្វើអ្វីមួយសម្រាប់ព្រះយេស៊ូនោះទេ។ ប៉ុន្តែពាក្យនៃការថ្លែងពាក្យទំនាយអាចបញ្ជាក់អំពីអ្វីដែលអ្នកបានដឹងរួចមកហើយ។

ដូច្នេះ ដូចឧទាហរណ៍ខាងលើ ពាក្យថ្លែងដែលនិយាយថា «អ្នកត្រូវទៅប្រទេសអាហ្វ្រិក» អាចជាពាក្យនៃការថ្លែងពាក្យទំនាយ ប្រសិនបើព្រះវិញ្ញាណដ៏វិសុទ្ធបានប្រាប់អ្នករួចហើយអំពីការនេះ ហើយទ្រង់ចង់បញ្ជាក់វាតាមរយៈពាក្យនៃការថ្លែងពាក្យទំនាយ។ ប៉ុន្តែប្រសិនបើការទៅប្រទេសអាហ្វ្រិកមិនធ្លាប់មានក្នុងគំនិតរបស់អ្នកពីមុនមកទេ ហើយវាជាលើកដំបូងដែលអ្នកបានឮអំពីវា នោះវាមិនមែនជាឧទាហរណ៍ដ៏ពិត សម្រាប់ពាក្យនៃការថ្លែងពាក្យទំនាយនៅក្នុងក្រុមជំនុំសម្ពន្ធមេត្រីថ្មីទេ។

វាពិតជាភ្លឺត្រឡើខ្លាំងណាស់ ដែលឮមនុស្សនិយាយបែបនេះ។ មានគ្រិស្តបរិស័ទដើរមករកខ្ញុំ ហើយនិយាយប្រាប់ខ្ញុំថា «ព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំនៅពេលប្រជុំថា ខ្ញុំនឹងបានចម្រុងចម្រើន»។ បាទ ត្រូវហើយ ហើយអ្នកមិនចាំបាច់ត្រូវការឱ្យនរណាម្នាក់មកប្រាប់អ្នកថា អ្នកនឹងចម្រុងចម្រើនទេ ព្រោះថាព្រះគម្ពីរបានប្រាប់យើងដូច្នេះរួចហើយ។ ខ្ញុំក៏បានឃើញគ្រិស្តបរិស័ទ ដើរសួរអ្នកជឿដទៃទៀត ថាតើពួកគេមានពាក្យអ្វីសម្រាប់ពួកគេដែរឬទេ? អ្នកមិនចាំបាច់ត្រូវការឱ្យនរណាម្នាក់ប្រាប់អ្នកនូវពាក្យណាមួយទេ! ព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់នៅក្នុងអ្នក នឹងមានបន្ទូលមកកាន់អ្នក ហើយពិតហើយ ព្រះជាម្ចាស់អាចបញ្ជូនពាក្យនៃការថ្លែងពាក្យទំនាយ ដើម្បីលើកទឹកចិត្តអ្នក តែមិនមែនដើម្បីដឹកនាំអ្នកទេ។

ឧទាហរណ៍ដ៏គួរឱ្យភ្ញាក់ផ្អើលបំផុតដែលបានកើតឡើងនៅក្នុងជីវិតរបស់ខ្ញុំ គឺពេលដែលខ្ញុំកំពុងតែស្វែងយល់ចិត្តគ្នាទៅវិញទៅមកជាមួយឌ្រិនដា។ នៅពេលនោះខ្ញុំបានទៅរដ្ឋចចចារ ដើម្បីសុំនាងរៀបការជាមួយខ្ញុំ។ ពេលខ្ញុំនៅទីនោះ ខ្ញុំបានទៅលេងក្រុមជំនុំរបស់នាងជាមួយនាង។ នៅពេលនោះផងដែរ គេទើបតែផ្តល់ការងារមួយឱ្យខ្ញុំនៅក្នុងឧស្សាហកម្មសេវាកម្មហិរញ្ញវត្ថុ ដែលខ្ញុំកំពុងតែតយុទ្ធជាមួយ។ ខ្ញុំត្រូវបានត្រាស់ហៅឱ្យប្រកាសព្រះបន្ទូលព្រះពេលខ្ញុំអាយុ១៩ឆ្នាំ ហើយខ្ញុំទើបតែបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ ជាមួយសញ្ញាបត្រព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ប៉ុន្តែ ខ្ញុំក៏មានអារម្មណ៍ថាត្រូវចាប់យកការងារផ្នែកហិរញ្ញវត្ថុនេះផងដែរ។ ខ្ញុំមានអារម្មណ៍ច្របូកច្របល់មិនដឹងថាត្រូវធ្វើអ្វីឱ្យប្រាកដទេ។

បន្ទាប់ពីចប់វេនថ្វាយបង្គំពេលព្រឹកថ្ងៃអាទិត្យនៅក្រុមជំនុំរបស់ឌ្រិនដា មានស្ត្រីម្នាក់ដែលខ្ញុំមិនធ្លាប់ស្គាល់ ប៉ុន្តែ ឌ្រិនដាស្គាល់គាត់ បានដើរមករកខ្ញុំ ហើយប្រាប់ខ្ញុំថា គាត់មានពាក្យមួយសម្រាប់ខ្ញុំ។ គាត់បាននិយាយថា «អ្នកកំពុងតែគិតអំពីការងារដែលគេផ្តល់ឱ្យអ្នក។ ការងារនោះមានលក្ខណៈ១០យ៉ាងដូចខាងក្រោម» ហើយគាត់បានរៀបរាប់អ្វីគ្រប់

យ៉ាងដែលខ្ញុំត្រូវធ្វើនៅកន្លែងការងារនោះយ៉ាងល្អឥតខ្ចោះ។ ហើយគាត់បាននិយាយថា « អ្នកត្រូវទទួលការងារនេះ ហើយព្រះអម្ចាស់គង់នៅជាមួយអ្នកក្នុងការងារមួយនេះ»។ នៅក្នុងករណីនេះ ខ្ញុំមានអារម្មណ៍ចង់ទទួលយកការងារនេះរួចហើយ ប៉ុន្តែ ខ្ញុំក៏មានអារម្មណ៍ច្របូកច្របល់ ដោយមិនដឹងថាហេតុអ្វីបានជាខ្ញុំមានអារម្មណ៍បែបនេះ។ ពាក្យនៃការថ្លែងពាក្យទំនាយរបស់គាត់ ធ្វើឱ្យខ្ញុំមានអារម្មណ៍ធូរស្បើយក្នុងចិត្ត និងលើកទឹកចិត្តខ្ញុំ ព្រមទាំងបានបញ្ជាក់អំពីទិសដៅដែលខ្ញុំគួរតែទៅ។ ជាថ្មីម្តងទៀត ព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងអ្នក នឹងដឹកនាំអ្នក ហើយនឹងក្លាយជាព្រះដ៏ជាជំនួយដល់អ្នក។

# ជំពូកទី១១
# ព្រះវិញ្ញាណដ៏វិសុទ្ធស្តាប់ទៅដូចជាចៅហ្វាយខ្ញុំ

កាលពីពេលដែលក្រុមជំនុំរបស់ខ្ញុំនៅតូចនៅឡើយ មានក្រុមគ្រួសារមួយដែលត្រូវការការងារធ្វើ។ ពួកគេជាក្រុមគ្រួសារមួយដ៏គួរឱ្យរាប់អាន ហើយតែងតែចង់ជួយដល់ក្រុមជំនុំ។ ក៏ប៉ុន្តែ តែងតែមានបញ្ហាលុយកាក់។ ឪពុកមិនមានការងារធ្វើទៀតហើយ ហើយខ្ញុំបានសម្រេចចិត្តជួយពួកគេ។ នៅពេលនោះខ្ញុំកំពុងតែសាងសង់ផ្ទះរបស់ខ្ញុំ ហើយខ្ញុំបានតភ្លើងនៅក្នុងផ្ទះដោយខ្លួនឯង។ ខ្ញុំបានដឹងថា ឪពុកនោះចេះតភ្លើងខ្លះដែរ ហើយខ្ញុំបានផ្តល់ឱកាសឱ្យគាត់ធ្វើការក្រៅម៉ោងឱ្យខ្ញុំ ព្រោះថាគ្រួសាររបស់ពួកគេហៀបនឹងអស់អាហារហើយ។ ដូច្នេះ គាត់បានជួយតភ្លើងឱ្យខ្ញុំបានល្អសមរម្យ។

ខ្ញុំមិនបានគិតអីច្រើនអំពីរឿងនេះទេ ប៉ុន្តែប្រហែលមួយខែក្រោយមកខ្ញុំទទួលបានទូរស័ព្ទពីគាត់។ គាត់បាននិយាយថាមានអ្នកនៅក្រុមជំនុំពីរបីនាក់ជួបជុំគ្នាអធិស្ឋានឱ្យខ្ញុំ។ ខ្ញុំបានសួរគាត់ថា «តើអធិស្ឋានអំពីអ្វីដែរ?» គាត់បាននិយាយថាមានកិច្ចការមួយចំនួនដែលត្រូវផ្លាស់ប្តូរនៅក្រុមជំនុំ ហើយគាត់បន្តនិយាយថា គាត់មានបញ្ជី១០ចំណុចដែលពួកគេកំពុងតែពិភាក្សាគ្នា។ ចំណុចទី១ក្នុងបញ្ជីនោះ គឺផ្ទះរបស់ខ្ញុំធំពេកហើយ។ ហើយគាត់បានសួរខ្ញុំត្រង់ៗថា តើក្រុមជំនុំឱ្យប្រាក់ខែខ្ញុំប៉ុន្មានដែរ ដើម្បីអាចធ្វើផ្ទះទំហំធំបែបនេះនោះ? ខ្ញុំប្រាប់គាត់យ៉ាងរហ័សថា ខ្ញុំមិនបានទទួលប្រាក់ខែពីក្រុមជំនុំទេ សូម្បីតែមួយកាក់មួយសេន។ បន្ទាប់ពីខ្ញុំបាននិយាយដូច្នេះហើយ ក៏មានភាពស្ងាត់ស្ងៀមមួយរយៈ។ បន្ទាប់មកគាត់បាននិយាយថា «ក្រុមជំនុំមិនបើកប្រាក់ខែឱ្យលោកគ្រូទេឬ?» «បាទ ត្រឹមត្រូវហើយ» ខ្ញុំបានឆ្លើយ។ ក៏មានភាពស្ងាត់ស្ងៀមជាថ្មីម្តងទៀត រហូតទីបំផុតគាត់បាននិយាយថា «

អ៊ីចឹង ក្រុមជំនុំគួរតែផ្ដល់ប្រាក់ខែដល់លោកគ្រូ» ហើយវាជាចុងបញ្ចប់នៃការសន្ទនារបស់យើងនៅថ្ងៃនោះ។

ក្រោយមក ប្រហែលបានមួយសប្ដាហ៍ ខ្ញុំបានឮអំពីឱកាសការងារនៅក្រុមហ៊ុនមួយដែលខ្ញុំគិតថា វានៅក្នុងវិស័យដែលគាត់ចាប់អារម្មណ៍ ដូច្នេះខ្ញុំក៏បានប្រាប់គាត់អំពីឱកាសការងារមួយនោះ។ គាត់បានទៅ និងបានដាក់ពាក្យសុំធ្វើការ ហើយក៏បានទទួលការងារនោះ។ ពេលនោះគ្រួសាររបស់គាត់ហៀបនឹងបានត្រូវគេបណ្ដេញចេញពីផ្ទះហើយ។ នៅក្នុងសប្ដាហ៍ដែលគាត់បានទទួលការងារថ្មីនោះ គាត់បានមកក្រុមជំនុំ ហើយបានប្រាប់ខ្ញុំថា គាត់បានសុំគេឈប់ធ្វើការហើយ។ ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ហើយបាននិយាយថា «អ្នកឈប់ធ្វើការហើយ? តើហេតុអ្វីទៅ?» គាត់បានប្រាប់ខ្ញុំវិញថា នៅរសៀលថ្ងៃសុក្រ ពួកគេរវល់បញ្ចប់ការងារសម្រាប់សប្ដាហ៍នោះ ហើយបានសុំខ្ញុំឱ្យបោសសម្អាតកម្រាលឥដ្ឋ។ គាត់បានប្រាប់ខ្ញុំថា នៅពេលគាត់សុំគេឈប់ គាត់ក៏បានប្រាប់ពួកគេថា គាត់មិនបានដាក់ពាក្យសុំធ្វើការងារជាអ្នកសម្អាតកម្រាលឥដ្ឋទេ។ ខ្ញុំស្ទើរតែមិនជឿអំពីអ្វីដែលខ្ញុំបានឮ។ ខ្ញុំដឹងថាបុរសវ័យក្មេងម្នាក់នេះ ត្រូវទទួលការបណ្ដុះបណ្ដាលឱ្យបានច្រើនជាងនេះ ប្រសិនបើគាត់ចង់ទទួលបានជោគជ័យនៅក្នុងជីវិតគាត់។ ខ្ញុំតែងតែមានអារម្មណ៍អាណិតប្រពន្ធគាត់។ ពួកគេក៏បានចាកចេញពីក្រុមជំនុំបន្តិចក្រោយមកទៀតផងដែរ ហើយខ្ញុំមិនបានឮដំណឹងអ្វីពីពួកគេបន្ទាប់ពីពេលនោះមកទេ។ យ៉ាងណាមិញ ខ្ញុំប្រហែលអាចធ្វើការទស្សទាយបានយ៉ាងល្អសមរម្យ។ ដោយផ្អែកលើឥរិយាបទក្រអឺតក្រទម និងការមិនចង់ធ្វើកិច្ចការតូចតាចរបស់គាត់ ខ្ញុំអាចសន្មតបានថា ក្នុងប្រវត្តិរូបសង្ខេបអំពីការងាររបស់គាត់ប្រហែលជាមានបទពិសោធការងារតិចតួច និងធ្វើការបានតែក្នុងរយៈពេលខ្លីទេ។ គាត់ស្ថិតក្នុងកម្រិតជីវភាព បានត្រឹមតែអាចរស់រានមានជីវិតតែប៉ុណ្ណោះ។ សូមកុំយល់ច្រឡំចំពោះខ្ញុំ។ ខ្ញុំជឿថាមនុស្សយើងអាចផ្លាស់ប្រែបាន ហើយខ្ញុំពិតជាសង្ឃឹមថាគាត់ពិតជាផ្លាស់ប្រែដើម្បីឱ្យជីវិតគាត់បានប្រសើរជាងនេះ។ ប៉ុន្តែ ខ្ញុំដឹងប្រាកដថា ពេលដែលខ្ញុំបានស្គាល់គាត់ គាត់កំពុងតែដើរក្នុងទិសដៅខុស។ អ្នកដឹងទេថា គាត់មិនបានអើពើនឹងព្រះសូរសៀងរបស់ព្រះជាម្ចាស់ទេ។

អ្នកប្រហែលជាអាចសួរខ្ញុំថា «តើអ្នកកំពុងតែនិយាយអំពីព្រះសូរសៀងរបស់ព្រះជាម្ចាស់ស្អីគេដែរ?»។ ខ្ញុំក៏ជឿថា គាត់មុខតែសួរសំណួរនេះដូចគ្នា ព្រោះពេលនោះគាត់មិនបានដឹងអំពីរឿងនេះ។ ប៉ុន្តែគាត់មិនបានអើពើនឹងវិធីសាស្ត្រចម្បងមួយដែលព្រះជាម្ចាស់ប្រើ ដើម្បីបណ្ដុះបណ្ដាល និងរៀបចំមនុស្សសម្រាប់ជោគវាសនារបស់ពួកគេទេ គឺការរៀន

ចេះចុះចូលនឹងសិទ្ធិអំណាច។ ខ្ញុំដឹងថាចំណងជើងជំពូកនេះ អាចធ្វើឱ្យអ្នកយល់ច្រឡំ។ តើថៅហ្វាយរបស់ខ្ញុំមានអីពាក់ព័ន្ធជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធ? អ្នកនឹងរៀនបានពីជំពូកនេះថា ថៅហ្វាយរបស់អ្នកពាក់ព័ន្ធច្រើនជាមួយសមត្ថភាពរបស់អ្នកក្នុងការស្ដាប់ព្រះវិញ្ញាណដ៏វិសុទ្ធ!

ខ្ញុំចង់ចាប់ផ្ដើមការសិក្សាអំពីប្រធានបទដ៏សំខាន់មួយនេះ ជាមួយខគម្ពីរមួយនៅក្នុង ម៉ាថាយ ៨:៥-១០។

*នៅពេលព្រះយេស៊ូយាងចូលក្រុងកាពើណិម មាននាយទាហានរ៉ូម៉ាំងម្នាក់ ចូលមកគាល់ព្រះអង្គ ទូលអង្វរថា៖ «លោកម្ចាស់អើយ! អ្នកបម្រើរបស់ខ្ញុំប្របាទដេកស្ដូកស្ដឹងនៅឯផ្ទះ ទាំងឈឺចុកចាប់យ៉ាងខ្លាំង»។*

*ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំនឹងទៅមើលគាត់ឱ្យបានជា»។*

*នាយទាហានទូលព្រះអង្គថា៖ «លោកម្ចាស់ ខ្ញុំប្របាទមានឋានៈទន់ទាបណាស់ មិនសមនឹងលោកអញ្ជើញចូលក្នុងផ្ទះខ្ញុំប្របាទទេ សូមលោកមានប្រសាសន៍តែមួយម៉ាត់ប៉ុណ្ណោះ អ្នកបម្រើរបស់ខ្ញុំប្របាទនឹងជាសះស្បើយមិនខាន។ <u>ខ្ញុំប្របាទជាអ្នកនៅក្រោមបញ្ជាគេ ហើយមានកូនទាហាននៅក្រោមបញ្ជាខ្ញុំប្របាទដែរ បើខ្ញុំប្របាទបញ្ជាអ្នកណាម្នាក់ឱ្យទៅ គេនឹងទៅ បើប្រាប់ម្នាក់ទៀតឱ្យមក គេនឹងមក។ ពេលខ្ញុំប្របាទប្រាប់អ្នកបម្រើឱ្យធ្វើការអ្វីមួយ គេនឹងធ្វើតាម</u>»។*
*កាលព្រះយេស៊ូទ្រង់ព្រះសណ្ដាប់ដូច្នេះហើយ ព្រះអង្គស្ងើចសរសើរណាស់ក៏មានព្រះបន្ទូលទៅកាន់អស់អ្នកដែលដើរតាមព្រះអង្គថា៖ «ខ្ញុំសុំប្រាប់ឱ្យអ្នករាល់គ្នាដឹងច្បាស់ថា ខ្ញុំមិនដែលឃើញនរណាមានជំនឿបែបនេះ នៅស្រុកអ៊ីស្រាអែលឡើយ។*

ម៉ាថាយ ៨:៥-១០

ហេតុអ្វីបានជាបុរសម្នាក់នេះងាយក្នុងការជឿថាព្រះយេស៊ូអាចប្រោសអ្នកបម្រើគាត់ឱ្យជាបាន? គាត់បានឆ្លើយសំណួរនេះដោយខ្លួនឯង។ គាត់បាននិយាយថា *«ខ្ញុំប្របាទជាអ្នកនៅក្រោមបញ្ជាគេ ហើយមានកូនទាហាននៅក្រោមបញ្ជាខ្ញុំប្របាទដែរ បើខ្ញុំប្របាទបញ្ជាអ្នកណាម្នាក់ឱ្យទៅ គេនឹងទៅ បើប្រាប់ម្នាក់ទៀតឱ្យមក គេនឹងមក។ ពេលខ្ញុំប្របាទប្រាប់អ្នកបម្រើឱ្យធ្វើការអ្វីមួយ គេនឹងធ្វើតាម»*។ ដោយសារគាត់បានដឹងអំពីរដំណើរការនៃសិទ្ធិអំណាច។ ដូចដែលគាត់នៅក្រោមបញ្ជាគេ គាត់ក៏មានកូនទាហានដែលនៅក្រោមបញ្ជា

គាត់ផងដែរ។ គាត់ដឹងថាពាក្យបញ្ជាពីថៅហ្វាយគាត់ ដូចជាពាក្យបញ្ជាពីសេសារអ៊ីចឹងដែរ។ តាមពិត បើគាត់បានដឹងពីការពិត សំឡេងរបស់ថៅហ្វាយគាត់ គឺជាសំឡេងរបស់សេសារ។ គាត់ក៏យល់ដែរថា សំឡេងរបស់គាត់ទៅកាន់កូនចៅគាត់ ប្រៀបដូចជាសំឡេងរបស់សេសារទៅកាន់ពួកគេផងដែរ។ នេះជាដំណើរការនៃសិទ្ធិអំណាច។ ដូច្នេះ ដោយសារគាត់បានយល់អំពីអត្ថន័យនៃការស្ថិតនៅក្រោមបញ្ជាគេ គាត់ក៏ងាយស្រួលយល់អំពីរបៀបដែលព្រះយេស៊ូអាចប្រើសិទ្ធិអំណាចរបស់ទ្រង់លើស្ថានភាពនេះ ដោយគ្រាន់តែមានបន្ទូល។ នេះជាអ្វីដែលគាត់ធ្វើជាមួយអ្នកបម្រើរបស់គាត់ផងដែរ។ ប្រសិនបើគាត់ប្រើអ្នកបម្រើគាត់ឱ្យធ្វើអ្វីមួយ ពួកគេធ្វើតាមបញ្ជាគាត់។ វាគឺសាមញ្ញដូច្នេះឯង។ នេះជាការពិតដែលអ្នកត្រូវរៀន៖

**អ្នកអាចមានសិទ្ធិអំណាចបាន លុះត្រាតែអ្នកចេះចុះចូលចំពោះសិទ្ធិអំណាច**!

ប្រសិនបើមារសាតាំងអាចដកការគោរពចុះចូលចំពោះសិទ្ធិអំណាចបាន ហើយបញ្ចុះបញ្ចូលមនុស្សគ្រប់គ្នាថា ពួកគេអាចធ្វើអ្វីទៅតាមចិត្តចង់ និងទៅតាមពេលដែលពួកគេចង់បាន នោះពិភពលោកនេះនឹងដួលរលំទៅក្នុងភាពច្របូកច្របល់ និងភាពវិនាសជាមិនខានទេ។ ហើយនេះជាអ្វីដែលវាបានតវ៉ាជាមួយអេវ៉ានៅសួនឧទ្យាន៖ «តើព្រះជាម្ចាស់ពិតជាមានបន្ទូលថា...»។ សូមស្ដាប់ មនុស្សគ្រប់គ្នានៅលើផែនដីនេះ គឺស្ថិតនៅក្រោមសិទ្ធិអំណាច ឬនៅក្រោមសិទ្ធិអំណាចច្រើនប្រភេទ។ ការទទួលស្គាល់ថា អ្នកស្ថិតនៅក្រោមសិទ្ធិអំណាចរបស់អ្នកណាម្នាក់ នឹងជួយអ្នកឱ្យដឹងថាអ្នកណាដែលអ្នកត្រូវស្ដាប់តាម ហើយអ្នកណាអ្នកមិនត្រូវស្ដាប់តាម។ ប៉ុន្តែ សព្វថ្ងៃនេះ គ្រប់គ្នាចង់មានសិទ្ធិអំណាច តែមិនចង់នៅក្រោមសិទ្ធិអំណាចទេ ហើយការនេះវាមិនអាចទៅរួចទេ។

ថ្មីៗនេះខ្ញុំបាននិយាយជាមួយអ្នកម៉ៅការម្នាក់ ដែលបានប្រាប់ខ្ញុំថាគាត់បើកប្រាក់ខែជាសាច់ប្រាក់ឱ្យអ្នកដែលធ្វើការជាមួយគាត់ ដើម្បីឱ្យពួកគេអាចជាសវាងការបង់ពន្ធបុគ្គលិក និងប្រាក់កម្រៃឈ្នួលរបស់កម្មករ។ ប៉ុន្តែ ខ្ញុំបានដឹងរួចទៅហើយថា រឿងនេះវានឹងក្លាយទៅជាយ៉ាងណា។ ថ្ងៃណាមួយ ពេលដែលនាយោជិកម្នាក់នោះរងរបួស ហើយបានដាក់ពាក្យទាមទារសំណងពីការរងរបួសនោះ រួចក្រោយមកស្វែងយល់ថាថៅហ្វាយមិនដែលបង់ថ្លៃសម្រាប់កម្មវិធីសំណងកម្មករទេ នោះគាត់នឹងប្ដឹងអ្នកម៉ៅការជាមិនខានទេ ព្រោះថាច្បាប់តម្រូវឱ្យមានការបង់ថ្លៃសម្រាប់សំណងកម្មករ។ រឿងនេះបានកើតឡើងចំពោះអ្នកម៉ៅការពីរបីនាក់នៅក្រុមជំនុំរបស់យើង។

សប្ដាហ៍មុននេះ ខ្ញុំបានជួបស្ត្រីម្នាក់ដែលនិយាយថា គាត់មិនត្រូវការគ្រូគង្វាលទេ គ្រាន់តែមានគាត់ និងព្រះវិញ្ញាណដ៏វិសុទ្ធ វាគ្រប់គ្រាន់ហើយ។ មែនក៏អី? បើមែននោះ គាត់គួរតែទៅនិយាយជាមួយព្រះយេស៊ូអំពីរឿងនេះ ព្រោះថាទ្រង់គឺជាអ្នកដែលបានតែងតាំងគ្រូគង្វាល និងបង្កើតក្រុមជំនុំដែលបានចែងក្នុងសៀវភៅអេភេសូ ជំពូកទី៤។ ប្រសិនបើគាត់ពិតជាដើរតាមព្រះយេស៊ូពិតមែន គាត់នឹងធ្វើតាមសិទ្ធិអំណាចដែលព្រះយេស៊ូបានបង្កើតឡើង។ តាមការពិត គាត់មិនបានចុះចូលនឹងព្រះយេស៊ូទេ ហើយគាត់ចង់ធ្វើអ្វីទៅតាមចិត្តរបស់គាត់។ គាត់នឹងធ្លាក់ចូលក្នុងការបោកបញ្ឆោត ហើយជួបការលំបាកដោយសារតែវា។

មិនយូរប៉ុន្មាន ខ្ញុំបាននិយាយជាមួយអ្នកលក់ម្នាក់ដែលកំពុងតែចាប់ផ្តើមបើកក្រុមហ៊ុនលក់ផ្ទាល់ខ្លួន គាត់បានយកអតិថិជនពីក្រុមហ៊ុនដែលគាត់បានធ្វើការឱ្យគេ ទៅជាមួយក្រុមហ៊ុនថ្មីរបស់គាត់ ទោះបីជាគាត់បានចុះហត្ថលេខា មិនប្រកួតប្រជែងដែលបញ្ជាក់ថាគាត់មិនធ្វើដូច្នេះក៏ដោយ។ ហើយគាត់គិតថា គាត់នឹងចម្រុងចម្រើនដោយធ្វើដូច្នេះឬ? វាប្រៀបដូចជាការលួចគេអ៊ីចឹង!

ខ្ញុំដឹងថា អ្នកប្រហែលជាមិនសូវចូលចិត្តជំពូកនេះ ដូចជំពូកផ្សេងទៀតដែលខ្ញុំបានរៀបរាប់រឿងរ៉ាវនៃការអស្ចារ្យ ដែលព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើនោះទេ ក៏ប៉ុន្តែប្រសិនបើអ្នកមិនធ្វើឱ្យបានត្រឹមត្រូវទេ ការអស្ចារ្យទាំងនោះនឹងមិនអាចកើតឡើងបានទេ ព្រោះថាព្រះជាម្ចាស់លើកកម្ពស់ឱ្យធ្វើអ្វីដែលត្រឹមត្រូវ។

ខ្ញុំចាំបានមានពេលមួយ មានស្ត្រីម្នាក់មករកខ្ញុំនៅការប្រជុំការអធិស្ឋានមួយ ទាំងស្រក់ទឹកភ្នែក ហើយគាត់បានសួរខ្ញុំថា ហេតុអ្វីបានជាខ្ញុំមិនហៅគាត់ឱ្យមកអធិស្ឋានផង។ ខ្ញុំភ្ញាក់ផ្អើលខ្លាំងមែនទែន! ហេតុអ្វីបានជារឿងតូចតាចមួយនេះ ក្លាយជារឿងធំសម្រាប់គាត់? លើកលែងតែអត្តសញ្ញាណរបស់គាត់ផ្អែកទៅលើការទទួលស្គាល់ពីមនុស្ស?

**ការទទួលស្គាល់ថា អ្នកស្ថិតនៅក្រោមសិទ្ធិអំណាចរបស់អ្នកណាម្នាក់ នឹងជួយអ្នកឱ្យដឹងថាអ្នកណាដែលអ្នកត្រូវស្ដាប់តាម ហើយអ្នកណាដែលអ្នកមិនត្រូវស្ដាប់តាម។**

ហើយតាមពិតទៅ ខ្ញុំអាចប្រាប់គាត់តាមត្រង់អំពីមូលហេតុដែលខ្ញុំមិនបានហៅគាត់ឱ្យចូលរួមការប្រជុំអធិស្ឋាននោះ ប្រសិនបើគាត់ចេះស្ដាប់អ្នកដទៃ។ ស្ត្រីម្នាក់នេះមិនគោរពប្ដីរបស់គាត់ទេ ហើយតែងតែនិយាយដើមប្ដីអំពីភាពខ្សោយខាងវិញ្ញាណរបស់គាត់។ នេះជាមូលហេតុដែលខ្ញុំមិនបានហៅ

គាត់ឱ្យមកចូលរួមការប្រជុំអធិស្ឋានមួយនេះ។ ការដែលគាត់ស្រក់ទឹកភ្នែក គឺដោយសារតែគេមិនបានឃើញគាត់ថាជាស្ត្រីរឹងមាំខាងវិញ្ញាណ ដូចដែលគាត់ធ្លាប់គិតអំពីខ្លួនឯង មុនពេលក្រុមទាំងមូលលាតត្រដាងថាគាត់មិនបានគោរពចុះចូលនឹងសិទ្ធិអំណាច ហើយដូច្នេះគាត់គឺជាស្ត្រីដ៏គ្រោះថ្នាក់ម្នាក់។

ដូច្នេះ ខ្ញុំសូមសួរសំណួរអ្នកមួយ។ តើអ្នកមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីទៅកន្លែងដែលអ្នកចង់ទៅ ជាកន្លែងនៃក្តីសុបិនរបស់អ្នកដែរឬទេ? ប្រសិនបើខ្ញុំសួរគ្រូគង្វាលរបស់អ្នក ឬថៅហ្វាយរបស់អ្នក តើអ្វីជាគំនិតស្មោះត្រង់របស់ពួកគេអំពីអ្នក? តើពួកគេនឹងនិយាយអ្វី? អ្នកឃើញទេ អ្នកមិនអាចមានសិទ្ធិអំណាចបានឡើយ លុះត្រាតែអ្នកឆ្លងកាត់ការធ្វើតេស្តនៃការចុះចូលនឹងសិទ្ធិអំណាចជាមុនសិន។ នេះមិនមែនជាពាក្យសម្តីរបស់ខ្ញុំទេ វាជាពាក្យរបស់ព្រះយេស៊ូ។

> *អ្នកណាស្មោះត្រង់ក្នុងកិច្ចការដ៏តូច អ្នកនោះក៏ស្មោះត្រង់ក្នុងកិច្ចការធំដុំដែរ។ អ្នកណាបោកបញ្ឆោតក្នុងកិច្ចការដ៏តូច អ្នកនោះក៏តែងបោកបញ្ឆោតក្នុងកិច្ចការធំដុំដែរ។ ប្រសិនបើអ្នករាល់គ្នាមិនស្មោះត្រង់ក្នុងរបៀបប្រើប្រាស់ទ្រព្យសម្បត្តិលោកិយដែលបញ្ឆោតចិត្តនេះទេ ព្រះជាម្ចាស់ក៏ពុំអាចប្រគល់ទ្រព្យសម្បត្តិដ៏ពិតប្រាកដមកអ្នករាល់គ្នាបានដែរ។ ប្រសិនបើអ្នករាល់គ្នាមិនស្មោះត្រង់នឹងទ្រព្យសម្បត្តិអ្នកដទៃផង ធ្វើម្តេចឱ្យព្រះជាម្ចាស់ប្រទានទ្រព្យសម្បត្តិដែលព្រះអង្គបម្រុងទុកសម្រាប់អ្នករាល់គ្នា មកអ្នករាល់គ្នាបាន!*

លូកា ១៦:១០-១២

**តើអ្នកជាមនុស្សដែលគួរឱ្យទុកចិត្តបាន ដែលគេអាចប្រគល់សិទ្ធិអំណាចឱ្យអ្នក? ភស្តុតាងគឺស្ថិតលើការចុះចូលរបស់អ្នក។**

យើងនឹងមើលរឿងមួយក្នុងព្រះគម្ពីរដែលមានឥទ្ធិពលខ្លាំងលើភាពជោគជ័យដែលអ្នកមានក្នុងជីវិតអ្នក។

> *ជនជាតិភីលីស្ទីនប្រមូលទ័ពចេញមកច្បាំងតទល់នឹងជនជាតិអ៊ីស្រាអែល។ ពួកគេមានរទេះចំបាំងចំនួនបីម៉ឺនគ្រឿង មានទ័ពសេះប្រាំមួយពាន់ និងមានពលទាហានច្រើនកុះករ ដូចខ្សាច់នៅឆ្នេរសមុទ្រ។ ពួកគេបានលើកទ័ពមកបោះជំរំនៅមីកម៉ាស់ខាងកើតបេតអាវេន។ កាលប្រជាជនអ៊ីស្រាអែលឃើញថាខ្លួនស្ថិតក្នុងភាពអាសន្ន*

*ព្រោះទ័ពអ៊ីស្រាអែលត្រូវខ្មាំងឡោមព័ទ្ធជិតដូច្នេះ ពួកគេក៏នាំគ្នារត់ទៅពួននៅតាមរអាងភ្នំ តាមគុហា តាមក្រហែងថ្ម តាមរូងភ្នំ និងនៅតាមជ្រោះ។ មានជនជាតិហេប្រឺខ្លះឆ្លងទន្លេយ័រដាន់រត់ទៅស្រុកកាដ និងស្រុកកាឡាដ។*

*រីឯព្រះបាទសូលវិញ ទ្រង់គង់នៅគីលកាល់នៅឡើយ ហើយកងទ័ពទាំងប៉ុន្មានដែលនៅជាមួយស្ដេច ញ័ររន្ធត់យ៉ាងខ្លាំង។ ព្រះបាទសូលរង់ចាំជួបលោកសាំយូអែល អស់រយៈពេលប្រាំពីរថ្ងៃ តែមិនឃើញលោកអញ្ជើញមកគីលកាល់ ដូចបានកំណត់ទេ។ ពួកទាហានក៏នាំគ្នារត់គេចខ្លួន ចេញឆ្ងាយពីស្ដេច។ ព្រះបាទសូលមានរាជឱង្ការថា៖ «ចូរយកតង្វាយដុតទាំងមូល និងយញ្ញបូជាមេត្រីភាព មកឱ្យខ្ញុំ»។ ស្ដេចក៏ថ្វាយតង្វាយដុតទាំងមូលនោះទៅ។*

១ សាំយ៉ូអែល ១៣:៥-៩

*លោកសាំយូអែលទូលព្រះបាទសូលថា៖ «ព្រះករុណាបានប្រព្រឹត្ត ដោយឥតពិចារណា! គឺព្រះករុណាមិនធ្វើតាមបទបញ្ជាដែលព្រះអម្ចាស់ជាព្រះរបស់ព្រះករុណាបានបង្គាប់មកទេ។ បើព្រះករុណាធ្វើតាមនោះ ម្ល៉េះសមព្រះអម្ចាស់ពង្រឹងរាជ្យរបស់ព្រះករុណា ឱ្យនៅស្ថិតស្ថេរលើជនជាតិអ៊ីស្រាអែលមិនខាន។ ឥឡូវនេះ រាជ្យរបស់ព្រះករុណាមិនអាចគង់វង្សឡើយ **<u>ព្រះអម្ចាស់ស្វែងរកមនុស្សម្នាក់ដែលគាប់ព្រះហឫទ័យព្រះអង្គ រួចតែងតាំងឱ្យធ្វើជាមេដឹកនាំលើប្រជារាស្ត្ររបស់ព្រះអង្គ</u>** ព្រោះព្រះករុណាមិនបានធ្វើតាមបទបញ្ជា ដែលព្រះអម្ចាស់បានបង្គាប់មកទេ»។*

១ សាំយ៉ូអែល ១៣:១៣-១៤

ស្ដេចសូលត្រូវបានដកសិទ្ធិអំណាច ដោយសារទ្រង់មិនបានចុះចូលនឹងសិទ្ធិអំណាចរបស់ព្រះជាម្ចាស់។ ដូច្នេះ ម្ដងទៀតហើយ យើងឃើញថា ប្រសិនបើអ្នកមិនអាចចុះចូលនឹងសិទ្ធិអំណាចទេ នោះអ្នកក៏មិនអាចមានសិទ្ធិអំណាចបានដែរ។ ខ្ញុំចង់បញ្ជាក់ចំណុចសំខាន់មួយនៅទីនេះ។ ព្រះជាម្ចាស់ស្វែងរកមនុស្សដែលគាប់ព្រះហឫទ័យព្រះអង្គ។ តើ «ការគាប់ព្រះហឫទ័យព្រះអង្គ» មានន័យយ៉ាងដូចម្ដេច?

*ក្រោយពីបានដករាជ្យពីព្រះបាទសូល ព្រះជាម្ចាស់ប្រទានឱ្យព្រះបាទដាវីឌឡើងគ្រងរាជ្យ។ ព្រះអង្គប្រទានសក្ខីភាពអំពីព្រះបាទដាវីឌនេះថា៖“យើងរកបាន*

*មនុស្សម្នាក់ ជាទីគាប់ចិត្តយើងណាស់ គឺដាវីឌជាបុត្ររបស់អ៊ីសាយ **<u>ដ្បិតដាវីឌនឹងបំពេញតាមបំណងទាំងប៉ុន្មានរបស់យើង</u>**”។*

កិច្ចការ ១៣:២២

តើព្រះជាម្ចាស់កំណត់ថា មនុស្សម្នាក់ជាទីគាប់ចិត្តរបស់ទ្រង់យ៉ាងដូចម្ដេច? ជាទូទៅ ពួកគេជាមនុស្សដែលស្អប់អ្វីដែលទ្រង់ស្អប់ ហើយស្រលាញ់អ្វីដែលទ្រង់ស្រលាញ់ ជាមនុស្សដែលនឹងធ្វើអ្វីដែលព្រះជាម្ចាស់ទ្រង់នឹងធ្វើ ប្រសិនបើទ្រង់គង់នៅទីនោះ។ អាចនិយាយម្យ៉ាងទៀតថា ប្រសិនបើព្រះជាម្ចាស់ស្អប់អំពើបាប ពួកគេក៏ស្អប់អំពើបាបដែរ។ ប្រសិនបើព្រះជាម្ចាស់ចង់សម្រេចកិច្ចការអ្វីមួយ ពួកគេក៏ចង់សម្រេចកិច្ចការនោះផងដែរ។ នៅក្នុងពិភពលោកនេះ យើងគិតថាមនុស្សជាទីគាប់ព្រះហឫទ័យព្រះ គឺជាមនុស្សដែលមានអំណោយទានខាងវិញ្ញាណច្រើនបំផុត។ យើងគិតថា ខាងវិញ្ញាណ គឺជាតន្រ្តីថ្វាយបង្គំព្រះយ៉ាងទន់ភ្លន់។ ក៏ប៉ុន្តែ ព្រះជាម្ចាស់បានមានបន្ទូលយ៉ាងច្បាស់ថា ការស្ដាប់បង្គាប់គឺជាការថ្វាយបង្គំខាងវិញ្ញាណ។

*លោកសាំយូអែលមានប្រសាសន៍ថា៖ «តើព្រះអម្ចាស់សព្វព្រះហឫទ័យនឹងតង្វាយដុតទាំងមូល ព្រមទាំងយញ្ញបូជា ខ្លាំងជាងការស្ដាប់បង្គាប់ព្រះអង្គឬ? ទេ! ការស្ដាប់បង្គាប់ប្រសើរជាងថ្វាយយញ្ញបូជាទៅទៀត <u>ការយកចិត្តទុកដាក់ស្ដាប់ក៏ប្រសើរជាងការថ្វាយខ្លាញ់ចៀមឈ្មោលដែរ</u>។ រីឯការបះបោរអាក្រក់ដូចការរកគ្រូទាយ ហើយចិត្តរឹងរូសក៏អាក្រក់ដូចការគោរពព្រះក្លែងក្លាយដែរ។ ព្រះករុណាបោះបង់ចោលព្រះបន្ទូលរបស់ព្រះអម្ចាស់ ដូច្នេះ ព្រះអង្គក៏បោះបង់ចោលព្រះករុណាលែងឱ្យធ្វើជាស្ដេចទៀតហើយ»។*

១ សាំយ៉ូអែល ១៥:២២-២៣

ដូច្នេះ ជាថ្មីម្ដងទៀត ខ្ញុំសូមនិយាយថា សំឡេងរបស់ព្រះជាម្ចាស់ស្ដាប់ទៅហាក់ដូចជាសំឡេងថៅហ្វាយរបស់អ្នក! ព្រះជាម្ចាស់អនុញ្ញាតឱ្យអ្នកឆ្លើយតបទៅកាន់សិទ្ធិអំណាច នៅពេលដែលមិនទាន់មាននរណាម្នាក់ស្គាល់ឈ្មោះអ្នកនៅឡើយ។ មនុស្សភាគច្រើនមិនយល់អំពីដំណើរការនេះទេ។ ពួកគេមិនចាត់ទុកថា ការងារក្រៅម៉ោងរបស់ពួកគេសំខាន់ទេ។ ពួកគេនិយាយថា វាគ្មានអ្វីសំខាន់

**ដូច្នេះ ជាថ្មីម្ដងទៀត ខ្ញុំសូមនិយាយថា សំឡេងរបស់ព្រះជាម្ចាស់ស្ដាប់ទៅហាក់ដូចជាសំឡេងចៅហ្វាយរបស់អ្នក!**

ទេ។ ប៉ុន្តែ អ្វីដែលពួកគេមិនបានដឹង គឺថាពួកគេកំពុងតែបណ្ដុះបណ្ដាលខ្លួនឯងឱ្យចុះចូលនឹងសិទ្ធិអំណាច ដោយវិនិច្ឆ័យទៅតាមស្តង់ដាផ្ទាល់ខ្លួនរបស់ពួកគេ ថាតើវាស័ក្តិសមឱ្យពួកគេចុះចូលដែរឬទេ ដោយផ្អែកលើអ្វីដែលពួកគេចង់បាន និងគោលដៅរបស់ពួកគេ។ ពួកគេមិនធ្លាប់បានរៀនថា នៅពេលដែលពួកគេយល់ព្រមទទួលធ្វើកិច្ចការអ្វីមួយ ទោះបីជាការងារក្រៅម៉ោងដ៏តូចតាចមួយក៏ដោយ ពួកគេបានយល់ព្រមធ្វើកិច្ចការនោះ ដូចជាអាជីវកម្មរបស់ពួកគេផ្ទាល់។ មនុស្សភាគច្រើនមិនយល់ឃើញដូច្នេះទេ។ ពួកគេតម្រង់ឆ្ពោះទៅរកគោលដៅដែលធំជាងនេះ។ យ៉ាងណាមិញ វាគ្រាន់តែជាការងារក្រៅម៉ោងសម្រាប់ប្រាក់បន្ថែមតែប៉ុណ្ណោះ វាមិនមែនជាកិច្ចការធំដុំអីទេ។ យល់ខុសហើយ!!!

គ្មានការងារអ្វីដែលជាការងារមិនសំខាន់ទេ។ មិនមានកិច្ចការណាដែលជាកិច្ចការតូចតាចទេ។ ដាវីឌមានការងារតូចតាច និងមិនសូវសំខាន់មួយ គឺគាត់ត្រូវមើលថែសត្វចៀម។ ប៉ុន្តែ ប្រសិនបើវាមិនសំខាន់ចំពោះគាត់ទេ នោះគាត់ក៏មិនបានប្រថុយជីវិតរបស់គាត់យ៉ាងហោចណាស់ពីរដង ដើម្បីការពារចៀមទាំងនោះដែរ។ អាចនិយាយបានម្យ៉ាងទៀតថា គាត់បានយកចិត្តទុកដាក់ចំពោះកិច្ចការដែលគេបានទុកចិត្តឱ្យគាត់ធ្វើ គាត់បានចាត់ទុកវាជាការងារសំខាន់ចំពោះគាត់។ ទោះបីមិនមាននរណាម្នាក់ផ្សេងទៀតស្គាល់គាត់ក៏ដោយ តែព្រះជាម្ចាស់បានស្គាល់គាត់! ហើយព្រះអង្គដឹងយ៉ាងច្បាស់ថាគាត់នៅកន្លែងណាគ្រប់ពេលវេលា។

ព្រះជាម្ចាស់ដឹងថាអ្នកនៅកន្លែងណា ហើយទ្រង់ក៏ជ្រាបដឹងអំពីដួងចិត្តរបស់អ្នកចំពោះសិទ្ធិអំណាចផងដែរ។ ចំណុចសំខាន់គឺថា ប្រសិនបើអ្នកមិនអាចចុះចូលចំពោះមនុស្សដែលអ្នកមើលឃើញទេ អ្នកក៏មិនអាចចុះចូលជាមួយព្រះជាម្ចាស់ដែលអ្នកមិនអាចមើលឃើញដែរ។ ខ្ញុំធ្លាប់បានឃើញមនុស្សជាច្រើនដែលមានផ្នត់គំនិត ជាផ្នត់គំនិតរបស់ជនរងគ្រោះ ដែលពួកគេយល់ឃើញថា វាតែងតែជាកំហុសរបស់អ្នកដទៃ។ ពួកគេតែងតែនិយាយថា វាជាកំហុសរបស់ចៅហ្វាយពួកគេ ឬជាកំហុសរបស់រដ្ឋាភិបាល ដូច្នេះ ពួកគេគ្រាន់តែធ្វើយ៉ាងណាឱ្យការងាររបស់ពួកគេចប់រួចរាល់ ពួកគេធ្វើការនៅពេលមានគេបង្ខំ។ ជាទូទៅ ពួកគេមានដំណើរការផ្លូវចិត្ត ដែលចាំបាច់ត្រូវមានអ្នកដទៃប្រាប់ពួកគេអំពីអ្វីដែលត្រូវធ្វើ ជាជាងគិតថាត្រូវធ្វើអ្វីដោយខ្លួនឯង។ ដូចជាករណីរបស់កូនចៅអ៊ីស្រាអែលផងដែរ ដែលពួកគេបានចាកចេញពីទាសភាពហើយ ប៉ុន្តែនៅតែបន្តគិតដូចជាទាសករដដែល។ គំនិតទាសភាពរបស់ពួកគេមិនអាចជួយពួកគេបានទេ នៅពេលពួកគេប្រឈមមុខនឹងយក្សនៃទឹកដីសន្យា។ ព្រះជាម្ចាស់ត្រូវបង្ហាត់បង្រៀនពួកគេឱ្យអាចទទួលជោគជ័យមុនពេល

ទៅដល់ទឹកដីនោះ។ ទ្រង់ក៏ត្រូវបង្ហាត់បង្រៀនអ្នកមុនពេលអ្នកចូលដល់ទឹកដីសន្យារបស់អ្នកផងដែរ។ ទឹកដីសន្យាដែលខ្ញុំកំពុងតែនិយាយនៅពេលនេះ គឺសំដៅលើជោគវាសនារបស់អ្នក។ ដូច្នេះ តើទ្រង់ពិតជាបានបង្ហាត់បង្រៀនពួកគេមែនឬ?

> *ព្រះអង្គបានឱ្យអ្នកជួបទុក្ខលំបាក និងការអត់ឃ្លាន ព្រះអង្គប្រទាននំម៉ាណាឱ្យអ្នកបរិភោគ គឺជាអាហារដែលអ្នក និងដូនតារបស់អ្នក ពុំធ្លាប់ស្គាល់។ ធ្វើដូច្នេះ ព្រះអង្គប្រៀនប្រដៅឱ្យអ្នកដឹងថា មនុស្សមិនមែនរស់ដោយអាហារប៉ុណ្ណោះទេ តែមនុស្សរស់ដោយសារព្រះបន្ទូលទាំងប៉ុន្មាន ដែលចេញមកពីព្រះឱស្ឋរបស់ព្រះអម្ចាស់។*

ទុតិយកថា ៨:៣

> *ព្រះអង្គប្រទាននំម៉ាណាឱ្យអ្នកបរិភោគ ជាអាហារដែលដូនតារបស់អ្នកពុំធ្លាប់ស្គាល់។* ***ព្រះអង្គធ្វើឱ្យអ្នកជួបទុក្ខលំបាក និងល្បងលអ្នកដូច្នេះ ដើម្បីប្រទានពរអ្នកនៅពេលក្រោយ។***

ទុតិយកថា ៨:១៦

ព្រះអង្គធ្វើឱ្យពួកគេជួបទុក្ខលំបាក បានសេចក្ដីថាទ្រង់ចង់បង្រៀនពួកគេថា ពួកគេមិនអាចធ្វើអ្វីដោយសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេបានទេ ពួកគេត្រូវការជំនួយ។ ពួកគេត្រូវរៀនរស់ដោយពឹងផ្អែកលើទ្រង់ មិនមែនពឹងផ្អែកលើសមត្ថភាពខ្លួនឯងនោះទេ។ ពួកគេនឹងប្រឈមមុខជាមួយការប្រយុទ្ធដែលធំជាងនេះ មិនគ្រាន់តែស្វែងរកអាហារ ដើម្បីបរិភោគនោះទេ។ ពួកគេនឹងជួបជាមួយយក្ស ព្រមទាំងទីក្រុងដែលមានកំផែងព័ទ្ធជុំវិញ ដែលនឹងធ្វើឱ្យពួកគេងាយមានអារម្មណ៍ភ័យខ្លាច លុះត្រាតែពួកគេមើលឃើញព្រះជាម្ចាស់ធំជាងបញ្ហារបស់ពួកគេ។

មេរៀនទីពីរដែលពួកគេត្រូវរៀនគឺ ត្រូវធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវដោយខ្លួនឯង ដោយមិនមានការបង្ខិតបង្ខំឱ្យធ្វើដូច្នេះឡើយ។ សព្វថ្ងៃនេះ ខ្ញុំឃើញឪពុកម្ដាយមានកំហុសមួយ ដោយព្យាយាមបង្រៀនកូនៗរបស់ពួកគេឱ្យប្រព្រឹត្តទៅតាមគន្លងមួយដែលពួកគេចង់បាន ជាជាងបង្រៀនពួកគេឱ្យធ្វើតាមដួងចិត្តរបស់ពួកគេផ្ទាល់។ ក្មេងម្នាក់ត្រូវបានគេប្រាប់ឱ្យសម្អាតបន្ទប់របស់ខ្លួន ហើយបន្ទាប់មកត្រូវបិទទ្វារទៅតាមអកប្បកិរិយាដែលពួកគេត្រូវធ្វើតាម ប៉ុន្តែ ពួកគេបានធ្វើកិច្ចការនោះដោយមានដួងចិត្តបះបោរ មិនមែន

ដោយដួងចិត្តនៃការចុះចូលទេ។ ឪពុកម្ដាយដែលចង់ធ្វើជាមិត្តរបស់កូនៗពួកគេ នឹងចូលមកមើលបន្ទប់ដែលពួកគេបានសម្អាតរួចហើយ ហើយសរសើរកិច្ចការដែលកូនពួកគេបានធ្វើ។ យល់ខុសហើយ។ ក្មេងៗធ្វើតាមតែពីខាងក្រៅប៉ុណ្ណោះ តែខាងក្នុងជម្រៅចិត្តរបស់ពួកគេវិញ វាមិនដូច្នោះទេ។ ការចុះចូលគឺធ្វើចេញពីជម្រៅដួងចិត្ត។ ថ្ងៃណាមួយ ឪពុកម្ដាយនឹងមិនអាចនៅជាមួយកូនៗរបស់ខ្លួន ដើម្បីជំរុញឱ្យពួកគេជ្រើសរើសជម្រើសត្រឹមត្រូវនោះទេ។ ដល់ពេលដែលឪពុកម្ដាយលែងមានសិទ្ធិក្នុងការគ្រប់គ្រងលើកូនៗរបស់ពួកគេ កូនៗពួកគេនឹងមានសេរីភាពក្នុងការធ្វើអ្វីទៅតាមចិត្តដែលពួកគេចង់ធ្វើ។ អ្វីដែលមាននៅក្នុងជម្រៅដួងចិត្តរបស់ពួកគេនឹងត្រូវបានលាតត្រដាងនៅពេលនេះឯង។ ដល់ដំណាក់កាលនេះ ទើបឪពុកម្ដាយជាច្រើនបានឃើញកូនៗរបស់ពួកគេមានបញ្ហា ហើយចាប់ផ្ដើមមានអារម្មណ៍ឆ្ងល់ ដោយនិយាយថា កូនរបស់ពួកគេគឺជាក្មេងដ៏ល្អម្នាក់កាលពីនៅក្មេង ហើយពេលនេះពួកគេភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះអកប្បកិរិយារបស់កូនពួកគេ នៅពេលដែលកូនពួកគេបានចូលរៀននៅមហាវិទ្យាល័យ ឬបន្ទាប់ពីពេលពួកគេបានរើចេញពីផ្ទះទៅរស់នៅដោយខ្លួនឯង។

ព្រះគម្ពីរបានចែងថា ព្រះជាម្ចាស់បានល្បងលប្រជាជនអ៊ីស្រាអែល ដើម្បីប្រទានពរពួកគេនៅពេលក្រោយ។ នេះជាអ្វីដែលយើងកំពុងតែនិយាយ។ មិនដូចជាឪពុកម្ដាយមួយចំនួនដែលខ្វល់ខ្វាយតែធ្វើយ៉ាងណាឱ្យកូនពួកគេចូលចិត្តពួកគេ រីឯព្រះជាម្ចាស់វិញទ្រង់យកចិត្តទុកដាក់ចំពោះសុខមាលភាពកូនៗពួកគេរយៈពេលវែងឆ្ងាយ។ ទ្រង់នឹងកែតម្រង់ឥរិយាបទតូចតាចនៃដួងចិត្តរបស់ពួកគេ មុនពេលវាក្លាយជាការប្រព្រឹត្តមិនត្រឹមត្រូវរយៈពេលយូរ។ នេះគឺជាអត្ថន័យ នៅពេលដែលព្រះគម្ពីរបានចែងថា ព្រះជាម្ចាស់នឹងល្បងលពួកគេ។ ទ្រង់អាចនឹងកែតម្រូវពួកគេ នៅពេលដែលពួកគេបង្ហាញឥរិយាបទនៃដួងចិត្តមិនត្រឹមត្រូវ ពេលដែលពួកគេត្រូវចុះចូលនឹងសិទ្ធិអំណាច។

មនុស្សគ្រប់រូបត្រូវឆ្លងកាត់ការល្បងលនៃការចុះចូលនឹងសិទ្ធិអំណាចនេះ! ដូច្នេះសព្វថ្ងៃនេះតើព្រះជាម្ចាស់បង្ហាត់បង្រៀនពួកយើងនៅកន្លែងណា បើគ្មានវាលខ្សាច់ដើម្បីត្រូវឆ្លងកាត់ផងនោះ? តើយើងអាចឮសំឡេងទ្រង់នៅទីណាបាន ដើម្បីយើងអាចរៀនពីការចុះចូលនឹងសិទ្ធិអំណាច ដើម្បីឱ្យយើងអាចមានលក្ខណៈល្អគ្រប់គ្រាន់សម្រាប់ការដំឡើងតំណែងបន្ទាប់របស់យើង? តើអ្នកនៅចាំបានអំពីអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលអំពីស្ដេចសូលទេ? ការស្ដាប់បង្គាប់ប្រសើរជាងការថ្វាយយញ្ញបូជាទៅទៀត។ ការគោរពប្រតិបត្តិខាងក្រៅរបស់អ្នកនៅក្រុមជំនុំ មិនមែនជាមូលដ្ឋាននៃការដំឡើងតំណែងបន្ទាប់របស់អ្នក

ទេ។ តើព្រះជាម្ចាស់អាចទុកចិត្តអ្នក ដោយប្រទានសិទ្ធិអំណាចឱ្យអ្នកបានដែរឬទេ? តើវាចាប់ផ្តើមនៅកន្លែងណា? វាត្រូវចាប់ផ្តើមពីផ្ទះទៅ។

> *កុមារាកុមារីអើយ ចូរស្តាប់បង្គាប់មាតាបិតា ដោយយល់ដល់ព្រះអម្ចាស់ ធ្វើដូច្នេះទើបត្រឹមត្រូវ។ «ចូរគោរពមាតាបិតា (នេះជាបទបញ្ជាទីមួយ ដែលមានទាំងព្រះបន្ទូលសន្យាជាប់មកជាមួយផង ដើម្បីឱ្យបានសេចក្តីសុខ និងមានអាយុវែងនៅលើផែនដីនេះ»*

អេភេសូ ៦:១-៣

ហេតុអ្វីបានជាការស្តាប់បង្គាប់ឪពុកម្តាយ ធ្វើឱ្យអ្នកមានអាយុវែង និងទទួលជោគជ័យក្នុងជីវិត? តើព្រះជាម្ចាស់ដាក់ពិន្ទុឱ្យអ្នក ពេលអ្នកស្តាប់បង្គាប់ឬ? អត់ទេ ក៏ប៉ុន្តែប្រសិនបើអ្នករៀនគោរព និងផ្តល់កិត្តិយសដល់ឪពុកម្តាយអ្នក ដែលមានសិទ្ធិអំណាចលើជីវិតអ្នក បន្ទាប់មកអ្នកនឹងផ្តល់កិត្តិយស និងការគោរពដល់ព្រះជាម្ចាស់។ ប្រសិនបើអ្នកគោរពសិទ្ធិអំណាចរបស់ព្រះជាម្ចាស់នៅក្នុងជីវិតអ្នក នោះអ្នកនឹងស្តាប់បង្គាប់ទ្រង់ ដើម្បីឱ្យអ្នកបានសេចក្តីសុខ។ ដូច្នេះ ខ្ញុំអាចនិយាយបានថា ព្រះសូរសៀងរបស់ព្រះជាម្ចាស់ស្តាប់ទៅដូចជាសំឡេងរបស់ឪពុកម្តាយអ្នក នៅពេលអ្នកនៅក្មេង និងស្ថិតនៅក្រោមការមើលថែរបស់ពួកគាត់។

កន្លែងទីពីរដែលព្រះជាម្ចាស់នឹងបង្ហាត់បង្រៀនអ្នកឱ្យចុះចូលជាមួយសិទ្ធិអំណាចគឺតាមរយៈការដាក់អ្នកនៅក្រោមសិទ្ធិអំណាចរបស់មនុស្ស។ ថៅហ្វាយរបស់អ្នក គ្រូគង្វាលរបស់អ្នក មន្ត្រីប៉ូលីស និងរដ្ឋាភិបាល គឺជាឧទាហរណ៍នៃសិទ្ធិអំណាចដែលព្រះជាម្ចាស់បង្គាប់យើងឱ្យចុះចូល។

ខ្ញុំចាំបានថា មានគ្រួសារមួយក្នុងក្រុមជំនុំរបស់ខ្ញុំ ដែលហាក់ដូចជាតែងតែត្អូញត្អែរ និងនិយាយអំពីបញ្ហារបស់ពួកគេ។ ពួកគេហៀបនឹងបាត់បង់ផ្ទះរបស់ពួកគេ ហើយត្រូវការប្រាក់ចំនួន១០,០០០ដុល្លារ ដើម្បីរក្សាផ្ទះនោះ និងជាសរាងការរឹបអូសយកទ្រព្យ។ ពួកគេច្បាស់ជាបានប្រាប់មនុស្សរាប់សិបអ្នកនៅក្រុមជំនុំអំពីរឿងរ៉ាវរបស់ពួកគេ។ នៅទីបំផុតមានគ្រួសារមួយបានសម្រេចចិត្តជួយពួកគេ ដោយផ្តល់ប្រាក់ចំនួន១០,០០០ដុល្លារដល់ពួកគេ។ ប៉ុន្តែ រយៈពេលពីរបីខែក្រោយមក ពួកគេបានធ្លាក់ក្នុងស្ថានភាពដើម ហើយបានបាត់បង់ផ្ទះរបស់ពួកគេ។ ខ្ញុំបានជជែកជាមួយប្តីប្រពន្ធទាំងពីរនាក់ដែលគ្មានការងារធ្វើទាំងពីរនាក់នោះ អំពីស្ថានភាពរបស់ពួកគេ។ ខ្ញុំបានណែនាំពួកគេថា យ៉ាងហោចណាស់ពួក

គេគួរតែធ្វើកិច្ចការអ្វីមួយដែលពួកគេអាចធ្វើបាន នៅពេលពួកគេកំពុងតែរង់ចាំការងារដែលត្រឹមត្រូវមកដល់។ ពួកគេអាចធ្វើការបណ្តោះអាសន្ននៅភោជនីយដ្ឋានណាមួយនៅក្នុងក្រុង ក៏ប៉ុន្តែ ពួកគេបាននិយាយថាការងារទាំងនេះមិនមែនសម្រាប់ពួកគេទេ។ ខ្ញុំគិតថា វាច្បាស់ណាស់ដែលបញ្ហារបស់ពួកគេគឺមិនមែនជាបញ្ហាផ្នែកហិរញ្ញវត្ថុទេ តែជាបញ្ហានៃការយល់ដឹងអំពីសិទ្ធិអំណាច និងការទទួលខុសត្រូវ។ ដោយសារហេតុផលណាមួយ ពួកគេមិនបានឃើញថា ពួកគេមានទំនួលខុសត្រូវផ្ទាល់ខ្លួន ក្នុងការមានសិទ្ធិអំណាចលើជីវិតរបស់ពួកគេ និងធ្វើអ្វីដែលពួកគេត្រូវធ្វើ ដើម្បីដោះស្រាយបញ្ហាទេ។

លោក រិក រិននើ ដែលជាមិត្តភក្តិរបស់ខ្ញុំ និយាយថាមុនពេលគាត់ជួលបុគ្គលិក គាត់សុំមើលឡានរបស់ពួកគេជាមុនសិន ឬមានពេលខ្លះទៀត គាត់ទៅផ្ទះរបស់ពួកគេដោយមិនបានប្រាប់ឱ្យដឹងមុន។ គាត់យល់ឃើញថា ប្រសិនបើនរណាម្នាក់មិនទទួលខុសត្រូវចំពោះឡានផ្ទាល់ខ្លួនរបស់ពួកគេទេ នោះពួកគេក៏មិនទទួលខុសត្រូវចំពោះរបស់ទ្រព្យរបស់គាត់ផងដែរ។ គាត់និយាយថាយូរឬឆាប់ ការិយាល័យរបស់គាត់នឹងមើលទៅដូចជាឡានរបស់ពួកគេអ៊ីចឹងដែរ។

ខ្ញុំបានឆ្លងកាត់ការហ្វឹកហាត់នៅទីរហោស្ថាន។ ហើយខ្ញុំមានចិត្តរីករាយណាស់ដែលព្រះជាម្ចាស់មិនអនុញ្ញាតឱ្យខ្ញុំមានឥរិយាបទព្រងើយកន្តើយចំពោះសិទ្ធិអំណាច។ ទ្រង់បានបង្ហាត់បង្រៀនខ្ញុំឱ្យចេះបន្ទាបខ្លួន និងបានល្បងលខ្ញុំ ដើម្បីទ្រង់អាចរៀបចំខ្ញុំសម្រាប់កិច្ចការបន្ទាប់របស់ខ្ញុំ។

ខ្ញុំនៅចាំបាន ពេលដែលយើងតានតឹងខ្លាំងផ្នែកថវិកា នៅពេលដែលយើងរស់នៅផ្ទះចម្ការរបស់យើងនៅឡើយ។ អរគុណណាស់ដែលខ្ញុំបានឈប់ធ្វើការវិនិយោគដ៏ធំមួយដែលខ្ញុំតែងតែបង់ថ្លៃវិក្កយបត្រយឺតយ៉ាវ។ ខ្ញុំចាំបានថា យើងមិនបានទទួលប្រាក់តាមមូលប្បទានបត្រទាន់ពេលទេ ដូច្នេះខ្ញុំក៏មានគំនិតដ៏អស្ចារ្យមួយៈ ខ្ញុំនឹងបើកគណនីថ្មីមួយនៅធនាគារថ្មី ហើយសរសេរមូលប្បទានបត្រដែលមិនមានទឹកប្រាក់ពីធនាគារថ្មីនេះទៅគណនីធនាគារចម្បងរបស់ខ្ញុំ ដោយសង្ឃឹមថានឹងទទួលបានមូលប្បទានបត្រដែលមានទឹកប្រាក់មកវិញនៅថ្ងៃបន្ទាប់ ហើយអាចដាក់ប្រាក់ចូលក្នុងធនាគារថ្មីវិញ ដើម្បីគ្របបាំងមូលប្បទានបត្រដែលមិនមានទឹកប្រាក់ដែលខ្ញុំបានចេញវា។ ប៉ុន្តែជាអកុសល មូលប្បទានបត្រនោះមិនបានមកដល់ថ្ងៃបន្ទាប់ទេ រហូតដល់ពីរសប្តាហ៍ក្រោយទើបវាមកដល់! ដូច្នេះ ជារៀងរាល់ថ្ងៃខ្ញុំត្រូវសរសេរមូលប្បទានបត្រមិនមានទឹកប្រាក់មួយទៅធនាគារមួយ

ទៀតរបស់ខ្ញុំ មុនពេលមូលប្បទានបត្រដែលមានទឹកប្រាក់បានមកដល់។ ខ្ញុំបានធ្វើដូច្នេះរហូតបានពីរសប្តាហ៍ ហើយមូលប្បទានបត្រដែលមិនមានទឹកប្រាក់បានកើនឡើងលើសពី ២,០០០ដុល្លារ ដោយសារខ្ញុំត្រូវចំណាយលើថ្លៃទិញម្ហូបអាហារ។ នៅអំឡុងពេលនោះចំនួនទឹកប្រាក់កាន់តែកើន
ឡើង។

ប៉ុន្តែអ្វីៗទាំងអស់ត្រូវបានបញ្ចប់នៅពេលអ្នកគ្រប់គ្រងធនាគារបានទូរស័ព្ទមកខ្ញុំនាពេលព្រឹកមួយ ហើយពាក្យដំបូងបង្អស់ដែលចេញពីមាត់របស់គាត់គឺ៖ «លោកឃីសុី ខ្ញុំបានដឹងថាលោកកំពុងតែធ្វើអ្វីហើយ ហើយខ្ញុំបានបិទគណនីរបស់លោកហើយ។ លោកត្រូវយកប្រាក់មកសងធនាគារយើងវិញ ហើយលោកនឹងមិនអាចបើកគណនីនៅធនាគារនេះម្តងទៀតទេ»។ គេតាមខ្ញុំទាន់ហើយ! អ្វីដែលពិតជាអាក្រក់ដែលទាក់ទងនឹងស្ថានភាពនេះ គឺខ្ញុំបានប្រើមូលប្បទានបត្រដែលមានខគម្ពីរនៅលើនោះ បានន័យថាខ្ញុំជាទីបន្ទាល់មិនល្អដល់អ្នកគ្រប់គ្រងធនាគារអំពីភាពអស្ចារ្យរបស់ព្រះ។ អរព្រះគុណព្រះជាម្ចាស់ ដែលមូលប្បទានបត្រដែលមានទឹកប្រាក់បានមកដល់ថ្ងៃនោះ ហើយខ្ញុំអាចយកប្រាក់ទៅដាក់ក្នុងធនាគារនោះ ដើម្បីសងបំណុលគេវិញ។ ក៏ប៉ុន្តែខ្ញុំត្រូវដើរចូលក្នុងការិយាល័យអ្នកគ្រប់គ្រងធនាគារនោះ កែប្រែចិត្តគំនិតនៅចំពោះមុខគាត់ ហើយបានប្រាប់គាត់ថា សូមកុំបន្ទោសព្រះជាម្ចាស់ ព្រោះវាជាទង្វើរបស់ខ្ញុំទេ ហើយវាជាភាពល្ងង់ខ្លៅរបស់ខ្ញុំ។

បន្ទាប់មកមានគ្រាមួយទៀតនៅឆ្នាំដំបូងៗនៃអាជីវកម្មរបស់ខ្ញុំ ដែលខ្ញុំត្រូវបានបណ្តុះបណ្តាលដោយអនុប្រធានប្រចាំតំបន់របស់ខ្ញុំ។ ពេលដែលគាត់កំពុងតែពិនិត្យមើលការលក់របស់ខ្ញុំ គាត់បានកត់សម្គាល់ឃើញថា ខ្ញុំបានភ្លេចឱ្យអតិថិជនចុះហត្ថលេខាក្នុងចន្លោះមួយលើឯកសាររបស់អតិថិជននោះ។ គាត់បាននិយាយថា «គ្មានបញ្ហាអីទេ អ្នកគ្រាន់តែលើកឯកសារនោះ ដាក់ឱ្យត្រូវពន្លឺ ហើយគូសតាមហត្ថលេខារបស់គាត់ នៅកន្លែងដែលគាត់មិនទាន់បានចុះហត្ថលេខានោះបានហើយ។ ព្រោះថា អតិថិជននោះពិតជាចង់បានផលិតផល ហើយបានចុះហត្ថលេខាលើកន្លែងផ្សេងៗទៀតរួចហើយ»។ ដូច្នេះ ខ្ញុំក៏ធ្វើតាមគាត់។ ប្រហែលមួយខែក្រោយមក ខ្ញុំបានទទួលទូរស័ព្ទពីមេធាវីរបស់អតិថិជនខ្ញុំ ដោយគាត់បានបញ្ជាក់ប្រាប់ខ្ញុំថា អតិថិជនរបស់ខ្ញុំបានប្តឹងខ្ញុំឱ្យសងសំណងប្រាក់ចំនួន១០,០០០ដុល្លារ ពីបទក្លែងបន្លំហត្ថលេខារបស់គាត់នៅលើទម្រង់បែបបទនៃការដកប្រាក់ពីធនាគារ។ ចំនួនទឹកប្រាក់ដែលត្រូវសងអតិថិជនរបស់ខ្ញុំត្រូវបានកាត់បន្ថយមកត្រឹម៥,០០០ដុល្លារ

ដោយសារអនុប្រធានប្រចាំតំបន់របស់ខ្ញុំមានទំនួលខុសត្រូវលើវាខ្លះដែរ ហើយគាត់ត្រូវបានគេបញ្ឈប់ពីការងារ។

ប៉ុន្តែ ខ្ញុំត្រូវរៀនមេរៀនពីកំហុសលើកនេះ! អ្នកតំណាងថ្មីម្នាក់របស់ខ្ញុំត្រូវធ្វើតេស្ដផានារ៉ាប់រង ហើយគាត់មិនមានលុយទិញឯកសារដើម្បីសិក្សាទេ ដូច្នេះ ខ្ញុំបានថតចម្លងពីឯកសារច្បាប់ដើមទុកឱ្យគាត់។ គាត់បានភ្លេចឯកសារនោះនៅកន្លែងធ្វើតេស្ដ ហើយខ្ញុំក៏បានទទួលទូរស័ព្ទមួយទៀតពីមេធាវីម្នាក់ ដែលកំពុងតែដាក់ពាក្យប្ដឹងខ្ញុំពីបទរំលោភកម្មសិទ្ធិបញ្ញា។ នៅសម័យនោះ ខ្ញុំស្គាល់ផ្លូវទៅការិយាល័យពន្ធដារ IRS ច្បាស់ដូចខ្នងដៃរបស់ខ្ញុំអ៊ីចឹង។ ខ្ញុំតែងតែត្រូវដោះស្រាយជាមួយវិក្កយបត្រពន្ធយឺតយ៉ាវ និងការផាកពិន័យផ្សេងៗ។ ឥឡូវនេះ ពេលខ្ញុំសម្លឹងត្រលប់ទៅក្រោយវិញ ខ្ញុំមានអារម្មណ៍លាយឡំចូលគ្នា។ ព្រះជាម្ចាស់បានបង្ហាត់បង្រៀនខ្ញុំឱ្យចេះទទួលខុសត្រូវ។ ទ្រង់ដឹងថាថ្ងៃណាមួយ ខ្ញុំនឹងមានទំនួលខុសត្រូវចំពោះលុយរាប់លានដុល្លារ ហើយទ្រង់មិនឱ្យខ្ញុំរួចខ្លួនពីទង្វើដែលខ្ញុំបានធ្វើមិនត្រឹមត្រូវទេ។ អរព្រះគុណព្រះសម្រាប់ការអស់ទាំងនេះ!

ខ្ញុំត្រូវរៀនថា ព្រះជាម្ចាស់ជាអ្នកដំឡើងតំណែងឱ្យខ្ញុំ ហើយទ្រង់មិនដំឡើងតំណែងដោយផ្អែកលើការប្រតិបត្តិតែម្យ៉ាងនោះទេ។ ភាពស្មោះត្រង់របស់ខ្ញុំក៏ត្រូវបានល្បងលផងដែរ។ ហេតុនេះហើយ ទើបខ្ញុំនិយាយថា ព្រះសូរសៀងរបស់ព្រះជាម្ចាស់ ស្ដាប់ទៅហាក់ដូចជាសំឡេងរបស់ថៅហ្វាយអ្នកអ៊ីចឹងដែរ។ ថៅហ្វាយរបស់អ្នកគឺជាឧបករណ៍មួយដែលព្រះជាម្ចាស់ប្រើ ដើម្បីបណ្ដុះបណ្ដាលអ្នក សម្រាប់កិច្ចការបន្ទាប់របស់អ្នក និងដើម្បីបង្រៀនអ្នកឱ្យចេះចុះចូលនឹងសិទ្ធិអំណាច។ តើអ្នកនឹងប្រលងជាប់ទេ?

> *ដ្បិតអ្នកដែលវិនិច្ឆ័យទោសមិនមែនមកពីខាងកើត ឬខាងលិច ហើយក៏មិនមែនមកពីខាងត្បូង ឬខាងជើងដែរ គឺព្រះជាម្ចាស់ទេតើ ដែលជាចៅក្រមវិនិច្ឆ័យទោស ព្រះអង្គដាក់ទោសអ្នកនេះហើយលើកលែងទោសអ្នកនោះ។*

ទំនុកតម្កើង ៧៥:៦-៧

> *ការវាយប្រដៅតែងតែធ្វើឱ្យមានទុក្ខព្រួយភ្លាមៗ មិនមែនធ្វើឱ្យសប្បាយទេ។ ក្រោយមក ទើបការវាយប្រដៅផ្ដល់ឱ្យអស់អ្នកដែលបានទទួលការអប់រំតាមរបៀបនេះមានសេចក្ដីសុខសាន្ដ និងសេចក្ដីសុចរិតទុកជាផល។*

ហេព្រើ ១២:១១

> *បងប្អូនជាខ្ញុំបម្រើអើយ ចូរស្ដាប់បង្គាប់ម្ចាស់របស់ខ្លួនក្នុងលោកនេះ ដោយគោរព កោតខ្លាចញាប់ញ័រ និងដោយចិត្តស្មោះសរដូចស្ដាប់បង្គាប់ព្រះគ្រិស្តដែរ មិនត្រូវធ្វើដូច្នេះ ដើម្បីគ្រាន់តែឱ្យម្ចាស់ទាំងនោះឃើញថា បងប្អូនចង់ផ្គាប់ចិត្តមនុស្សឡើយ គឺត្រូវធ្វើដូចជាខ្ញុំបម្រើព្រះគ្រិស្ត ដែលយកចិត្តទុកដាក់ <u>ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់</u>។ ត្រូវបម្រើម្ចាស់ដោយស្ម័គ្រចិត្ត ដូចបម្រើព្រះអម្ចាស់ ពុំមែនបម្រើមនុស្សទេ ដោយដឹងថាមនុស្សម្នាក់ៗ ទោះជាអ្នកងារ ឬអ្នកជាក្ដីនឹងទទួលរង្វាន់ពីព្រះអម្ចាស់ តាមអំពើល្អដែលខ្លួនបានប្រព្រឹត្ត។ រីឯបងប្អូនដែលជាម្ចាស់វិញ ចូរប្រព្រឹត្តចំពោះអ្នកបម្រើរបស់បងប្អូនបែបនោះដែរ គឺមិនត្រូវគំរាមកំហែងគេឡើយ។ តោងដឹងថា ទាំងពួកគេ ទាំងបងប្អូនមានម្ចាស់តែមួយនៅស្ថានបរមសុខ ហើយព្រះអង្គមិនរើសមុខនរណាសោះឡើយ។*

អេភេសូ ៦:៥-៩

ត្រូវស្ដាប់បង្គាប់ ដោយមានចិត្តគោរព និងចិត្តកោតខ្លាច! នេះគឺជាឥរិយាបទដែលអ្នកត្រូវមានចំពោះថៅហ្វាយរបស់អ្នក។ លោកប៉ូលចាត់ទុក ការស្ដាប់បង្គាប់ថៅហ្វាយរបស់អ្នក គឺជាការធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ តើអ្នកភ្ញាក់ផ្អើលដែរឬទេ? ខ្ញុំវិញ ខ្ញុំពិតជាភ្ញាក់ផ្អើល! តើព្រះសូរសៀងរបស់ព្រះជាម្ចាស់ស្ដាប់ទៅដូចសំឡេងអ្នកគេ? ដូចសំឡេងថៅហ្វាយអ្នក!

## វាគឺជាការល្បងល!

ពេលដែលខ្ញុំធ្វើការបញ្ចប់ការសិក្សាអំពីប្រធានបទមួយនេះ ខ្ញុំជឿជាក់ថា អ្នកទទួលបានការបំផុសគំនិត និងការលើកទឹកចិត្ត។ ព្រះវិញ្ញាណដ៏វិសុទ្ធពិតជាដៃគូដ៏អស្ចារ្យសម្រាប់ជីវិតអ្នក ទ្រង់បានសន្យាថា ទ្រង់នឹងមិនចាកចេញពីអ្នក ឬបោះបង់អ្នកចោលឡើយ។ វាជាកិត្តិយសដ៏ធំមួយដែលខ្ញុំអាចចែករំលែកសេចក្ដីពិតដែលមានតម្លៃដ៏លើសលប់មួយនេះជាមួយអ្នក។

ហ្គារី ឃីស៊ី

សម្រាប់ព័ត៌មានបន្ថែមអំពីការចាកចេញពីបំណុល និងការវិនិយោគប្រកបដោយសុវត្ថិភាព សូមទាក់ទងមកក្រុមហ៊ុនរបស់ខ្ញុំ៖ ហ្វរើដ ហ្វាយណាន់ គ្រុប ទូរស័ព្ទ៖ ១-(៨០០)-៨១៥-០៨១៨។

សម្រាប់ព័ត៌មានបន្ថែមអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ សូមចូលទៅគេហទំព័រ៖ FaithLifeNow.com

សម្រាប់ព័ត៌មានទាក់ទងនឹងក្រុមជំនុំជំនឿជីវិត សូមចូលទៅគេហទំព័រ FaithLifeChurch.org

# ជំពូកទី១២

# របៀបអធិស្ឋាន និងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ

យើងទទួលបានអ្វីៗពីព្រះជាម្ចាស់តាមរយៈជំនឿ ដូចទ្រង់បានប្រាប់យើងនៅក្នុងព្រះបន្ទូលរបស់ទ្រង់ ហើយការទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធក៏មិនខុសគ្នាដែរ។ មុនពេលអ្នកអធិស្ឋានដើម្បីទទួលពិធីនេះ សូមប្រាកដថា អ្នកបានសិក្សាខគម្ពីរដែលបានដកស្រង់ក្នុងសៀវភៅនេះរួចរាល់ហើយ ហើយអ្នកជឿជាក់ថាព្រះជាម្ចាស់សព្វព្រះហឫទ័យឱ្យអ្នកទទួលពិធីនេះ ព្រមទាំងបានទទួលចម្លើយសម្រាប់សំណួរដែលអ្នកមានទាក់ទងនឹងប្រធានបទនេះហើយផងដែរ។ បន្ទាប់ពីអ្នកមានទំនុកចិត្តថា ពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធគឺសម្រាប់អ្នក អ្នកគ្រាន់តែអធិស្ឋានតាមលំនាំនៃការអធិស្ឋានដូចខាងក្រោម៖

> **«ឱព្រះវរបិតាអើយ ទូលបង្គំសុំទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដ៏មានព្រះចេស្តាពីព្រះអង្គក្នុងថ្ងៃនេះ។ ទូលបង្គំទទួលវាឥឡូវនេះ ដូចព្រះបន្ទូលរបស់ទ្រង់បានចែង ជាមួយមានសមត្ថភាពក្នុងការនិយាយជាភាសាដទៃ។ ទូលបង្គំសុំក្នុងព្រះនាមព្រះអង្គម្ចាស់ព្រះយេស៊ូគ្រិស្ត និងសម្រាប់សិរីល្អរបស់ទ្រង់! អាម៉ែន។»**

អ្នកមិនមែនកំពុងតែស្វែងរកបទពិសោធ ឬអារម្មណ៍ដ៏ជាក់លាក់ណាមួយទេ ប៉ុន្តែអ្នកប្រកាន់ខ្ជាប់នូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយជឿជាក់ថាអ្នកទទួលបានអ្វីដែលអ្នកបានអធិស្ឋានសុំ។ បន្ទាប់ពីបានទទួលហើយ សូមចាប់ផ្តើមសរសើរតម្កើងព្រះជាម្ចាស់ និងអរព្រះគុណទ្រង់ ដែលទ្រង់បានចាក់ប្រេងតាំងនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដូចទ្រង់បានសន្យា។

**បន្ទិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក៖** អំណាចនៃយុទ្ធសាស្ត្រ

នៅពេលអ្នកអធិស្ឋាន សូមប្រាកដថា អ្នកដឹងថាអ្នកបានទទួលពេលដែលអ្នកសុំ មិនមែនពេលដែលអ្នកឃើញភស្តុតាងបញ្ជាក់ថាអ្នកបានទទួលទេ។ ភស្តុតាងគឺព្រះបន្ទូលព្រះ។

*ហេតុនេះហើយបានជាខ្ញុំសុំប្រាប់អ្នករាល់គ្នាថា អ្វីក៏ដោយ ឱ្យតែអ្នករាល់គ្នាអធិស្ឋានសុំ ចូរជឿថាអ្នករាល់គ្នាបានទទួលហើយ នោះព្រះជាម្ចាស់នឹងប្រទានឱ្យអ្នករាល់គ្នាជាពុំខាន។*(ម៉ាកុស ១១:២៤)

សូមប្រាកដថា អ្នកបានចំណាយពេលថ្វាយបង្គំព្រះអង្គ ហើយនៅពេលអ្នកអធិស្ឋាន សូមមានជំនឿថាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់មានសេរីភាពក្នុងការបង្ហាញអង្គទ្រង់ក្នុងភាសាអធិស្ឋានរបស់អ្នក។ ព្រះជាម្ចាស់នឹងមិនធ្វើឱ្យបបូរមាត់អ្នកធ្វើចលនាទេ! អ្នកត្រូវប្រើមាត់អ្នក អធិស្ឋានជាភាសាដទៃ។ ជាធម្មតា មនុស្សមានអារម្មណ៍រំភើប ឬតឹងក្នុងពោះរបស់ពួកគេ នៅពេលពួកគេអធិស្ឋាន ឬមានអារម្មណ៍អំពីវត្តមានរបស់ព្រះជាម្ចាស់។

នៅពេលអ្នកបន្តថ្វាយបង្គំ សូមចុះចូលចំពោះព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ អ្នកនឹងចាប់ផ្តើមមានអារម្មណ៍ថា មានសំឡេង ឬព្យាង្គដែលខុសប្លែកពីធម្មតាចេញពីវិញ្ញាណរបស់អ្នក។ អ្នកត្រូវបន្ទន់តាមសំឡេងទាំងនោះដោយជំនឿ។ នៅពេលអ្នកធ្វើដូច្នេះ លំហូរ និងការស្រាយនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នឹងកាន់តែកើនឡើង។

ប្រសិនបើដោយសារមូលហេតុណាមួយ អ្នកមិនទាន់អធិស្ឋានជាភាសាដទៃភ្លាមៗទេ សូមកុំព្រួយបារម្ភអី។ អ្នកបានទទួលដោយជំនឿ ដូច្នេះ សូមគ្រាន់តែបន្តអរព្រះគុណព្រះជាម្ចាស់ សម្រាប់ការចាក់ប្រេងតាំងរបស់ទ្រង់។ ខ្ញុំធ្លាប់ឃើញមនុស្សត្រលប់ទៅផ្ទះវិញ បន្ទាប់ពីការជួបជុំនៅក្រុមជំនុំ និងបានអធិស្ឋាន ដើម្បីទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទើបតែចាប់ផ្តើមអធិស្ឋានជាភាសាដទៃនៅតាមផ្លូវទៅផ្ទះវិញ ឬពេលពួកគេកំពុងតែងូតទឹកនៅព្រឹកបន្ទាប់ ឬពេលកំពុងតែកាត់ស្មៅពីរបីថ្ងៃក្រោយមក។ ចំណុចសំខាន់គឺត្រូវទទួលដោយជំនឿ មិនមែនដោយសារអារម្មណ៍នោះទេ។

សូមធ្វើឱ្យការអធិស្ឋានជាភាសាដទៃទៅជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់អ្នក និងអភិវឌ្ឍជីវិតនៃការអធិស្ឋានរបស់អ្នកឱ្យរឹងមាំ។ ព្រះជាម្ចាស់នឹងមានបន្ទូលមកកាន់អ្នក និងដឹកនាំអ្នក ដោយផ្តល់ចម្លើយទាក់ទងនឹងរឿងសព្វគ្រប់បែបយ៉ាង! ខ្ញុំជឿជាក់ថា អ្នកនឹងចំណាយពេលដើម្បីអធិស្ឋានក្នុងវិញ្ញាណ ព្រមទាំងរីករាយជាមួយអត្ថប្រយោជន៍ទាំងអស់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលអ្នកមានរួចហើយនៅក្នុងអ្នក!

# កំណត់សម្គាល់

1. ចារិដ ដាប្លីន «អ្នកគាំទ្រដែលជាប់ពន្ធនាគារ ដោយសារបានប្តឹង NFL ទារសំណងផ៨ពាន់លានដុល្លារ ទាក់ទងនឹងការចាប់បាល់មិនបានរបស់ ដិស ប្រាយអិន ពេលប្រកួតជាមួយក្រុមផេកឃឺរ» ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥៖ https://www. cbssports.com/nfl/news/jailed-fan-suing-nfl-for-88-billion-over-dez- bryant-non-catch-vs-packers/.
2. http://www.dictionary.reference.com/browse/Edified?s=t.
3. លីន អេដវឺដស៍ «អ្នកចិត្តសាស្ត្រនិយាយថា ទារកអាចដឹងខុសត្រូវតាំងពីវ័យ៦ខែ» ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០៖ https://medicalxpress. com/news/2010-05-psychologists-babies-wrong-months.html

# បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក
## អំណាចនៃយុទ្ធសាស្ត្រ

ជីវិតពោរពេញដោយការសម្រេចចិត្តធំៗ។

*តើអ្នកដឹងដោយរបៀបណាថាផ្ទះមួយណាដែលអ្នកគួរទិញ នរណាដែលអ្នកគួររៀបការជាមួយ ឬការងារណាដែលត្រូវទទួលយក?*

ប្រសិនបើចង់ជោគជ័យ អ្នកត្រូវការយុទ្ធសាស្ត្រមួយ។ ក៏ប៉ុន្តែតើអ្នករៀបចំផែនការយុទ្ធសាស្ត្រដោយរបៀបណា នៅពេលដែលអ្នកគ្មានចម្លើយសម្រាប់ចម្ងល់ទាំងអស់?

អាថ៌កំបាំងរបស់ព្រះជាម្ចាស់បានលាក់ទុកឱ្យអ្នក មិនមែនលាក់កំបាំងពីអ្នកទេ។

**ព្រះជាម្ចាស់ចង់ឱ្យអ្នកទទួលបានចម្លើយដែលអ្នកត្រូវការ ហេតុដូច្នេះហើយបានជាទ្រង់ប្រទានអាវុធសម្ងាត់មួយដល់អ្នក!**

នៅក្នុងវគ្គទីបីនៃស៊េរីសៀវភៅ *«បដិវត្តន៍ហិរញ្ញវត្ថុរបស់អ្នក»* នេះលោក ហ្គារី ឃីស៊ី បង្ហាញពីធាតុផ្សំដ៏សំខាន់បំផុតមួយនៃភាពជោគជ័យរបស់គាត់ និងអាថ៌កំបាំងដ៏សំខាន់នៅក្នុងព្រះរាជ្យនៃព្រះ៖ *អំណាចនៃយុទ្ធសាស្ត្រ!* អ្នកណាក៏អាចចាប់ត្រីបានដែរ ប្រសិនបើគេដឹងកន្លែងដែលត្រូវដាក់អួន។ ព្រះជាម្ចាស់មានចម្លើយដែលអ្នកត្រូវការ ក៏ប៉ុន្តែអ្នកត្រូវតែយល់ពីរបៀបស្តាប់ចម្លើយទាំងនោះ ហើយអនុវត្តវានៅក្នុងជីវិតរបស់អ្នក ហើយនោះជាអ្វីដែលអាចរកឃើញនៅក្នុងសៀវភៅនេះ។

សូមចូលរួមជាមួយលោក ហ្គារី ក្នុងដំណើរនៃការបើកសម្តែងឱ្យឃើញនេះ ហើយស្វែងយល់ពីរបៀបអនុវត្ត*អំណាចនៃយុទ្ធសាស្ត្រ*ក្នុងជីវិតរបស់អ្នក!



លោកហ្គារី ឃីស៊ី គឺជាអ្នកនិពន្ធ វាគ្មិន សហគ្រិន អ្នកជំនាញហិរញ្ញវត្ថុ និងជាគ្រូគង្វាលដែលមានចិត្តឆេះឆួលក្នុងការជួយមនុស្សឱ្យមានជ័យជម្នះក្នុងជីវិត ជាពិសេសទាក់ទងនឹងជំនឿ ក្រុមគ្រួសារ និងហិរញ្ញវត្ថុ។ លោកហ្គារី និងអ្នកស្រី ឌ្រិន ដា ជាភរិយាបានបង្កើតអាជីវកម្មដ៏ជោគជ័យជាច្រើន ព្រមទាំងជាស្ថាបនិកព័ន្ធកិច្ច Faith Life Now ដែលផលិតកម្មវិធីទូរទស្សន៍ចំនួនពីររួមមាន *Fixing the Money Thing* និង *Drenda* សន្និបាតជុំវិញពិភពលោក ព្រមទាំងធនធានអនុវត្តជាច្រើន។ ក្រុមគ្រួសារឃីស៊ី ក៏ជាគ្រូគង្វាលនៅក្នុងក្រុមជំនុំ Faith Life Church នៅក្បែរទីក្រុង កូឡំបឺស រដ្ឋអូហៃយ៉ូ។

P. O. Box 779, New ALBANY, OH 43054
1.888.391.LIFE | garykeesee.com